ស្រាវជ្រាវ ប្រែសម្រួល និង រៀបរៀងដោយៈ កែខ ចិត្រ

# តម្រាពិជ័យសង្គ្រាម

បុរាណចិន

ភាគទី២



## ស៊ុន អ៊ូ

ឆ្នាំ ៥៤៤ - ៤៩៦

មុន គ.ស

ព្រលឹងខ្មែរ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# លិខិតថ្លែងអំណរគុណ

ការបោះពុម្ពផ្សាយ តម្រាពិជ័យសង្គ្រាម បុរាណចិន លើកទី១ ទាំងពីរភាគនេះ គឺ បានទទួលការឧបត្ថម្ភពីសំណាក់

**ឯកឧត្តម ខៀវ កាញារីទ្ធ រដ្ឋមន្ត្រី ក្រសួងព័ត៌មាន**

និងជា

**សមាជិកបណ្ឌិតសភាវិទ្យាសាស្ត្រនយោបាយ**

**នៃ ទីក្រុងញូយ៉ក សហរដ្ឋអាមេរិច**

អ្នកស្រាវជ្រាវ ប្រែសម្រួល និង រៀបរៀងតម្រាពិជ័យសង្គ្រាម សូមថ្លែងអំណរគុណចំពោះ ឯកឧត្តម ខៀវ កាញារីទ្ធ និង លោកជំទាវ ព្រមទាំង ក្រុមគ្រួសារ សូមបាន ប្រកបដោយពុទ្ធពរទាំង ៤ប្រការ គឺ៖ អាយុ វណ្ណៈ សុខ និង ពលៈ កុំបីឃ្លាងឃ្លាតឡើយ។

សូមឯកឧត្តម មេត្តាទទួលនូវគារវកក្តីភាពដ៏ស្មោះស្ម័គ្រអំពីខ្ញុំបាទ។

កំពង់ធំ, ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១២

កែវ ចិត្រ (ប៉ាកកាឯក)

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ចំណេះដឹងគ្រប់វិនាទី

# មាតិកា

## តម្រាពិជ័យសង្គ្រាម


មាតិកា (ភាគទី២) ........................................ ២

ជំពូកទី ៩ ៖ ការឃោត្រាទ័ព / ការចល័តទ័ព ........................ ៣

ជំពូកទី ១០ ៖ លក្ខណៈសណ្ឋានដី / សណ្ឋានដីទីតាំង (ជ័យភូមិ) ........................ ៤៧

ជំពូកទី ១១ ៖ ស្ថានការណ៍ទាំង ៩ ប្រការ / លក្ខណៈទីតាំងទាំង ៩ ប្រការ ........................ ៧៧

ជំពូកទី ១២ ៖ ការវាយប្រហារដោយភ្លើង / ការវាយប្រហារដូចភ្លើង ........................ ១៧៧

ជំពូកទី ១៣ ៖ ការប្រើចារកម្ម / ការប្រើសតិបញ្ញា ........................ ២០១

បញ្ជីរិចិត្ររូប ........................ ២៣៩



www.facebook.com/7khmer
Fb page : Entertainment And Knowledge

# គម្ពីរពិជ័យសង្គ្រាម

(ភាគទី២)

និពន្ធដោយៈ ស៊ុនអ៊ូ

ឆ្នាំ ៥៤៤ - ៤៩៦ មុន គ.ស

ស្រាវជ្រាវ ប្រែសម្រួល និង រៀបរៀងដោយៈ

កែវ ចិត្រ

កំពង់ធំ. ខែមេសា គ.ស ២០១២



www.facebook.com/7khmer
Fb page : Entertainment And Knowledge

# មាតិកា

(ភាគទី២)

ជំពូកទី 9 ៖ ការយាត្រាទ័ព / ការចល័តទ័ព

ជំពូកទី 10 ៖ លក្ខណៈសណ្ឋានដី / សណ្ឋានដីទីតាំង

ជំពូកទី 11 ៖ ស្ថានការណ៍ទាំង៩ប្រការ / លក្ខណៈ ទីតាំង ទាំង៩ប្រការ

ជំពូកទី 12 ៖ ការវាយប្រហារដោយភ្លើង / ការវាយ ប្រហារដូចភ្លើង

ជំពូកទី 13 ៖ ការប្រើចារកម្ម / ការប្រើសតិបញ្ញា

បញ្ជីរូបភាព



www.facebook.com/7khmer
Fb page : Entertainment And Knowledge

## ជំពូកទី ៩. ការយាត្រាទ័ព / ការចល័តទ័ព

សេចក្តីផ្តើម៖ សេចក្តីដែលមាននៅក្នុងជំពូក ដ៏គួរឲ្យចាប់អារម្មណ៍នេះ គឺ ផ្តើមបង្ហាញ បានយ៉ាងល្អក្នុងប្រការទី១ គឺ ល្អជាងចំណងជើងរបស់វាទៅទៀត។

ប្រការទី 1 ៖ ស៊ុនអ៊ូ បានពោលថា៖ ឥឡូវ យើងចូលដល់សេចក្តីសំខាន់ អំពី ការតាំងបន្ទាយទាហាន និង ការសង្កេតមើលសញ្ញា របស់ សត្រូវហើយ។ ចូរឆ្លងកាត់ភ្នំទាំងឡាយឲ្យបានលឿនរហ័ស ហើយ ត្រូវរក្សាទីតាំង នៅជិតជ្រលងដងអូរ។

សេចក្តីអធិប្បាយ៖ គំនិត ស៊ុនអ៊ូ ដែលមានសេចក្តីដូចខាងលើនេះ គឺ ចង់និយាយថា ចូរកុំឲ្យនៅអែនអននបង្អែរបង្អង់ តាមចំណោមទីទួលសោះកក្រោះ គឺ ត្រូវយកទីតាំងក្បែរនឹងចំណុចផ្គត់ផ្គង់ទឹក និង ស្មៅ។ បើប្រៀបធៀបជាមួយស្នាដៃ វូអ៊ូ ជំពូកទី៣ មានសេចក្តីថា៖ «កុំអាស្រ័យនៅតាមរូងធម្មជាតិ ដូចជា៖ ប្រហោងច្រកភ្នំ»។ ចាងអ៊ី និទានរឿងខ្លី ជាឧទាហរណ៍ថា៖


www.facebook.com/7khmer
Fb page : Entertainment And Knowledge

វូទូឈាំង គឺជា មេចោរ កាលពីចុងរជ្ជកាលហាន់ ហើយ ម៉ាយាន់ ត្រូវបានរាជការបញ្ជូន ឲ្យទៅកម្ទេចបនចោររបស់គាត់។ មេចោរ វូទូឈាំង ដោយបានរកឃើញជម្រកមួយក្នុងរូងភ្នំ ចំណែក ម៉ាយាន់ មិនបានប្រឹងប្រែងសម្រុកចូលទៅច្បាំងនោះទេ ប៉ុន្តែបែរជា ម៉ាយាន់ ទៅដណ្ដើមកាន់កាប់រាល់ ទីតាំងអនុគ្រោះទាំងឡាយ ដែលអាចគ្រងបញ្ជាបាន នូវជំនួយទឹក និង ស្មៅចំណីសត្វ។ វូទូឈាំង ក៏ធ្លាក់ខ្លួនចូលទៅក្នុងស្ថានភាពដុនដាបអស់សង្ឃឹម ហើយត្រូវការភ័ស្តុតាបម្រុង ដែលរឿងនេះ បានជម្រុញឲ្យគាត់ចុះចាញ់ទាំងស្រុង។ នេះក៏ដោយសារតែ គាត់មិនបានយល់ដឹង អំពី ការមានប្រៀប ដោយនៅជិតជ្រលងដងអូរ។

ប្រការទី **2** ៖ (១). ចូរបោះបន្ទាយនៅលើទីទួលខ្ពស់,

សេចក្ដីអធិប្បាយ៖ តែមិនមែននៅលើភ្នំខ្ពស់នោះទេ គឺគ្រាន់តែជាដីទួល ឬ កូនភ្នំទាប ដែលមានកម្ពស់ខ្ពស់ផុតពីដីភូមិស្រុក ដែលនៅជុំវិញនោះប៉ុណ្ណោះ។


www.facebook.com/7khmer
Fb page : Entertainment And Knowledge

ប្រការទី 2 ៖ (២). ចូរបែរមុខបន្ទាយទៅរកព្រះអាទិត្យ។

សេចក្តីអធិប្បាយ៖ ទូមូ យកសេចក្តីនេះមក ដើម្បីបកស្រាយបញ្ជាក់ថា៖ «ចូរបែរមុខទៅទិសខាងត្បូង» ចំណែក ឆិនហាវ វិញពោលថា៖ «ចូរបែរមុខទៅទិសខាងកើត» (នឹងបរិយាយម្តងទៀត នូវសេចក្តីដូចមានក្នុងជំពូកដដែលនេះនៅប្រការទី១១ ដល់ប្រការទី១៣)។

ប្រការទី 2 ៖ (៣). ចូរកុំឡើងទីទួលខ្ពស់ ដើម្បីវាយប្រយុទ្ធឡើយ មានហេតុភេទច្រើនណាស់ ក្នុងសង្គ្រាមឡើងភ្នំនេះ។

ប្រការទី **3** ៖ បន្ទាប់ពីបានឆ្លងស្ទឹង ទន្លេ រួចហើយ អ្នកត្រូវចាកចេញឲ្យឆ្ងាយពីវា។

សេចក្តីអធិប្បាយ៖ តាមសេចក្តី ដែល ឆាវកុង អះអាងគឺ៖ «ដើម្បីជន្លបញ្ឆោតសត្រូវ ឲ្យដេញតាមអ្នកមក» ហើយ ចាងអ៊ី ក៏និយាយដែរថា៖ «ដើម្បីកុំឲ្យទុចអាក់ដំណើរចលនាទ័ពរបស់អ្នក»។ នៅក្នុងអំណានស្នាដៃតុងធាន យើងឃើញមានជាសេចក្តី ថា៖ «ក្រែងលោសត្រូវវាឆ្លងទន្លេតាមមក» .ល. ក៏ប៉ុន្តែ តាមន័យ





www.facebook.com/7khmer
Fb page : Entertainment And Knowledge

*ប្រយោគចុងក្រោយ សេចក្ដីនេះ ហាក់ដូចគ្រាន់តែជាការថែមថយតែប៉ុណ្ណោះ។*

ប្រការទី 4៖ នៅពេល ដែលកងទាហាន (សត្រូវ) ទន្ទ្រានឆ្លងស្ទឹង ទន្លេ តាមដំណើរព្យុហ៍ទ័ពទៅមុខរបស់ពួកវា ចូរកុំសម្រុកទៅជួបតទល់នឹងពួកវា នៅពាក់កណ្ដាលស្ទឹង ទន្លេឲ្យសោះ។ ការណ៍ដែលល្អបំផុតនោះ ចូរសម្ងំ ទុកឲ្យទាហានពួកវា ចំនួនពាក់កណ្ដាលឆ្លងឲ្យរួចសិន រួចសឹមយើងបើកការវាយប្រហារទៅលើពួកវា។

*សេចក្ដីអធិប្បាយ៖ លីឈាន់ និយាយសំដៅ ដល់ជ័យជំនះ ដ៏មហិមា របស់ ហាន់ស៊ីន ទៅលើ លុងជូ នៅទន្លេវ៉ី។ បើងាកទៅមើលស្នាដៃ ឈានហានស៊ុ ជំពូកទី ៣៤ សន្លឹកក្រាសធំបត់ជាពីរ ត្រង់សន្លឹកទី ៦ លើផ្ទៃផ្នត់ខាងឆ្វេង យើងឃើញថា រឿងចម្បាំងនោះ ត្រូវបានគេពិពណ៌នាដូចតទៅ៖ «ទាហានទាំងពីរពួក ប្រឈមមុខគ្នា នៅច្រាំងម្ខាងម្នាក់ នៃ ទន្លេ។ នៅវេលាយប់ ហាន់ស៊ីន បានបញ្ជាទាហាន របស់ គាត់ឲ្យយកស្បោងរាប់ម៉ឺនច្រកដីខ្សាច់ ពេញៗ ហើយដាក់គរលើគ្នា សាងជាទំនប់បានខ្ពស់ឡើង។ ខណៈនោះ គាត់ក៏កំពុងតែ*




www.facebook.com/7khmer
Fb page : Entertainment And Knowledge

នាំទាហានរបស់គាត់ ចំនួនពាក់កណ្ដាលឆ្លងទន្លេទៅដែរ គាត់ក៏វាយប្រហារទៅលើទ័ព លុងជូ ក៏ប៉ុន្តែ បន្ទាប់ពីគាត់បានប្រយុទ្ធមួយរយៈមក ក៏ធ្វើពុតជា ចាញ់ដៃបរាជ័យ, គាត់ក៏ដកទ័ពថយវិលទៅកាន់ច្រាំងម្ខាងទៀតនៃ ទន្លេវិញ។ លុងជូ ត្រេកអរណាស់នឹងជោគជ័យដែលមិននឹកស្មានដល់នេះ ហើយក៏ឧទ្ទានថា៖ «ខ្ញុំមានអារម្មណ៍ថា ហាន់ស៊ិន ពិតជាកំសាកមែនតែម្ដងហើយ!» រួចលុងជូ ក៏ដេញតាមហាន់ស៊ិនទៀត ហើយក៏ចាប់ផ្ដើម ឆ្លងទន្លេតាមទៅ ជាវេនរបស់គាត់ម្ដង។ ហាន់ស៊ិន ពេលនោះ ក៏បញ្ជូនទាហានមួយកង ឲ្យទៅកាត់ផ្ដាច់បាវខ្សាច់ ដែលទប់ឆ្លងទន្លេនោះ ហេតុនេះបានបើកឲ្យទឹកហូរគំហុកយ៉ាងខ្លាំង ទឹកហូរប៉ើងនាំទាហាន លុងជូ ដែលកំពុងឆ្លង ឲ្យចុះទៅខាងក្រោមទឹក ហើយខ្សែទឹកហូរ ក៏បានរារាំងមិនឲ្យ ទាហានជាច្រើនរបស់ លុងជូ ទាំងនោះឆ្លងទន្លេរួចឡើយ។ ពេលនោះហាន់ស៊ិន បាន លើកទ័ពបកមកវាយទាហានខាងមុខរបស់ លុងជូ ដែលត្រូវបានកាត់ផ្ដាច់ទ័ពក្រោយទៅហើយនោះ គឺ បើកការវាយម្ទេចយ៉ាងកោលាហល




www.facebook.com/7khmer
Fb page : Entertainment And Knowledge

លុងជូ ខ្លួនឯងក៏លង់ខ្លួន នៅចំពាកណ្ដាលនៃសេចក្ដីវិនាស។ ទាហាននឹងទៀត របស់ លុងជូ ដែលនៅសល់លើច្រាំង ក៏រត់រប៉ាត់រប៉ាយ និង ភៀសខ្លួនទៅគ្រប់ទិស។

ប្រការទី **5**៖ បើសិនជា អ្នកអន្ទះសារ រសើបចិត្តចង់ច្បាំង អ្នកមិនត្រូវទៅជួបប្រឈមនឹងពួកសត្រូវនៅជិតទន្លេ ដែលវាត្រូវឆ្លងនោះទេ។

សេចក្ដីអធិប្បាយ៖ ការណ៍នេះ ព្រោះខ្លាចក្រែងវាបង្កប់ទ័ពការពារទាហានរបស់វា ដែលត្រូវឆ្លងស្ទឹងនោះ។

ប្រការទី **6**៖ (១). ចូរចត ចងជលយានរបស់អ្នកនឹងខ្សែពួរ ឲ្យដើបខ្ពស់ឡើងជាងសត្រូវហើយបែរមុខទៅព្រះអាទិត្យ។

សេចក្ដីអធិប្បាយ៖ សូមមើល ប្រការទី២ ក្នុងជំពូកនេះឡើងវិញ។ ការសរសេរផ្ទួនគ្នានៅទីនេះ ដោយភ្ជាប់ទៅនឹងទីតាំងលើទឹក គឺ ពិតជាឆ្គង។ ចាងអុី កត់ត្រាទុកដូច្នេះថា «អាចនិយាយបានថា ទោះជាកងទាហាននៅត្រៀមចាំខាងលើច្រាំងស្ទឹង ទន្លេ ឬ នៅលើទូកដែលបោះយុថ្កាក្នុងស្ទឹងទន្លេក្ដី ក្នុងករណីដូចគ្នានេះ គឺ




www.facebook.com/7khmer
Fb page : Entertainment And Knowledge

ចាំបាច់ត្រូវតែតាំងទី ឲ្យបានខ្ពស់ជាងសត្រូវ ហើយបែរមុខទៅរកព្រះអាទិត្យដែរ»។ អ្នកអត្ថាធិប្បាយដទៃទៀត មិនបាននិយាយ ឲ្យច្បាស់លាស់ផងទេនៅក្នុងចំណុចនេះ។

ប្រការទី 6 ៖ (២). ចូរកុំធ្វើចលនាបញ្ច្រាសទឹក ដើម្បី ទៅជួប ប្រឈមនឹងសត្រូវឡើយ។

សេចក្ដីអធិប្បាយ៖ ទូមូ ពោលថា៖ «ដូចដែលទឹកហូរពីលើចុះមកក្រោម យើងមិនត្រូវ បោះបន្ទាយនៅលើទីទំនាបសំយ៉ុងចុះមកស្ទឹងទន្លេបានទេ ព្រោះខ្លាចក្រែងសត្រូវនឹងបើកទ្វារទឹកបង្ហូរ ឲ្យប៉ើងយើងវិវក់ហូរចុះទៅតាមទឹក។ ជូក្វូហូវ បានសម្គាល់ឃើញ ថា នៅក្នុងកិច្ចការចម្បាំងតាមស្ទឹង ទន្លេ យើងមិនត្រូវសម្រុកទៅមុខបញ្ច្រាសទឹកទេ មានហេតុភេទច្រើនណាស់ដែលត្រូវនាំមកនិយាយ ដូចជា កងនាវារបស់យើងមិនត្រូវបោះយុថ្កាចតនៅក្រោមទឹកនៃសត្រូវទេ ដោយសារសត្រូវអាចនឹងយកប្រៀបតាមខ្សែទឹក ហើយវាមកវាយកម្ទេចយើងយ៉ាងរហ័សមួយរំពេច» នៅមានគ្រោះថ្នាក់





www.facebook.com/7khmer
Fb page : Entertainment And Knowledge

បែបផ្សេងទៀត ដែលត្រូវបានកត់ត្រាទុក ដោយអ្នកអត្ថាធិប្បាយដ៏ទៃទៀត ដែលនិយាយថា សត្រូវអាចដាក់ថ្នាំបំពុលក្នុងទឹកឲ្យហូរចុះមករកយើងជាដើម។

ប្រការទី 6 ៖ (៣). មានហេតុភេទច្រើនណាស់ ក្នុងកិច្ចការចម្បាំងតាមស្ទឹង ទន្លេនេះ។

ប្រការទី **7** ៖ ចំពោះ ការឆ្លងកាត់វាលភក់ ក្នុងស្រែអំបិល ការព្រួយបារម្ភណ៍ជំពាក់ចិត្ត មានតែមួយគត់ គឺ ត្រូវឆ្លងកាត់វាលភក់នេះ ឲ្យបានឆាប់រហ័សបំផុត ដោយកុំពន្យាពេលសោះឡើយ។

*សេចក្ដីអធិប្បាយ៖ ដោយសារការខ្វះទឹកសុទ្ធ សភាពគ្មានគុណភាព នៃ រុក្ខជាតិជាអាហារ របស់ មនុស្ស, សត្វ និង ព្រោះវាជាទីទំនាប, ដីរាប ដែលមានលក្ខណៈបើកចំហ ចាំទទួលរងការវាយប្រហារ។*

ប្រការទី **8** ៖ (១). បើសិនជា អ្នករងការបង្ខំឲ្យចូលប្រយុទ្ធក្នុងវាលស្រែអំបិល អ្នកត្រូវមានទឹក (សាប) និង ស្មៅ នៅជិតខ្លួនរបស់អ្នក ហើយត្រូវបែរខ្នងរបស់អ្នក សំដៅទៅរកគុម្ពោធព្រៃ។


www.facebook.com/7khmer
Fb page : Entertainment And Knowledge

*សេចក្ដីអធិប្បាយ៖ លីឈាន់ កត់សម្គាល់ថា៖ ដីហាក់ដូចជា មិនសូវទុរយសប៉ុន្មានទេ ចំពោះទីណា ដែលមានដើមឈើ, ចំណែក ទូមូ ពោលថា៖ ដើមឈើទាំងនោះនឹងជួយ ការពារផ្នែកខាងក្រោយខ្នងយើង។*

ប្រការទី 8៖ (២). មានហេតុភេទច្រើនណាស់ ចំពោះយុទ្ធនាការសឹក ក្នុងស្រែអំបិលនេះ។

ប្រការទី **9**៖ (១). នៅលើទីស្ងួតហួតហែង ចូរពង្រាបផ្ទៃដីឲ្យរាបតាមថ្នាក់, ចូរលើកដីឲ្យមាន ទីតាំងខ្ពស់ស្រឡះស្រួលចូលដល់ ដោយឲ្យមានដីទួលនៅផ្នែកខាងស្ដាំ និង ផ្នែកខាងក្រោយខ្នងរបស់អ្នក,

*សេចក្ដីអធិប្បាយ៖ ទូមូ ដកស្រង់សម្ដី តៃកុង ដែលបាននិយាយថា៖ «កងយោធាណានីមួយត្រូវមានស្ទឹងឬវាលភក់នៅផ្នែកខាងឆ្វេង និង ភ្នំ ឬ ទីទួលនៅផ្នែកខាងស្ដាំ។*

ប្រការទី 9៖ (២). បើថា មានគ្រោះភ័យកើតឡើង គឺ វានៅតែពីខាងមុខ ហើយសុវត្ថិភាពនៅផ្ដេកផ្ដិតជាប់ពីខាងក្រោយខ្នងយើង។ មានហេតុភេទច្រើនណាស់ចំពោះយុទ្ធនាការណ៍សឹក នៅលើទីតាំងផ្ទៃរាបស្មើនេះ។





www.facebook.com/7khmer
Fb page : Entertainment And Knowledge

ប្រការទី 10 ៖ (១). សេចក្តីទាំងនេះ ជាមែកធាង ទាំង ៤ប្រការ ដ៏សំខាន់ នៃ វិជ្ជាកងទ័ព។

* សេចក្តីអធិប្បាយ៖ មែកធាងទាំង ៤ប្រការនេះ មានឈ្មោះថា៖ (១). ភ្នំ, (២). ស្ទឹងទន្លេ,(៣). វាលភក់, (៤). វាលរាប ។ សូមធ្វើសេចក្តីប្រៀបធៀប ជាមួយ ភាសិតយោធារបស់ ណាប៉ូឡេអុង លេខ១។

ប្រការទី 10 ៖ (២). ការណ៍ទាំងអស់នេះហើយ ដែលអាចញ៉ាំងឲ្យ អធិរាជលឿង (ឬ អធិរាជ ហ័ងទី ឆ្នាំ 2697 – 2598 មុន គ.ស) ដែលបានរំលំរំលាយឲ្យវិនាសអធិរាជ ចំនួន ៤អង្គ ផ្សេងទៀត រហូតទាល់តែបានសម្រេច។

សេចក្តីអធិប្បាយ៖ ចំពោះរឿង «អធិរាជលឿង» នេះ ម៉ីយ៉ាវឆិន ក៏បានពិនិត្យឃើញ មានភាពទំនងគួរឲ្យជឿខ្លះដែរ ដែលថា មានការភាន់ច្រឡំក្នុងអត្ថបទ ព្រោះថាគ្មានអ្វីបញ្ជាក់សោះ អំពី ការដែលថា អធិរាជហ័ងទីបានយកជ័យជំនះលើអធិរាជ ចំនួន៤អង្គ ផ្សេងទៀតនោះ។ ក្នុងស្នាដៃ ស៊ីឈី (ជំពូកទី១) បាននិយាយតែអំពី ជ័យជំនះ របស់ព្រះអង្គ លើ យិនទី និង ឈីអ៊ីតែប៉ុណ្ណោះ។ នៅក្នុងស្នាដៃ លាវតាវ មាននិយាយ ថា




www.facebook.com/7khmer
Fb page : Entertainment And Knowledge

«អធិរាជហ័ងទី បានធ្វើចម្បាំង ចំនួន៧០ដង និង ធ្វើឲ្យអាណាចក្រ មានសន្តិភាព តែប៉ុណ្ណោះ។ ការពន្យល់របស់ ឆាវកុង មានជាសេចក្តីថា៖ អធិរាជលឿង ជាស្តេចទី១ ដែលបានស្ថាបនាប្រព័ន្ធសក្តិភូមិ លើស្តេចនគរចំណុះទាំងឡាយ ហើយ ស្តេចនៅនគរចំណុះមួយអង្គៗ (មានចំនួនដល់ទៅ ៤អង្គ) កាន់តំណែងជាអធិរាជ។ លីឈាន់ ប្រាប់យើងទៀតថា៖ គម្រាពិជ័យសង្គ្រាមបានប្រសូត្រជាដំបូងបំផុតគឺនៅក្រោមអំណាចអធិរាជហ័ងទី ដែលព្រះអង្គបានទទួលវា ពីមន្ត្រីរបស់ព្រះអង្គឈ្មោះ ហ្វឹងហូវ។

ប្រការទី 11 ៖ (១). យោធាទាំងអស់ចូលចិត្តទីខ្ពស់ជាងទីទាប។

សេចក្តីអធិប្បាយ៖ ម៉ីយ៉ាវឆិន ពោលថា៖ «ទីតាំងខ្ពស់មិនមែនត្រឹមតែជាទីដែល យល់ព្រមត្រូវគ្នា និង មានសុខភាពល្អ ថ្លៃថ្នូរប៉ុណ្ណោះទេ ប៉ុន្តែ វាថែមទាំងមានឥស្សរៈភាពក្នុងទស្សនៈយោធាថែមទៀតផង, ទីទំនាប




www.facebook.com/7khmer
Fb page : Entertainment And Knowledge

*វាមិនមែនត្រឹមតែសើមជាំកខ្វក់ និងឧបទ្រពប៉ុណ្ណោះទេ វាថែមទាំងចាញ់ប្រៀបគេក្នុងការប្រយុទ្ធថែមទៀត»។*

ប្រការទី 11 ៖ (២). ហើយទាហាន ក៏ចូលចិត្តទីដែលមានពន្លឺព្រះអាទិត្យ ជាងទីងងឹតផងដែរ។

ប្រការទី **12** ៖ (១). បើសិនជា អ្នកយកចិត្តទុកដាក់ចំពោះទាហានរបស់អ្នក,

*សេចក្តីអធិប្បាយ៖ ឆាវកុង ពោលថា៖ «ចូរធ្វើចលនាសំដៅទៅទីកស្អាត និង វាលស្មៅ ដែលអ្នកអាចឲ្យសត្វរបស់អ្នកស៊ីស្មៅបាន»។*

ប្រការទី 12 ៖ (២). ហើយតាំងបន្ទាយនៅលើដីរឹង ទាហានក៏នឹងមិនឆ្លងរោគាព្យាធិគ្រប់បែបយ៉ាងនោះឡើយ។

*សេចក្តីអធិប្បាយ៖ ចាងអ៊ី ពោលថា៖ «ភាពស្រស់ស្អូតនៃ អាកាសធាតុ ជួយការពារ សភាពឆ្លងរាលដាល នៃជម្ងឺទាំងឡាយបាន»។*

ប្រការទី 12 ៖ (៣). ហើយ អ្វីៗ ទាំងនេះ ក៏នឹងក្លាយជាមន្តអាគមន៍ នៃ ជ័យជំនះ។




www.facebook.com/7khmer
Fb page : Entertainment And Knowledge

ប្រការទី 13 ៖ នៅពេលណា ដែលអ្នកចូលមកដល់ទីទួល ឬច្រាំងស្ទឹងទន្លេ ចូរកាន់កាប់ ចាប់យកផ្នែកខាងណា ដែលមានពន្លឺព្រះអាទិត្យ ដោយមានទីទួលចំណោតចុះមកពីខាងក្រោយ និង ស្តាំដៃរបស់អ្នក។ បើធ្វើដូចនេះបាន អ្នកនឹងអាចចាត់ការកិច្ចការពារជាប្រយោជន៍សម្រាប់ ទាហានរបស់អ្នកតែម្តង និង ទាញយកមកប្រើ នូវ ការមានប្រៀបខាងធម្មជាតិតាមលក្ខណៈរបស់សណ្ឋានដីបានទៀតផង។

ប្រការទី 14 ៖ នៅពេលណា ដែលមានការទទួលរងផលប៉ះពាល់ពីទឹកភ្លៀងធំជន់ឡើងពេញ ស្រុកភូមិ, ទឹកស្ទឹង ទន្លេដែលអ្នកនឹងឆ្លងកាត់ ក៏ជន់ឡើង ហើយបែកពពុះ ជាដុំៗ អ្នកត្រូវតែ រង់ចាំ ទាល់តែវាជ្រាបស្រកទៅវិញសិន។

ប្រការទី 15 ៖ (១). នៅទីឋាន ស្រុកណា ដែលមានច្រាំងចំណោតផ្ទាំងថ្ម ប្រកបដោយ ខ្សែទឹកហូរតាមចន្លោះនោះព្រមទាំងមានក្រហែងប្រហោងធម្មជាតិ រពើតរពើងជ្រងជ្រៅ,

*សេចក្តីអធិប្បាយ៖ នៅផ្នែកខាងក្រោយ អាចមានន័យថាជា៖ «ទីតាំងដែលហ៊ុំព័ទ្ធជុំវិញដោយច្រាំងរអិលចោតមានទឹកអូរនៅបិទខ្ទប់ពីខាងក្រោយ»។*




www.facebook.com/7khmer
Fb page : Entertainment And Knowledge

ប្រការទី 15 ៖ (២). គឺជាទីតាំងត្រូវកំណត់ព្រំប្រទល់ទុក,

សេចក្ដីអធិប្បាយ៖ វាត្រូវគេបានកំណត់លក្ខណៈថាជា «ទីឃុំឃាំង ឬ គុកធម្មជាតិ» ឬ «ទីតាំង ដែលព័ទ្ធជុំវិញដោយជ្រោះនៅជាប់ជ្រុងទាំង៣ នាំឲ្យងាយស្រួលចូលទៅទីខាងក្នុង ក៏ប៉ុន្តែ ពិបាកនឹងចេញមកវិញណាស់»។

ប្រការទី 15 ៖ (៣). ទីដែលមានគុម្ពោធព្រៃក្រាស់ជំពាក់ជំពិន,

សេចក្ដីអធិប្បាយ៖ វាត្រូវបានគេកំណត់លក្ខណៈថាជា «ទីតាំងគ្របដណ្ដប់ទៅដោយគុម្ពោធព្រៃក្រាស់ ដែលមិនអាចប្រើលំពែងបាន»។

ប្រការទី 15 ៖ (៤). ទីតាំងដែលមានភក់ជ្រៅ,

សេចក្ដីអធិប្បាយ៖ វាត្រូវបានគេកំណត់លក្ខណៈថាជា «ទីតាំង ដែលមានផ្ទៃរាបទាប មានភក់ជ្រៅ ដែលរទេះចម្បាំង និង ទាហានសេះមិនអាចឆ្លងកាត់បាន»។

ប្រការទី 15 ៖ (៥). និង ទីតាំង ដែលមានដីប្រេះក្រហែង។




www.facebook.com/7khmer
Fb page : Entertainment And Knowledge

សេចក្តីអធិប្បាយ៖ លក្ខណៈទីតាំងមួយចំនួន ត្រូវបានកំណត់ដោយ ម៉ីយ៉ាវឆិន ថាជា៖ «ផ្លូវចង្អៀត ដែលលំបាក នៅចន្លោះពើងថ្ម»។ ចំណែកនៅក្នុងកំណត់ត្រារបស់ ទូមូ បានសរសេរថា៖ «ដីដែលក្រាលគ្របដោយដើមឈើ និង ផ្ទាំងថ្ម ហើយ ជួបប្រសព្វដោយជ្រោះ និង ជ្រលង ជ្រៅៗ»។ ការនិយាយយ៉ាងនេះ វាមិនសូវច្បាស់ទេ ប៉ុន្តែ ចាលីន បានពន្យល់យ៉ាងច្បាស់ល្មមគ្រប់គ្រាន់ ថាជា ទីតាំង ដែលមានលក្ខណៈតូចចង្អៀត និង ស្មោកគ្រោក, ចំណែក ចាងអ៊ុ ក៏យល់ឃើញដូចគ្នាយ៉ាងនេះដែរ។

និយាយជារួម, ទម្ងន់ នៃ ការបកស្រាយ របស់អ្នកអត្ថាធិប្បាយទាំងឡាយ គឺពិតជា ទន់ទោរទៅរកការយល់ឃើញថាជា «ជ្រលងភ្នំ»។ ក៏ប៉ុន្តែន័យសេចក្តីជាចម្បង ក្នុងភាសាចិននៅក្នុងទីនេះ គឺជា «ទីចង្អៀត ឬ ច្រកតូច» ហើយចំពោះ ការពិតក្នុងន័យសេចក្តីជាភាសាចិននៅចំណុចដទៃ ក្នុងប្រយោគនេះ បង្ហាញថាជា ធម្មជាតិនៃជ្រលងភ្នំទៅវិញ, ការណ៍នេះ បាននាំ




www.facebook.com/7khmer
Fb page : Entertainment  And Knowledge

ឲ្យខ្ញុំគិតថា នៅចំណុចនេះ ស៊ុនអ៊ូ កំពុងតែនិយាយ ត្រឹមតែជា ទីដែលមានដីប្រេះក្រហែងតែប៉ុណ្ណោះឯង។

ប្រការទី 15 ៖ (៦). អ្នកគួរតែ ចាកចេញ ពីទីតាំងទាំងនោះ ឲ្យបានលឿន តាមដែលអាចធ្វើទៅបាន ហើយ កុំចូលទៅ ជិតទីនោះទៀតឲ្យសោះ។

ប្រការទី **16** ៖ នៅពេល ដែលយើងចាកចេញពីតាំងរបៀប ដូចនេះហើយ យើងត្រូវញ៉ាំង ឲ្យសត្រូវរបស់យើងចូលទៅ ក្នុងទីនោះវិញម្តង, នៅពេលយើងបែរមុខទៅរកទីរបៀបនេះ យើងត្រូវ ទុកឲ្យសត្រូវរបស់យើង បែរខ្នងទៅរកទីរបៀបនេះ វិញទៅចុះ។

ប្រការទី **17** ៖ នៅក្បែរបន្ទាយទាហានរបស់អ្នក, បើមានភូមិស្រុក ប្រកបដោយភ្នំ អូរ ត្រពាំង ដែលមានវារីជាតិព័ទ្ធជុំវិញ, មានក្រឡុក ដែលប្រកបដោយ សារពើរុក្ខជាតិ ដូចជា ដើមប្របុស្ស, ត្រែង ឬ ដើមឈើ ប្រកបដោយគុម្ពោធពីក្រោម, អ្វីៗ ទាំងនេះ អ្នកត្រូវតែកាត់ជម្រះវាចេញ ឲ្យស្អាត ស្រឡះ ដោយប្រយ័ត្នប្រយែង ហើយរកមើល បើវានៅមានទៀត ព្រោះទីរបៀបនេះហើយ ដែលអាចបង្កប់ទ័ពបាន ឬ ពួកចារកម្មមានល្បិច ចូលចិត្តសម្ងំលាក់ខ្លួន។





www.facebook.com/7khmer
Fb page : Entertainment And Knowledge

សេចក្តីអធិប្បាយ៖ ចាងអ៊ី បានកត់ត្រាទុកជាសេចក្តីថា៖ «យើងត្រូវតែរក្សាការពារជានិច្ច ទល់នឹង ជនក្បត់ដែលលាក់ខ្លួននៅ ជិតៗ នោះ លបធ្វើរោរកម្មបញ្ចូនចេញដោយសម្ងាត់នូវដំណឹង អំពី ចំណុចខ្សោយរបស់យើង និង លបស្តាប់បទបញ្ជារបស់យើង»។

ប្រការទី 18 ៖ បើសត្រូវស្ថិតនៅ ជិតខ្លួនយើង ហើយវានៅតែស្ងប់ស្ងៀមនោះ គឺ វាកំពុងតែពឹងផ្អែក អាស្រ័យលើ ភាពខ្លាំងពីធម្មជាតិ នៃ ទីតាំងរបស់វាហើយ។

សេចក្តីអធិប្បាយ៖ ស៊ុនអ៊ូ បានកត់ត្រានៅទីនេះម្តងទៀតហើយ ស្តីពី ការអានសញ្ញាទាំងឡាយ វាជាប្រការល្អណាស់ ដែលការណ៍នេះ អាចបញ្ចូលទៅក្នុងសៀវភៅក្បួនយោធាសម័យទំនើប ដូចជា៖ ស្នាដៃរបស់ មេទ័ពបាដិន ផូវែល (Gen. Baden – Powell) ដែលមាន ចំណងជើងថា៖ «ជំនួយស្នាតីទាហានឈ្លប» (Aids to Scouting)។




www.facebook.com/7khmer
Fb page : Entertainment And Knowledge

ប្រការទី 19 ៖ នៅពេល ដែលសត្រូវ វារក្សាគម្លាតចម្ងាយមួយអន្លើ ហើយវាព្យាយាម ដើម្បីបង្កហេតុ បបួលច្បាំងជាមួយនឹងយើង គឺ វារសើបរសល់ ចង់ឲ្យកងណាមួយ របស់វា នៅភាគម្ខាងទៀត បានសម្រុកចូលមករកយើងហើយ។

សេចក្ដីអធិប្បាយ៖ ការណ៍នេះ ប្រហែលជាដោយសារតែវាឃើញយើងស្ថិតនៅលើទីតាំង ដែលមានប្រៀបខ្លាំងជាងវា ហើយវាចង់ដេញយើងចេញ ដើម្បីដណ្ដើមយកទីនេះតែម្ដង។ ទូមូ ពោលថា៖ «បើវាចូលមកក្បែរជិតយើង ហើយវាព្យាយាមជម្រុញ យើងឲ្យចូលច្បាំងនោះ វាហាក់ដូចជាស្អប់ខ្ពើមយើង ហើយមានលទ្ធភាពតិចណាស់ ដែលយើងត្រូវឆ្លើយតបចំពោះការប្រជែងរបៀបនេះ»។

ប្រការទី 20 ៖ បើសិនជា មើលទៅ ទីតាំងបន្ទាយរបស់វាមានសភាពងាយស្រួលឲ្យយើងចូលវាយលុកនោះ គឺវាកំពុងតែលួងលោម អន្ទងបញ្ឆោត ដាក់នុយឲ្យយើងតែប៉ុណ្ណោះ។

ប្រការទី 21 ៖ (១). បើមាន ចលនាកក្រើក តាមរវាងដើមឈើក្នុងព្រៃ វាបង្ហាញថា សត្រូវកំពុងសម្រុកចូលមកហើយ។




www.facebook.com/7khmer
Fb page : Entertainment And Knowledge

សេចក្តីអធិប្បាយ៖ ឆាវកុង ពន្យល់រឿងនេះថាជា «ការរំលំដើមឈើបើកផ្លូវ» ហើយចំណែក ចាងអ៊ីពោលថា៖ «ត្រូវឲ្យទាហានឈ្លបយកការណ៍ ម្នាក់ៗ ឡើងដើមឈើខ្ពស់ ហើយសង្កេតមើលចលនាសត្រូវ។ បើទាហានឈ្លបយកការណ៍បានឃើញថា ដើមឈើក្នុងព្រៃ កំពុងតែមានចលនា ហើយ ញ័ររញ្ជួយ, គេគួរតែដឹងថា ពួកសត្រូវកំពុងតែកាត់ដើមឈើរំលំសម្អាតច្រកផ្លូវសម្រាប់ព្យូហ៍ទ័ពរបស់វាហើយ»។

ប្រការទី 21 ៖ (២). បើលេចចេញ នូវ ផ្ទាំងទស្សនីយ៍ភាពអ្វីមួយនៅកណ្តាលវាលស្មៅក្រាស់ នោះមានន័យថា សត្រូវចង់ធ្វើឲ្យយើងមានការសង្ស័យហើយ។

សេចក្តីអធិប្បាយ៖ ការពន្យល់ របស់ ទូអ៊ុ ដែលបានខ្ចីពីឆាវកុង មកនោះ មានជាសេចក្តីថា៖ «ការលេចបង្ហាញចេញមក នូវ ផ្ទាំងទស្សនីយ៍ភាពមួយចំនួនណានោះ ឬរូបរាងជា រោងនៅចំកណ្តាលកម្រាស់ នៃ សារពើរុក្ខជាតិ គឺ ជាសញ្ញាយ៉ាងប្រាកដថា សត្រូវបានភៀសខ្លួនទៅហើយ តែថា ដោយសារវាខ្លាចយើងដេញតាម វាក៏បានសាងសង់កន្លែង ដោយលាក់កំបាំង ដើម្បីនឹង




www.facebook.com/7khmer
Fb page : Entertainment And Knowledge

ធ្វើឲ្យយើងសង្ស័យថាជា កងទ័ពបង្កប់»។ វាជាសញ្ញា លេចចេញមកថា «ផ្ទាំងទស្សនីយ៍ភាព» ទាំងអស់នេះ គឺ ត្រូវបានគេសាងសង់តម្លើងរួមជាមួយគ្នា ដោយដើម ស្មៅ វែងៗ ដែលបានមកពីទាហានខ្មាំងយកមកតាម ផ្លូវ ដែលវាបានដកថយឆ្លងកាត់មកនោះ។

ប្រការទី **22** ៖ (១). ការណ៍ដែលមាន សត្វបក្សាបក្សី វា ផ្អើល ហើរឡើងទៅខាងលើអាកាស វាជាសញ្ញាបញ្ជាក់ថា មានកងទ័ពពួនស្ទាក់នៅម្តុំទីនោះហើយ។

សេចក្តីអធិប្បាយ៖ សេចក្តីពន្យល់របស់ ចាងអ៊ី គឺពិត ជាត្រឹមត្រូវ ដោយគ្មានមន្ទិលសង្ស័យអ្វីឡើយ ត្រង់ថា៖ «កាលណា សត្វបក្សាបក្សី កំពុងតែហោះហើរ តាម បណ្តោយជួររបស់វា ត្រង់ៗ សុខៗ ក៏ស្រាប់តែស្ទុះហើរ ឡើងទៅខាងលើ នេះមានន័យថា មានទាហានពួន បង្កប់ ស្ទាក់ នៅចំណុចណាមួយខាងក្រោមនោះ មិន ខានឡើយ»។


www.facebook.com/7khmer
Fb page : Entertainment And Knowledge

ប្រការទី 22 ៖ (២). ការណ៍ ដែលសត្វព្រៃស្ទុះ ភ្ញាក់ ផ្អើលឡើង វាជាសញ្ញាឲ្យដឹងថា ការវាយប្រហារជាបន្ទាន់ណាមួយកំពុងតែខិតជិតមកដល់ហើយ។

ប្រការទី 23 ៖ (១). នៅពេល មានធូលីហុយឡើង ដូចជាសសរយ៉ាងខ្ពស់ វាជាសញ្ញាបញ្ជាក់ន័យថាមានរទេះចម្បាំងកំពុងតែសម្រុកចូលមកហើយ, ពេលដែល មានធូលីហុយឡើងលើ ក្នុងរយៈកម្ពស់ទាប តែវាហុយក្នុងទ្រង់ទ្រាយធំទូលាយ នេះជាសញ្ញាបញ្ជាក់ឲ្យឃើញថា មានទ័ពថ្មើរជើងកំពុងតែសម្រុកចូលមកជិតហើយ។

*សេចក្ដីអធិប្បាយ៖ «ខ្ពស់ ហើយ ស្រួច» ឬ ឆ្ពោះឡើងទៅខាងលើយ៉ាងខ្ពស់ គឺ ពិតជាអ្វីដែលត្រូវបាននិយាយបំផ្លើសចំពោះការហុយធូលី។ ចំពោះអ្នកអត្ថាធិប្បាយទាំងឡាយ ពន្យល់ អំពី បាតុភូតនេះ ដោយនិយាយថាគឺជា សេះ និង រទេះ ដែលវាធ្ងន់ជាងមនុស្ស ហើយធ្វើឲ្យហុយប៉ើងធូលីច្រើនជាង ហើយរទេះ បរតាមគ្នាពីមួយ ទៅមួយ ឯចំណែកទាហាន គឺ លើកគ្នាដើរដោយជើង ជាច្រើនជួរទន្ទឹមគ្នា ។*





www.facebook.com/7khmer
Fb page : Entertainment And Knowledge

ទាក់ទងទៅនឹង ចាងអ៊ី ដែលគាត់និយាយថា៖ «រាល់ការយាត្រាទ័ព ត្រូវតែបញ្ជូនកងឈ្លបយកការណ៍ឲ្យទៅជាមុន, នរណា ដែលមើលឃើញធូលីហុយឡើងទៅលើដោយសារសត្រូវ នឹងត្រូវបំផាយសេះ បកមករាយការណ៍ ជូនអគ្គបញ្ជាការកងទ័ពវិញភ្លាម»។ បើប្រៀបធៀបជាមួយស្នាដៃ មេទ័ព បាដិន ផូវែល ដែលសរសេរថា៖ «នៅពេលអ្នកធ្វើចលនាតាមបណ្ដោយផ្លូវ អាចនិយាយថា នៅក្នុងប្រទេសសត្រូវទៅចុះ, ភ្នែករបស់អ្នកត្រូវមើលឲ្យបានឆ្ងាយ រំពៃរកសត្រូវ ឬ សញ្ញាទាំងឡាយរបស់វា ដូចជា ចំនួនលេខ, ធូលី ដែលហុយឡើង, សត្វស្លាបដែលវាផ្អើលហើរឡើង, ពន្លឺចាំងចេញពីអាវុធ .ល. ។ (ជំនួយស្មារតីកងឈ្លបយកការណ៍, Aids to Scouting ទំព័រទី ២៦)។

ប្រការទី ៖ 23 (២). ពេលណា ឃើញថា សត្រូវបំបែកគ្នាចេញទៅតាមទិសដៅ ផ្សេងៗ គ្នា ការណ៍នេះ បង្ហាញថា កងទាហានសត្រូវទាំងនេះ ត្រូវបានគេបញ្ជូន ឲ្យទៅប្រមូលឧសដុត។ បើមានធូលីអណ្ដែតឡើងពីរ បីដុំ ដូចជា ពពកទៅមកៗ មានន័យថា ទាហានកំពុងតែបោះជំរុំ។




www.facebook.com/7khmer
Fb page : Entertainment And Knowledge

ចាងអ៊ី ពោលថា៖ «នៅក្នុងការបែងចែក ភារកិច្ច ការពារតាមទិសតំបន់ រៀងៗខ្លួន គឺត្រូវបញ្ជូនសេះលឿនទៅស្ទាបស្ទង់មើលទីតាំង និង មើលឲ្យដឹងច្បាស់ពីចំណុចខ្លាំង និង ចំណុចខ្សោយ តាមគ្រប់រាល់កាលទេសៈ។ ដូចនេះ ចលនាទ័ពអាចនាំឲ្យមានធូលីហុយតិចតួច ដោយសារតែចលនារបៀបនេះប៉ុណ្ណោះឯង។

ប្រការទី **24** ៖ (១). មិនសូវនិយាយ ឬ និយាយដាក់ខ្លួនហើយ បង្កើនការត្រៀមរៀបចំ នេះជាសញ្ញា បង្ហាញថាសត្រូវកំពុងតែត្រៀមខ្លួនសម្រុកចូលមកហើយ។

សេចក្ដីអធិប្បាយ៖ ទូមូ ពោលថា៖ «បើគិតទៅ ពួកសត្រូវនៅមានគោលជំហរទន់ខ្សោយ ដោយសារពួកវាខ្លាចក្រែងយើងយ៉ាងខ្លាំង។ កម្មវត្ថុរបស់ពួកវា គឺធ្វើឲ្យយើងប្រមាថ និង ធ្វេសប្រហែស បន្ទាប់ពីនោះមកវានឹងវាយប្រហារយើងតែម្ដង»។ ចាងអ៊ី និយាយដល់រឿង ចានតាន់ នៃ នគរឈីម៉ូ កំពុងប្រឈមច្បាំងនឹងកងទ័ពយេន ដែលដឹកនាំដោយ ឈីឈា។ នៅក្នុង





www.facebook.com/7khmer
Fb page : Entertainment And Knowledge

ជំពូកទី៨២ នៃ ស្នាដៃ ស៊ុឈឺ ដែលយើងបានអាន គឺមានសេចក្ដីថា៖ «ធានតាន់ បាននិយាយដោយចំហថា៖ សេចក្ដីភ័យខ្លាចរបស់ខ្ញុំ មានតែមួយគាត់ គឺ ក្រែងតែទាហានយេនកាត់ប្រមុះអ្នកទោសនគរឈីម៉ូ ហើយយកពួកគេទៅដាក់នៅពីមុខជួរទាហានវា ដើម្បីវាយប្រហារតតាំងនឹងយើងទេ នោះនឹងក្លាយទៅជា សេចក្ដីអន្តរាយ នៃ ក្រុងរបស់យើងនេះហើយ។

ភាគីម្ខាងទៀត ដែលជាសត្រូវនោះ ត្រូវបានគេនាំពាក្យធានតាន់យកទៅប្រាប់ បន្ទាប់មក ពួកគេក៏ធ្វើតាម ប្រៀបដូចជា ការឲ្យយោបល់អញ្ចឹងដែរ ប៉ុន្តែចំពោះ អ្នកនៅក្នុងក្រុងវិញ គេមានចិត្តក្ដៅក្រហាយដោយសារ សាច់ញាតិសារលោហិតរបស់ពួកគេ ត្រូវបានកាត់អាវយវៈចេញ ហើយពួកគេ ក៏មានសេចក្ដីភ័យខ្លាច ក្រែងលោខ្លួនគេធ្លាក់ខ្លួនទៅក្នុងដៃសត្រូវដែរ ដូចនេះ ពួកគេ ក៏នៅមានវិញ្ញាណរក្សាសេចក្ដីក្លាហានការពារខ្លួនយ៉ាងក្រអើតលើសដើមទៅទៀត។




www.facebook.com/7khmer
Fb page : Entertainment And Knowledge

លើកនេះ ម្តងទៀតហើយ ធានតាន់ បាន បញ្ជូនចារបុរសឲ្យនាំពាក្យទៅប្រាប់សត្រូវថា៖ «អ្វីដែលខ្ញុំកោតខ្លាចជាងគេនោះ គឺ ក្រែងតែទាហាននគរយេន អាចនឹងជីកកកាយផ្នូរដូនតា ដែលនៅក្រៅក្រុង ហើយប្រមាថមើលងាយ មើលថោកមកលើ ដីដូនជីតា បុព្វបុរសរបស់យើងទេ ទើបនាំឲ្យយើង ឈឺចាប់ក្នុងចិត្តខ្លាំងបំផុតនោះ។

ភ្លាមនោះដែរ ទាហានយេន ដែលឡោមព័ទ្ធក្រុងទាំងនោះ ក៏នាំគ្នាជីកកកាយ ផ្នូរ និង ដុតសាកសព ដែលមាននៅក្នុងផ្នូរទាំងនោះដែរ។ អ្នកក្រុងជីម៉ូ មើលឃើញយ៉ាងជាក់ស្តែង ដោយកំពីងពីក្នុងកំផែងជញ្ជាំងក្រុងទៅ ឃើញនឹងភ្នែក ក៏នាំគ្នាយំសោក ដោយសេចក្តីអាណិតអាសូរដីដូនជីតារបស់ខ្លួន ហើយ ទាំងអស់គ្នាអស់សេចក្តីអត់ធន់ខន្តីអ្វីទាំងអស់ ពួកគេនឹកចង់តែចេញទៅក្រៅក្រុង ទៅរកច្បាំងគ្នាតែម្តង សេចក្តីក្រេវក្រោធរបស់ពួកគេ ក៏កើនឡើងដល់ទៅដប់ដង។ ខណៈនោះ ធានតាន់ ដឹងថា ឃោធារបស់គាត់ មានលក្ខណៈរួចរាល់ ដើម្បីបើកការវាយប្រហារហើយ។ ជាការ





www.facebook.com/7khmer
Fb page : Entertainment And Knowledge

៥ ជំនួសឲ្យដាវ ដែលគាត់ខ្លួនឯង ក៏ធ្វើអញ្ចឹងដែរ គឺ គាត់បែរជាកាន់ចបកាប់នៅនឹងដៃរបស់គាត់ និង បញ្ជាអ្នកដទៃទៀត ដោយមិនរើសមុខមនុស្សក្នុងចំណោមអ្នកចម្បាំង ល្អៗ បំផុតរបស់គាត់ឲ្យធ្វើដូចនេះដែរ, ចំណែកជួរទាហានទាំងឡាយ ត្រូវបំពេញដោយ ប្រពន្ធ និង សហាយ។ ពេលនោះ គាត់ទទួលទានអាហារទាំងអស់ដែលនៅសល់ ហើយ គាត់ក៏បញ្ជាទាហានរបស់គាត់ឲ្យបរិភាគឆ្អែតដែរ។ ទាហាន មែនទែននោះ ត្រូវបានគាត់ប្រាប់ឲ្យនៅលាក់ខ្លួនកុំឲ្យគេឃើញ ហើយនៅតាម
៦ កំពែងទីក្រុង គាត់ដាក់សុទ្ធតែមនុស្សចាស់, មនុស្សជរា និង មនុស្សស្រីឲ្យនៅយាមរក្សា។

កិច្ចការនេះត្រូវបានបំពេញរួចរាល់ បេសកជនក៏ត្រូវបានបញ្ជូនទៅបន្ទាយ សត្រូវដើម្បីរៀបចំដំណើរសុំចុះចាញ់, ខណៈនោះ ទាហានយេន ក៏ចាប់ផ្ដើមស្រែកច្រៀងយ៉ាងសប្បាយរីករាយឡើង។ ធានតាន់ ក៏បានប្រមូលប្រាក់សុទ្ធ ចំនួន ២០,០០០អោនស៍ ពីប្រជានុរាស្ត្រ និង បានឲ្យអភិជនក្នុងនគរឈីម៉ូ ជួយបញ្ជូនប្រាក់ទាំងនេះ ទៅជូនមេទ័ពយេន ព្រមដោយពាក្យ




www.facebook.com/7khmer
Fb page : Entertainment And Knowledge

អង្គរល្បងលោមថា នៅពេលដែលក្រុងនេះ ចុះចាញ់ មែនទែនទៅ គាត់នឹងឲ្យយកទ្រព្យសម្បត្តិតាមផ្ទះ ឬ ប្រគល់ឲ្យនូវ នារីៗ ទាំងឡាយ ដើម្បីទុកជាការលេង សើចកំសាន្តអារម្មណ៍ថែមទៀតផង។

ឈីឈា ដោយមានសេចក្ដីកម្រើកចិត្ត ត្រេក អរ ភ្លេចខ្លួន ក៏បានទទួលយកការសុំចុះចូល និង ពាក្យ អង្វរនេះ ក៏ប៉ុន្តែទាហានគាត់ឥឡូវនេះ បែរជាខ្ជីខ្ជារ និង ធ្វេសប្រហែសទៅវិញ។ នៅគ្រានោះ ធានតាន់ ប្រមូល បានគោឈ្មោល ចំនួន ១,០០០ក្បាល, តុបតែងវាដោយ សំពត់សូត្រក្រហម, លាបថ្នាំលើខ្លួនវាដូចជានាគ, មាន ឆ្នូតពណ៌ ផ្សេងៗ, ចងភ្ជាប់ផ្លែកាំបិតមុតស្រួចនៅនឹង ស្នែង និង មានចងរុក្ខជាតិងាយឆេះ លាបខ្លាញ់យ៉ាង ជោកនៅលើកន្ទុយរបស់គោទាំងនោះ។ លុះពេលយប់ មកដល់ គាត់ដុតចុងម្ខាង នៃ រុក្ខជាតិ ដែលងាយឆេះ ទាំងនោះ ហើយដេញគោទាំងនោះ ឲ្យចេញទៅ តាម ប្រហោងទាំងឡាយ ដែលគាត់បានចោះ នៅតាម កំផែងជញ្ជាំង ដោយបញ្ជិះពីលើខ្នងគោទាំងនោះ នូវ អ្នកចម្បាំងជម្រើស ចំនួន ៥,០០០នាក់។ សត្វគោ




www.facebook.com/7khmer
Fb page : Entertainment  And Knowledge

ទាំងនោះ ឆ្កួតវង្វេងខឹង ដោយសារការឈឺចាប់ ក៏ស្ទុះបោលចេញទៅ ដោយកំហឹងចូលទៅក្នុងបន្ទាយសត្រូវ ជាទីដែលគោទាំងនោះយល់ច្រឡំដ៏ខ្លាំងក្លា និង ដេញបំភ័យមនុស្សជាសត្រូវទាំងនោះ, កន្ទុយរបស់វា មានតួនាទីដូចជាចន្លុះបំភ្លឺ បញ្ចាំងឲ្យឃើញនូវរូបរាង យ៉ាងអាក្រក់នៅលើខ្លួនវា ហើយកាំបិតនៅលើស្នែង ទុកដើម្បីសម្លាប់ ឬ បង្ករបួសស្នាម ចំពោះនរណា ដែលទាក់ទងនឹងវា។ នៅខណៈនោះដែរ កងទាហាន ចំនួន ៥,០០០នាក់ បានលបលូនចូលទៅជាមួយឆ្នុកមាត់ នៅក្នុងមាត់, ក៏ចាប់ផ្តើមវាយប្រហារលើសត្រូវ។ នៅពេលនោះដែរ សូរសន្ធឹកដ៏គួរឲ្យរន្ធត់ ក៏លាន់លេចចេញមកពីក្នុងទីក្រុង គឺ មនុស្សទាំងនោះ ដែលនៅខាងក្រោយត្រូវធ្វើឲ្យមានសម្លេងទ្រហឹងអឺងអាប់ ឲ្យខ្លាំងក្លា តាមដែលអាចធ្វើបាន ដោយទូងស្គរ និង វាយគងសំរឹទ្ធលុះត្រាតែមេឃ និង ដីកើតវប្បល្លាស ដោយសារសូរសម្លេងដ៏ទ្រហឹងអឺងអាប់យ៉ាងនេះ។

វាជាការវាយសម្លុត, ទាហានយេនរត់ យកតែរួចខ្លួន រប៉ាត់រប៉ាយទៅ ត្រូវបានគេដេញតាមយ៉ាង




www.facebook.com/7khmer
Fb page : Entertainment And Knowledge

ប្រកិត ដោយទាហាននគរឈីម៉ូ ដែលបានទទួលជ័យ ជំនះ ហើយ ប្រល័យជីវិតមេទ័ពឈីឈា...។ លទ្ធផល នៃ ចម្បាំងចុងក្រោយ គឺ បានរំដោះយកក្រុង ទាំង ៧០ ដែលធ្លាប់ជាកម្មសិទ្ធិរបស់នគរឈីម៉ូកាលពីមុនមកវិញ ទាំងអស់។

ប្រការទី 24 ៖ (២). ការប្រើភាសាហឹង្សា និង ភាពគឃ្លើន ដូចជា ចង់ចូលប្រយុទ្ធណាស់ គឺជា សញ្ញា មានន័យថា សត្រូវរៀបនឹងដកថយទៅហើយ។

ប្រការទី 25 ៖ នៅពេល ដែលរទេះចម្បាំងប្រភេទស្រាល ចេញមកខាងមុខ ហើយក៏ចូលទៅ កាន់ទីតាំងលើស្លាបទាំង សងខាងនោះ វាជាសញ្ញាបង្ហាញថា សត្រូវកំពុងរៀបចំទ័ព ដើម្បីវាយប្រយុទ្ធហើយ។

ប្រការទី 26 ៖ ការស្នើសុំផ្អាកសង្គ្រាម ដែលមិនបានភ្ជាប់ មកជាមួយនូវសន្តិសញ្ញា ស្បថស្បែ មកផងទេ វាបង្ហាញថា ជាគម្រោងការក្បត់។

សេចក្តីអធិប្បាយ៖ អំណាននៅទីនេះ ហាក់ដូចជា មិន សូវច្បាស់លាស់ទេ។ លីឈាន់បញ្ជាក់ថា៖ «សន្ធិសញ្ញា

ត្រូវមានការស្បថស្បែ ជាតឹកតាង និង មានការដូរឈ្លើយសឹកគ្នាផងដែរ»។ យ៉ាងណាមិញ វ៉ាងស៊ី និង ចាងអ៊ី ពោលយ៉ាងសាមញ្ញថា៖ «សេចក្តីនេះ វាគ្មានហេតុផល» និង «គ្រាន់តែ ជាលេសឥតខ្លឹមសារប៉ុណ្ណោះ»។

ប្រការទី 27 ៖ (១). នៅពេល មានការរត់ត្រហេបត្រហាបក្នុងសភាពប្រសេចប្រសាច,

សេចក្តីអធិប្បាយ៖ គឺ ទាហានគ្រប់រូប ដែលប្រញាប់ប្រញាល់ ដោយរត់សំដៅទៅរកទីតាំងឈរជើង របស់ខ្លួន តាមបដាសញ្ញាកងឯកភាពរបស់ខ្លួន នីមួយៗ។

ប្រការទី 27 ៖ (២). ហើយបន្ទាប់មកទាហានទាំងអស់នោះក៏ចូលទៅក្នុងជួរ, វាមានន័យថា ពេលវេលាដ៏មធ្យ័តបានមកដល់ហើយ។

ប្រការទី 28 ៖ នៅពេល ឃើញមានទាហានខ្លះ សម្រុកចូលទៅមុខ និង ទាហានខ្លះដកថយ នោះគឺ គ្រាន់តែជាការបញ្ឆោតប៉ុណ្ណោះ។



www.facebook.com/7khmer

Fb page : Entertainment And Knowledge

* ប្រការទី 29 ៖ នៅពេល ទាហានទាំងឡាយឈរ ដោយផ្អែកពិតទៅលើលំពែង នោះមានន័យថា ពួកគេទន់ខ្សោយកម្លាំងដោយសេចក្ដីឃ្លានអាហារហើយ។

* ប្រការទី 30 ៖ បើទាហានទាំងឡាយ ដែលត្រូវបានបញ្ជូនឲ្យទៅដងទឹកនោះ គេចាប់ផ្ដើមផឹកទឹក ដោយខ្លួនឯងជាមុន នោះមានន័យថា ពលទាហានកំពុងតែស្រេកទឹកហើយ។

*សេចក្ដីអធិប្បាយ៖ ដូចដែល ទូមូ កត់សម្គាល់ទុកថា៖ «គង់មានអ្នកខ្លះអាចនឹងយល់ ដឹងបាន នូវបែបផែនរបស់យោធាទាំងមូល ដោយសារ ការសម្គាល់ចំពោះចរិតលក្ខណៈរបស់មនុស្សម្នាក់ ចេញពីពួកទាហាន គ្នាគេនោះឯង។*

* ប្រការទី 31 ៖ បើសិនជា សត្រូវមើលឃើញគុណសម្បត្តិ ដើម្បីកេងចំណេញយកប្រៀបហើយ តែពួកវាមិនបានប្រឹងប្រែង ដើម្បីធានាការពារវាទុកទេ ការណ៍នោះ មានន័យថា ពួកសត្រូវ ក៏ខ្សោះខ្សោយសោះអង្គើយទៅហើយដែរ។




www.facebook.com/7khmer
Fb page : Entertainment And Knowledge

\+ ប្រការទី **32 ៖** (១). បើសិនជា សត្វបក្សាបក្សីប្រមូលផ្តុំគ្នានៅលើទីចំណុចឯណានីមួយ មានន័យថា ទីតាំងនោះ មិនទាន់មាននរណាចូលទៅកាន់កាប់នៅឡើយទេ។

*សេចក្តីអធិប្បាយ៖ ដូចដែល ឆិនហាវ លើកជាតួយ៉ាង មានសេចក្តីថា ការពិតដ៏មានប្រយោជន៍ដែលត្រូវចាំក្នុងចិត្តនោះ គឺថា សត្រូវបានបោះបង់បន្ទាយរបស់វានៅទីនោះ ចោលដោយសម្ងាត់ជាស្រេចទៅហើយ។*

\+ ប្រការទី 32 ៖ (២). សម្រែកគឹកកងរំពងនាពេលរាត្រី គឺជាសញ្ញាបញ្ជាក់ន័យ អំពី ការភ័យរអើល។

* ប្រការទី **33 ៖** បើសិនជា មានការរំខានកើតឡើងខាងក្នុងបន្ទាយ គឺមកពីអំណាចរបស់មេទ័ពទន់ខ្សោយ។ បើសិនជាបដា និង ទង់ទាំងឡាយផ្លាស់ប្តូររកេតរកូតហើយ នោះជាសញ្ញាបង្ហាញថា ការបះបោរកំពុងតែកើតមានហើយ។ បើសិនជា នាយទាហានកើតខឹង នោះមានន័យថា កូនទាហានធុញថប់អស់កម្លាំងហើយ។

*សេចក្តីអធិប្បាយ៖ ទូមូ យល់ឃើញប្រយោគនេះ តាមន័យផ្សេងថា៖ «បើសិនជា នាយទាហានទាំងអស់ក្នុងកងទ័ព កើតខឹងនឹងមេទ័ពរបស់ពួកគេ នោះមានន័យ*





www.facebook.com/7khmer
Fb page : Entertainment And Knowledge

ថា ពួកគេនឿយណាយ សោះអង្គើយចំពោះការងារ ពិបាកៗ ហើយ» ដោយហេតុថា ការងារចេះតែមាន ដែលមេទ័ពបានបញ្ជាឲ្យពួកគេធ្វើថែមទៀត។

ប្រការទី 34 ៖ (១). នៅពេល ដែលទាហាន ឲ្យសេះស៊ី សុទ្ធតែគ្រាប់ធញ្ញជាតិ ហើយ ពួកគេសម្លាប់សត្វពាហនៈ របស់គេជាអាហារនោះ,

សេចក្តីអធិប្បាយ៖ តាមដំណើរធម្មតា នៃ មនុស្ស នឹងត្រូវចិញ្ចឹមខ្លួនដោយអាហារ និង ធញ្ញជាតិ ចំណែក សេះ ភាគច្រើនស៊ីស្មៅជាអាហារ។

ប្រការទី 34៖ (២). ហើយនៅពេល ដែលទាហានមិនព្រម ព្យួរឆ្នាំងបាយសម្លរបស់ខ្លួន ទុកនៅ ពីលើផ្ទះបាយតាមជំរុំ របស់ពួកគេទេ ទាំងនេះ ជាសញ្ញាបង្ហាញថា ពួកគេនឹងមិន វិលទៅជំរុំវិញឡើយ អ្នកត្រូវដឹងថា ពួកគេបានកំណត់ទុកថា នឹងច្បាំងទាល់តែស្លាប់ខ្លួន។

សេចក្តីអធិប្បាយ៖ ខ្ញុំអាចនឹងដកស្រង់សម្តី ពី ស្នាដៃ ហូវហាន់ស៊ុ យកមកពន្យល់ក្នុង ទីនេះ តាមជំពូកទី៧១ ដែលមានសេចក្តីសង្ខេបដោយ ប៉ិរិនយុនហ្វ៊ូ ថា៖ ពួក





www.facebook.com/7khmer
Fb page : Entertainment And Knowledge

ឧទ្ទាម វ៉ាំងគូ នៃ ដែនដីលាំង កំពុងតែឡោមព័ទ្ធក្រុង ឆិនឆាង ដែលមាន ហ័ងហ៊្វស៊ុង ជាមេបញ្ជាការជាន់ខ្ពស់នៅក្រុងនោះ ចំណែក ទុងចូ ត្រូវបានរាជការបញ្ជូន ឲ្យមកជួយច្បាំងទល់នឹងពួកឧទ្ទាម ប៉ុរិនយុនហ៊្វ នេះ។ ពួកឧទ្ទាម ប៉ុរិនយុនហ៊្វ បានបុករុកទម្លាយក្រុងយ៉ាងខ្លាំង តែ ហ័ងហ៊្វស៊ុង មិនព្រមស្តាប់តាមទីប្រឹក្សារបស់គាត់សោះឡើយ។

នៅចុងក្រោយ ពួកឧទ្ទាម ក៏ចាប់ផ្តើមចាញ់ដៃវិញយ៉ាងធ្ងន់ធ្ងរ ហើយក៏តាំងនាំគ្នាបោះអាវុធចោលដោយស្ម័គ្រចិត្តខ្លួនឯង។ ហ័ងហ៊្វស៊ុង មិនទាន់បានសម្រុកដេញ តាមវាយប្រហារពួកឧទ្ទាមភ្លាមនៅឡើយទេ ក៏ប៉ុន្តែ ទុងចូ បាននិយាយថា៖ «តាមគោលការណ៍ក្នុងសឹកសង្គ្រាម គឺ កុំដេញតាមពួកទាហាន ដែលអស់សង្ឃឹមទៅហើយនោះ និង កុំបុករុក សង្កត់សង្កិនទាហានដែលកំពុងតែដកថយទៅហើយនោះឲ្យសោះ។ ហ័ងហ៊្វស៊ុង ឆ្លើយតបមកវិញថា៖ «តែទីនេះ វាមិនមែនអញ្ចឹងទេ។ ការណ៍ដែលខ្ញុំ ប្រុងនឹងដេញវាយប្រហារនេះ គឺជា ពួកទាហានដែលបាក់ទ័ព គឺ មិនមែនជា





www.facebook.com/7khmer
Fb page : Entertainment And Knowledge

ទាហាន ដែលកំពុងដកថយ ដោយមានវិន័យនោះទេ, ខ្ញុំចូលវាយលុកលើហ្វូងទាហាន ដែលរញ៉េរញ៉ៃ គ្មានសណ្តាប់ធ្នាប់ គឺ មិនមែនកងទាហានដែលអស់សង្ឃឹមនោះទេ។ ពេលនោះ គាត់ ក៏នាំទ័ពសម្រុកចូលច្បាំង ដោយគ្មានការគាំទ្រ ពី សហសេវិករបស់គាត់ឡើយ ហើយ ក៏ដេញកាប់ចាក់ធ្វើឲ្យសត្រូវបាក់បែកទ័ពអស់ទៅ។ វ៉ាំងគួ ត្រូវបានគេប្រល័យជីវិតចោល នាពេលនោះទៅ។

ប្រការទី **35** ៖ ការណ៍ដែលមាន ពួកទាហានខ្សឹបខ្សៀវ ជុំៗគ្នា ជាក្រុម តូចៗ ឬ មានឮ ទឹកដមសម្លេងនិយាយបង្រ្កាប វាចង្អុលបង្ហាញថា មានការបាក់បែកក្នុងចំណោមពលទាហានក្នុងជួរ និង កងទាហាននៅថ្នាក់ក្រោមនោះមិនខាន។

ប្រការទី **36** ៖ (១). ការផ្តល់បំណាច់រង្វាន់ញយដងពេក ជាសញ្ញាបញ្ជាក់ថា សត្រូវប្រើជិតអស់ស្បៀងរបស់វាហើយ។

សេចក្តីអធិប្បាយ៖ ដូចដែល ទូមូ និយាយអញ្ចឹងថា៖ ព្រោះនៅពេលណា ដែលកងយោធាទទួលរង នូវ ការ





www.facebook.com/7khmer
Fb page : Entertainment  And Knowledge

បុករុក វាយទម្លាយដ៏ខ្លាំងក្លា ជានិច្ចកាល មេទ័ពតែងតែមាន អារម្មណ៍ភ័យខ្លាចក្រែងមានអំពើបះបោរផ្ទៃក្នុងកើតឡើង ក៏តាំងតែ ចែកចាយ កញ្ចះកញ្ចាយ នូវអំណោយ ជាបំណាច់រង្វាន់ ឲ្យទៅមនុស្សទាំងឡាយ ដើម្បីរក្សាអ្នកទាំងនោះ ឲ្យនៅមានចិន្តារម្មណ៍ល្អនឹងនរជាមួយខ្លួនតទៅទៀត។

ប្រការទី 36 ៖ (២). ទណ្ឌកម្មច្រើនហួសពេក នាំឲ្យមានការឈឺចាប់ ក៏នឹងញ៉ាំងអំពើពុតត្បុតក្បត់ឲ្យកើតឡើងបាន។

សេចក្តីអធិប្បាយ៖ ព្រោះថា នៅក្នុងករណីរបៀបនេះ រាល់គោលវិន័យ តែងតែត្រូវបានគេបន្ធូរបន្ថយ ហើយក្នុងភាពចលាចលមិនធម្មតាយ៉ាងនេះ កិច្ចការ ដែលចាំបាច់នោះគឺ ត្រូវរក្សាមនុស្សនៅតាមតំណែងឲ្យបំពេញភារកិច្ចសិន។

ប្រការទី 37 ៖ ចូរចាប់ផ្តើម ដោយសម្តីអួតក្អេងក្អាង ប៉ុន្តែបន្ទាប់មក ចូរធ្វើជាភ័យរន្ធត់ ចំពោះ ចំនួនកម្លាំងទ័ពរបស់សត្រូវ ហើយ ចូរបង្ហាញនូវការទុញទាល់ផ្នែកសតិបញ្ញាទៅឲ្យសត្រូវបានឃើញផង។





www.facebook.com/7khmer
Fb page : Entertainment And Knowledge

សេចក្ដីអធិប្បាយ៖ ខ្ញុំសូមយកតាមសេចក្ដីបកស្រាយរបស់ ឆាវកុង ដែលសេចក្ដីនេះ ត្រូវបានទទួលយល់ស្របដោយ លីឈាន់, ទូមូ និង ចាងអ៊ី។ ការបកស្រាយមួយបែបទៀត ដែលអាចប្រើការបាន របស់ ទូអ៊ី, ចាលីន, ម៉ីយ៉ាវធិន និង វ៉ាងស៊ី គឺមានជាសេចក្ដីថា៖ «មេទ័ពណា ដែលជិះជាន់ សង្កត់សង្កិនកូនទាហាន របស់ខ្លួន ជាមុន ក៏អាចនឹងធ្លាក់ខ្លួនចូលទៅក្នុងអំពើបះបោរ ...ល...»។ ការណ៍ដែលនិយាយយ៉ាងនេះ វាមានន័យ អាចភ្ជាប់សេចក្ដីទៅនឹងប្រយោគដែលនិយាយមកពីខាងដើម អំពី បំណាច់រង្វាន់ និងការដាក់ទណ្ឌកម្មបានហើយ។

ប្រការទី 38 ៖ នៅពេលណាដែលមានការបញ្ជូនបេសកជនដោយឲ្យនាំមកជាមួយ នូវ ពាក្យសម្ដីសរសើរចេញពីមាត់របស់គេនោះផង នេះជាសញ្ញាបង្ហាញថា សត្រូវមានបំណងផ្អាកសង្គ្រាមហើយ។

សេចក្ដីអធិប្បាយ៖ ទូមូ ពោលថា៖ «បើសិនជា សត្រូវបើកចំហចំណងទាក់ទង ជាមិត្តភាព ហើយបញ្ជូន


www.facebook.com/7khmer
Fb page : Entertainment And Knowledge

ឈ្លើយសឹកមកឲ្យវិញ នេះជាសញ្ញា បញ្ជាក់ន័យថា ពួកវាមានសភាពអន្ទះសារ ចង់បញ្ចប់សង្គ្រាមហើយ ដោយហេតុថា ពួកវាអស់កម្លាំង ឬក៏ មានហេតុផលដទៃទៀត»។ ប៉ុន្តែវាពិតជាចាំបាច់ណាស់ ដែលត្រូវការឲ្យ ស៊ុនអ៊ូ គាត់លើកឡើងឲ្យឃើញជាប្រត្យក្សនៅក្នុងបទវិចារណារបស់គាត់នៅទីនេះផង។

ប្រការទី **39 ៖** បើសិនជា កងទាហានរបស់សឹកសត្រូវលើកជាព្យុហ៍ទ័ព ប្រកបដោយភាពខឹងសម្បារ ហើយក៏ស្រាប់តែឈប់ទ្រឹង នៅប្រឈមមុខ ទល់នឹងទាហានរបស់យើង អស់កាលដ៏យូរ ដោយមិនព្រមចូលប្រយុទ្ធ ឬ មិនបានដកខ្លួនចេញទេ នោះគឺជា ស្ថានការណ៍មួយ ដែលទាមទារឲ្យមានការឃ្លាំមើលជិតដល់ មុតមាំ និង ការប្រុងប្រយ័ត្នដល់កម្រិតខ្ពស់បំផុត។

សេចក្តីអធិប្បាយ៖ ឆាវកុង ពោលថា ក្នុងសមយុទ្ធបែបនេះ អាចជាឧបាយបញ្ឆោត ដើម្បីកេងចំណេញពេលវេលា ក្នុងគោលបំណងចោមវាយយើង ពីចំណុចណាមួយផ្សេងទៀត ដែលយើងមិនអាចនឹងគិតដឹងជាមុន ឬ ដើម្បីនឹងបង្កប់កម្លាំងសម្ងាត់ របស់វា ឲ្យពួន




www.facebook.com/7khmer
Fb page : Entertainment  And Knowledge

ស្ទាក់វាយប្រហារ នៅតាមចំណុច ណាមួយទៀត តែប៉ុណ្ណោះ។

ប្រការទី 40 ៖ (១). បើសិនជា ចំនួនកងកម្លាំងរបស់យើង តិចជាងចំនួនកម្លាំងខាងសត្រូវ នោះគឺជា ការចាញ់ប្រៀប លើសលប់ ស្ថានការណ៍បែបនេះ គឺ មិនអាចបើកការវាយ ប្រយុទ្ធ ដោយផ្ទាល់បានទេ។

សេចក្ដីអធិប្បាយ៖ បើតាមន័យរបស់ពាក្យ គឺថា «គ្មាន ការវាយសម្រុកណា ដែលអាចធ្វើទៅកើតនោះទេ» គឺ អាចនិយាយបានថាជា ឧបាយកលឆេង ហើយ ត្រូវ គេចវាងកុំវាយប្រហារពីខាងមុខ ហើយ ចូរបែរមកប្រើ កលយុទ្ធជាជំនួសវិញ។

ប្រការទី 40 ៖ (២). អ្វីដែលយើងអាចធ្វើបាននោះ គឺ ជា សាមញ្ញធម្មតា ត្រូវប្រមូលផ្ដុំទាហាន ដែលនៅមាន ចាំឃ្លាំ មើលសត្រូវឲ្យបានជិតដល់ និង សុំកម្លាំងទ័ពជំនួយបន្ថែម។

សេចក្ដីអធិប្បាយ៖ នេះជាប្រយោគពិបាកយល់ និង មិនដែលមានអ្នកអត្ថាធិប្បាយណាម្នាក់អាចនឹងឈ្លេច យកអត្ថន័យពីវា ឲ្យបានល្អនោះទេ។ ខ្ញុំសូមយកតាម



www.facebook.com/7khmer



Fb page : Entertainment And Knowledge

លីឈាន់ ដែលគាត់បានផ្ដល់នូវការពន្យល់ដ៏សាមញ្ញជាងគេថា៖ «មានតែភាគីខាងណា ដែល មានកម្លាំងច្រើនជាងគេទេ ដែលអាចនឹងឈ្នះបាន»។

សេចក្ដីអធិប្បាយ៖ ជាសំណាងល្អ យើងមាន ចាងអ៊ីដែលបរិយាយនូវសេចក្ដីឲ្យយើងបានដឹង តាមភាសាច្បាស់ស្រឡះងាយយល់ ជាសេចក្ដីថា៖ «កាលណាចំនួនកម្លាំងស្មើគ្នា តែគ្មានឱកាសណាល្អទេ ដូចនេះកម្លាំងរបស់យើងមិនអាចរឹងមាំល្មមគ្រប់គ្រាន់ ដើម្បីនឹងប្រយុទ្ធជាប់បានយូរទេ យើងអាចនឹងលៃលក រករើសកម្លាំងបន្ថែមពីចំណោមអ្នកលក់ដូរឥវ៉ាន់ (ឲ្យពួកទាហាន) និង ពួកអ្នកតាមហែហមមកជាប់ជាមួយតាមបន្ទាយ, ពេលហ្នឹង ត្រូវប្រមូលផ្ដុំកម្លាំងទាហានរបស់យើងទាំងអស់ ហើយចាំឃ្លាំមើលសត្រូវឲ្យបានដិតដល់ ដើម្បីនឹងដាក់ផែនការដណ្ដើមយកជ័យជំនះឲ្យបាន។ ក៏ប៉ុន្តែយើងត្រូវតែចៀសវាងពីការខ្ចីទាហានបរទេសឲ្យមកជួយ»។ គាត់ ក៏បានដកស្រង់សម្ដី របស់វ៉ីលាវអ៊ូ ជំពូកទី៣ មានជាសេចក្ដីថា៖ «កម្លាំង ដែលមានតែឈ្មោះ នៃ ទាហានស៊ីឈ្នួល បើថា មានចំនួន




www.facebook.com/7khmer
Fb page : Entertainment And Knowledge

១០០,០០០នាក់ តែតម្លៃពិតប្រាកដ គឺ មានមិនច្រើនជាងពាក់កណ្តាលនៃចំនួនសរុបនោះទេ»។

ប្រការទី 41 ៖ នរជនណាដែលមិនចេះគិតទុកជាមុន ហើយមើលស្រាលចំពោះគូសត្រូវ គឺពិតជា នឹងត្រូវសត្រូវចាប់ខ្លួនបានជាប្រាកដ។

សេចក្តីអធិប្បាយ៖ ឆិនហាវ ស្រង់សម្តីរបស់ ឆ្វូឈាន់ ដែលនិយាយថា៖ «បើសិនជាសត្វឃ្មុំ និង ខ្យាដំរីនៅតែមានពិសនៅឡើយ ប្រទេសជាអមិត្ត ក៏នៅតែពិសពុលខ្លាំងឡើង! សូម្បីតែគូសត្រូវ ដ៏កំប៉ិកកំប៉ុកក្តី ចូរកុំមើលងាយពួកគេឲ្យសោះ»។

ប្រការទី 42 ៖ បើសិនជា ទាហានទទួលទណ្ឌកម្មមុនពេលដែលគេបានមកចុះចូលជាមួយនឹងអ្នក គេនឹងមិនបង្ហាញនូវការឱនលំទោនស្តាប់បង្គាប់ឡើយ ហើយបើទោះជាពួកគេឱនលំទោនស្តាប់បង្គាប់ហើយក៏ដោយ ក៏ពួកគេនៅតែគ្មានប្រយោជន៍ដែរ។ បើសិនជា ពេលណាទាហាន មកចុះចូលជាមួយយើងហើយ បើទណ្ឌកម្មមិនត្រូវបានអនុវត្តទេនោះ ពួកគេក៏នៅតែប្រើការមិនបានដដែល។





www.facebook.com/7khmer
Fb page : Entertainment  And Knowledge

ប្រការទី 43 ៖ (១). ហេតុនេះហើយ ត្រូវតែប្រព្រឹត្តិចំពោះទាហាន ក្នុងដំណាក់កាលដំបូង ដោយអំពើមនុស្សធម៌ ប៉ុន្តែត្រូវរក្សាពួកគេឲ្យនៅក្រោមអំណាចត្រួតត្រាតាមមធ្យោបាយកណ្តាប់ដៃដែក។

សេចក្តីអធិប្បាយ៖ យិនអ៊ូ (ឆ្នាំ៤៩៣ មុន គ.ស) បានពិពណ៌នា អំពី ស៊ូម៉ាចាងជូ ជាសេចក្តីថា៖ «គុណធម៌ស៊ីវិលរបស់គាត់ បានញ៉ាំងឲ្យ ប្រជាជនស្រឡាញ់ចូលចិត្តគាត់, យោធវីរកម្មរបស់គាត់ បានញ៉ាំងឲ្យសត្រូវរបស់គាត់ស្ថិតនៅក្នុងសភាពបាក់បបខ្លបខ្លាច»។ បើប្រៀបធៀបនឹងស្នាដៃ វូអ៊ូ ជំពូកទី៤ មានជាសេចក្តីថា៖ «មេបញ្ជាការ ដែលមានសតិបញ្ញា គេបង្រួបបង្រួមពលទាហាន ឲ្យបង្អោនចូលមក ប្រកបដោយវប្បធម៌ចូលចិត្តសង្គ្រាម, ភាពជារអាជីព នៃ កងកម្លាំងប្រដាប់អាវុធ ទាមទារ ឲ្យមានភាពលាយឡំឆ្លាស់គ្នារវាងភាពរឹង និង ភាពទន់ ទាំងពីរធាតុនេះ»។

ប្រការទី 43 ៖ (២). នេះជាមាគ៌ាដ៏ពិតប្រាកដ ឆ្ពោះទៅដល់ជ័យជំនះ។




www.facebook.com/7khmer
Fb page : Entertainment  And Knowledge

ប្រការទី 44 ៖ បើសិនជា ក្នុងកំឡុងពេលហ្វឹកហ្វឺនទាហាន បទបញ្ជាទាំងឡាយត្រូវបានអនុវត្ត ជាប់ជាទម្លាប់ យ៉ាងខ្ជាប់ខ្ជួន នោះទាហាននឹងគោរពវិន័យបានល្អ តែបើមិនដូច្នោះទេ វិន័យនឹងសោះអង្គើយរសាយរសាត់ខ្ចីខ្ចារទៅ។

ប្រការទី 45 ៖ (១). បើសិនជា មេទ័ពមានជំនឿទុកចិត្តលើកូនទាហានរបស់ខ្លួនហើយ ប៉ុន្តែ គាត់ជានិច្ចកាល នៅតែសុំអង្វរឲ្យពួកគេស្ដាប់បង្គាប់របស់គាត់ទៀត,

សេចក្ដីអធិប្បាយ៖ ទូមូពោលថា៖ «នៅពេលស្រុកទេសមានសន្តិភាព មេទ័ព ម្នាក់ៗ គួរតែបង្ហាញនូវសន្ដានចិត្តល្អ និង មានទំនុកចិត្តក្នុងចំណោមកូនទាហានរបស់ខ្លួន ហើយរក្សានូវអំណាចយោធា ឲ្យគេគោរពស្រឡាញ់ ដើម្បីឲ្យមានភាពប្រាកដថា នៅ ពេលណាមានសត្រូវ ត្រូវប្រឈមមុខ បទបញ្ជាអាចត្រូវបានអនុវត្ត និង វិន័យត្រូវបាន គេប្រកាន់ខ្ជាប់ ពីព្រោះពួកគេនៅមានជំនឿជាក់ និងកោតសរសើរចំពោះគាត់នៅឡើយ»។ ទោះជាយ៉ាងណាក៏ដោយ អ្វីដែល ស៊ុនអ៊ូបាននិយាយក្នុងប្រការទី៤៤ កន្លងមក វានាំការអះអាងដល់ចំណុចមួយ ដែលរំពឹងទុក តាមលំនាំដូចនេះថា៖




www.facebook.com/7khmer
Fb page : Entertainment And Knowledge

«បើសិនជា មេទ័ពម្នាក់ណា ដែលនៅតែមានទំនុកចិត្ត ជាប់ជានិច្ចថា បទបញ្ជារបស់គាត់ ត្រូវបានគេអនុវត្ត តាម . ..ល.. . »។

ប្រការទី 45 ៖ (២). ផលចំណេញ ក៏នឹងបានមកសងខាង ដូចគ្នា។

សេចក្តីអធិប្បាយ៖ ចាងអ៊ី ពោលថា៖ «មេទ័ព ត្រូវមាន ទំនុកចិត្តលើកូនទាហានដែលនៅក្រោមបញ្ជារបស់ខ្លួន ហើយកូនទាហានទាំងនោះស្លូតបូត, និងមានទំនុកចិត្ត លើគាត់វិញ។ ដូចនេះ ផលចំណេញ គឺ មានដូចគ្នា»។ គាត់ដកស្រង់សម្តី តាមប្រយោគ ដ៏សមទំនងរបស់ វ៉ិលាវអ៊ូ ជំពូកទី៤ ជាសេចក្តីថា៖ «សិល្បៈ នៃ ការដាក់ បទបញ្ជា គឺមិនមែន គ្រាន់តែដើម្បីព្យាយាមកែតម្រូវ ភាពផ្តេសផ្តាសចោលម្សៀត និង មិនមែនទោរទន់ យោលយោក មិនច្បាស់ស្រឡះទៅខាងណា ដោយការ សង្ស័យ កម្ហូចកម្ហី កំប៉ិកកំប៉ុកនោះទេ»។ ដំណើរ ប្រែប្រួល និង ភាពសូញសាញ ជាមធ្យោបាយដ៏ពិត ប្រាកដបំផុត ក្នុងការបំផ្លាញទំនុកចិត្តពលទាហាន។


www.facebook.com/7khmer
Fb page : Entertainment  And Knowledge

សេចក្ដីអធិប្បាយ៖ ម៉ីយ៉ាវឆិន ពោលថា៖ «ឲ្យតែជាទីដែលសំបូរផ្លូវចូលទៅដល់ និងមានមធ្យោបាយទាក់ទងបានតាមច្រើនបែបយ៉ាង»។

ប្រការទី 1 ៖ (២). ទីតាំងដីដែលមានលក្ខណៈស្មុគស្មាញ,

សេចក្ដីអធិប្បាយ៖ អ្នកអត្ថាធិប្បាយដដែលបានពោលថា៖ «ជាទីភូមិស្រុកដែលមានសណ្ឋានទ្រង់ទ្រាយដូចជាសំណាញ់ បើអ្នកហ៊ានប្រថុយចូលទៅ នោះអ្នកនឹងពិបាកស្មុគស្មាញហើយ»។

ប្រការទី 1 ៖ (៣). ទីតាំង ដែលត្រូវពន្យាពេលរង់ចាំឱកាស,

សេចក្ដីអធិប្បាយ៖ គឺជា ប្រភេទទីដី ដែលត្រូវឲ្យអ្នក «ពន្យាពេល ឬ រង់ចាំឲ្យផុតគ្រោះភ័យ» សិន (សឹមចាត់ការតទៅទៀត)។

ប្រការទី 1 ៖ (៤). ទីតាំងមានច្រកចង្អៀត, (៥). ទីតាំងខ្ពស់ហើយចោត, (៦). ទីតាំងមានរយៈចម្ងាយឆ្ងាយពីសត្រូវ។

សេចក្ដីអធិប្បាយ៖ វាជាការណ៍ចាំបាច់ណាស់ ដែលត្រូវចង្អុលឲ្យចំកម្រិតលម្អៀងឲ្យបានជាក់លាក់ នៅក្នុង





www.facebook.com/7khmer
Fb page : Entertainment And Knowledge

ការបែងចែកសណ្ឋានដីជាទីតាំង តាមរបៀបខាងលើនេះ។ វាជាកង្វះខាតដ៏ចម្លែក នូវការយល់ដឹងខាងផ្នែកតក្កវិជ្ជា ដែលបានបង្ហាញចេញមកតាមរយៈ ការទទួលយកដោយមិនមានសំណួរ ចំពោះការណ៍ ដែលបានឃើញនូវការបែងចែករបៀបដូចខាងលើនេះហើយ។

ប្រការទី 2 ៖ ទីតាំងដី ដែលអាចឆ្លងកាត់បាន ដោយសេរីដោយភាគីទាំងសងខាង គេហៅថា ទីតាំងដែលអាចចូលទៅដល់។

ប្រការទី 3 ៖ (១). ដោយយោលទៅតាម លក្ខណៈធម្មជាតិរបស់ដី ដែលជាទីតាំង ចូរធ្វើឲ្យបានមុនសត្រូវ ដោយចូលទៅកាន់កាប់ចំណុចទីតាំង ដែលងើបខ្ពស់ និង មានពន្លឺព្រះអាទិត្យចូលដល់ ហើយ ការពារយ៉ាងមុតមាំឲ្យបាននូវខ្សែផ្លូវនាំស្បៀងជំនួយរបស់អ្នក។

សេចក្តីអធិប្បាយ៖ អត្ថន័យជាទូទៅ ក្នុងឃ្លាចុងក្រោយគឺ ជម្រះភាពមន្ទិលសង្ស័យតែម្តង ដូចដែល ទូមូ ពោលថា៖ «កុំបណ្តោយ ឲ្យសត្រូវកាត់ផ្តាច់ខ្សែទំនាក់ទំនងរបស់អ្នក»។ តាមន័យក្នុងភាសិតរបស់ ណាប៉ូឡេអុង




www.facebook.com/7khmer
Fb page : Entertainment And Knowledge

មានជាសេចក្ដីថា៖ «អាចិកំបាំង នៃ សង្គ្រាម, វាស្ថិតនៅលើខ្សែបណ្ដាញទំនាក់ទំនង» យើងអាចយល់ឃើញថា៖ ស៊ុនអ៊ូ បាននិយាយចូលជ្រៅមកក្នុង~~ក្នុង~~ប្រធានបទ ដ៏សំខាន់នេះ និង នៅក្នុងជំពូកទី១ ប្រការទី១០, ជំពូកទី៧ ប្រការទី១១ ផងដែរ។ លំនាំដូចគ្នានេះដែរ វរៈសេនីយ៍ឯក ហ៊ិនដឺសុន ពោលថា៖ «ខ្សែផ្លូវ នាំជំនួយផ្គត់ផ្គង់ អាចត្រូវបានគេនិយាយថា វាមានសារសំខាន់ជាសារវន្ត ចំពោះ ការរស់រានរបស់កងទ័ព វាប្រៀបដូចជា បេះដូង នៃ ជីវិតរបស់មនុស្សយើងអញ្ចឹងដែរ»។ ម្យ៉ាងទៀត ឧទាហរណ៍ដូចជា៖ អ្នកប្រយុទ្ធតស៊ូ ដែលឃើញថា ខ្លួនគេបានធ្លាក់ចូលទៅក្នុងស្ថានភាព ដែលសត្រូវនឹងគម្រាមកំហែងគេដល់ស្លាប់ជីវិត ហើយ កិច្ចការពារខ្លួនរបស់គេ ក៏ខ្ចាត់ខ្ចាត់ទៅទៀត ពេលនោះគេក៏នឹងត្រូវបង្ខំចិត្ត អនុលោមតាម ការបង្គាប់បញ្ជារបស់បច្ចាមិត្ររបស់គេ ហើយគេអាចបាន ត្រឹមតែបំពេញចិត្តរបស់ខ្លួន ដោយការគ្រងរក្សាខ្លួនឯងទល់នឹងការវាយសម្រុកពីគូប្រយុទ្ធតែប៉ុណ្ណោះ ហេតុនេះហើយមេបញ្ជាការ ដែលធ្លាប់តែមានខ្សែទំនាក់ទំនង ដ៏ល្អ





www.facebook.com/7khmer
Fb page : Entertainment And Knowledge

ក៏ស្រាប់តែ មួយរំពេចនោះ ខ្សែទំនាក់ទំនងនោះឯង ក៏ទទួលរងនូវការឈ្លានពានគម្រាមកំហែងឲ្យអាន់ខាន មេបញ្ជាការ ក៏ត្រូវដឹងខ្លួនឯងថា បានធ្លាក់ចូលទៅក្នុង ស្ថានការណ៍មិនពិត ហើយគាត់នឹងនៅមាន សំណាង ល្អ បើសិនជា គាត់មិនបានផ្លាស់ប្តូរផែនការទាំងអស់ របស់គាត់ ដើម្បីនឹងបំបែកកម្លាំង ជាកងច្រើនជាងមុន ឬ ជាកងតិចជាងមុន ហើយចូលវាយប្រយុទ្ធ ដោយ ចំនួនកម្លាំងទ័ពតិចជាងគេ តាមដែលគាត់ មិនបាន មានពេលវេលារៀបចំត្រៀមទ័ពផង ហើយពិតមែនតែ ការចុះចាញ់ (មួយគ្រា) មិនមែនជា បរាជ័យជាប្រក្រតី (រហូត) នោះក៏មែនហើយ ប៉ុន្តែវានាំឲ្យមានការខូច ខាតពលទាហាន ឬ នាំឲ្យ កងទ័ពទាំងមូលអន្តរាយ (វិទ្យាសាស្ត្រសង្គ្រាម, ជំពូកទី២) ។

ប្រការទី 3 ៖ (២). បើធ្វើដូច្នេះបាន អ្នកនឹងអាចប្រយុទ្ធ ដោយមានប្រៀប។

ប្រការទី 4 ៖ ទីតាំងដី ដែលអាចបោះបង់ចោលបាន ប៉ុន្តែ វាពិបាកនឹងចូលមកកាន់កាប់យកវិញម្តងទៀត គេហៅថា៖ ទីតាំងពិបាកស្មុគ្រស្មាញ។




www.facebook.com/7khmer
Fb page : Entertainment And Knowledge

ប្រការទី 5 ៖ ចំពោះចំណុចណាមួយ នៃ ទីតាំងប្រភេទនេះ បើសិនជា សត្រូវមិនបានត្រៀមខ្លួនជាមុននោះទេ អ្នកអាចនឹងសម្រុកទៅមុខចូលវាយលុក និង កម្ទេចពួកវាតែម្តង។ ក៏ប៉ុន្តែ បើសិនជា សត្រូវបានត្រៀមខ្លួនរួចជាស្រេច រង់ចាំអ្នកចូលទៅដល់វិញនោះ ហើយបើអ្នកខកខាន មិនបានវាយកម្ទេចវាទេ ខណៈនោះ បើអ្នកវិលត្រូវមកវិញ ដោយមិនអាចនឹងវាយប្រហារវាបាន គ្រានោះ គ្រោះមហន្តរាយនឹងជាលទ្ធផលរបស់អ្នក។

ប្រការទី 6 ៖ នៅពេលណា ដែលទីតាំងណាមួយ ស្ថិតនៅក្នុងសភាពការណ៍ ដែលគ្មានភាគីខាងណាមួយ អាចនឹងដណ្តើមយកបានដោយបឋមចលនាទេនោះ គេហៅវាថាជាទីតាំងរង់ចាំឱកាស។

*សេចក្តីអធិប្បាយ៖ ទូមូ ពោលថា៖ «ភាគីទាំងសងខាងពិបាកនឹងកម្រើកធ្វើចលនាណាស់ ហើយស្ថានការណ៍ក៏នឹងនៅតែជាប់គាំងស្ទូកដដែល»។*

ប្រការទី 7 ៖ (១) នៅក្នុងស្ថានការណ៍របៀបនេះ សត្រូវអាចនឹងដាក់នុយបញ្ឆោត យ៉ាងគួរឲ្យចាប់ចិត្តជាប់អារម្មណ៍មកជន្លយើង,




www.facebook.com/7khmer
Fb page : Entertainment And Knowledge

សេចក្តីអធិប្បាយ៖ ទូអ៊ី ពោលថា៖ «ពួកសត្រូវអាចនឹងបែរខ្នងដាក់យើង ហើយ វាធ្វើពុតជារត់ភៀសខ្លួន»។ ប៉ុន្តែការណ៍នេះ វាគ្រាន់តែជា ការល្បួង មួយបែបក្នុងការដាក់នុយបញ្ឆោតទាំងឡាយ ដែលអាចនឹងមកជន្លជន្លេញអន្ទងចិត្តយើង ឲ្យចាកចេញពីទីតាំងរបស់យើងតែប៉ុណ្ណោះទេ។

* ប្រការទី 7 ៖ (២). នៅក្នុងស្ថានការណ៍របៀបនេះ គួរឲ្យជាដំបូន្មានថា កុំគប្បីកកូរកកាយ ឲ្យរឹករវ ទៅមុខទៀតឡើយ យកល្អ គួរតែត្រូវដកថយមកវិញសិន ធ្វើដូចនេះ ដើម្បីជន្លបញ្ឆោតចិត្តសត្រូវ តាមលំដាប់លំដោយរបស់ពួកវា, ខណៈនោះឯង នៅពេលដែលមួយភាគនៃកម្លាំង របស់វាបានលើកដេញតាមយើងហើយ យើងក៏អាចបើកការវាយប្រហារដោយមានប្រៀបលើវាតែម្តង។

*ប្រការទី **8** ៖ តាមដំណើរ ដែលថា ទីតាំងច្រកតូចចង្អៀត, បើសិនជា អ្នកអាចចូលទៅកាន់កាប់ទីនោះបានជាមុន ចូរដាក់ទ័ពច្រចាំការរក្សាទុក ដោយអានុភាព ដ៏ខ្លាំងក្លាចុះ ហើយ ចូររង់ចាំការមកដល់នៃសត្រូវ ។




www.facebook.com/7khmer
Fb page : Entertainment And Knowledge

សេចក្តីអធិប្បាយ៖ ដូចដែល ទូអ៊ី សង្កេតឃើញថា «ការនាំអាទិ៍ គឺ យើងជាអ្នកផ្តើមធ្វើ ហើយតាមរយៈការវាយប្រហារ ដ៏ទាន់ហន់ ដែលសត្រូវគិតមិនបានដល់ជាមុននោះ យើងគួរតែធ្វើឲ្យ សត្រូវនៅក្រោមអំណាចរបស់យើង តាមដែលយើងចង់បាន»។

ប្រការទី 9 ៖ ក្នុងករណី សត្រូវដណ្តើមយកច្រកចង្អៀតបានជាមុនទៅហើយ, ចូរកុំទៅតាមពួកវាធ្វើអ្វី បើសិនជាតាមច្រកនោះ ពួកវាបានតាំងទ័ពដោយពេញលេញរួចទៅហើយ, ប៉ុន្តែចូរទៅតាមពួកវាចុះ បើសិនជានៅតាមច្រកនោះ ពួកវាតាំងទ័ពត្រឹមតែចំនួនតិចតួចស្តួចស្តើងទេនោះ។

ប្រការទី 10 ៖ ចំពោះទីខ្ពស់ហើយចោត, បើសិនជា អ្នកចូលកាន់កាប់ទីនោះ បានមុនសត្រូវ ចូរអ្នកប្រកាន់យកទីតាំងដែលដើបខ្ពស់ ហើយ មានពន្លឺព្រះអាទិត្យចូលដល់ រួចរង់ចាំសត្រូវវាចូលមកដល់។

សេចក្តីអធិប្បាយ៖ ឆាវកុង ពោលថា៖ «ការមានប្រៀបជាពិសេសដោយឡែក ក្នុងការរក្សាបាននូវទីទួលខ្ពស់ និង ជ្រលងភ្នំ គឺ មានប្រយោជន៍ថា ដើម្បីកុំឲ្យសត្រូវ




www.facebook.com/7khmer
Fb page : Entertainment And Knowledge

ចេះតែបង្កើតរឿងតាមតែអំពើចិត្តរបស់វាមកបង្គាប់បញ្ជាលាល់ទង្វើរបស់អ្នកគ្រប់បែបយ៉ាងនោះ»។ (សម្រាប់ការបរិយាយ អំពី គោលការណ៍ សំខាន់ៗ នៃ ចំណុចនេះ សូមមើល ជំពូកទី៦ (ប្រការទី២)។

ចាងអ៊ី និទានរឿងខ្លី អំពី ប៊ីស៊ីងឈាន (ឆ្នាំ៦១៩ ដល់ ឆ្នាំ៦៨២ នៃ គ.ស) មានសេចក្ដីដូចតទៅនេះថា៖ ប៊ីស៊ីងឈាន ត្រូវបានគេបញ្ជូន ឲ្យទៅធ្វើទោសទណ្ឌប្រឆាំងនឹងពួកកុលសម្ព័ន្ធទួគ៍។ ដំណើររឿងនេះ មានសេចក្ដីថា «នាពេលរាត្រី គាត់បោះតង់ តាំងបន្ទាយដូចសព្វមួយដង, អ្វីគ្រប់យ៉ាង គឺ ត្រៀមលក្ខណៈការពារពេញលេញ រួចរាល់ ដោយមានកំផែង និងប្រឡាយស្នាភ្លោះការពារផង, ស្រាប់តែមួយរំពេចនោះ គាត់ក៏ដាក់បទបញ្ជាថា ឲ្យទាហានផ្លាស់ប្ដូរទីតាំងបញ្ជាការដ្ឋាន ទៅតាំងនៅលើកូនភ្នំជិតទីនោះវិញ។ ការណ៍នេះ បានធ្វើឲ្យនាយទាហានទាំងឡាយរបស់គាត់មិនសប្បាយចិត្តឡើយ ហើយពួកគេ ក៏នាំគ្នាស្រែកឡូឡាតវ៉ាប្រឆាំងទល់នឹងការងារដ៏លំបាកជា បន្ទុកបន្ថែមនេះដែលវាតម្រូវចាំបាច់ចំពោះលើអ្នកទាំងនោះ។ ទោះជា



www.facebook.com/7khmer
Fb page : Entertainment And Knowledge

យ៉ាងណាក៏ដោយ ក៏ ប៊ីស៊ីងឈាន មិនបានយកចិត្ត ទុកដាក់នឹងការប្រកែកតវ៉ានោះទេ ហើយក៏ ឲ្យទាហាន រើបន្ទាយរួចរាល់ បានយ៉ាងលឿនរហ័ស តាមដែល អាចធ្វើបាន។ យប់ដដែលនោះ ជួនជា មានព្យុះភ្លៀង ដ៏គួរឲ្យព្រឺខ្លាចធ្លាក់ចុះមក ហើយ បានជន់លិចអតីត ទីតាំងបន្ទាយ ដែលទើបតែបានបោះបង់ចោលនោះ ដោយមានជម្រៅដល់ទៅ ១២ហ្វីត។ នាយទ័ពនាយកង ដែលចចើងចចេស បានឃើញហើយ ក៏មានសេចក្តី ភ្ញាក់ផ្អើល និង ទទួលសារភាពថា ពួកគេពិតជា ខុស ហើយ។ ពួកគេទាំងនោះ ក៏សួរទៅ ប៊ីស៊ីងឈាន ថា៖ ហេតុម្តេច ទើបលោកម្ចាស់ដឹងថា នឹងមានរឿង បែប នេះកើតឡើង? ប៊ីស៊ីងឈាន ក៏ឆ្លើយតបទៅវិញថា៖ ចាប់ពីពេលនេះតទៅ ចូរអស់លោកពេញចិត្ត នាំគ្នាធ្វើ តាមបញ្ជា សូមកុំសួរនាំនូវសំណួរ ដែលមិនចាំបាច់ នោះធ្វើអ្វី។ ចាងអ៊ី បន្តថា៖ ចាប់ពីនេះទៅ យើងអាច យល់បានថា ទីតាំងខ្ពស់ និង មានពន្លឺព្រះអាទិត្យ វាមិន ត្រឹមតែ មានប្រៀបក្នុងចម្បាំងប៉ុណ្ណោះទេ តែវាមាន




www.facebook.com/7khmer
Fb page : Entertainment And Knowledge

លក្ខណៈទ្រង់ទ្រាយរួចផុតពីគ្រោះ មហន្តរាយទឹកជំនន់នោះផងដែរ»។

ប្រការទី 11 ៖ បើសិនជា សត្រូវ កាន់កាប់ទីតាំងនោះ បានមុនអ្នកទៅហើយ ចូរកុំតាមពួកវាធ្វើអ្វី តែត្រូវដកថយមកវិញ ហើយព្យាយាមល្បួងបញ្ឆោតពួកវាឲ្យចេញពីទីនោះវិញម្តង។

សេចក្តីអធិប្បាយ៖ ចំណុចរបត់ នៃ យុទ្ធនាការណ៍សឹក របស់ លីស៊ីមីង កាលពីឆ្នាំ៦២១ នៃ គ.ស ប្រឆាំងទល់នឹងក្រុមឧទ្ទាមបះបោរចំនួនពីរពួក មាន៖ ទូឈានតេ ជាស្តេចនៃនគរស្យៀ និង វ៉ាំងស៊ីឈុង ជាស្តេច នៃ នគរឆេង គឺ ការដែលគាត់ (លីស៊ីមីង) ដណ្តើមបាននូវទីទួលអ៊ូឡាវ ដោយខ្សែក ស្តេចទូឈានតេ តស៊ូមានៈ បន្តការព្យាយាមរបស់ទ្រង់ ដើម្បីរំដោះសម្ព័ន្ធមិត្តនៅក្នុងក្រុងឡូយ៉ាំង ក៏ធ្លាក់ខ្លួនបរាជ័យ និងត្រូវបានគេចាប់ជាឈ្លើយសឹក (ស្នាដៃឈាវថាង, ជំពូកទី២, សន្លឹកទី៥ ទំព័រខាងឆ្វេង និង ជំពូកទី៥៤ ផងដែរ)។




www.facebook.com/7khmer
Fb page : Entertainment And Knowledge

ប្រការទី 12 ៖ (១). បើសិនជា អ្នកបានបោះទីតាំង ដោយមានរយៈចម្ងាយឆ្ងាយពីសត្រូវ ហើយ កម្លាំងទ័ពទាំងសងខាង មានចំនួនស្មើគ្នា វាមិនមែនជារឿងស្រួលទេ ក្នុងការណ៍ (ដែលអ្នក) ទៅបង្កហេតុបបួលច្បាំងនោះ,

*សេចក្តីអធិប្បាយ៖ ចំណុចនេះចង់និយាយថាយើងមិនត្រូវគិតតែ អំពី ការលើកព្យូហ៍ទ័ពពីរយៈចម្ងាយ ដ៏វែងឆ្ងាយ និង តប់ប្រម៉ល់នោះទេ ដូចដែល ចាងអ៊ី ពោលថា៖ «នៅចុងបញ្ចប់ យើងនឹងហេវហត់អស់កម្លាំង រីឯចំណែកបច្ចាមិត្ររបស់យើងវិញ គេនៅស្រស់បស់ និងមានអំនួតវាងវៃ»។*

ប្រការទី 12 ៖ (២). ហើយបើអ្នកចូលច្បាំង អ្នកក៏អាចចាញ់ប្រៀបក្នុងការប្រយុទ្ធរបៀបនេះ។

ប្រការទី 13 ៖ (១). លក្ខណៈសណ្ឋានដី ទាំង៦ប្រការ ដូចដែលបានបរិយាយខាងលើនេះ គឺជាគោលការណ៍ដែលមានជាប់ទាក់ទងនឹងព្រះធរណី។



www.facebook.com/7khmer
Fb page : Entertainment And Knowledge

សេចក្ដីអធិប្បាយ៖ ឬក៏ ប្រហែលជា «គោលការណ៍ដែលមានជាប់ទាក់ទងនឹងផ្ទៃដី» ក៏ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ សូមមើល ជំពូកទី១, ប្រការទី៨ ផង។

ប្រការទី 13 ៖ (២). មេទ័ពរូបណា ដែលមានមុខនាទីទទួលខុសត្រូវតាមតំណែង មេទ័ពនោះ ត្រូវតែមានសេចក្ដីប្រុងប្រយ័ត្ន ក្នុងការសិក្សាស្វែងយល់ អំពី គោលការណ៍ទាំង ៦ប្រការ ខាងលើនេះ។

ប្រការទី 14 ៖ ឥឡូវនេះយើងចូលដល់បទវិចារជាសេចក្ដីថា យោធាអាចជួបនឹងវិបត្តិ ចំនួន ៦ប្រការ ដែលវិបត្តិ ទាំង៦ប្រការនេះ វាមិនមែនកើតចេញពីមូលហេតុធម្មជាតិអ្វីទេ តែវាលេចចេញមកពីកំហុសទាំងឡាយ ដែលតំណែងជាមេទ័ពត្រូវតែទទួលខុសត្រូវ ចំពោះ ប្រការ ទាំង៦នេះ។ ប្រការទាំង៦នេះមាន៖ (១). ការភៀសខ្លួន, (២). ចរិតរឹងរូសមិនស្ដាប់បទបញ្ជា, (៣). ការបែកបាក់, (៤). សភាពវិនាសហិនហោច, (៥). សភាពខ្ជីខ្ជាគ្មានរបៀបរបប និង (៦). ការបាក់ទ័ព។

ប្រការទី 15 ៖ បើសិនជាលក្ខ័ណ្ឌដទៃទៀតមានសុពលភាពស្មើគ្នាហើយក៏ដោយ តែបើសិនជា កងកម្លាំងខាងណាមួយវាយសម្រុកតទល់នឹងកងកម្លាំងម្ខាងទៀតដែលគេមានចំនួន




www.facebook.com/7khmer
Fb page : Entertainment And Knowledge

ច្រើនលើសលប់ជាងដល់ទៅ ១០ដងឯណោះ, លទ្ធផលគឺ៖ អ្នកដែលនាំអាទ៏វាយប្រហារនឹងត្រូវរត់ភៀសខ្លួន។

* ប្រការទី 16 ៖ (១). នៅពេល ដែលពលទាហានសាមញ្ញ ខ្លាំងពូកែមែនទែន តែលោកនាយរបស់គេ បែរជាខ្សោយបំផុតទៅវិញ លទ្ធផលគឺ៖ ចរិតរឹងរូសមិនស្តាប់បទបញ្ជា។

សេចក្តីអធិប្បាយ៖ ទូមូ ទាញយកឧទាហរណ៍មកសម្អាងចំពោះរឿងមិនសប្បាយចិត្តមួយ អំពី ធានពូ (ក្នុងស្នាដៃ ស៊ីនថាងស៊ូ ជំពូកទី១៤៨) ដែល ធានពូ ត្រូវបានគេបញ្ជូនទៅដល់នគរវ៉ី កាលពីឆ្នាំ៨២១ នៃ គ.ស តាមបញ្ជាដើម្បីដឹកនាំពលយោធា ប្រយុទ្ធតទល់នឹង វ៉ាំងទីងឆូវ។ ក៏ប៉ុន្តែ ពេលវេលាទាំងអស់ ដែលគាត់ទទួលបញ្ជា ឲ្យចេញទៅដឹកនាំប្រតិបត្តិការសឹកនោះ ពលទាហានរបស់គាត់បានប្រព្រឹត្តិចំពោះគាត់ ដោយភាពគឃ្លើនដ៏មុះមុតបំផុត និង ចម្អកឡកឡឺយជាចំហចំពោះអាជ្ញាសឹករបស់គាត់ ដោយពួកគេ បានជិះសត្វលាវីវក់ពាសពេញបន្ទាយទាហាន ម្តងៗ មានគ្នារាប់ពាន់នាក់ឯណោះ។ ធានពូ ខ្សោយអំណាចក្នុងការ




www.facebook.com/7khmer
Fb page : Entertainment And Knowledge

បញ្ឈប់ នូវ អាកប្បកិរិយារបៀបនេះ ហើយនៅពេលក្រោយមក ប៉ុន្មានខែបានកន្លងផុតទៅ គាត់បានធ្វើការប៉ុនប៉ងដើម្បីចាប់ផ្ដើមវាយលុកទៅលើសត្រូវ ស្រាប់តែពលទាហានរបស់គាត់បានបែរក្បាល និង បែកខ្ញែករប៉ាត់រប៉ាយ ទៅគ្រប់ទិសតំបន់។ បន្ទាប់ពីនោះមកនាយទាហានអភ័ព្វម្នាក់នេះ ក៏បានសម្លាប់ខ្លួនដោយអារ ក ខ្លួនឯងទៅ។

ប្រការទី 16 ៖ (២). បើលោកនាយ របស់គេ ខ្លាំងពូកែពេក ហើយពលទាហានសាមញ្ញខ្សោយពេក នោះលទ្ធផល គឺ៖ ការបែកបាក់គ្នា។

សេចក្ដីអធិប្បាយ៖ ឆាវកុង ពោលថា៖ «នាយទាហានគឺ ត្រូវស្វាហាប់ ហើយ ចង់តែបុករុកវាយលុកទៅមុខ តែបើទាហានធម្មតាល្ងិតល្ងើយ ការណ៍នេះ អាចនឹងបែកបាក់គ្នាមួយរំពេច»។

ប្រការទី 17 ៖ នៅពេលនាយទាហាន ដែលមានបណ្ដាស័ក្តិខ្ពស់ ក្រេវក្រោធ ហើយមិនចំណុះ មិនស្ដាប់បង្គាប់នោះ លុះដល់ពេលត្រូវជួបប្រឈមមុខនឹងសត្រូវ ក៏បើកការវាយ




www.facebook.com/7khmer
Fb page : Entertainment And Knowledge

ប្រហារ ដោយចិត្តឯងតាមតែអំពើចិត្ត ដែលបណ្ដាលមកពី សេចក្ដីអន់ចិត្តដែលមានមកពីពេលមុនដែលអគ្គមេបញ្ជាការ មិនទាន់ទាំងបានបញ្ជាថាយ៉ាងនេះយ៉ាងនោះផង ក៏ស្រាប់តែ គេចូលទៅប្រយុទ្ធជាមុនទៅហើយ ហេតុនេះ លទ្ធផលគឺៈ សភាពវិនាសហិនហោច។

សេចក្ដីអធិប្បាយ៖ តាមកំណត់ត្រារបស់ វ៉ាងស៊ី មាន ជាសេចក្ដីថា៖ «ចំណុចនេះ មានន័យថា៖ មេទ័ពមាន សេចក្ដីក្រេវក្រោធ ដោយគ្មានហេតុផល ហើយក្នុង ពេលជាមួយគ្នានោះ គាត់មិនបានកោតសរសើរគុណ បំណាច់សមត្ថភាពរបស់នាយទ័ពនាយកង ដែលនៅ ក្រោមបញ្ជារបស់គាត់ទេ ហេតុដូចនេះហើយ គាត់ក៏ បែរជា បញ្ចេញឫកពារកាចសាហាវ របៀបខកចិត្ត ហើយការណ៍នេះ ក៏នាំដល់សភាពវិនាសទាំងកម្រោល ចេញពីក្នុងខួរក្បាលរបស់គាត់តែម្ដង»។

ប្រការទី **18** ៖ (១). នៅពេលដែលមេទ័ពទន់ខ្សោយ ហើយ គ្មានអាជ្ញាសឹក, បទបញ្ជារបស់គាត់ រមែងតែងតែមិនមាន លក្ខណៈច្បាស់លាស់ និង ស្រឡះទេ,




www.facebook.com/7khmer
Fb page : Entertainment  And Knowledge

សេចក្តីអធិប្បាយ៖ លាវអ៊ូ បានបរិយាយនៅក្នុងស្នាដៃរបស់គាត់ត្រង់ជំពូកទី៤ ជាសេចក្តីថា៖ «បើមេបញ្ជាការដាក់បទបញ្ជាប្រកបដោយការសម្រេចចិត្តច្បាស់លាស់ នោះពលទាហាននឹងមិននៅរង់ចាំស្តាប់ ជាលើកទីពីរទៀតទេ ហើយបើចង្វាក់ចលនា របស់គាត់ នៅតែគ្មានសញ្ញាផ្លាស់ប្តូរប្រែប្រួលអ្វីទេ នោះពលទាហាន ក៏នឹងមិនមាន គំនិតបែកខ្ញែកជាពីរ នៅក្នុងភារកិច្ចរបស់ពួកគេនោះដែរ»។

មេទ័ពបារាំងនៅផ្លូវលពោលទុកថា៖ «អាថ៌កំបាំងនៃ ការទទួលភាពជោគជ័យ ក្នុងការងារពីមនុស្ស ដែលបានទទួលការបង្វឹកពីអ្នក គឺមាន នៅក្នុងសេចក្តីជាសង្ខេបថា ជោគជ័យទាំងនេះ ត្រូវទទួលបានមក ដោយសារ សេចក្តីណែនាំដែលពួកគេ ទទួលយកពីអ្នកទៅនោះ មានសភាពច្បាស់លាស់ល្អ»។(ស្នាដៃ ជំនួយស្មារតីឈ្លបយកការណ៍ ទំព័រ xii )។ បើប្រៀបធៀប ជាមួយស្នាដៃ វូអ៊ូ ដែលបានបរិយាយក្នុងសំណេរ របស់គាត់ត្រង់ជំពូកទី៣ មានជាសេចក្តីថា៖ «គ្រោះកម្ម ដែលវាបាចផលឲ្យមកនៅ ក្នុងចំណោមមេទ័ព វាផ្សេងទៅវិញ




www.facebook.com/7khmer
Fb page : Entertainment And Knowledge

គឺ មហន្តរាយអាក្រក់ផុតលេខ ដែលធ្លាក់មកលើយោធានោះ វាតែងតែចេញមកពីការស្ទាក់ស្ទើររារែកចិត្តនោះឯង»។

ប្រការទី 18 ៖ (២). នៅពេលណា ដែលគ្មានភារកិច្ចជាប់លាប់ ជាប្រចាំត្រូវបានដាក់ឲ្យនាយទ័ព នាយកង និងពលទាហានទេ,

សេចក្ដីអធិប្បាយ៖ ទូ មូ ពោលថា៖ «គឺចំពោះនាយទ័ព នាយកង ព្រមទាំងពលទាហាន ដែលពួកគេគ្មានទម្លាប់ជា ដដែលៗ នោះឯង»។

ប្រការទី 18 ៖ (៣). ហើយបើជួរទាហាន លេចចេញជារូបរាងមានលក្ខណៈគ្មានរបៀបរៀបរយ, ស្មោគគ្រោគ លទ្ធផលដែលស្ដែងចេញមកគឺ៖ សភាពខ្ចីខ្ចារ គ្មានរបៀបរបប។

ប្រការទី 19 ៖ នៅពេល ដែលមេទ័ព គ្មានសមត្ថភាពប៉ាន់ស្មានកងកម្លាំងរបស់សត្រូវបានទេ នោះវានឹងនាំដល់ការណ៍ដែលគាត់ដឹកនាំកងកម្លាំងតិច ដែលចាញ់ប្រៀបទៅប្រយុទ្ធទល់នឹងកងកម្លាំងរបស់គេ ដែលធំធេងជាងខ្លួន ឬក៏ បញ្ជូនកងកម្លាំង ដែលទន់ខ្សោយណាមួយឲ្យទៅ ប្រយុទ្ធតទល់នឹងកងកម្លាំង ដែលមានអានុភាពជាង, ហើយក៏ធ្វេស




www.facebook.com/7khmer
Fb page : Entertainment And Knowledge

ប្រហែស ដោយមិនបានយកទាហានជម្រើសឯក ទៅដាក់នៅជួរមុខ លទ្ធផលដែលនឹងបានមកគឺ៖ ការបាក់ទ័ព។

សេចក្តីអធិប្បាយ៖ ចាងអ៊ី ពន្យល់ឃ្លាបន្ទាប់ នៅក្នុងប្រយោគខាងលើជាបន្តថា៖ «នៅគ្រប់ពេល ដែលត្រូវធ្វើការវាយប្រយុទ្ធ ទាហានដែលមុះមុតជាងគេ ត្រូវបានចាត់តាំងឲ្យទៅបម្រើនៅជួរមុខ ទាំងសងខាងនេះ គឺ ដើម្បីពង្រឹងនូវសេចក្តីអង់អាច នៃ ពលទាហានរបស់យើងផង និង ដើម្បីបំបាក់ទឹកចិត្តសត្រូវផងដែរ»។

ប្រការទី 20 ៖ ទាំងអស់នេះ គឺជា មាគ៌ាទាំង ៦ប្រការ ដែលអាចនាំទៅដល់បរាជ័យ ដែលមាគ៌ាទាំងនេះ ត្រូវតែបានកត់ត្រាទុក ឲ្យបានប្រយ័ត្នប្រយែងបំផុត ដោយមេទ័ពរូបណាដែលទទួលខុសត្រូវភារកិច្ចតាមមុខតំណែងរបស់ខ្លួន។

សេចក្តីអធិប្បាយ៖ សេចក្តីអធិប្បាយពន្យល់ គឺមានដូចប្រការទី១៣ ដែរ ។

ប្រការទី 21 ៖ (១). បែបផែន ទ្រង់ទ្រាយស្រុកទេស តាមដំណើរធម្មជាតិរបស់វា គឺជា សម្ព័ន្ធមិត្ត ដ៏ល្អបំផុតរបស់កងទ័ព,




www.facebook.com/7khmer
Fb page : Entertainment And Knowledge

*សេចក្ដីអធិប្បាយ៖ ឆិនហាវ ពោលថា៖ «គុណសម្បត្តិនៃ អាកាសធាតុ និង រដូវកាលក៏នៅមានប្រៀបមិនស្មើនឹងលក្ខណៈទ្រង់ទ្រាយទាំងឡាយ នៃទីតាំងដីនោះទេ»។*

ប្រការទី 21 ៖ (២). ក៏ប៉ុន្តែ ឋាមពល ខាងការប៉ាន់ស្មានសត្រូវ, ឋាមពល ខាងការត្រួតត្រាកម្លាំងយកឈ្នះ និង ឋាមពល ខាងការគណនាភាពលំបាកលំបិនទាំងឡាយ, គ្រោះថ្នាក់ទាំងឡាយ និង រយៈចម្ងាយ ដោយភាពវៃឆ្លាតល្អិតល្អន់ និង គ្រប់ជ្រុងជ្រោយ វាត្រូវបានគេប្រតិដ្ឋឡើងជាការសាកល្បងមេទ័ពដ៏មហិមានេះឯង។

ប្រការទី **22** ៖ នរជនណា ដែលយល់ដឹង នូវ អ្វីៗ ទាំងអស់នេះហើយ និង យកចំណេះចំណានទាំងនេះ មកអនុវត្តក្នុងចម្បាំង ក៏នឹងមានជោគជ័យក្នុងការប្រយុទ្ធរបស់គាត់។ ផ្ទុយទៅវិញ នរជនណា ទោះជាបានយល់ដឹង ឬ មិនយល់ដឹងចំណេះចំណានទាំងនេះក្ដី ដែលមិនបានអនុវត្ត ក៏នឹងបរាជ័យជាប្រាកដ។

ប្រការទី **23** ៖ បើយើងដឹងថា ការប្រយុទ្ធនោះ ប្រាកដតែពីខាងឈ្នះហើយ ខណៈនោះ ចូរអ្នកច្បាំងចុះ បើទោះជាមេដឹកនាំបានហាមប្រាមហើយក៏ដោយចុះ, តែបើការប្រយុទ្ធ





www.facebook.com/7khmer
Fb page : Entertainment And Knowledge

នោះ នឹងមិនបានជ័យជំនះវិញនោះទេ អ្នកមិនត្រូវច្បាំងទេ ទោះជាមេដឹកនាំបានដាក់បញ្ជាមកហើយក៏ដោយ។

សេចក្តីអធិប្បាយ៖ បើប្រៀបធៀប ជាមួយ ស្នាដៃ ហ័ងស៊ីគង់ ជំពូកទី៨ ប្រការទី៣ ដែលបានបន្សល់ទុក តាំងពីរាជវង្សឈិន ព្រមទាំងមានគេនិយាយថា គាត់ គឺជា ឧបត្ថម្ភក៏ជនចំពោះ ចាងលាំង ហើយគាត់បាន សរសេរឯកសារឈ្មោះ សានលួ មាន ទាំងពាក្យសម្តី សំដៅដល់ខ្លួនគាត់ថា៖ «ភារៈ ដែលត្រូវទទួលខុសត្រូវ ក្នុងកិច្ចការរៀបចំ យោធាឲ្យមានសភាពរស់រវើក គឺ ត្រូវប្រគល់ទៅឲ្យមេទ័ពតែម្នាក់ឯងគត់, ក៏ប៉ុន្តែ បើការ សម្រុកទៅចូល និង ការដកថយ ត្រូវបានត្រួតត្រាបញ្ជា មកពីរាជវាំងវិញនោះ លទ្ធផលល្អ មុខជាពិបាកនឹង សម្រេចបានណាស់។ ហេតុនេះ មេដឹកនាំដូចព្រះ និង ព្រះមហាក្សត្រដែលរុងរឿង ទ្រង់ / គាត់ សប្បាយចិត្ត នឹងដើរតួដាក់ខ្លួន មកក្នុងការជួយជ្រោមជ្រែង ដើម្បី បុព្វហេតុប្រទេសជាតិរបស់ ទ្រង់ / គាត់ (តាមន័យ អក្សរសាស្ត្រ គឺ លត់ជង្គង់ចុះ ហើយរុញច្រានរទេះ ចម្បាំងឲ្យបានទៅមុខ)»។/ សេចក្តីនេះ គឺ មានន័យថា៖





www.facebook.com/7khmer
Fb page : Entertainment And Knowledge

ជារឿងដែលស្ថិតនៅក្រៅពីថៃវឋានសួគ៌, ការសម្រេចចិត្តនៅក្នុងកងទ័ព គឺទាមទារនូវភាពដាច់ខាត»។ ចាងអ៊ីក៏ដកស្រង់ភាសិត មកបង្ហាញផងដែរថា៖ «ក្រិត្យក្រម ទេវបុត្រ នៃ ឋានសួគ៌ មិនត្រូវការដឹងឮរឿងកំពែងបន្ទាយអ្វីនោះទេ»។

ប្រការទី 24 ៖ (១). មេទ័ពរូបណា ដែលសម្រុកចូលទៅមុខ ដោយមិនចង់បានកិត្តិយស និង ដកថយ ដោយមិនរអៀសខ្លាចចំពោះសេចក្ដីអាម៉ាស់នោះ,

សេចក្ដីអធិប្បាយ៖ ខ្ញុំគិតថា គឺ លោកវែលីងតុន (Wellington) ដែលបាននិយាយថា៖ រឿង ដែលពិបាកធ្វើជាងគេបំផុតសម្រាប់ទាហាននោះ គឺ ការដកថយនេះហើយ»។

ប្រការទី 24 ៖ (២). នរជនណា ដែលគ្រាន់តែ មានគំនិតការពារប្រទេសជាតិ របស់ខ្លួន និង បម្រើសេវាការពារដំពិសិដ្ឋថ្វាយចំពោះអធិរាជរបស់គេ នរជនទាំងនេះ គឺជារតនបុគ្គល របស់ ប្រទេសជាតិហើយ។





www.facebook.com/7khmer
Fb page : Entertainment And Knowledge

សេចក្ដីអធិប្បាយ៖ អព្ភន្តរញ្ញាណ ដ៏ថ្លៃថ្នូរមួយ ចំពោះនរជនទាំងនេះ មានពិពណ៌នាត្រឹមតែពាក្យ ពីរ បី ម៉ាត់ក្នុងភាសាចិនតែប៉ុណ្ណោះ គឺ៖ «អ្នកចម្បាំងដ៏រីករាយ»។ ហាស៊ី បានពិពណ៌នាយ៉ាងខ្លី អំពី នរជនប្រភេទនេះថា៖ «បើសិនជា គាត់ទទួលរងការឈឺចាប់ ដោយសារតែទារុណកម្មក៏ដោយចុះ រូបគាត់ ក៏គង់នឹងមិនសោកស្ដាយ ចំពោះអ្វី ដែលគាត់បានធ្វើនេះទេ»។

ប្រការទី **25** ៖ ចូរចាត់ទុកកូនទាហាន របស់អ្នក ឲ្យដូចជាកូនចៅរបស់អ្នកអញ្ចឹង ហើយពួកគេនឹងដើរតាមអ្នក ទោះជាត្រូវចូលទៅក្នុងក្រហែងរូងភ្នំជម្រៅណាក៏ដោយ, ចូរមើលថែពួកគេ ឲ្យដូចជា កូនៗ ជាទីស្រឡាញ់របស់អ្នកផងចុះ ពួកគេនឹងនៅតែគាំទ្រអ្នក ទោះបីជា សេចក្ដីស្លាប់ ហៀបនឹងមកដល់ហើយក៏ដោយ។

សេចក្ដីអធិប្បាយ៖ តាមន័យនេះ ទូមូ គូសបញ្ជាក់ប្រាប់យើងនូវបទពណ៌នា ដ៏គួរឲ្យចាប់ចិត្ត ដោយប្រៀបធៀបទៅនឹងសេចក្ដី ដែលបានពោលមកហើយ ក្នុងជំពូកទី១ ប្រការទី៦ អំពី មេទ័ព ដ៏ល្បីល្បាញ ឈ្មោះអ៊ូឈី ដែលខ្ញុំតែងតែដកស្រង់សម្ដី ជាញឹកញយ នូវ


www.facebook.com/7khmer
Fb page : Entertainment And Knowledge

សេចក្តីអធិប្បាយ អំពី រឿងអ៊ូឈី នេះថា៖ «គាត់ស្លៀកពាក់ សម្លៀកបំពាក់ និង បរិភោគអាហារ ដែលមិនគួរជាទីត្រេកត្រអាល ដូចជា ទាហានរបស់គាត់អញ្ចឹងដែរ គាត់បដិសេធ មិនទទួលយករបបសេះ, មិនទទួលយកកន្ទេលមកដេក គាត់វេចស្លាយតែរបស់សំណល់ពីរបបគាត់ ក្នុងបង្វិចមួយតែប៉ុណ្ណោះ ហើយគាត់ចេះតែជួយចូក ជួយថៃវ រំលែកសេចក្តីលំបាកជាមួយកូនទាហានរបស់គាត់ជាដរាបរហូតមក។ ក្នុងចំណោម ពលទាហានរបស់គាត់ មានកូនទាហានម្នាក់កើតសេចក្តីឈឺចាប់ ដោយសារតែដម្ងីបូស វាបណ្តាលឡើង អ៊ូឈីក៏ជួយបឺតយកចេញ នូវ មេរោគ ដោយខ្លួនគាត់ផ្ទាល់។ ពេលដែលមាតា នៃ កូនទាហានរូបនោះបានឮដូចនេះ ក៏ចាប់ផ្តើមទួញទ្រហោយំ។ មានគេមកសួរគាត់ថា៖ «ហេតុអ្វីបានជាអ្នកយំយ៉ាងនេះ? កូនប្រុស របស់អ្នក គ្រាន់តែជា កូនទាហានសាមញ្ញធម្មតា ម្នាក់ប៉ុណ្ណោះ ហើយ លោកអគ្គមេបញ្ជាការកងទ័ព ក៏បានជួយគេ ដោយបឺតយកចេញ នូវ មេរោគពីដំបៅបូសកូនរបស់អ្នក ដោយខ្លួនគាត់ផ្ទាល់ហើយនោះ»។ ស្ត្រីចំណាស់




www.facebook.com/7khmer
Fb page : Entertainment And Knowledge

ក៏បានឆ្លើយតបវិញថា៖ «ជាច្រើនឆ្នាំ កន្លងទៅហើយ លោកម្ចាស់អ៊ូបានជួយបម្រើប្តីរបស់ខ្ញុំក្នុងរឿងស្រដៀងគ្នានេះដែរ ដែលពេលក្រោយមក ប្តីខ្ញុំមិនដែលរត់ចោលលោកមេទ័ពទេ ទីបំផុត ក៏ត្រូវខ្មាំងចាប់បាន ហើយសម្លាប់ចោលទៅ។ ឥឡូវនេះ លោកមេទ័ព ក៏ធ្វើដូចគ្នា ចំពោះ កូនប្រុសរបស់ខ្ញុំទៀត ដែលកូនប្រុសរបស់ខ្ញុំនេះ ក៏អញ្ចឹងដែរ គឺ គង់នឹងធ្លាក់ខ្លួនក្នុងការប្រយុទ្ធដែរ គ្រាន់តែខ្ញុំមិនដឹងថា នៅទីណាតែប៉ុណ្ណឹងទេ»។

ចំណែក លីឈាន់ ក៏បានលើករឿងខ្លីមកបញ្ជាក់ដែរ ទាក់ទងនឹងអភិជន នគរឈូ ដែលបានចូលទៅលុកលុយនគរតូចតាចមួយ គឺ នគរស៊ាវ នាកំឡុងរដូវរងារ។ ស្តេចត្រាញ់ក្រុងសិន បាននិយាយទៅកាន់គាត់ថា៖ «មានពលទាហានជាច្រើន កំពុងតែរងគ្រោះរងារយ៉ាងញ័រញាក់ ដោយសាររអាកាសធាតុត្រជាក់»។ គ្រាន់តែបានឮដូចនេះ គាត់ចេញទៅដើរចច្រប់ពេញបន្ទាយទាហានទាំងមូល ដោយល្បួងលោម និង លើកទឹកចិត្តកូនទាហានទាំងឡាយ ក៏ស្រាប់តែពលទាហាន




www.facebook.com/7khmer
Fb page : Entertainment And Knowledge

ទាំងនោះ មានអារម្មណ៍ថា ហាក់ដូចជា ត្រូវបានគ្រប ដណ្ដប់ ដោយក្រណាត់សំពត់ ដែលធ្វើពីសសៃសូត្រ អញ្ចឹង។

* ប្រការទី **26** ៖ ទោះជាយ៉ាងណាក្តី បើអ្នកចេះអត់ឱន ក៏ប៉ុន្តែ អ្នកមិនអាចនឹងធ្វើឲ្យអំណាច របស់អ្នកមានប្រសិទ្ធភាពបាន, បើអ្នកមានចិត្តល្អ តែអ្នកមិនអាចនឹងអនុវត្តបទបញ្ជា របស់ អ្នកបាន, ហើយអ្នកអសមត្ថភាព ជាងនេះទៅទៀត គឺ មិន អាចពង្រាបឲ្យរាបរយនូវសភាពគ្មានសណ្ដាប់ធ្នាប់បាន នោះ កូនទាហានរបស់អ្នក ក៏ប្រៀបបាននឹងកូនក្មេង ដែលទម្រើស ហួសហេតុអញ្ចឹងដែរ ពួកគេ ក៏គ្មានបានកើតជាការអ្វីឡើយ ហើយ មិនអាចនឹងប្រើប្រាស់ សម្រាប់គោលបំណង ជា ប្រយោជន៍ណាមួយកើតឡើយ។

សេចក្តីអធិប្បាយ៖ មានគ្រាម្តងនោះ លីជីង ពោលថា បើសិនជាអ្នកអាចធ្វើឲ្យពលទាហានរបស់អ្នកខ្លាចអ្នក ពួកគេ ក៏នឹងនៅតែមិនខ្លាច ចំពោះ ពួកខ្មាំងដែរ។ ទូមូ នៅចាំរំឭកបាននូវតួយ៉ាងនៃទាហានដែលគោរពវិន័យ តឹងរ៉ឹង ដែលកើតមានកាលពី ឆ្នាំ២១៩ នៃ គ.ស, នៅ ពេលដែល លូម៉ឹង កំពុងតែកាន់កាប់ក្រុងឈាំងលីង។




www.facebook.com/7khmer
Fb page : Entertainment And Knowledge

គាត់បានដាក់បទបញ្ជា យ៉ាងតឹងតែង ចំពោះ ពលទាហានរបស់គាត់ថា កុំឲ្យធ្វើបាបអ្នកស្រុកភូមិ ហើយក៏កុំឲ្យបង្ខំជម្រិតយករបស់ អ្វីៗ ពីពួកគេ ដោយប្រើកម្លាំងឲ្យសោះ។ ទោះជាមានបទបញ្ជាយ៉ាងនេះហើយក៏ដោយ មាននាយទាហានសំខាន់ម្នាក់ ដែលបម្រើការក្រោមបង្គាប់ របស់គាត់ បានប្រទះឃើញបុរសទីក្រុងម្នាក់ ក៏ប្រថុយស្ទុះទៅ ដណ្ដើមយកមួកឫស្សីពីបុរសនោះ មកពាក់ពីលើមួកទាហានរបស់ខ្លួន ដើម្បីការពារទឹកភ្លៀង។ លូម៉ឹង ពិចារណាទៅមកក៏ឃើញថា ការពិតនៃ ជីវិតរស់នៅរបស់គាត់ ក៏ជា មនុស្សមានកំណើតមកពីស្រុកឃ្យូណានដែរ តែក៏មិនត្រូវលើកលែង ចំពោះបទល្មើស ដែលប្រឆាំងទល់នឹងវិន័យនេះទេ តាមរយៈនេះ គាត់ក៏បញ្ជាឲ្យគេប្រហារជីវិត ទាហាននោះទៅព្រមទាំង មានទឹកភ្នែករមៀលស្រក់ចុះមកកាត់ថ្ពាល់មុខរបស់គាត់ផង, ទោះជាយ៉ាងណាក៏ដោយ គាត់ត្រូវតែចាត់ការដូចនេះ។ ទង្វើ ដែលប្រកបដោយភាពមធ្យ័តនេះបានចាក់បំពេញឲ្យកងយោធានូវសេចក្ដីកោតខ្លាចដែលនាំដល់ភាពត្រឹមត្រូវជារួមមួយ ហើយចាប់ពីពេល





www.facebook.com/7khmer
Fb page : Entertainment And Knowledge

*នោះមក ទោះជា មានរបស់របរកំប៉ិកកំប៉ុកអ្វីជ្រុះរាយតាមផ្លូវដ៏ដោយ ក៏ពួកគេមិនរវល់រើសយកដែរ។*

ប្រការទី 27 ៖ បើសិនជា យើងបានដឹងថា ពលទាហានរបស់យើង ស្ថិតនៅក្នុងស្ថានការណ៍ ប្រុងប្រៀបប្រយុទ្ធរួចទៅហើយ ក៏ប៉ុន្តែ យើងនៅតែទាន់មិនបានដឹងសភាពការណ៍ថា សត្រូវបានបើកចំហ ដើម្បីចូលប្រយុទ្ធ ឬ នៅឡើយនោះទេ, ការណ៍នេះ យើងទៅដល់បានត្រឹមតែពាក់កណ្ដាលផ្លូវ នៃ ជ័យជំនះតែប៉ុណ្ណោះ។

*សេចក្ដីអធិប្បាយ៖ ហេតុនេះហើយ បានជា ឆាវកុងពោលថា៖ «រឿងរ៉ាវក្នុងករណីនេះ នៅមិនទាន់ជាក់លាក់ទេ»។*

ប្រការទី 28 ៖ បើសិនជា យើងដឹងថា សត្រូវបានបើកចំហដើម្បីវាយប្រយុទ្ធហើយ ប៉ុន្តែខាងយើង នៅឡើយមិនបានដឹងថា ពលទាហានរបស់យើង បានស្ថិតក្នុងស្ថានការណ៍ត្រៀមប្រយុទ្ធ ឬ នៅឡើយទេនោះ យើងក៏ទើបតែបានទៅដល់ត្រឹមពាក់កណ្ដាល នៃ ជ័យជំនះតែប៉ុណ្ណោះ។





www.facebook.com/7khmer
Fb page : Entertainment And Knowledge

សេចក្តីអធិប្បាយ៖ សូមប្រៀបធៀបជាមួយ ជំពូកទី៣ ប្រការទី១៣ (១)។

ប្រការទី 29 ៖ បើសិនជា យើងដឹងថា សត្រូវបានបើកចំហ ដើម្បីវាយប្រយុទ្ធ ហើយយើងក៏បានដឹងថា ពលទាហាន របស់យើង ក៏ស្ថិតក្នុងស្ថានការណ៍ត្រៀមប្រយុទ្ធដែរ ក៏ប៉ុន្តែ យើងមិនបានដឹងថា ធម្មជាតិ នៃ សណ្ឋានដីជាទីតាំង ដែល ត្រូវធ្វើការប្រយុទ្ធនោះ មិនអាចនឹងធ្វើការវាយប្រយុទ្ធកើត ឬ យ៉ាងណានោះឡើយ, យ៉ាងនេះ យើងក៏ទៅបានត្រឹមតែ ពាក់កណ្តាលផ្លូវ នៃ ជ័យជំនះ តែប៉ុណ្ណោះដែរ។

ប្រការទី 30 ៖ ដូចនេះ ទាហានដែលធ្លាប់មានបទពិសោធន៍ ឲ្យតែគេចេញដំណើរប្រតិបត្តិការសឹកហើយ គឺ គេមិនដែល ទុញទាល់សុញគំនិតអ្វីឡើយ, ហើយឲ្យតែគេបានរើបន្ទាយ របស់គេហើយ គេក៏មិនដែលស្ទាក់ស្ទើរចិត្តបង់ខាតដែរ។

សេចក្តីអធិប្បាយ៖ ហេតុផលដែលកំពុងនិយាយនេះ មានជាប់ទាក់ទងនឹង ទូមូ ដែលគាត់បានចាត់វិធាន ការណ៍ ប្រកាន់យកនូវការវាស់វែងយ៉ាងហ្មត់ចត់ ក្នុង គោលបំណងធ្វើឲ្យប្រាកដប្រជាថា នឹងទទួលបានជ័យ





www.facebook.com/7khmer
Fb page : Entertainment And Knowledge

ជំនះ ជាមុនសិន សឹមចេញទៅប្រយុទ្ធ។ ចាងអ៊ី ពោលថា៖ «គាត់មិនមែនយាត្រាទ័ព ដោយធ្វេសប្រហែសទេ ធ្វើដូចនេះ ដើម្បីឲ្យប្រាកដថា ពេលគាត់ធ្វើចលនា គាត់មិនធ្វើអ្វីឲ្យភ្លាត់ខុសសោះឡើយ»។

ប្រការទី 31 ៖ ដូចនេះហើយ ទើបមានភាសិត ជាសេចក្ដីថា៖ បើអ្នកដឹង អំពី សត្រូវ និង ដឹងអំពី ខ្លួនឯង ជោគជ័យរបស់អ្នកនឹងមិនស្រពេចស្រពិលទេ, បើអ្នកដឹង អំពី មេឃ និង ដឹង អំពី ដី នោះអ្នកអាចនឹងធ្វើឲ្យជោគជ័យរបស់អ្នកលេចចេញមកជារូបរាង ដោយពេញលេញបាន។

សេចក្ដីអធិប្បាយ៖ លីឈាន់ បូកសរុបសេចក្ដីដូចតទៅនេះថា៖ «មានចំណោះបីប្រការ ដែលជាកិច្ចការ របស់កូនប្រុស គឺរដូវកាលនៃមេឃា និងការមានប្រៀបខាងធម្មជាតិនៃដែនដីជ័យភូមិ នោះជ័យជំនះ គឺជាម្កុដ មកបំពាក់ពីលើការតស៊ូរបស់អ្នក ដោយមិនប្រែប្រួលជាប្រការដទៃទេឡើយ»។ សូមមើល (១). "Pensees de Napoleon 1er," no. 47, (២). វិទ្យាសាស្ត្រសង្គ្រាម (Science of War,) ជំពូកទី២, (៣). ជំនួយស្មារតីឈ្លបយកការណ៍ (Aids to Scouting, p. xii)




www.facebook.com/7khmer
Fb page : Entertainment  And Knowledge

## ជំពូកទី 11.

# ស្ថានការណ៍ទាំង៩ប្រការ/លក្ខណៈទីតាំងទាំង៩ប្រការ

ប្រការទី 1៖ ស៊ុនអ៊ូ ពោលមុតថា ជំនាញខាងសឹកសង្គ្រាម ទទួលស្គាល់ទីតាំងជាមូលដ្ឋាន ខុសៗគ្នា ចំនួន៩ប្រការ គឺ៖ (១). មូលដ្ឋាន ដែលមានលក្ខណៈពង្រាយ, (២). មូលដ្ឋាន ដែលមានលក្ខណៈងាយធ្វើការ, (៣). មូលដ្ឋាន ដែលមាន លក្ខណៈងាយកើតវិវាទដណ្ដើមគ្នា, (៤). មូលដ្ឋានដែលមាន លក្ខណៈបើកចំហ, (៥). មូលដ្ឋានដែលមានផ្លូវធំបំបែក, (៦). មូលដ្ឋាន ដែលមានលក្ខណៈមធ្យ័ត, (៧). មូលដ្ឋានដែល មានលក្ខណៈ លំបាកធ្វើការ, (៨). មូលដ្ឋាន ដែលមាន លក្ខណៈខ័ណ្ឌព័ទ្ធពីក្រៅចំហតែខាងក្នុង និង (៩). មូលដ្ឋាន ដែលមានលក្ខណៈអស់សង្ឃឹម។

ប្រការទី 2៖ នៅពេលណា ដែលប្រមុខកងទ័ព កំពុង (ដឹក នាំទ័ព) ធ្វើការវាយប្រយុទ្ធនៅលើទឹកដីរបស់ខ្លួន គេហៅថា មូលដ្ឋានដែលមានលក្ខណៈពង្រាយ។

*សេចក្ដីអធិប្បាយ៖ គេហៅយ៉ាងនេះ ដោយហេតុថា ពលទាហានទាំងឡាយ កំពុងស្ថិតនៅជិតផ្ទះសម្បែង*


www.facebook.com/7khmer
Fb page : Entertainment And Knowledge

របស់ពួកគេ និង កើតក្តីរំភើបចង់ទៅឃើញមុខប្រពន្ធកូនរបស់ពួកគេ ហើយម្យ៉ាងទៀត ពួកគេហាក់ដូចជាចង់ដណ្តើមយកឱកាស ដែលផ្តល់ដោយសង្គ្រាមនេះ ហើយចាកចេញទៅគ្រប់ទិសទី។ ទូមូ សង្កេត ឃើញថា «ពួកគេបាត់បង់សេចក្តីក្លាហាន ដោយសារភាពអស់សង្ឃឹម ហើយនៅពេល ដែលពួកគេដកថយទៅវិញ ពួកគេនឹងទៅរកទីជម្រករអាស្រ័យដើម្បីស្នាក់នៅ»។

ប្រការទី 3 ៖ នៅពេល ដែលនរជនណា ឈានជើងចូលដល់ទឹកដីសត្រូវហើយ ប៉ុន្តែចូលទៅមិនសូវជ្រៅប៉ុន្មានទេ គេហៅថាជា មូលដ្ឋាន ដែលមានលក្ខណៈងាយធ្វើការ។

សេចក្តីអធិប្បាយ៖ លីឈាន់ និង ហាស៊ី ពោលថា៖ «ការណ៍នេះ ព្រោះតែវាងាយនឹងដកថយចេញមកវិញ» និង អ្នកអត្ថាធិប្បាយដទៃទៀត ផ្តល់សេចក្តីពន្យល់ស្រដៀងគ្នានេះដែរ។ ទូមូ កត់ត្រាទុកថា៖ «នៅពេលដែលទាហានរបស់អ្នក បានកន្លងឆ្លងព្រំដែនរួចហើយ អ្នកគួរតែដុតទូក និង ស្ពានចោលទៅ ដើម្បីធ្វើឲ្យ




Fb page : Entertainment And Knowledge

ប្រាកដចំពោះមនុស្សទាំងអស់គ្នានោះថា នឹងមិនមានការនឹកនាចង់វិលត្រឡប់ទៅផ្ទះសម្បែងវិញទេ»។

ប្រការទី 4 ៖ ការចាប់យកទីតាំងដី ដែលមានប្រៀបដ៏ធំធេងសមប្រកប អំណោយផលចំពោះ ភាគីទាំងសងខាងដូចគ្នា គឺជាមូលដ្ឋានដែលមានលក្ខណៈងាយកើតវិវាទដណ្ដើមគ្នា។

សេចក្ដីអធិប្បាយ៖ ទូមូ កំណត់លក្ខណៈសណ្ឋានដីប្រភេទនេះ ថាជា «ទីតាំងដែលត្រូវតស៊ូសម្រេចយកឲ្យបាន»។ ឆាវកុង ពោលថា៖ «ជាទីតាំង ដែលមានសណ្ឋានដីបង្កលក្ខណៈឲ្យមនុស្សតិច និងកម្លាំងខ្សោយអាចយកឈ្នះមនុស្សច្រើននិងកម្លាំងខ្លាំងជាងខ្លួនបាន» យ៉ាងនេះ គេហៅថា «ដើមច្រកផ្លូវ» ដែលត្រូវបានលើកជាតួយ៉ាងដោយ លីឈាន់។ ហេតុនេះហើយ បានជាក្នុងសង្គ្រាមទែម៉ូពីឡាយ (War of Thermopylae, នៅប្រទេសក្រិច ពី ថ្ងៃទី៧ ខែសីហា ដល់ ថ្ងៃទី៨ ឬ ទី១០ ខែកញ្ញា ឆ្នាំ៤៨០ មុន គ.ស) ដែលប្រទេសពែក្ស បានដណ្ដើមយកប្រៀបក្នុងសង្គ្រាមរបៀបនេះ ដោយសារតែ ពួកគេចាប់យកបាននូវទីតាំង ដូចដែលបាន





www.facebook.com/7khmer
Fb page : Entertainment And Knowledge

និយាយមកខាងលើនេះ, ទោះជាបានត្រឹមតែ ពីរ បីថ្ងៃក៏ដោយ តែវាមានន័យថា បានចូលលុកលុយ និងបង្ខាំងទាហានខ្មាំងទាំងមូល ហើយធ្វើទុក្ខឲ្យវិវក់ ដើម្បីកេងចំណេញពេលវេលាដ៏មានតម្លៃ។

បើប្រៀបធៀប ជាមួយ ស្នាដៃ វូអ៊ូ ជំពូកទី៥ ដែលមានសេចក្តីថា៖ «សម្រាប់កងទ័ពណា ដែលត្រូវប្រយុទ្ធដោយកម្លាំងជាមធ្យមមួយនាក់ទល់នឹងដប់នាក់ គ្មានទីតាំងណា ល្អជាងការប្រើប្រាស់ច្រកចង្អៀតនោះទេ»។ នៅពេលដែល លូគ័ង កំពុងតែ វិលត្រឡប់ពីបំពេញបេសកកម្មយោធា ដ៏មានជោគជ័យពីទូគីស្តានវិញ កាលពី ឆ្នាំ៣៨៥ នៃ គ.ស ហើយគាត់បានចាកចេញមកឆ្ងាយដល់កោះហូ បានទាំងនាំយកមកជាមួយ នូវ ជ័យភ័ណ្ឌ ដ៏ច្រើនសន្ធឹកសន្ធាប់ផងដែរ ចំណែក លាំងស៊ី ដែលជាអ្នកកាន់ រដ្ឋបាលកងទ័ពលាំងជូ បានកេងចំណេញពីការសោយទិវង្គត់នៃស្តេចហ្វូឈាន របស់ នគរឈីន បានដាក់គម្រោងការប្រឆាំងនឹង លូគ័ង ហើយរារាំងស្ទាក់ផ្លូវមិនឲ្យគាត់ បានចូលទៅក្នុងស្រុកវិញ។ យ៉ាងហាន ប្រមុខ នៃ ខេត្ត




www.facebook.com/7khmer
Fb page : Entertainment And Knowledge

ការឆាង បានឲ្យយោបល់ទៅ លាំងស៊ី ដោយនិយាយថា៖ «លូគ័ង មានជ័យជំនះ ស្រស់ៗ ឆ្ពោះមកពីទិសខាងលិច ចំណែកឯ ទាហានរបស់គេ ក៏ស្វាហាប់ មាំមួន ហើយក្លៀវក្លាទៀតផង។ បើយើងចង់ច្បាំងទល់នឹងគេនៅលើគំនរវាលខ្សាច់ដែល ផុរៗ នោះ យើងមិនមែនជាដៃគូប្រកួតនឹងគេទេ ហេតុនេះហើយ យើងត្រូវតែព្យាយាមធ្វើតាមផែនការផ្សេងវិញ ទើបបាន។ ចូរយើងប្រញាប់ទៅចាប់យកទីតាំង នាមាត់ច្រកភ្នំកៅអ៊ូ ដើម្បីកាត់ផ្តាច់ផ្លូវផ្គត់ផ្គង់ទឹករបស់ពួកវា នៅពេលដែលទាហានវាដុនដាបដោយដាច់ទឹកហើយនោះ គឺដល់វេនយើងចាត់ការវាយប្រហារពួកវាវិញម្តង ដោយមិនចាំបាច់ចល័តទ័ពទៅណាឡើយ ឬ បើសិនជា លោកម្ចាស់គិតថា ច្រកភ្នំ ដែលខ្ញុំបាននិយាយអម្បាញ់មិញនោះ វានៅឆ្ងាយពេក យើងអាចទៅបោះទីតាំងពង្រឹងជំហរទ័ពរបស់យើង តទល់នឹងពួកវានៅច្រកកោះអ៊ូ ដែលនៅជិតជាងហ្នឹងវិញក៏បាន។ លាំងស៊ី បានបដិសេធមិនធ្វើតាមយោបល់នេះទេ ដោយនិយាយថា បើតាមភាពប៉ិនប្រសប់ និង ភាពប៉ិនកែខៃលៃលក របស់




www.facebook.com/7khmer
Fb page : Entertainment And Knowledge

អ៊ូហ្វាំង វិញ ក៏នឹងមិនចំណាយទ័ព ដោយឥតសារ ឥតការ ឲ្យទៅប្រឈមទល់នឹងកម្លាំងទ័ពដ៏មហិមារបស់ លូគ័ង តាមចំណុចទីតាំងទាំងពីរនោះទេ។ ចុងបញ្ចប់ ទាហាន លាំងស៊ី ក៏ត្រូវបានបំផ្លាញឲ្យវិនាស ដោយ ទាហាន របស់ លូគ័ង។

ប្រការទី **5** ៖ ការបោះទីតាំងលើដែនដី ដែលភាគីទាំងសង ខាង អាចមានសេរីភាពក្នុងការធ្វើចលនាបានដូចគ្នា គេហៅ ថា មូលដ្ឋានដែលមានលក្ខណៈបើកចំហ។

សេចក្ដីអធិប្បាយ៖ វាមានន័យអាចយកមកបកស្រាយ បានច្រើនយ៉ាងណាស់ តាមគុណនាម ក្នុងភាសាចិន ដែលនិយាយ អំពី ទីតាំងមូលដ្ឋាន តាមលក្ខណៈ សណ្ឋានដី ដែលបានពោលមកនេះ។ ឆាវកុង បាន ពោលថា៖ «ទីតាំងនោះមានផ្លូវជាច្រើនខ្សែ» ប្រៀប បាននឹងក្រឡាអុកចក្រត្រង្គ។ ហាស៊ី ឲ្យយោបល់ថា៖ «ជាទីតាំងដែលបង្កលក្ខណៈ ឲ្យអន្តរគមនាគមន៍ ទាំង ឡាយដំណើរការបានដោយងាយស្រួល»។


www.facebook.com/7khmer
Fb page : Entertainment And Knowledge

- ប្រការទី 6 ៖ (១). ទីតាំង ដែលមានទម្រង់ជាចំណុចគន្លឹះ ផ្តុំគ្នាជាប់ប្រទេសចំនួនបី,

សេចក្តីអធិប្បាយ៖ ឆាវកុង កំណត់ទីតាំងប្រភេទនេះថា៖ «ប្រទេសយើងនៅជាប់គ្នានឹងប្រទេស របស់ សត្រូវ និង មានប្រទេសទីបីមួយទៀត ដែលមានព្រំប្រទល់នៅជាប់ប្រទេសទាំងពីរនេះ»។ ម៉េងស៊ី ទាញជាតួយ៉ាងអំពី ក្សត្រនៃនគរឆេង ដែលមានភាគឥសាន្ត នៃព្រំដែននគរ របស់ព្រះអង្គ ជាប់នឹងនគរឈើ ខាងលិចជាប់នឹងនគរឈីន ហើយ ខាងត្បូងជាប់នឹងនគរឈូ។

- ប្រការទី 6 ៖ (២). ដូច្នេះ បើសិនជា គាត់បានកាន់កាប់ទីតាំងនេះមុនគេ គាត់នឹងគ្រប់គ្រងលើភាគច្រើន នៃអាណាចក្រទាំងឡាយ ដែលតាំងនៅលើតំបន់នេះបានស្ទើរតែទាំងអស់ ឲ្យបង្អោនចូលមក នៅក្រោមអំណាចបញ្ជាត្រួតត្រារបស់គាត់,

សេចក្តីអធិប្បាយ៖ នរជនណាដែលគេឆ្លាតវៃកាន់កាប់ទីតាំងនេះបាន គេក៏អាចគ្របសង្កត់លើប្រទេស ទាំងឡាយ ដែលតាំងនៅលើតំបន់នេះបានដែរ ថែមទាំង





www.facebook.com/7khmer
Fb page : Entertainment And Knowledge

មានលទ្ធភាព អាចនឹងបង្ខិតបង្ខំភាគច្រើន នៃ ប្រទេសទាំងនោះឲ្យចូលជាសម្ព័ន្ធភាពជាមួយគេថែមទៀត។

ប្រការទី 6 ៖ (៣). ទីនោះ គឺជា ជាមូលដ្ឋាន ដែលមានផ្លូវធំបំបែក។

ប្រការទី **7** ៖ នៅពេល ដែលកងយោធា បានចូលទៅជ្រៅដល់បេះដូង នៃ នគររបស់សត្រូវ ដោយរំលងហួសក្រុងទាំងឡាយ ដែលមានកម្លាំងកងទ័ពខ្លាំងគួរសម ឲ្យនៅពីខាងក្រោយពួកគេវិញនោះ វាជាមូលដ្ឋានដែលមានលក្ខណៈមធ្យ័ត។

*សេចក្ដីអធិប្បាយ៖ វ៉ាងស៊ី ពន្យល់ចំឈ្មោះ ទីតាំងរបៀបនេះដោយបាននិយាយថា៖ «នៅពេលណាដែលកងយោធាចូលទៅដល់ទីកន្លែងឯណានីមួយ ដែលមានលក្ខណៈដូច្នេះ ស្ថានការណ៍របស់គេ ក៏មធ្យ័តខ្លាំងណាស់ដែរ»។*

ប្រការទី **8** ៖ (១). ព្រៃភ្នំ,

*សេចក្ដីអធិប្បាយ៖ ឬហៅដោយសាមញ្ញថាជា «ព្រៃ»។*





www.facebook.com/7khmer
Fb page : Entertainment And Knowledge

ប្រការទី 8 ៖ (២). ទីលំបាក ក្រឡិកក្រឡុក មានចំណោត ភក់ និង ទំនាប នៅតាមគ្រប់ភូមិ ស្រុកទាំងឡាយ ដែលពិបាកនឹងឆ្លងកាត់៖ ទីរបៀបនេះ ត្រូវបានគេហៅថាជា មូលដ្ឋាន ដែលមានលក្ខណៈលំបាកធ្វើការ។

ប្រការទី 9 ៖ ទីតាំង ដែលអាចចូលដល់បានដោយច្រកតូចចង្អៀត ហើយ ដែលយើងអាចត្រឹមតែ គេចខ្លួនចេញបាន តាមច្រកផ្លូវបត់បែន វាបង្កលក្ខណៈឲ្យសត្រូវ ដែលមានគ្នាតិចអាចនឹងមានអានុភាពល្មមគ្រប់គ្រាន់ ដើម្បីនឹងកម្ទេចកងកម្លាំង ដែលមានទ្រង់ទ្រាយធំ របស់ទាហានយើងបាន ទីរបៀបនេះ គេហៅថា មូលដ្ឋានមានលក្ខណៈខ័ណ្ឌព័ទ្ធពីក្រៅចំហាតែខាងក្នុង។

ប្រការទី 10 ៖ ទីតាំង ដែលយើងអាចត្រឹមតែ ការពារខ្លួនពីវិនាសកម្មបាន តាមរយៈការវាយប្រហារ ដោយគ្មានការពន្យាពេល គឺជា មូលដ្ឋាន ដែលមានលក្ខណៈអស់សង្ឃឹម។

*សេចក្តីអធិប្បាយ៖ តាមការពន្យល់របស់ ឆាវកុង មានសេចក្តីថា ទីតាំងនេះ មានលក្ខណៈស្រដៀងគ្នានឹង «ទ្រង់ទ្រាយដូចគេក្រសោបព័ទ្ធជុំវិញ» ត្រង់ចំណុចនេះលើកលែងតែថា គេមិនអាចគេចដោះខ្លួនឲ្យរួចបាន*




www.facebook.com/7khmer
Fb page : Entertainment  And Knowledge

ដោយសារមាន «ភ្នំខ្ពស់ត្រដែតនៅពីខាងមុខ មានទន្លេធំនៅពីខាងក្រោយ ទៅមុខក៏មិនរួច ថយក្រោយវិញក៏មិនបាន»។ ចំណែក ឆិនហាវ ពោលថា៖ «ការស្ថិតនៅលើទីតាំង ដែលអស់សង្ឃឹមរបៀបនេះ វាមានសភាព ដូចជា ការជិះពីលើទូក ដែលលេចធ្លុះធ្លាយ ឬដូចជា សម្ងំនៅក្នុងផ្ទះកំពុងតែឆេះយ៉ាងដូច្នោះដែរ»។

ទូមូ ដកស្រង់សម្តី ពី លីជីង ដែលមានការពិពណ៌នាយ៉ាងច្បាស់អំពីអាការៈនៃយោធាយ៉ាងដូច្នេះថា៖ «សន្មត់ថា កងយោធា ដែលកំពុងចូលលុកលុយវាតត្បាតទឹកដីក្នុងនគររបស់ខ្មាំង ដោយគ្មានជំនួយ ពីអ្នកនាំផ្លូវក្នុងតំបន់ដែលត្រូវលុកលុយនោះទេ ការណ៍នេះ វានឹងធ្លាក់ចូលទៅក្នុងអន្ទាក់ នៃ គ្រោះកម្ម និងរង់ចាំតែសេចក្តីត្រាប្រណីពីសត្រូវតែប៉ុណ្ណោះ។ ច្រកដែលមានចំណោតខ្ពស់ចង្អៀតនៅពីខាងឆ្វេង ភ្នំនៅពីខាងស្តាំ ច្រកផ្លូវដែលប្រកបដោយគ្រោះថ្នាក់ ដែលអាចមានធ្លាក់ទាក់ចងសេះ ដោយខ្សែព្រួរ និង រទេះចម្បាំង ដែលត្រូវផ្ទុកទៅដោយដង្ហក់ធុនធំ គ្មានផ្លូវចំហពីខាងមុខ ផ្លូវដកថយនៅខាងក្រោយត្រូវបានស្ទាក់កាត់




www.facebook.com/7khmer
Fb page : Entertainment  And Knowledge

គ្មានជម្រើសទេ ហើយត្រូវប្រព្រឹត្តិទៅបាន ដោយដាក់តែទាហានមួយជួរប៉ុណ្ណោះ។ ខណៈនោះ នៅមុនពេលរៀបចំជួរទាហានរបស់យើង ដើម្បីនឹងចូលច្បាំង កងកម្លាំងសត្រូវ ដ៏ច្រើនលើសលប់ ក៏ស្រាប់តែមកដល់ភ្លាមៗ តែម្តង។ បើត្រូវសម្រុកទៅមុខ យើងមិនអាចមានពេលដកដង្ហើមសម្រាកយកកម្លាំងបានទេ, បើត្រូវដកថយមកវិញ យើងក៏គ្មានជម្រកស្នាក់អាស្រ័យ។ យើងត្រូវស្នាក់អាស្រ័យនៅលើទីតាំងរួមជាមួយសត្រូវ តែបើគ្មានជោគជ័យទេ ត្រូវនៅតាំងជំហរត្រៀមការពារខ្លួន ក្នុងចំណោមយើងទាំងអស់គ្នានេះ គ្មាននរណាម្នាក់មានពេលសម្រាកទេ។ បើយើងប្រកាន់ខ្ជាប់នូវទីតាំងរបស់យើង យ៉ាងបែបសាមញ្ញ ពេញមួយថ្ងៃទៅមួយថ្ងៃ រហូតដល់ពេញមួយខែ ចេះតែរំលងទៅល្អិកណា ដែលយើងធ្វើចលនា ល្អិកនោះយើងត្រូវតែបន្តការពារទល់នឹងការវាយប្រហារពី សត្រូវទាំងពីខាងមុខ និង ពីខាងក្រោយជានិច្ច។ បើស្ថិតនៅក្នុងភូមិស្រុកប្រកបដោយ លក្ខណៈសោះសូន្យ ខ្សត់ទឹក និង រុក្ខជាតិ កងយោធាខ្វះខាតនូវរបស់ចាំបាច់សម្រាប់ជីវិតរស់នៅ





www.facebook.com/7khmer
Fb page : Entertainment And Knowledge

សេះក៏ល្អិតល្ហៃអស់កម្លាំង ហើយមនុស្សក៏នឿយហត់ រាល់ធនធានដែលជាកម្លាំង និង បំណិន ក៏ទៅជាអសារឥតការ ច្រកផ្លូវក៏តូចចង្អៀតក្រៃលែង សូម្បីសត្រូវទុកទាហានតែម្នាក់ឲ្យនៅយាមឃ្លាំមើល ក៏អាចចាំសង្កេតយកការណ៍ កងទ័ពយើងបានដល់ មួយម៉ឺននាក់ រាល់មធ្យោបាយក្នុងការធ្វើប្រទូស្តរាយ វាស្ថិតនៅក្នុងកណ្តាប់ដៃរបស់សត្រូវអស់ទៅហើយ រាល់ទីកន្លែងតាមទីតាំងទាំងឡាយ ត្រូវបានធ្វើឲ្យបាត់បង់ដោយយើងខ្លួនឯង៖ នៅក្នុងសភាពការណ៍ ដ៏គួរឲ្យភ័យខ្លាចនេះ ទោះបីជា យើងមានទាហានក្លាហានបំផុតក៏ដោយ ទោះជាមានអាវុធដ៏មុតស្រួចយ៉ាងណាហើយក៏ដោយ តើគួរត្រូវប្រើប្រាស់យ៉ាងម៉េច ជាមួយនឹងប្រសិទ្ធិភាពយ៉ាងកំសោយរបៀបនេះ?»

និស្សិតទាំងឡាយដែលសិក្សាប្រវត្តិសាស្ត្រក្រិចក៏អាចចងចាំបាននូវការបញ្ចប់ទៅ នៃ ដំណើរប្រព្រឹត្តិទៅរបស់ជនជាតិក្រិចបុរាណ និង ការភ័យខ្លាច នៃ អ្នក ក្រុងអាតែន ស្ថិតក្រោមអំណាចរបស់ នីស្យាស់




www.facebook.com/7khmer
Fb page : Entertainment And Knowledge

និង ដេម៉ូស្តែន (មានសរសេរក្នុង សៀវភៅ Thucydides, VII. 78 sqq.)។

- ប្រការទី 11 ៖ ដូច្នេះ នៅលើមូលដ្ឋាន ដែលមានលក្ខណៈពង្រាយ ចូរកុំច្បាំង។ នៅលើមូលដ្ឋាន ដែលមានលក្ខណៈងាយធ្វើការ ចូរកុំបញ្ឈប់ការច្បាំងឡើយ។ នៅលើមូលដ្ឋាន ដែលមានលក្ខណៈងាយកើតវិវាទ ចូរកុំចូលប្រយុទ្ធ។

សេចក្តីអធិប្បាយ៖ ប៉ុន្តែយកល្អ គួរប្រើឋាមពលរបស់អ្នក ជំនះតែខាងដណ្តើមយកទីតាំង ដែលមានប្រៀបឲ្យបានជាមុនសិនចុះ។ ហេតុនេះហើយ ទើប ឆាវកុង, លីឈាន់ និង អ្នកដទៃទៀត ពោលថា៖ ទោះជាយ៉ាងណាក៏ដោយ បើអ្នកបានដឹងថា សត្រូវបានប្រុងប្រៀបត្រៀមចាំយើងរួចជាស្រេចទៅហើយ ដូចនេះវាជាអំពើឆ្កួតលីលា ដែលនឹងចូលទៅវាយប្រហារពួកវាដោយ ត្រង់ៗ របៀបនេះ។ នៅក្នុងកិច្ចការ (ទាហាន) របស់ ស៊ុនអ៊ូ នាពេលដែលស្តេច ស៊ូលូ នៃ នគរអ៊ូ បានសាកសួរថា ក្នុង ករណីនេះ តើយើងត្រូវធ្វើអ្វីខ្លះ? ស៊ុនអ៊ូបានឆ្លើយថា៖ «ក្បួនដែលត្រូវធ្វើចំពោះមូលដ្ឋាន




www.facebook.com/7khmer
Fb page : Entertainment And Knowledge

ដែលមានលក្ខណៈងាយកើតវិវាទ ដណ្ដើមគ្នា របៀបនេះ គឺថា នរណា ដែលដណ្ដើមកាន់កាប់បាននូវទីតាំងបែបនេះ គឺ មានប្រៀប លើភាគីម្ខាងទៀតហើយ, ក្រាបទូល។ បើសិនជា ទីតាំងបែបនេះត្រូវបានកាន់កាប់ដោយសត្រូវជាមុនទៅហើយ ចូរចងចាំថា ត្រូវវាយប្រហារលើសត្រូវតែម្ដងទៅ។ ចូរល្បួង បញ្ឆោតពួកវាឲ្យចាកចេញពីទីតាំងនោះ ដោយយើងធ្វើពុតជារត់គេចខ្លួន ដោយបង្ហាញឲ្យពួកវាឃើញ នូវទង់បដា និងទូងស្គរ, ត្រូវធ្វើជាស្ទុះស្ទាទៅចាប់យកទីតាំងណាផ្សេងទៀត ដែលសត្រូវ វាមិនអាចទ្រាំមើលការបាត់បង់ដោយសារបានមកយើង, ត្រូវកាច់មែកឈើ មកចងអូសពីក្រោយឲ្យហុយធូលីឡើង, ត្រូវបញ្ឆោតឲ្យច្រឡំបល់ចំពោះភ្នែក និង ត្រចៀករបស់វា, ចូរបំបែកកងកម្លាំងជំឆ្នើមរបស់អ្នក ហើយបង្កប់យ៉ាងសម្ងាត់ចាំវាយឆ្មក់លើពួកវានៅទីតាំងណាមួយ។ ខណៈនោះ គូបដិបក្ខរបស់អ្នកនឹងរត់សម្រុកទៅមុខចូលជួយ ដើម្បីសង្គ្រោះគ្នាវា»។



www.facebook.com/7khmer



Fb page : Entertainment And Knowledge

ប្រការទី 12 ៖ (១). នៅលើមូលដ្ឋាន ដែលមានលក្ខណៈបើកចំហ ចូរកុំព្យាយាមបិទផ្លូវសត្រូវឡើយ។

សេចក្តីអធិប្បាយ៖ ដោយហេតុថា ការខិតខំប្រឹងប្រែងតស៊ូរបស់យើង នឹងទៅជាអសារឥតការ ហើយក៏អាចបញ្ចេញបង្ហាញកងទាហាន ដែលយើងខំបង្កប់ទុកនោះចេញមកឲ្យគេឃើញ ប្រឈមប្រថុយនឹងគ្រោះថ្នាក់ទៅវិញទេ។ មានការបកស្រាយពីរយ៉ាង ចំពោះចំណុចនេះ។ ខ្ញុំសូមយកតាមគំនិត ចាងអ៊ុ។ គំនិតដទៃទៀតផ្សេងពីនេះ គឺ មានការបញ្ជាក់នៅក្នុងស្នាដៃ របស់ ឆាវកុងមានសេចក្តីជាសង្ខេបថា៖ «ចូរទាញ យកកងកម្លាំងរបស់យើងឲ្យមកនៅ ជិតៗ គ្នា និង ប្រមូលផ្តុំគ្នា» ដូចជា៖ បង្ហាញថា មួយភាគធំ នៃ ទាហានរបស់យើងមិនត្រូវបានគេកាត់ផ្តាច់នោះទេ។

ប្រការទី 12 ៖ (២). នៅលើមូលដ្ឋាន ដែលមានផ្លូវធំបំបែកចូររួមដៃជាមួយសម្ព័ន្ធមិត្តរបស់អ្នក។

សេចក្តីអធិប្បាយ៖ ឬក៏ ប្រហែលជា «កងកម្លាំងមកពីសម្ព័ន្ធភាពជាមួយនគរ ដែលនៅជិតខាងគ្នានោះ»។



www.facebook.com/7khmer
Fb page : Entertainment And Knowledge

ប្រការទី 13 ៖ (១). នៅលើមូលដ្ឋាន ដែលមានលក្ខណៈ មធ្យ័ត ចូរប្រមូលផ្ដុំកម្លាំងរបស់អ្នកចេញឆ្មក់ប្លន់ (កំណត់ត្រា អ្នកបកប្រែ៖ ប្លន់យកបន្ទាយសត្រូវ)។

សេចក្ដីអធិប្បាយ៖ នៅក្នុងករណីនេះ លីឈាន់ មាន កំណត់ត្រាយ៉ាងគួរឲ្យចាប់ចិត្តជាសេចក្ដីថា៖ «នៅពេល ដែលកងយោធា ចូលលុកលុយជ្រៅ ទៅក្នុងប្រទេស របស់សត្រូវ សេចក្ដីប្រុងប្រយ័ត្ន ក៏ត្រូវតែមានជាប់ ជានិច្ច ដោយមិនត្រូវធ្វើទុក្ខបុកម្នេញប្រជារាស្ត្រដោយ អំពើអយុត្តិធម៌ជាដាច់ខាត។ បើតាម ឧទាហរណ៍ ជា តឹកតាង របស់ អធិរាជ នៃ រាជវង្សហាន់ កាវស៊ុ វិញ នោះ ទាហានណា ដែលយាត្រាចូលទឹកដីនគរឈីន គឺ បាន ស្ដែងឡើងថា មិនហ៊ានប្រព្រឹត្តិអំពើហឹង្សាលើ ស្ត្រីភេទ ឬ មិនលួចប្លន់របស់មានតម្លៃអ្វីឡើយ។ (គួរ កត់សម្គាល់ថា៖ រឿងនេះ បានកើតឡើងនា ឆ្នាំ២០៧ នៃ គ.ស ហើយ រឿងស្រដៀងគ្នានេះ បានធ្វើឲ្យយើង នឹកអៀនខ្មាសជំនួសទាហានគ្រិះស្ទៀន ដែលបានចូល ទៅដល់ក្រុងប៉េកាំង កាលពី ឆ្នាំ១៩០០ នៃ គ.ស) បើធ្វើ បែបនេះបាន គឺ គាត់បាន ឈ្នះលើចិត្តមនុស្សទាំងអស់



www.facebook.com/7khmer



Fb page : Entertainment And Knowledge

ហើយ។ ខណៈនេះ បើតាមក្បួនជាធរមាន ខ្ញុំគិតថា អំណានពិតប្រាកដ នៃ សេចក្ដីនេះ គឺ មិនមែនត្រឹមតែ មិនឆក់ប្លន់នោះទេ ប៉ុន្តែ គឺ កុំឆក់ប្លន់សោះតែម្ដង»។

តែគួរឲ្យអនិច្ចា ខ្ញុំខ្លាចតែនៅក្នុងឧទាហរណ៍ជាតួយ៉ាងនេះ អារម្មណ៍ដ៏ពិតត្រង់របស់អ្នកអត្ថាធិប្បាយទាំងឡាយបានរត់ចោលការវិនិច្ឆ័យរបស់គាត់បាត់អស់ទៅហើយទេដឹង? នៅចុងក្រោយ ទូមូ មិនមានមាយាការណ៍បៀបនេះទេ។ គាត់ពោលថា៖ «នៅពេលដែលទៅបោះទីតាំង លើមូលដ្ឋានមានលក្ខណៈមធ្យ័តដែលមិនបង្កលក្ខណៈងាយស្រួល ឲ្យបានសម្រុកចូលទៅមុខទៀត ហើយក៏គ្មានលទ្ធភាពអាចនឹងដកថយមកវិញបាននោះ គេគួរតែចាត់វិធានការណ៍ ដើម្បីបន្តការទប់ទល់តទៅទៀត ដោយត្រូវនាំកងកម្លាំងជំនួយបន្ថែម មកពីតំបន់ឯទៀត និង ត្រូវឃ្លាំមើល សត្រូវឲ្យបានជិតដល់បំផុត។

ប្រការទី 13៖ (២). នៅលើមូលដ្ឋាន ដែលមានលក្ខណៈលំបាកធ្វើការ ចូររក្សាក្បួនទ័ពឲ្យមាំមួនខ្ជាប់ខ្ជួន។




www.facebook.com/7khmer
Fb page : Entertainment And Knowledge

សេចក្ដីអធិប្បាយ៖ ឬក៏ បើនិយាយតាមសេចក្ដី ដែលបានពិពណ៌នារួចហើយក្នុងជំពូកទី៨ ប្រការទី២ ថា៖ «ចូរកុំតាំងបន្ទាយអ្វីឡើយ»។

ប្រការទី **14** ៖ (១). នៅលើមូលដ្ឋាន ដែលមានលក្ខណៈខ័ណ្ឌព័ទ្ធពីក្រៅចំហតែខាងក្នុង ចូរកែខៃលៃកល រកឧបាយកល យកមកប្រើប្រាស់។

សេចក្ដីអធិប្បាយ៖ ឆាវកុង ពោលថា៖ «ចូរព្យាយាមអនុវត្ត នូវ ឧបាយកល ចម្លែកៗ» ហើយ ទូអ៊ុ បានអធិប្បាយជាបន្ថែម ទៅលើភាសិតនេះថា៖ «នៅលើទីតាំងរបៀបនេះ ត្រូវប្រឌិតគម្រោងឧបាយ ខ្លះៗ ដែលវាអាចស៊ីគ្នានឹងកាលទេសៈរបៀបហ្នឹង ហើយបើយើងអាចបំភាន់សត្រូវបានសម្រេច នោះយើង ក៏អាចនឹងគេចផុតពីសភាពការណ៍គ្រោះថ្នាក់បានដែរ»។

សភាពការណ៍របៀបនេះ គឺ វាដូចគ្នាមែនទែនទៅនឹងអ្វីដែលបានកើតឡើងកាលពីសម័យហានីបាល់ (Hannibal មេទ័ពក្រិចបុរាណ) ដែលគាត់បានស្ថិតនៅ





www.facebook.com/7khmer
Fb page : Entertainment And Knowledge

ក្នុងចំណោមភ្នំ ដែលព័ទ្ធជុំវិញតាមផ្លូវទៅទីក្រុង កាស៊ីលីនុម (Casilinum ជាទីក្រុងបុរាណមួយរបស់អ៊ីតាលី) និង អាការៈ ដែលគាត់បានធ្លាក់ខ្លួនចូលទៅក្នុងអន្ទាក់សត្រូវ ដែលត្រូវបានដាក់ដោយមេគំនិត ហ្វាបៀស (Quintus Fabius Maximus Verrucosus ជាត្រូកលយុទ្ធរបស់កងទ័ពរ៉ូម៉ាំង)។ កលយុទ្ធ ដែល ហានីបាល់ បានរកឃើញហើយយកមកអនុវត្តក្នុងសង្គ្រាមវាយប្រហារលើសត្រូវរបស់គាត់ គឺហាក់ដូចជា គួរឲ្យចាប់អារម្មណ៍ខ្លាំងណាស់ គឺដូចដែលធានតាន់បានប្រើប្រាស់វាហើយទទួលបានជ័យជំនះតាំងពី៦២ឆ្នាំមុននោះមកម្លេះ (សូមអានជំពូកទី៩ ប្រការទី២៤ ត្រង់សេចក្ដីអធិប្បាយ)។ នាពេលរាត្រីឈានចូលមកដល់ ទាហានរបស់ ហានីបាល់ បានកាត់មែកឈើងាយឆេះទាំងឡាយ យកមកចងរឹតយ៉ាងណែន ជាប់នឹងស្នែងគោឈ្មោល ចំនួន ២,០០០ ក្បាល ហើយក៏បង្កាត់ភ្លើងដុតមែកឈើទាំងនោះឲ្យឆេះឡើង សត្វគោដែលវាឈឺ ភ័យខ្លាចយ៉ាងខ្លាំង ពេលនោះក៏ស្ទុះបោលយ៉ាងលឿនភ្លែតទៅមុខតាមបណ្ដោយច្រកភ្នំ ឆ្ពោះសំដៅទៅរកច្រក ដែលចោមរោមហ៊ុំព័ទ្ធដោយ



www.facebook.com/7khmer

Fb page : Entertainment And Knowledge

ពួកទាហានរ៉ូម៉ាំង។ ទស្សនីយ៍ភាពដ៏របើកសរឆើត នៃចលនា ដោយពន្លឺភ្លើងយ៉ាងតក់ក្រហល់ បានបញ្ចេញជាភេរវសញ្ញា និង ញុះញង់ចិត្តទាហានរ៉ូម៉ាំងឲ្យឆ្ងល់សង្ស័យ ហើយបានដកថយ ពីទីតាំងហ៊ុំព័ទ្ធរបស់ខ្លួនអស់ទៅ ចំណែកទាហាន របស់ ហានីបាល់ ក៏មានឱកាស បានឆ្លងកាត់ជ្រលងភ្នំនោះ ដោយសុវត្ថិភាព។ (សូមមើល Polybius, III. 93, 94; Livy, XXII. 16 17)។

ប្រការទី 14 ៖ (២). នៅលើមូលដ្ឋាន ដែលមានលក្ខណៈអស់សង្ឃឹម ចូរវាយប្រហារចុះ។

សេចក្តីអធិប្បាយ៖ ដូចដែល ចាលីន កត់សម្គាល់ថា៖ «បើ សិនជា អ្នកចូលទៅប្រយុទ្ធ ដោយអស់ពីទំហឹងអានុភាព របស់ អ្នក នោះអ្នកអាចនឹងមានសំណាងសម្រាប់ជីវិតរស់បាន តែបើសិនជា អ្នកផ្កាប់មុខរករត់តែប្រាសអាយុទេ គឺពិតជា រត់ទៅរកសេចក្តីស្លាប់»។

ប្រការទី 15 ៖ (១). នរជនណា ដែលគេហៅថាជា មេដឹកនាំដ៏ចំណាន មានចំណេះចេះដឹងចំណាប់ អំពី វិធីស៊កសៀត



www.facebook.com/7khmer



Fb page : Entertainment And Knowledge

ត្រង់ចំណុចចន្លោះប្រហោង ក្នុងរវាងកម្លាំងទ័ពខាងមុខ និងកម្លាំងទ័ពក្រោយរបស់សត្រូវបាន,

*សេចក្តីអធិប្បាយ៖ បើតាមន័យរបស់ពាក្យ គេអាចនិយាយថា៖ «ចេះវិធីធ្វើឲ្យទ័ពមុខ និងទ័ពក្រោយ (របស់សត្រូវ) ដាច់ទំនាក់ទំនងពីគ្នាបាន»។*

ប្រការទី **15** ៖ (២). ដើម្បីទប់ស្កាត់កិច្ចសហការគ្នា និង គ្នា ក្នុងរវាងកងកម្លាំងទាំងឡាយទាំងតូច ទាំងធំ របស់សត្រូវ, ដើម្បីរាំងខ្ទប់កងកម្លាំង ឆ្នើមៗ របស់សត្រូវមិនឲ្យចូលជួយសង្គ្រោះគ្នាវាបាន, រាំងខ្ទប់ មិនឲ្យនាយទាហាន ទាំងឡាយរបស់សត្រូវ កុំឲ្យវាជួយកែលម្អកូនទាហានរបស់វាបាន។

ប្រការទី **16** ៖ បើសិនជា ពលទាហានខាងសត្រូវ វារូបរួមស្រុះស្រួលគ្នា សត្រូវនឹងគ្រប់គ្រងពលទាហាន របស់ពួកវាទាំងនោះ តាមរបៀបគ្មានសណ្តាប់ធ្នាប់ទៅវិញ។

ប្រការទី **17** ៖ បើពួកសត្រូវ វាសម្លឹងឃើញថា វាមានប្រៀបហើយ វាក៏នឹងធ្វើចលនាឆ្ពោះទៅមុខ បើមិនដូច្នោះទេ ពួកវាឈប់ទ្រឹងនៅនឹងមួយកន្លែង។



www.facebook.com/7khmer
Fb page : Entertainment  And Knowledge

សេចក្តីអធិប្បាយ៖ ម៉ីយ៉ាវឆិន បានភ្ជាប់ករណីនេះជាមួយនឹងអ្វី ដែលបាននិយាយរួចមកហើយនៅខាងលើនោះថា៖ «ការដែលខ្មាំងបានបំបាក់បំបែក កម្ចាត់កម្ចាយ យកឈ្នះលើសត្រូវ របស់វា យ៉ាងដូច្នេះហើយពួកវា ក៏នឹងបរពលរុលរុញទៅខាងមុខទៀត ដើម្បីនឹងចាប់ផ្តើមយកប្រៀបឈ្នះជាបន្ត តែបើសិនជា គ្មានប្រៀបទេ ពួកវានៅត្រង់ណាគឺរក្សាទីត្រង់ហ្នឹងហើយ»។

ប្រការទី 18 ៖ បើមានគេសួរខ្ញុំថា តើត្រូវតស៊ូយកឈ្នះទល់នឹងកម្លាំងសត្រូវ ដ៏រៀបរយច្រើនសន្ធឹក ក្នុងកំឡុងពេលវាលើកព្យុហ៍ទ័ពមកប្រយុទ្ធនោះយ៉ាងម៉េចទៅ? ខ្ញុំនឹងឆ្លើយជូនវិញថា៖ «គឺត្រូវចាប់ផ្តើម ដោយរឹបអូសយកនូវរបស់អ្វី ដែលសត្រូវរបស់អ្នក វាស្រឡាញ់គោរពជាងគេ, ពេលនោះ វានឹងលែងមានឥទ្ធិពលលើអំណាចឆន្ទៈរបស់អ្នកទៀតហើយ»។

សេចក្តីអធិប្បាយ៖ មានមតិជាច្រើន ខុសៗ គ្នា ចំពោះអ្វីដែល ស៊ុនវូ បានចារឹកទុកមកខាងលើនេះ។ ឆាវកុងគិតថា៖ របស់នោះ គឺ «ការមានប្រៀបខាងយុទ្ធសាស្ត្រគឺអ្វី ដែលសត្រូវវាកំពុងពឹងអាស្រ័យ។ ទូមូ ពោលថា៖ «រឿង ៣ប្រការ ដែលសត្រូវសើបស្រើបចិត្ត ចង់តែធ្វើ





www.facebook.com/7khmer
Fb page : Entertainment And Knowledge

និង សម្រេចឲ្យបាននោះ វាពឹងលើ៖ (១). ការដណ្តើមយកទីតាំងដ៏អំណោយផលរបស់យើង, (២). បំផ្លាញដីដាំដុះបង្កបង្កើនផលរបស់យើង, (៣). ការពារខ្សែរយៈទំនាក់ទំនងរបស់វា»។ កម្មវត្ថុរបស់យើង គឺត្រូវទប់ស្កាត់ផែនការរបស់វា តាមទិសដៅទាំងបីនេះឯង ហើយការណ៍នេះ ញ៉ាំងឲ្យសត្រូវតែលតោលឥតទីពឹង។ បើប្រៀបធៀបនឹងជំពូកទី៣ ប្រការទី៣ យើងឃើញថា បើយើងច្បាមដណ្តើមយក ការផ្តួចផ្តើមគំនិត តាមវិធីទាំងអស់នេះហើយ យើងក៏ដូចជា បានដាក់របាំងការពារខ្លួនយើងបានមួយចំណែករួចទៅហើយដែរ។

ប្រការទី 19 ៖ (១). ភាពរហ័សរហួន គឺជា ធាតុសំខាន់ចាំបាច់បំផុត សម្រាប់ការធ្វើសង្គ្រាម៖

សេចក្តីអធិប្បាយ៖ ទាក់ទងនឹងករណីខាងលើនេះ ទូមូបាននិយាយថា៖ «នេះជា ចំណុចបូកសរុប នៃ គោលការណ៍ ដឹកនាំសឹកសង្គ្រាមហើយ» ហើយគាត់បានបន្ថែមទៀតថា៖ «នៅមានការពិត ដែលស៊ីជម្រៅបំផុតជាច្រើនប្រការទៀត នៅក្នុងវិទ្យាសាស្ត្រយោធា និង





www.facebook.com/7khmer
Fb page : Entertainment And Knowledge

នៅក្នុងភារកិច្ច ធំៗ របស់មេទ័ព»។ រឿងខ្លីខាងក្រោម នេះ ត្រូវបាននិទានឡើងដោយ ហាស៊ី គឺបានបង្ហាញនូវ សារៈសំខាន់ចាំបាច់ ដែលមានជាប់មកជាមួយដំណើរ លឿនរហ័ស ក្នុងការងារចម្បាំងរបស់កំពូលមេទ័ពចិន ពីរនាក់។ កាលពី ឆ្នាំ២២៧ នៃ គ.ស ម៉េងតា (ឯកសារ ខ្លះសរសេរថា ប៉េងតាត់) ជាចៅហ្វាយស្រុក ស៊ីនឆឹង
* នៅក្រោមអំណាចអធិរាជ នគរវុយ ព្រះនាមវិនទី (ខាង ឆាវឆាវ)។ ចៅហ្វាយ ស្រុកម៉េងតា មានបំណងនឹងក្បត់ ចុះចូលនឹងសំណាក់នគរស៊ូ (ខាងស៊ុឈ្យូន) ហើយក៏ ទៅ ទាក់ទងជាមួយនឹង ជូកឺល្យាង (ឬ ខុងប៉េង ឬ ខុងម៉េង ឬ ខុងមីង) ដែលជាឧបរាជនៃនគរស៊ូនេះ។ មេទ័ពនគរវុយ ឈ្មោះ ស៊ីម៉ាអ៊ី ដែលកាលនោះ ជាចៅហ្វាយស្រុកវិន ផង បានទទួលដំណឹង អំពី អំពើក្បត់របស់ ម៉េងតា, ភ្លាមនោះ ស៊ីម៉ាអ៊ី ក៏ចេញដំណើរជាមួយទាហាន ដើម្បី ទៅដល់ឲ្យបានមុនអំពើក្បត់របស់ ម៉េងតា ដោយបាន ទាំងឲ្យមនុស្ស ទៅល្បួងបញ្ឆោត ម៉េងតា ជាមុន តាម ពាក្យសម្ដីរាក់ទាក់ស្និទ្ធស្នាល ដូចជាថា ស៊ីម៉ាអ៊ី មិនដឹង
* រឿងអ្វីទាំងអស់។ នាយទាហាន ទាំងឡាយ របស់



www.facebook.com/7khmer

Fb page : Entertainment And Knowledge

ស៊ីម៉ាអ៊ី ចូលទៅរកគាត់ ហើយនិយាយដាស់តឿនថា៖ «ម៉េងតា នៅជិតបង្កើយជាប់ នគរអ៊ូ និង នគរស៊ូ កិច្ចការដែលសំខាន់នោះគឺ ត្រូវស៊ើបអង្កេតឲ្យបានហ្មត់ចត់សិន សឹមយើងចាត់ការ»។ ស៊ីម៉ាអ៊ី បានឆ្លើយតបទៅវិញថា៖ «ម៉េងតា ជាមនុស្សគ្មានគោលការណ៍ទេហើយ យើងគួរតែចេញដំណើរ ទៅចាប់វាដាក់ទោសភ្លាមៗ តែម្តង នៅពេលដែលខ្លួនវា កំពុងតែមិនទាន់ដាច់ស្រេច ទៅខាងនគរណាជាប្រាកដនៅឡើយនេះ និង មុនពេល ដែលវាមិនទាន់ដោះស្រោមមុខលាក់បាំងអំពើក្បត់របស់វាចេញ ! »។

ខណៈនោះតាមរយៈព្យុហ៍ទ័ព ជាស៊េរី គាត់បាននាំទាហាន របស់គាត់ មកដល់ មុខកំពែងស្រុកស៊ីនឆឹង ក្នុងរយៈកាលតែ ៨ថ្ងៃ ប៉ុណ្ណោះ។ ឥឡូវនេះម៉េងតា ទើបតែមុនហ្នឹងបន្តិច បានបញ្ជូនសារសម្ងាត់ទៅឲ្យ ជូកឺលៀង ដែលមានសេចក្តីថា៖ «ស្រុកវ៉ិន ស្ថិតនៅចម្ងាយដល់ទៅ ១,២០០លី ពីទីនេះ។ ទំរាំតែដំណឹងស្តីពី អំពើក្បត់របស់ខ្ញុំ ដឹងដល់ ស៊ីម៉ាអ៊ី ពេលនោះស៊ីម៉ាអ៊ី នឹងចូលទៅទូលសុំរាជានុញ្ញាត ពីស្តេចសិន *




www.facebook.com/7khmer
Fb page : Entertainment  And Knowledge

ប៉ុន្តែយ៉ាងហោចណាស់ ក៏ត្រូវចំណាយពេល មួយខែពេញដែរ មុននឹងមានជំហាន ណាមួយនៃចំណាត់ការនោះនឹងត្រូវបានគេធ្វើឡើង ហើយ នៅពេលនោះស្រុករបស់ខ្ញុំនេះ នឹងមានកម្លាំងមាំមួន រួចជាស្រេចទៅហើយ។ ទន្ទឹមនឹងនេះដែរ សីម៉ាអ៊ី ក៏មុខជា នឹងមិនមកដោយខ្លួនឯងនោះទេ ហើយមេទ័ពរូបណាផ្សេងពីនេះនឹងត្រូវគេបញ្ជូនឲ្យមកតទល់នឹងខ្ញុំនោះ គឺ នឹងមិនមានអ្វី ឲ្យយើងព្រួយសោះឡើយ។ ទោះជាយ៉ាងណាក៏ដោយ ជាបន្ទាប់មក ម៉េងតា ក៏ទៅជាស្រឡាំងកាំងភាន់ភាំង ទាំងឆ្ងល់ថា៖ «គិតទៅ គឺ រយៈពេលតែ ៨ថ្ងៃប៉ុណ្ណឹងសោះ តាំងពីខ្ញុំបានប្រែចិត្ត គិតឈប់ស្វាមីភក្តិជាមួយ សីម៉ាអ៊ី ក៏ស្រាប់តែទាហានគាត់មកដល់ច្រកទ្វារក្រុងនេះ រួចជាស្រេចទៅហើយ។ នេះពិតជាល្បឿនរហ័សមហាអស្ចារ្យណាស់ !»។ រយៈពេល ពីរអាទិត្យក្រោយមក ស្រុកស៊ីនឆឹង ក៏បានបែកទៅហើយម៉េងតាបានដាច់ក្បាល (មាននៅក្នុងស្នាដៃ ជិនស៊ូ ជំពូកទី១)។

ឧទាហរណ៍មួយទៀត៖ កាលពី ឆ្នាំ៦២១ នៃ គ.ស លីជីង ត្រូវបានគេបញ្ជូនពី ស្រុកក្វយចូវ ក្នុងខេត្ត




www.facebook.com/7khmer
Fb page : Entertainment And Knowledge

ស៊ូឈាន់ ឲ្យទៅជួយទប់ទល់ពួកចោរព្រៃ សៀវសៀន ដែលកំពុងតែឡើងដៃ និង ដែលបានតែងតាំងខ្លួនឯងជាស្តេចស្រុកជីងចូវទំនើប ក្នុងតំបន់ហ៊ូប៉េ។ គ្រានោះជាសរទរដូវ ហើយ ទន្លេយ៉ាំងសេ ពេលនោះ មានទឹកជំនន់នៅឡើយ សៀវសៀន មិនដែលទាំងបានយល់សប្តិសោះថា គូសត្រូវរបស់គាត់នឹង ផ្សងព្រេង កាត់ព្រៃកាត់ផ្សៃ កាត់ទន្លេ ចូលមកសោះ ហេតុនេះហើយគាត់មិនបានត្រៀមរៀបចំអ្វី ទុកទប់ទល់ឡើយ។ ប៉ុន្តែលីជីង វិញឯណោះវិញ គាត់បាននាំទាហានចុះឆ្លងទូកទៅ ដោយមិនឲ្យខាតពេលឡើយ ហើយគាត់ចាប់ផ្តើមចេញដំណើរទៅ ពេលនោះមេទ័ពរបស់គាត់ទាំងឡាយបានអង្វរសុំគាត់ ឲ្យពន្យាពេលកុំអាលចេញដំណើរ ឲ្យចាំដល់ពេលទឹកស្រកសិន ព្រោះវា មិនសូវមានគ្រោះថ្នាក់ សឹមចេញដំណើរទៅតែម្តង។ លីជីង ឆ្លើយតបទៅវិញថា៖ «ចំពោះទាហាន ដំណើរលឿនរហ័សបំផុតគឺជាកិច្ចការដ៏សំខាន់ក្រៃលែង! ហើយទាហានទាំងអស់មិនត្រូវខកខានចំពោះឱកាសល្អបែបនេះទេ។ ពេលនេះជាវេលាត្រូវវាយលុកហើយ គឺ វាយលុក ឲ្យបានមុន



www.facebook.com/7khmer
Fb page : Entertainment  And Knowledge

ពេលដែល សៀវសៀន វាបានដឹងថា យើងបានប្រមូលផ្តុំទាហានរួចរាល់។ បើយើង ឆក់យកឱកាសនេះ នៅពេលដែលទឹកទន្លេកំពុងតែឡើងផងនោះយើងនឹងបានបង្ហាញខ្លួន នៅមុខកំពែងក្រុងរបស់វា ដោយធ្វើឲ្យវាស្រឡាំងកាំងមួយរំពេច ប្រៀបដូចជា សម្លេងរន្ទះបាញ់ដែលពុះហ័សខ្ទរខ្ទារ រកតែពេលវេលា នឹងយកដៃខ្ទប់ត្រចៀក ក៏មិនទាន់ដូច្នោះដែរ (សូមមើល សេចក្តីអធិប្បាយជំពូកទី៧ ប្រការទី១៩) នេះគឺជាគោលការណ៍ដ៏សំខាន់បំផុតក្នុងសឹកសង្គ្រាមហើយ។ ទោះបីជាសត្រូវនឹងដឹង អំពី ដំណើររបស់យើងក៏ដោយ វាក៏នឹងត្រូវកេណ្ឌទ័ពរបស់វា តាមដំណើរ តក់ក្រហល់យ៉ាងនេះ ទាហានពួកវាទាំងនោះ ក៏មិនធន់ល្មម ធ្វើជាគូប្រយុទ្ធតទល់ជាមួយទ័ពយើងបាននោះទេ។ ដូចនេះ ផលជ័យជំនះ ដ៏ពេញលេញ ក៏នឹងនៅតែជារបស់យើងដដែលនេះឯង»។ អ្វីៗ ក៏បានកើតឡើង ដូចដែលគាត់បានព្យាករណ៍ទុក ហើយ សៀវសៀន ក៏បានចុះចាញ់, ចំណុចនេះ ត្រូវតែបែងចែក ឲ្យបានដាច់ស្រឡះថា មនុស្សរបស់គេ (សៀវសៀន) គឺ ត្រូវបានលើកលែង




www.facebook.com/7khmer
Fb page : Entertainment  And Knowledge

ទោសឲ្យ ហើយ មានតែគេ (ស្បៀវស្បៀន) ម្នាក់ឯងគត់ ដែលទទួលទោសប្រហារជីវិត។

ប្រការទី 19 ៖ (២). ចូរដណ្ដើមយកប្រៀបលើចំណុច ដែលសត្រូវមិនមានភាពរួចរាល់, ចូរជ្រើសរើសយកវិធីធ្វើការណា ដែលសត្រូវនឹកស្មានមិនដល់ ហើយចូរវាយប្រហារឲ្យចំលើចំណុចណា ដែលសត្រូវមិនបានត្រៀមការពារ។

ប្រការទី 20 ៖ ខាងក្រោមនេះ គឺជា គោលការណ៍ ដែលត្រូវប្រតិបត្តិ ដោយកងយោធាឯណានីមួយ ដែលត្រូវធ្វើការលុកលុយរាតត្បាត៖ ពេលចូលកាន់តែជ្រៅទៅក្នុងទឹកដីនគរណាមួយ ទាហានរបស់អ្នកកាន់តែសាមគ្គីគ្នា គឺ កាន់តែប្រសើរឡើង, បើធ្វើដូចនេះបាន ទាហានខ្មាំងនឹងមិនអាចមានអំនួតលើអ្នកបានទេ។

ប្រការទី 21 ៖ ចូរចេញប្លន់ យកស្បៀង នៅក្នុងភូមិ ស្រុកសំបូរភោគផលដំណាំ ដើម្បីផ្គត់ផ្គង់ចំណីអាហារ ឲ្យទាហានរបស់អ្នក។





www.facebook.com/7khmer
Fb page : Entertainment And Knowledge

សេចក្តីអធិប្បាយ៖ សូមប្រៀបធៀបនឹងជំពូកដដែល ប្រការទី១៣។ លីឈាន់ មិនបានចារ ជាកំណត់ត្រា នៅប្រការនេះផងទេ។

ប្រការទី **22** ៖ (១). ចូរសិក្សា ដោយប្រុងប្រយ័ត្ន ចំពោះ សុខុមាលភាព នៃ ពលទាហានរបស់អ្នក,

សេចក្តីអធិប្បាយ៖ សម្រាប់ពាក្យថា «សុខុមាលភាព» វ៉ាងស៊ី ចង់និយាយថា៖ «ចូរចិញ្ចឹមដោយចូលចិត្តពួកគេ ចូរបណ្តោយ តាមចិត្តសប្បាយរបស់ពួកគេ, ចូរបើក របប ឲ្យពួកគេបានបរិបូរណ៍ នូវ ចំណីអាហារ និង ទឹក ហើយ ចូរថែរក្សាពួកគេជាលក្ខណៈទូទៅ»។

ប្រការទី 22 ៖ (២). ហើយចូរកុំហួតពន្ធ លើសកំណត់ពីពួក គេ។ ចូរធ្វើវិវេគ ប្រមូលឋាមពល និង ផ្សំផ្គុំកម្លាំងរបស់អ្នក។

សេចក្តីអធិប្បាយ៖ លោកឆិន (ម៉ីយ៉ាវឆិន ឬ ឆិនហាវ?) នៅចងចាំបានព្រឹត្តិការណ៍មួយខ្សែ ដែលកើតមាន នា ឆ្នាំ២២៤ មុន គ.ស ដែលព្រឹត្តិការណ៍នោះ ត្រូវបាន បង្កើត ឡើងដោយមេទ័ពដ៏ល្បីឈ្មោះ វ៉ាងឈាន ដែល



www.facebook.com/7khmer



Fb page : Entertainment And Knowledge

មានទាហានដ៏មានវិសាលភាពខ្លាំងពូកែអស្ចារ្យ ហើយ មានវិភាគទានយ៉ាងធំធេង ចំពោះ ជ័យជំនះ របស់ ព្រះចៅអធិរាជទីមួយ។ គាត់បានដឹកនាំទ័ព ចូលលុកលុយទឹកដីនគរឈូ ហើយចំណែក ពួកនគរឈូ បាន កេណ្ឌទ័ពជាសាកលយោធា ដើម្បីមកច្បាំងទប់ទល់នឹង គាត់។ ក៏ប៉ុន្តែ មិនចាំបាច់មានការសង្ស័យអ្វីឡើយ អំពី សតិអារម្មណ៍ នៃ កងទ័ព របស់គាត់នោះ, គាត់បាន បដិសេធ មិនព្រមចូលច្បាំង ហើយនៅតែតាំងខ្ទាប់ក្នុង បន្ទាយ ការពារយ៉ាងមាំមួនដដែល។ ជាការអសារ ឥតការ ដែលមេទ័ពនគរឈូ បានព្យាយាមញុះញង់ ជម្រុញឲ្យគាត់ចូលច្បាំង ពីមួយថ្ងៃ ទៅមួយថ្ងៃ វាំងឈាន រក្សាការតាំងខ្ទាប់នៅតែក្នុងបន្ទាយ គឺ មិន ចេញមកខាងក្រៅសោះ ប៉ុន្តែគាត់បានយកអស់ពេល វេលា និង ថាមពល របស់គាត់ ដើម្បីធ្វើសតិអារម្មណ៍ និង កសាងទំនុកចិត្តឲ្យកូនទាហានរបស់គាត់។ គាត់ យកចិត្តទុកដាក់គិតថា ពួកគេគួរតែមានអាហារ សមរម្យ គាត់បានចែករំលែកអាហារជាមួយពួកគេ ចែករំលែកគ្រឿងប្រដាប់សម្រាប់ងូតទឹក ហើយប្រើប្រាស់





www.facebook.com/7khmer
Fb page : Entertainment And Knowledge

រាល់គោលវិធី នៃ សុភវិនិច្ឆ័យមិនប្រកាន់ទោសអរូស ដំណើរ ដើម្បីផ្សារភ្ជាប់ពួកគេឲ្យចូលក្នុង ធម៌ស្វាមីភក្តិ និង រួមគ្នាជាផ្លូវតែមួយ បានក្លាយជាកងឯកភាព សុខុដុមរម្យនា។ ពេលវេលាចេះតែកន្លងផុតទៅ គាត់បានប្រាប់មនុស្សជំនិតម្នាក់របស់គាត់ឲ្យតាមដានមើលថាតើពលទាហានទាំងនោះ គេកំសាន្តសប្បាយតាមវិធីណាខ្លះ?។ ចម្លើយ គឺថា ពួកគេបានលេងចំបាប់គ្នាដោយថ្លឹងទម្ងន់ និង លោតចម្ងាយ។ នៅពេលដែលវ៉ាងឈាន បានឮថា ពួកគេចាប់ផ្ដើមខិតខំធ្វើអត្តពលកម្ម តាមរបៀបដូច្នេះហើយ គាត់ក៏យល់បានថាស្មារតីរបស់ពួកគេ បានបើកលាតត្រដាងហើយ ដើម្បីទទួលយកការវាយប្រយុទ្ធតាមតម្រូវការ និង ឃើញថាពួកគេឥឡូវនេះ មានសភាពរួចរាល់ ដើម្បីចូលប្រយុទ្ធហើយ។ នៅពេលនេះ ទាហាននគរឈូ បន្ទាប់ពីមកបបួលច្បាំង ម្ដងហើយ ម្ដងទៀត មិនបានសម្រេច ក៏ដកថយចេញទៅឆ្ងាយតាមទិសខាងកើតដោយសេចក្ដីរង្គៀសចិត្តយ៉ាងជិនឆ្អន់។ ភ្លាមនោះដែរ លោកមេទ័ពវ៉ាងឈាន ក៏ឲ្យទាហានរើបន្ទាយ ហើយដេញតាម



www.facebook.com/7khmer
Fb page : Entertainment And Knowledge

ពួកសត្រូវទាំងនោះ។ ជាផលសម្រេចបានពីសង្គ្រាមនេះ ពួកសត្រូវរបស់ទ័ពវ៉ាងឈាន បានបាក់បែកទ័ពរត់ខ្ចាត់ខ្ចាយ អន្តរាយអស់ទៅ។ ក្រោយមក មិនយូរប៉ុន្មាន នគរឈូទាំងមូលក៏បានចុះចាញ់នគរឈីន ហើយស្តេចហ៊្វូឈូ ក៏ត្រូវគេចាប់ខ្លួនបាន។

ប្រការទី 22 ៖ (៣). ចូរគ្រងរក្សាទាហានរបស់អ្នក ឲ្យនៅតែសកម្មជាប់ជានិច្ច។

សេចក្តីអធិប្បាយ៖ ការណ៍នេះ គឺដើម្បីញុំាងសត្រូវ មិនឲ្យដឹងបានថា អ្នកនៅទីណាពិតប្រាកដ។ ន័យសេចក្តីហាក់ដូចជា រាងខ្វាស់គ្នាបន្តិច តែទោះជាយ៉ាងណាក៏ដោយ ក៏នៅតែមានន័យថា «ចូរញុំាង ឲ្យទាហានរបស់អ្នក មានទំនាក់ទំនងគ្នាយ៉ាងល្អស្មោះសស្អុខុម»។

ប្រការទី 22 ៖ (៤). និង បង្កើតផែនការ ដែលគ្មាននរណាអាចយល់ដឹងបាន។

ប្រការទី 23 ៖ (១). ចូរបញ្ជូនទាហានរបស់អ្នក ឲ្យបានយ៉ាងរហ័ស ទៅកាន់ទីតាំងណាមួយ ដោយកុំធ្វើឲ្យមានលក្ខណៈដូចជា ការត់រៀសខ្លួននោះឲ្យសោះ ហើយពួកគេ ក៏នឹង




www.facebook.com/7khmer
Fb page : Entertainment And Knowledge

ពេញចិត្តចូលច្បាំងទាល់តែស្លាប់ខ្លួន។ បើដូនជា ពួកគេនឹងត្រូវប្រឈមមុខជាមួយសេចក្តីស្លាប់ ក៏គ្មានអ្វីដែលថា ពួកគេសម្រេចមិនបាននោះទេ។

សេចក្តីអធិប្បាយ៖ ចាងអ៊ី ដកស្រង់សម្តីរបស់ វ៉ីល្បៅវអ៊្វ (ជំពូកទី៣) ដែលជាទីពេញចិត្តរបស់គាត់ថា៖ «បើដូនជា មានបុរសម្នាក់ ត្រាច់ចរលើលាកាន់ដាវដើរនៅតាមទីផ្សារហើយមនុស្សដទៃទៀតគេនាំគ្នាដេញគាត់ចេញចំពោះខ្ញុំវិញ គឺ មិនទុកឲ្យ មនុស្សឯកាម្នាក់នេះរងអំពើរបៀបហ្នឹងឡើយ មនុស្សម្នាក់នេះមានសេចក្តីក្លាហានឯមនុស្សដទៃផ្សេងទៀតក្រៅពីនេះ គឺ ពិតជាកំសាកគួរឲ្យស្អប់ខ្ពើម។ ការពិត គឺថា មនុស្សចិត្តដាច់ និង អ្នកដែលបានកំណត់តម្លៃជីវិត របស់គេ រួចហើយនោះ គេមិនដែលមានពេល ដើម្បីនឹងភ្ញាក់ផ្អើល ចំពោះ រឿងទាំងឡាយនោះឡើយ»។

ប្រការទី **23** ៖ (២). នាយទាហាន ក៏ដូចជា កូនទាហានដែរ គេនឹងចេញមុខយកកម្លាំង មកពាំង (ទល់នឹងគ្រោះភ័យ) រហូតដល់ទីបំផុត។



www.facebook.com/7khmer
Fb page : Entertainment  And Knowledge

សេចក្ដីអធិប្បាយ៖ ចាងអ៊ី ពោលថា៖ «បើសិនពួកគេបានជា ផ្ទស់ឆ្ពោយ ធ្លាក់ខ្លួន ចូលទៅក្នុងទីតាំងណានីមួយ ដោយភាពឆោតល្ងង់ របស់ពួកគេទាំងអស់គ្នានោះ ពួកគេពិតជា នឹងខំប្រឹងចូលដៃរួបរួមកម្លាំងគ្នាដើម្បីចាកចេញពីទីនោះឲ្យទាល់តែបាន។

ប្រការទី 24 ៖ កងទាហាន នៅពេល ដែលពួកគេធ្លាក់ខ្លួនចូលទៅក្នុងសភាពទីទ័ល អស់សង្ឃឹម ពួកគេបាត់បង់នូវវិញ្ញាណខ្លាចរអាអស់ហើយ។ បើសិនជា គ្មានកន្លែងជ្រកកោនសម្រាប់ពួកគេទេនោះ ពួកគេ ក៏នឹងនៅតែមានគោលជំហររឹងមាំដដែល។ បើជួនជា នៅក្នុងប្រទេសបច្ចាមិត្រវិញនោះ ពួកគេនឹងបង្ហាញចេញមកនូវសភាពក្លាហាន ឡើងមកជួរខាងមុខតែម្ដង។ បើមិនមាននរណាមកជួយទេ ពួកគេក៏នឹងតស៊ូច្បាំងយ៉ាងខ្លាំងក្លាអស់ពីដៃពីជើង។

ប្រការទី 25 ៖ (១). ដូចនេះ ដោយមិនបាច់ចាំប្រាប់ឲ្យចូលត្រៀមទេ ពួកទាហានទាំងនោះ នឹងនៅយាមរំពៃជាប់ជានិច្ចហើយដោយមិនរង់ចាំទាល់តែគេប្រើឡើយ ពួកគេនឹងធ្វើ អ្វីៗទាំងនោះដែលជាឆន្ទៈរបស់អ្នក,




www.facebook.com/7khmer
Fb page : Entertainment And Knowledge

*សេចក្ដីអធិប្បាយ៖ បើតាមន័យរបស់ពាក្យ គឺមានន័យថា៖ «មិនចាំបាច់សុំទេ អ្នកនឹងនៅតែទទួលបាន»។*

ប្រការទី **25** ៖ (២)៖ មិនចាំបាច់ដាក់កម្រិតទេ ពួកគេនឹងស្មោះស្ម័គ្រស្វាមីភក្តិ, មិនចាំបាច់ដាក់បទបញ្ជាទេ ពួកគេទាំងនោះ អាចទុកចិត្តបានហើយ។

ប្រការទី **26** ៖ ចូរដាក់កំហិត ហាមប្រាម កុំឲ្យពួកគេជឿប្រផ្នូលទាំងឡាយឲ្យសោះ ហើយ ចូរបំបាត់ ការពិភាល់សង្ស័យ ដែលពឹងលើមន្តអាគមន៍ អបិយ៍ជំនឿទាំងឡាយឲ្យអស់។ គឺថា គ្មានទុក្ខព្រួយចង្រៃអ្វី ដែលត្រូវភ័យខ្លាចទាំងអស់ លើកលែងតែ សេចក្ដីស្លាប់មកដល់ជាក់ស្ដែងប៉ុណ្ណោះ។

*សេចក្ដីអធិប្បាយ៖ មន្តអាគមន៍ អបិយជំនឿ «នាំឲ្យមនុស្សរវល់តែនឹងពិភាល់សង្ស័យ, ភាពគភ្លើន និង ការភ័យខ្លាចថា យ៉ាងនេះ យ៉ាងនោះ» ទាំងអស់នេះហើយ វាបង្កើតឲ្យមាន ភាពកំសាក និង «នាំឲ្យពួកគេស្លាប់ច្រើនដង មុនសេចក្ដីស្លាប់ពិតប្រាកដ របស់ពួកគេទៅទៀត» (ស្លាប់ទាំងរស់ ដោយសភាពបាក់ស្បាត)។ ទូមូ ដកស្រង់សម្ដីរបស់ ហ៊ាងស៊ីគង់ ជាសេចក្ដីថា៖*




www.facebook.com/7khmer
Fb page : Entertainment And Knowledge

«អំពើអំពាន់ មន្តអាគមន៍ និង មន្តគាថាបាលី ត្រូវតែបានហាមឃាត់យ៉ាងតឹងរ៉ឹងជាដាច់ខាត ហើយ គ្មាននាយទាហានណាម្នាក់ ត្រូវបានអនុញ្ញាតិ ឲ្យស្វែងរកការទស្សន៍ទាយ អំពី រឿងអនាគតរបស់កងទ័ពទេ វាជាអ្វីដែលនាំឲ្យមានសេចក្តីភ័យខ្លាចចំពោះសតិអារម្មណ៍របស់កងទ័ព គឺជា រឿងដែលត្រូវព្រួយបារម្មណ៍។ នេះមានន័យថា បើសិនជាសេចក្តីវារែកចិត្ត និង មន្ទិលសង្ស័យ ត្រូវបានជម្រះ ឲ្យស្អាតចេញពីក្នុងចិត្តគំនិតហើយនោះ ពលទាហានរបស់អ្នក ក៏នឹងមិនស្ទាក់ស្ទើរនៅក្នុងការតាំងចិត្តរបស់ពួកគេ លុះរហូត ទាល់តែស្លាប់ខ្លួន»។

ប្រការទី 27 ៖ បើសិនជា កូនទាហានរបស់អ្នក មិនសូវងប់ងុលនឹងលុយកាក់ខ្លាំងពេកទេ នេះវាមិនមែនមកពីពួកគេស្អប់ខ្ពើមសភាពមានបាននោះទេ, បើសិនជា ជីវិតរបស់ពួកគេរស់នៅមិនបានយឺនយូរនោះទេ គឺមិនមែនមកពីពួកគេមិនពេញចិត្តនឹងទីឃាយុនោះដែរ។




www.facebook.com/7khmer
Fb page : Entertainment And Knowledge

សេចក្តីអធិប្បាយ៖ ត្រង់ចំណុចនេះ ចាងអ៊ី មានកំណាត់ត្រាគួរឲ្យចាប់ចិត្ត ដែលមានសេចក្តីថា៖ «ទ្រព្យសម្បត្តិនិងទីឃាយុ (អាយុវែង) គឺជា អ្វីៗ ដែលសារជាតិមនុស្សទាំងអស់ប្រាថ្នាចង់បានជាធម្មតា។ ដូចនេះ បើពួកគេដុតចោល ឬ លែងគិតគូរ អំពី តម្លៃ នៃ របស់ទាំងអស់នេះ ហើយបែរខ្លួនមកបូជាជីវិតរបស់ពួកគេ គឺ មិនមែន មកពីពួកគេមិនចូលចិត្តរបស់ជាទីប្រាថ្នាទាំងនេះទេ ប៉ុន្តែជារឿងសាមញ្ញងាយយល់ណាស់ គឺថាមកតែពីពួកគេគ្មានជម្រើស»។ ស៊ុនអ៊ូ មានសេចក្តីវាងវៃណាស់ ក្នុងការបញ្ច្រៀតបញ្ចូលចំណុចទាំងនេះបាន ដោយហេតុថា ទាហាន ក៏ជាសារជាតិមនុស្សដែរ គឺ អាស្រ័យលើមេទ័ពទេ ដែលអាចចេះមើលឃើញចេតនារបស់ពួកគេ ដែលមានទំនង គេចចេញពីការប្រយុទ្ធ និង ការចង់មានចង់បាន ហើយ ឃ្លាតចាកពីមាគ៌ាជីវិតទាហានរបស់ពួកគេនោះ។

ប្រការទី **28** ៖ (១). នៅថ្ងៃ ដែលពួកគេទទួលបញ្ជាឲ្យចេញទៅធ្វើសឹកសង្គ្រាម កូនទាហានរបស់អ្នក អាចមានអ្នកខ្លះយំសោក។



www.facebook.com/7khmer

Fb page : Entertainment And Knowledge

សេចក្តីអធិប្បាយ៖ តាមពាក្យជាភាសាចិន គឺ៖ «សោកសង្រេង»។ ពាក្យនេះ ត្រូវបានគេយកមកសរសេរពិពណ៌នា អំពី សេចក្តីទុក្ខសោកយ៉ាងច្បាស់ក្រឡែតថា មិនមែនយំដោយគ្រាន់តែមានទឹកភ្នែកធម្មតានោះទេ។

ប្រការទី 28 (២). មានអ្នកខ្លះនៅអង្គុយច្រងំក់ប្រស់ព្រហ្មសម្លៀកបំពាក់របស់ពួកគេហើយមានអ្នកខ្លះទៀតទម្រេតខ្លួនដោយបង្ហូរទឹកភ្នែកស្រក់មកលើថ្ពាល់របស់គេទៀតផង។

សេចក្តីអធិប្បាយ៖ នេះមិនមែន ពីព្រោះតែ ពួកគេខ្លាចនោះទេ ប៉ុន្តែដូចដែល ឆាវកុង ពោលជាសេចក្តីថា៖ ពួកគេទាំងអស់គ្នានោះបានប្រកាន់យកនូវការតាំងចិត្តដ៏មុះមុត ជ្រើសរើសយកនូវជម្រើស ថាតើ ជ្រើសរើសយកការប្រយុទ្ធក្នុងសង្គ្រាម ឬក៏ ត្រូវស្លាប់ខ្លួន?»។ យើងប្រហែលជា អាចចងចាំបាន នូវ វីរៈជន នៅក្នុងកំណាព្យវីរៈកម្មក្រិច (របស់អ្នកនិពន្ធ Homer កាលពីសតវត្សរ៍ទី៨ មុនគ.ស) ដែលវីរៈជនទាំងនោះបានបង្ហាញនូវវេទនារម្មណ៍ មានសភាពប្រហាក់ប្រហែលនឹងកូនក្មេងអញ្ចឹង។ ចាងអ៊ី ក៏ បាននិយាយដល់ការណ៍ដែលត្រូវបែកគ្នា ប្រកបដោយសេចក្តីសោកសង្រេង នាមាត់




www.facebook.com/7khmer
Fb page : Entertainment And Knowledge

ច្រាំងទន្លេអ៊ី រវាង ជីងកូ និង មិត្តភក្តិ នៅពេលដែល គាត់ ត្រូវបានគេចាត់បញ្ជូន ឲ្យទៅធ្វើគត់ ស្តេចឈីន កាលពីឆ្នាំ២២៧ មុន គ.ស។ ទឹកភ្នែករបស់វីរៈជនទាំងអស់នោះ បានហូរស្រក់ រមៀលចុះមកដូចជាតំណក់ទឹកភ្លៀងអញ្ចឹង នៅពេល ដែលគាត់លាមិត្តរបស់គាត់ចេញទៅ ហើយបានបន្លឺជាវាចា ដូចតទៅនេះថា៖ «ព្យុះចិត្តគំនុំ កំពុងតែបក់បោកក្នុងចិត្ត ភ្លើងគំនុំ គ្មានស្គាល់មិត្តភាព ជើងឯកអ្នកប្រយុទ្ធរបស់មិត្ត កំពុងតែចេញដំណើរទៅហើយគឺទៅរហូតមិនវិលមកវិញទេ»។

ប្រការទី **28** (៣). ក៏ប៉ុន្តែ ចូរទុកឲ្យពួកគេ បានដឹកនាំចិត្តគំនិតរបស់ខ្លួន ចូលមកក្នុងរង្វង់មនសិការវិញ តាមហេតុផលដ៏មានកិត្តយស បន្ទាប់ពី ពួកគេសម្រាកភ្លេចខ្លួនមួយរយៈកន្លងមក ហើយពួកគេ ក៏នឹងចាប់ផ្តើមសម្តែង នូវ សេចក្តីក្លាហានអង់អាច តាមក្បួនយុទ្ធសាស្ត្រ៖ «ឈូ» ឬ «កួយ»។

សេចក្តីអធិប្បាយ៖ សាច់រឿង គឺ មានសេចក្តីដូច្នេះថា ក្បួន «ឈូ» គឺ យកតាមឈ្មោះ របស់ ឈាន់ឈូ ជាអ្នកស្រុក នគរអ៊ូ ជំនាន់ ស៊ុនអ៊ូ នេះដែរ ដែល ឈាន់ឈូ នេះ ត្រូវបាន កុងអ៊ូគ័ង ចិញ្ចឹមទុកប្រើប្រាស់




www.facebook.com/7khmer
Fb page : Entertainment And Knowledge

បើហៅថា ហ្វូលូវ៉ាង នឹងមានគេស្គាល់ច្រើនជាង, កុងអ៊ូគ័ង ចិញ្ចឹម ឈាន់ឈូ ទុកឲ្យធ្វើគត់ស្តេច របស់គាត់ ព្រះនាមវ៉ាងលាវ ដោយប្រើកូនកាំបិតស្នៀតយ៉ាងតូច ស្រួចចុងសងខាង ដែលគាត់បង្កប់ក្នុងពោះត្រីថ្វាយស្តេច ជាក្រយាក្នុងពិធីជប់លៀង។ គាត់បានសម្រេចបំណងមែន ក៏ប៉ុន្តែ ភ្លាមនោះ គាត់ក៏ត្រូវបានអង្គរក្សរក្សាព្រះអង្គ កាប់ចិញ្ចាំ ឲ្យទៅជា កំណាត់ៗដែរ។ ព្រឹត្តិការណ៍នេះបាន កើតឡើងនៅឆ្នាំ៥១៥ មុន គ.ស។

វីរជនម្នាក់ទៀត ឈ្មោះ ឆាវក្វយ (ឬ ឆាវម៉ៃ) បានទាញយកផលចំណេញយ៉ាង ល្អពីក្បួនយុទ្ធសាស្ត្ររបស់គាត់ ដែលធ្វើឲ្យគាត់មានឈ្មោះ បោះសម្លេងតាំងពីរយៈ ពេល ១៦៦ឆ្នាំ មុន ឈាន់ឈូ មកម្លេះ គឺកាលពី ឆ្នាំ៦៨១ មុន គ.ស។ សាច់រឿង គឺ វាដូច្នេះ នគរលូ ត្រូវបាននគរឈី វាយឲ្យចាញ់ ដល់ទៅបីដង ហើយ កំពុងតែសម្រេចបង្កើយសន្ធិសញ្ញា ដើម្បីចុះចាញ់និងប្រគល់ទឹកដីមួយភាគធំទៅឲ្យសត្រូវ ស្រាប់តែពេលនោះ ឆាវក្វយ បានចាប់ខ្លួនស្តេចត្រាញ់ ហ៊ាន់កុង




www.facebook.com/7khmer
Fb page : Entertainment And Knowledge

របស់នគរឈើ នៅពេលដែល ស្តេចត្រាញ់អង្គនេះ នៅឈរលើជណ្តើរអាសនៈបូជា គឺ ឆាវក្វយ បានដក យកកាំបិតស្នៀត មកភ្ជង់ ចំដើមទ្រូង ស្តេចនគរឈើ តែម្តង។ ពេលនោះ គ្មានអង្គរក្សណាម្នាក់ហ៊ានកម្រើក ខ្លួនឡើយ ហើយឆាវក្វយ ទាមទារយកសំណងមកវិញ យ៉ាងពេញលេញ ព្រមទាំងបានប្រកាសថា នគរលូ ត្រូវបានគេធ្វើទុក្ខបុកម្នេញ យ៉ាងអយុត្តិធម៌ ក៏ព្រោះតែ នគរនេះ ជារដ្ឋតូចតាច ហើយទន់ខ្សោយទៀតផង។ ហ៊ាន់កុង នៅពេល ដែលគ្រោះអាសន្នមកដល់ទល់ដូច្នេះ ក៏សុខចិត្តយល់ព្រម តាមការទាមទារនេះ តែម្តងទៅ ខណៈនោះ ឆាវក្វយ ក៏ គ្រវែងកាំបិតរបស់ខ្លួនចោល ហើយក៏វិលចូលទៅកាន់កន្លែង របស់គាត់វិញ នៅក្នុង ចំណោមក្រុមមនុស្ស ដ៏គួរឲ្យភ័យខ្លាច ដោយគ្មានទាំង ប្រែប្រួលទឹកមុខ ពណ៌សម្បុរអ្វី បន្តិចសោះឡើយ។ ដូចដែលបានគិតទុកអញ្ចឹង ក្រោយមក ស្តេចត្រាញ់ នគរឈើ ចង់បដិសេធនូវអ្វី ដែលព្រះអង្គទើបនឹងបាន យល់ព្រមពីការតថ្លៃគ្នា អម្បាញ់មិញនេះ ក៏ប៉ុន្តែ មានទីប្រឹក្សាចំណាស់ ប្រកបដោយ គតិបណ្ឌិតម្នាក់




www.facebook.com/7khmer
Fb page : Entertainment And Knowledge

របស់ព្រះអង្គ ឈ្មោះក្អួនចុង បានចង្អុលប្រាប់ទ្រង់ថា: នេះជានយោបាយខុស ដែល ក្បត់ពាក្យសម្ដីខ្លួនឯង។ នៅទីបំផុត ទង្វើរបស់ ឆាវក្អួយ បានចាត់ការធ្វើឲ្យនគរលូ បានទទួលមកវិញនូវអ្វី ដែលនគរនេះបានបាត់បង់ក្នុងសង្គ្រាមចំនួនបីលើកមកហើយនោះ។

ប្រការទី **29** ៖ (១). កលយុទ្ធវិទូ ដ៏មានជំនាញមែនទែន អាចត្រូវបានគេប្រៀបប្រដូច ទៅនឹង សត្វពស់ស៊ួយចាន។ ឥឡូវនេះ ស៊ួយចាន គឺជា សត្វពស់ ដែលគេឃើញមាននៅភ្នំចាង។

សេចក្ដីអធិប្បាយ៖ «ស៊ួយចាន» មានន័យថា «ភ្លាមៗ» ឬ «យ៉ាងរហ័ស» ហើយរឿងពស់ ដែលត្រូវយកមកជជែកគ្នានេះ គឺ មិនចាំបាច់សង្ស័យឡើយ ចលនារបស់វា មានសភាពបត់បែន រហ័សរហួនណាស់។ តាមសេចក្ដីជាភាសាចិននៅទីនេះ អាចឲ្យយើង ហៅបាន ក្នុងន័យថា៖ «ឧបាយកលយោធា»។

ប្រការទី **29** ៖ (២). បើអ្នកវាយក្បាល របស់វា អ្នកនឹងរងការវាយប្រហារ ពីកន្ទុយរបស់វា, បើអ្នកវាយកន្ទុយ របស់វា




www.facebook.com/7khmer
Fb page : Entertainment And Knowledge

អ្នកនឹងរងការវាយប្រហារពីក្បាលរបស់វា, បើសិនជាអ្នកវាយកណ្តាលខ្លួនរបស់វា អ្នកនឹងរងការវាយប្រហារពីសងខាង គឺពីក្បាល និង ពីកន្ទុយរបស់វាតែម្តង។

ប្រការទី 30 ៖ (១). បើសិនជា មានគេមកសួរថា តើមានទាហានណា អាចស្ម័គ្រចិត្តធ្វើត្រាប់តាមសត្វពស់ សួយចាននេះ បានដែរឬទេ?,

សេចក្តីអធិប្បាយ៖ ដូចដែល ម៉ីយ៉ាវឆិន ពោលថា៖ «តើជាការណ៍ ដែលអាចធ្វើទៅកើតទេ ក្នុងការរៀបចំទ័ពមុខ និង ទ័ពក្រោយ នីមួយៗ ឲ្យពួកគេអាចជួយគ្នាឆ្លើយតបគ្នា ទៅវិញទៅមក បានយ៉ាងរហ័សរហួន ក្នុងការជួយយកអាសារគ្នាវាយប្រហារទៅលើសត្រូវនោះ? បើគិតទៅ ពួកគេទាំងពីរពួកនេះ ប្រៀបដូចជា ផ្នែកទាំងឡាយរបស់អង្គកាយមួយទាំងមូលអញ្ចឹង»។

ប្រការទី 30 ៖ (២). ខ្ញុំពេញចិត្តនឹងឆ្លើយថា៖ «បាន ! » ។ សម្រាប់ទាហាន នគរអ៊ូ របស់យើង ហើយចំណែកទាហាននគរយៀក គឺជា ខ្មាំង។



www.facebook.com/7khmer
Fb page : Entertainment And Knowledge

សេចក្តីអធិប្បាយ៖ សូមប្រៀបធៀបជាមួយ ជំពូកទី៦ ប្រការទី២១។

ប្រការទី 30 ៖ (៣). ហេតុនេះគឺ ប្រៀបបាននឹងពួកគេកំពុងតែឆ្លងស្ទឹង ទន្លេ ដោយជិះទូកជាមួយគ្នា ហើយពេលត្រូវខ្យល់ព្យុះបោកបក់ រុញច្រាន អ្នកទាំងឡាយ ក្នុងទូកនោះក៏ក្លាយមកជាជំនួយការឲ្យគ្នាទៅវិញទៅមក ដូចដែល ដៃខាងឆ្វេង ជួយដៃខាងស្តាំបានយ៉ាងដូច្នោះដែរ។

សេចក្តីអធិប្បាយ៖ ចំណុចនេះ អាចមានសេចក្តីថា៖ បើជួនជា មានសត្រូវពីរនាក់ ជួយយករអាសារគ្នា នាពេលអាសន្នមកដល់ វាជាការជួយបង្កើនកម្លាំងបន្ថែមឲ្យទាហានទាំងសងខាងដូចគ្នា ពួកគេ ត្រូវបានរឹតបញ្ចូលគ្នាជាធ្លុងតែមួយ ដោយសារ រាល់ចំណាងផលប្រយោជន៍ និង អារម្មណ៍មិត្តភក្តិ។ ក៏ប៉ុន្តែ វានៅតែជារឿងជាក់ស្តែង គេតែងដឹងឮជាទូទៅ ដែលថា មានយុទ្ធនាការសឹក ជាច្រើនមកហើយ ដែលបានបរាជ័យ ដោយសារ ភាពខ្វះកិច្ចសហប្រតិបត្តិការ ជាពិសេសករណីទាហានជាប់ក្នុងចំណងសម្ព័ន្ធភាពញ្ញើងតែម្តង។





www.facebook.com/7khmer
Fb page : Entertainment And Knowledge

ប្រការទី 31 ៖ ដូចនេះ វានៅមិនទាន់គ្រប់គ្រាន់ទេ ដើម្បីនឹងយកសេចក្តីទុកចិត្ត ទៅចងចិត្ត (ផ្ញើទុកនឹង) វីរៈជននោះ, វាដូចជាការកប់កង់រទេះចម្បាំងទៅក្នុងដីដូច្នោះដែរ។

សេចក្តីអធិប្បាយ៖ ស្នៀតទាំងអស់នេះគឺដើម្បីទប់ស្កាត់រាល់ទាហានទាំងឡាយណា ដែលចង់ រត់គេចចេញ យើងអាចនៅចងចាំបាន អំពី វីរៈជនសូហ្សាន របស់ទីក្រុងអាតែនបុរាណ ដែលគាត់បានយកយុថ្កាជាប់នឹងខ្លួន នាសម័យសង្គ្រាមប្លាតាយ តាមមធ្យោបាយ ចង លំពែងនោះជាប់នឹងខ្លួនគាត់។ ស៊ុនអ៊ូ ពោលថា ប៉ុណ្ណឹងនៅមិនទាន់គ្រប់គ្រាន់ទៀតគឺត្រូវចាត់ការធ្វើឲ្យការវាយប្រហារតាមមធ្យោបាយ និង យន្តការរបៀបនេះ ដែលសំដៅមកលើយើង មិនអាចប្រព្រឹត្តិទៅបានទៀតផង។ អ្នកនឹងមិនអាចសម្រេចជោគជ័យបានទេ លុះណាតែទាហានរបស់អ្នក មានគោលបំណងស្ថិតស្ថាញ និង សាមគ្គីភាព ជាងនេះទៅទៀត គឺ សហប្រតិបត្តិការដោយស្មើភាពគ្នា។ នេះគឺជា មេរៀន ដែលយើងអាចរៀនបានពីសត្វពស់សួយចាន។




www.facebook.com/7khmer
Fb page : Entertainment And Knowledge

ប្រការទី 32 ៖ គោលការណ៍ ដើម្បីគ្រប់គ្រងកងទ័ព គឺត្រូវបង្កើតឲ្យមានស្តង់ដារ នៃ សេចក្តីក្លាហានមួយ ដែលមនុស្សទាំងអស់គ្នា អាចធ្វើបានគ្រប់គ្នា។

សេចក្តីអធិប្បាយ៖ តាមន័យរបស់ពាក្យ គឺ «ត្រូវធ្វើឲ្យមនុស្សមានសេចក្តីក្លាហាន ស្មើៗ គ្នា (គ្រប់រូបទាហានទាំងអស់) បើធ្វើដូចនេះបាន គឺប្រៀបដូចជាអង្គប្រាណតែមួយ»។ បើសិនជា ត្រូវការបង្កើតកងឯកភាពយោធាណាមួយទាំងមូល នោះគឺ គួរតែត្រូវធ្វើតាមមាត៌ា ដែលជាការសម្រេច និង ស្មាតីដែលថា គ្រប់ភាគ គ្រប់ផ្នែកទាំងអស់ ត្រូវតែមានគុណភាព ដូចៗ គ្នា ឬ ត្រឹមកម្រិតណាមួយ ដែលមិនទាបជាងគំរូស្តង់ដារ ជាក់លាក់ណាមួយជាដាច់ខាត។ សេចក្តីពិពណ៌នាអំពីវែលីងតិនបានបង្ហាញថា មានលក្ខណៈហាក់ដូចជា មិនសូវទទួលបាននូវការដឹងគុណ ពីកូនទាហានរបស់គាត់ ប៉ុន្មានទេ ដោយសារ «ផលអាក្រក់មកពីការបញ្ជាទ័ពរបស់គាត់» មានន័យថាមិនអាចមានអ្វីល្អជាងហ្នឹងទៀតទេ ទោះបីជាថា ការណ៍ប៉ុណ្ណឹងមិនទាន់ល្អគ្រប់គ្រាន់ ក៏ដោយចុះតែក្នុងសភាពការណ៍ជាក់លាក់ដោយឡែកនេះ វាទាម





www.facebook.com/7khmer
Fb page : Entertainment And Knowledge

ទារឲ្យមានការនូវ ឯកភាព យ៉ាងសំខាន់ដោយឡែក ខាងស្មារតី និង សេចក្ដីក្លាហាន។ បើសិនជា គាត់មិន បានគិតឃើញជាមុន នូវ គម្រោងការក្បត់របស់ពួក ទាហានបៃលហ្សិក និង បានដាក់ពួកទាហានទាំងនោះ ឲ្យនៅផ្នែកខាងក្រោយទេ គាត់ក៏នឹងពិតជាត្រូវបាត់បង់ ថ្ងៃជ័យជំនះរបស់គាត់បាត់ទៅហើយ។

ប្រការទី **33** ៖ តើធ្វើយ៉ាងណា ទើបអាចទាញ យកផល ចំណេញយ៉ាងអស់លទ្ធភាពពី ភាពខ្លាំង និង ភាពខ្សោយ បាន? នេះជាសំណួរមួយ ដែលជាប់ទាក់ទងយ៉ាងស្អិតរមួត ជាមួយការប្រើប្រាស់ លក្ខណៈទីតាំងសណ្ឋានដីជ័យភូមិ ឲ្យ បានត្រឹមត្រូវ។

សេចក្ដីអធិប្បាយ៖ ម៉ីយ៉ាវឆិនបកស្រាយជាសេចក្ដីថា៖ «វិធី ដើម្បីជួយទាញយកចំណេញ ពីភាពខុសគ្នា នៃ ភាពខ្លាំង និង ភាពខ្សោយ ហើយចម្រាញ់យកវា ឲ្យមក បម្រើយើងវិញនោះ គឺត្រូវប្រើប្រាស់លក្ខណៈទ្រង់ទ្រាយ សណ្ឋានដីដែលមានមកហើយ តាមចៃដន្យនោះឯង»។ បើសិនជា យើងតាំងទ័ពនៅលើទីតាំងរឹងមាំ (ជាជ័យ





www.facebook.com/7khmer
Fb page : Entertainment And Knowledge

ភូមិ) បានហើយនោះ គឺ វាធ្វើឲ្យទាហានយើងមិនសូវពិបាកនឿយពេកនោះទេ គឺអាច តស៊ូបានយូរទល់នឹងទាហាន ដែលគេឆ្អើមជាងយើង ដែលពួកទាហានឆ្អើមជាងយើងទាំងនោះ តាំងនៅលើទី ដែលមិនសូវមានលក្ខណៈសមប្រកប។ ការមានប្រៀបខាងទីតាំង (ជាជ័យភូមិ) អាចជួយយើង ឲ្យជួយទប់ទល់នឹងឱនភាពនៃ សេចក្ដីស្វាហាប់ និង សេចក្ដីក្លាហានបានផងដែរ។

វរៈសេនីយ៍ឯក ហិនសីសុន ពោលថា៖ «បើនិយាយដល់សៀវភៅអាននិងការបង្រៀនអំពីតាក់ទិចនានាវិញនោះ ខ្ញុំបាក់ចិត្តគិតថាការសិក្សាអំពីលក្ខណៈសណ្ឋានដីទីតាំង គឺ តែងតែត្រូវបាន គេមើលរំលងតាមរយៈនេះហើយ បានជា រឿងកន្លងមកបង្ហាញថាមិនដែលមានភាពចាំបាច់គ្រប់គ្រាន់សមល្មមនឹងឲ្យគេធ្វើការសម្រេចចិត្តជ្រើសរើសយកទីតាំង ណាៗ នោះទេ ... ហើយ បើនិយាយ អំពី ការមានប្រៀបដ៏អស្ចារ្យវិញនោះ គឺវាតែងតែកើតចេញមកពីលក្ខណៈសណ្ឋានដី នេះឯង មិនថាឡើយ ទោះបីជា អ្នកកំពុងតែការពារខ្លួន ឬក៏ វាយប្រយុទ្ធនោះក៏ដោយ ការមានប្រៀប





www.facebook.com/7khmer
Fb page : Entertainment And Knowledge

ទាំងឡាយ គឺ វាកើតចេញមក ពីការចេះប្រើប្រាស់ លក្ខណៈទីតាំងសណ្ឋានដីជ័យភូមិ ដែលមានស្រាប់ពីធម្មជាតិនោះឯង។

ប្រការទី **34** ៖ ដូចនេះ មេទ័ពដែលមានជំនាញ គាត់ដឹកនាំកងទ័ពរបស់គាត់ គឺដូចជាការដែល គាត់ដឹកនាំមនុស្សតែម្នាក់គត់ដូច្នោះដែរ គឺ គាត់ដឹងស្គាល់ និង បង្កើត ឲ្យមានកិច្ចការ អ្វីៗ គ្រប់បែបយ៉ាងបានទាំងអស់។

សេចក្តីអធិប្បាយ៖ ទូមូ ពោលថា៖ «បើប្រៀបធៀបទៅគឺ មានសេចក្តីថា៖ គាត់អាចមានពេលវេលាគ្រាន់នឹងសម្រាកបានខ្លះផង»។

ប្រការទី **35** ៖ វាជាកិច្ចការរបស់មេទ័ពដែលត្រូវមានឱកាសស្ងប់ស្ងាត់ខ្លះ ហើយការណ៍នេះ វាធានាបាននូវអ្វី ដែលគេហៅថា លាក់ការណ៍សម្ងាត់, ឧត្តមភាព និង យុត្តិធម៌ គឺ អ្វីៗទាំងអស់នេះហើយ ដែលវានាំដល់ ភាពមានសណ្តាប់ធ្នាប់។

ប្រការទី **36** ៖ (១). គាត់ត្រូវចេះ លួងលោម បញ្ឆោតនាយទាហាន និង ពលទាហានរបស់គាត់ តាមរយៈការសម្តែង





www.facebook.com/7khmer
Fb page : Entertainment And Knowledge

ចេញមកជាអាការៈខាងក្រៅ និង រាយការណ៍ប្រឌិត ខ្លះៗ ផងដែរ,

សេចក្តីអធិប្បាយ៖ តាមន័យរបស់ពាក្យ គឺមានសេចក្តីថា៖ «ការបំភាន់ភ្នែក និង ត្រចៀករបស់ពួកគេ»។

ប្រការទី 36 ៖ (២). ហេតុនេះហើយ ចូររក្សាទុកពួកគេ ឲ្យស្ថិតនៅក្នុងសភាពអវិជ្ជាជាទូទៅ។

សេចក្តីអធិប្បាយ៖ ឆាវកុង បានផ្តល់ឲ្យយើង នូវគតិបណ្ឌិតភាសិតមួយ ក្នុងចំណោមស្នាដៃទាំងឡាយរបស់គាត់ ជាសេចក្តីថា៖ «មិនត្រូវអនុញ្ញាតិ ឲ្យកងទាហានចូលរួមចំណែក និង ដឹងពុតម្រោងការរបស់អ្នកពីដំបូងឡើយ ពួកគេបានត្រឹមតែចូលរួម ត្រេកត្រអាលជាមួយអ្នក នៅពេលណា ដែលបានលទ្ធផលពេញចិត្ត តែប៉ុណ្ណោះ បានហើយ»។ ការនិយាយថា៖ «ចូរបោកបញ្ឆោតសត្រូវ, នាំពួកសត្រូវឲ្យយល់ខុស និង ធ្វើឲ្យសត្រូវភ្ញាក់ផ្អើល» គឺជា គោលការណ៍មួយក្នុងចំណោមគោលការណ៍ ចម្បងៗ ទាំងឡាយ ដែលត្រូវបានគេនិយាយចំ និងគិតដល់នៅក្នុងសឹកសង្គ្រាម។ ប៉ុន្តែពេល





www.facebook.com/7khmer
Fb page : Entertainment And Knowledge

នេះ តើមានវិធីធ្វើការ ដទៃៗ យ៉ាងណាខ្លះទៀតទៅ បានជាត្រូវបោកបញ្ឆោតកូនទាហានខ្លួនឯងយ៉ាងនេះ? មានមនុស្សជាច្រើន គង់គិតថា ស៊ុនអ៊ូ នេះ ដូចជា ដាច់អហង្ការជ្រុលហួសហេតុពេកហើយ បើតាមសេចក្ដីដែលគាត់បានសរសេរទុកនេះ។

ត្រង់ចំណុចនេះ បើគេបានអានសេចក្ដីកត់ត្រារបស់វរសេនីយ៍ឯក ហ៊ិនដឺសុន ស្ដីពី យុទ្ធនាការសឹកតាមជ្រលងភ្នំ របស់ លោក ស្តូនវ៉ល ជេកសុន មានជាសេចក្ដីថា៖ «ការឈឺចុកចាប់ គ្មានដែនកំណត់ ជាមួយជេកសុន ដែលចេះតែបិតបាំង សូម្បីតែជាមួយនាយទាហាន ដែលជាទីទុកចិត្តរបស់គាត់ក៏ដោយ, គឺថា៖ ចលនារបស់គាត់, ចេតនារបស់គាត់ និង គំនិតរបស់គាត់ បើសិនជា មេបញ្ជាការម្នាក់ណា ដែលមិនសូវបានគិតគូរហ្មត់ចត់វិញនោះ គេនឹងនិយាយចេញមកថា វាជារឿងឥតប្រយោជន៍តែម្ដង. . . ល . . .»។

បើតាមកំណត់ត្រាក្នុងសៀវភៅ ហូវហានស៊ុ មានជាសេចក្ដីថា កាលពី ឆ្នាំ៨៨ នៃ គ.ស ប៉ានចាវ



www.facebook.com/7khmer



Fb page : Entertainment And Knowledge

បានចូលប្រឡូក ធ្វើសង្គ្រាម ក្នុងសមរភូមិ ជាមួយ ពលទាហាន ចំនួន២៥,០០០នាក់ មកពី នគរខូតាន់ និងនគរនៅអាស៊ីភាគកណ្តាលផ្សេងទៀតជាច្រើន ដោយមានបំណងថា នឹងវាយកម្ទេចដែនដី យ៉ាកាន់ តែម្តង។ ស្តេច នៃ នគរគូឆា បានឆ្លើយតបមកវិញ ដោយចាត់បញ្ជូនអគ្គមេបញ្ជាការកងទ័ព របស់ទ្រង់ ឲ្យទៅជួយសង្គ្រោះទីតាំងនោះ ដោយនាំ ពលទាហាន យកមកពីនគរវិនស៊ុ, គូម៉ូ និង វ៉ឺចូវ សរុបទាំងអស់ត្រូវជា ទាហានចំនួន៥០,០០០នាក់។ ប៉ានចាវ បានកោះប្រជុំ នាយទាហានរបស់ខ្លួន រួមទាំងស្តេចនគរខូតាន់ផងដែរ ដើម្បីប្រឹក្សាគ្នា អំពី សឹកសង្គ្រាមនេះ ហើយគាត់ក៏និយាយឡើងថា៖ ពេលនេះ កងទ័ពរបស់យើង មានចំនួនច្រើនលើសលប់ ហើយនៅឡើយតែមិនទាន់ដឹងថា តើធ្វើយ៉ាងណា ដើម្បីនឹងតទល់ជាមួយសត្រូវបាននោះទេ? តាមដំណើរនេះ គម្រោងការ ដែលល្អបំផុតសម្រាប់ពួកយើងនោះគឺត្រូវយើងបំបែកគ្នា ហើយធ្វើជារត់បាក់ទ័ពបែកខ្ញែកទៅតាមទិសតំបន់ដោយ សព្វៗ ខ្លួនទៅចុះ។ ស្តេចនគរខូតាន់ នឹងត្រូវនាំទាហានរត់ទៅតាមទិសខាង




www.facebook.com/7khmer
Fb page : Entertainment And Knowledge

កើត ហើយចំណែកខ្លួនខ្ញុំ នឹងសូមវិលខ្លួនបករត់ទៅទិសខាងលិចវិញ។ ចូរយើងរង់ចាំ រហូតដល់ពេលព្រះស្គរពេលល្ងាចបន្លឺឡើង ហើយពេលហ្នឹង យើងនឹងចាប់ផ្តើមធ្វើអ្វី ដែលយើងបានសន្មតគ្នាទុកនេះ។ ចំណែកប៉ានចាវ វិញ បានលួចដោះលែងឈ្លើយសឹក ដែលគាត់បានទុកជីវិត ឲ្យនៅរស់យ៉ាងសម្ងាត់ ហើយ (មានចេតនា) ឲ្យពួកអតីតៈ អ្នកឈ្លើយសឹកទាំងនោះបាននាំគម្រោងការខាងលើរបស់ ប៉ានចាវ ទៅប្រាប់ស្តេច នគរគូឆារបស់ខ្លួនផង។ ពេលទទួលបានដំណឹងយ៉ាងនោះស្តេចនគរគូឆា សប្បាយព្រះទ័យណាស់ បន្ទាប់មកក៏ចាត់ទ័ពសេះ ចំណានៗ ចំនួន១០,០០០នាក់ ឲ្យទៅចាំស្កាត់ផ្លូវ ប៉ានចាវ ដែលថា ប្រុងដកថយរត់ទៅទិសខាងលិចនោះ ចំណែក ស្តេចនគរ វិនស៊ុ នាំទ័ពសេះ ៨,០០០នាក់ ឆ្ពោះទៅទិសខាងកើត ដើម្បីចាំស្កាត់ផ្លូវស្តេចនគរខូតាន់។ នៅពេលដែល ប៉ានចាវ បានស៊ើបដឹងថា មេទ័ពទាំងពីររបស់ស្តេចនគរគូឆា បាននាំទ័ពចេញទៅចាំស្កាត់ផ្លូវពួកខ្លួនតាមទិសខាងលិច និង ទិសខាងកើតហើយ គាត់ក៏កោះហៅប្រជុំគ្រប់ផ្នែក គ្រប់កង



www.facebook.com/7khmer



Fb page : Entertainment And Knowledge

ក្នុងទ័ពគាត់ម្ដងទៀត ដោយដាក់ផែនការឲ្យពួកគេជាថ្មីម្ដងទៀត ឲ្យចូលទៅវាយលុក កម្ទេចពួកទាហានយ៉ាកាន់ ដែលនៅសេសសល់ ក្នុងបន្ទាយតែម្ដង។ ប៉ានចាវនាំទាហានដេញកាប់ចាប់យ៉ាងប្រកិតវាយលុកយ៉ាងសាហាវ ធ្វើឲ្យពួកសត្រូវស្លន់ស្លោ រត់ខ្ចាត់ខ្ចាយវង្វេងវង្វាន់។ មានក្បាលខ្មាំងជាង៥,០០០និងសម្ភារសឹកមួយចំនួនធំទៀត រួមទាំងសេះ សត្វពាហនៈផង ដែលត្រូវបានរឹបអូស យកជាជ័យភ័ណ្ឌ។ ចាប់ពីពេលនោះមក ពួកយ៉ាកាន់ ក៏បានចុះចាញ់ នគរគូឆា និង នគរដទៃទៀត ក៏បានដកទាហានតែ រៀងៗ ខ្លួនថយចេញទៅវិញអស់។ បន្ទាប់ពីនោះមក កិត្យានុភាព របស់ប៉ានចាវ ក៏បានល្បីល្បាញយ៉ាងខ្លាំង ពេញភូមិភាគនគរទាំងឡាយនៅដែនដីភាគខាងលិច»។

ក្នុងករណីនេះ យើងឃើញថា មេទ័ពចិន មិនត្រឹមតែរក្សាទុក ឲ្យនាយទាហានរបស់គាត់ ស្ថិតក្នុងភាពងងឹតងងុល មិនដឹងគម្រោងការដាក់លាក់ របស់គាត់ប៉ុណ្ណឹងទេ ប៉ុន្តែជាការពិត គាត់បានចាត់ការតាម




www.facebook.com/7khmer
Fb page : Entertainment And Knowledge

ជំហានយ៉ាងមធ្យ័ត ដោយបំបែកទាហាន របស់គាត់ទាំងនោះ ដើម្បីបំភាន់ដំណើររបស់សត្រូវទៀតផង។

ប្រការទី **37** ៖ (១). តាមរយៈ ការរៀបចំ ប្រែប្រួលកិច្ចកល និង ផ្លាស់ប្តូរផែនការរបស់គាត់,

សេចក្តីអធិប្បាយ៖ វ៉ាងស៊ី គិតថា ចំណុចនេះមានន័យថា មិនមែនជា ការប្រើប្រាស់ឧបាយកល ដដែលៗ នោះទេ។

ប្រការទី **37** ៖ (២). គាត់នូវបានគ្រងរក្សាពួកសត្រូវ មិនឲ្យដឹងឮ អំពី គាត់ពិតប្រាកដទៀតផង,

សេចក្តីអធិប្បាយ៖ ចាងអ៊ី បានដកស្រង់សម្តីពីសំណេរដទៃ ដែលមានសេចក្តីថា៖ «សឹកសង្គ្រាម មានមូលដ្ឋានលើការបោកបំភាន់ ឯសេចក្តីសុចរិតប្រព្រឹត្តិល្អយកមកអនុវត្តប្រើប្រាស់ ជាមួយ សត្រូវមិនកើតទេ។ អ្នកក៏ត្រូវបំភាន់ ទាំងទាហាន របស់អ្នក ផងដែរ។ ចូរញ៉ាំងឲ្យពួកគេធ្វើតាមអ្នក ដោយមិនចាំបាច់ឲ្យពួកគេដឹង អំពីមូលហេតុអ្វីឡើយ»។





www.facebook.com/7khmer
Fb page : Entertainment And Knowledge

- ប្រការទី 37 ៖ (៣). តាមរយៈ ការចល័តបន្ទាយទាហានរបស់គាត់ និង ការជ្រើសរើសយកផ្លូវ ដែលបត់បែនវៀចវេរ, គាត់អាចទប់ស្កាត់សត្រូវ មិនឲ្យវាធ្វើអ្វីបានមុនបំណងរបស់គាត់ឡើយ។

* ប្រការទី 38 ៖ នៅក្នុងឱកាសតឹងតែងបំផុត ដែលសម្រេចជោគវាសនាស្លាប់រស់ មេដឹកនាំទ័ព ធ្វើដូចជាមនុស្សម្នាក់ដែលបានឡើងទៅលើទីខ្ពស់ រួចហើយ ក៏ធាក់ជណ្ដើរចេញឲ្យឆ្ងាយពីខ្លួនគាត់។ គាត់នាំកងទ័ព របស់គាត់ ចូលទៅជ្រៅក្នុងទឹកដី របស់សត្រូវសិន មុននឹង ប្រាប់រឿងសម្ងាត់ទាំងឡាយ ឲ្យពួកគេដឹង។

*សេចក្ដីអធិប្បាយ៖ តាមន័យរបស់ពាក្យ គឺ មានសេចក្ដីថា៖ «ចាំតម្លោះបន្លុអ៊ីស័រ ឬ កេះកៃ» (បាននិយាយពិស្ដារផងដែរ នៅជំពូកទី៥ (ប្រការទី១៥) នេះជា ការប្រកាន់យក នូវដំណើរ តាមជំហាន ន៍ម៉ឹងម៉ាត់ ដែលញ៉ាំងឲ្យទាហានមិនមានលទ្ធភាពនឹងវិលត្រឡប់ទៅផ្ទះវិញបាន ប្រៀបបាននឹង ស៊ាំងអ៊ុ ដែលពន្លិចនាវារបស់គាត់ បន្ទាប់ពី គាត់បានឆ្លងទន្លេ រួចហើយនោះ។ ចាលីន បានយល់ស្របជាមួយ ឆិនហាវ ចំពោះ សេចក្ដី*


www.facebook.com/7khmer
Fb page : Entertainment And Knowledge

ថា៖ «យកឧបាយកលដឹកមុខទាហាន ចំពោះ រាល់ បទបញ្ជា របស់គាត់»។

ប្រការទី 39 ៖ គាត់ដុតទូកហើយបំបែកឆ្នាំងបាយរបស់គាត់ គាត់ធ្វើដូចជា នាយគង្វាល កៀងដេញហ្វូងចៀម គឺ គាត់ ដឹកនាំ ពលទាហាន របស់គាត់ តាមវិធីរបៀបនេះ ឬ វិធី ស្រដៀងនេះ ហើយគ្មាននរណាដឹងបានថា គាត់ធ្វើដំណើរ តាមផ្លូវណា ឬ តាមវិធីណាទេ។

សេចក្តីអធិប្បាយ៖ ទូមូ ពោលថា៖ «ពលទាហាន គេចេះដឹងត្រឹមតែ បទបញ្ជាថា ត្រូវសម្រុកទៅមុខ ឬ ត្រូវដកថយតែប៉ុណ្ណោះ ពួកគេមិនយល់ដឹងទេ នូវ អ្វី ដែលជាគោលបំណង និង ហេតុផល ដែលមានកប់ ក្នុងជម្រៅ នៃ ការវាយប្រយុទ្ធ និង ការដណ្តើមយក ជ័យជំនះនោះ»។

ប្រការទី 40 ៖ គឺ ការគេណ្ឌយកទាហានរបស់គាត់ និង ការ នាំពួកគេសម្រុកចូល ទៅពុះពារគ្រោះមហន្តរាយ, ប្រហែល នេះហើយ ជាការជំពាក់កម្មពារក្នុងកិច្ចការជាមេទ័ព។





www.facebook.com/7khmer
Fb page : Entertainment And Knowledge

សេចក្ដីអធិប្បាយ៖ ខាងលើនេះ ស៊ុនអ៊ូ ចង់និយាយថា បន្ទាប់ពីការយាត្រាទ័ពហើយ គួរតែ កុំដកឃ្លាពន្យាពេលឲ្យសោះក្នុងការធ្វើ អ្វីៗ ដែលជាគោលបំណងជន្លញ់ៈញង់ ឲ្យរសើបរសល់ដល់ដួងចិត្តរបស់សត្រូវ។ ចូរកត់ចំណាំរបៀបដែលគាត់ (ស៊ុនអ៊ូ) និយាយវិលមកចំណុចនេះម្ដងហើយ ម្ដងទៀត។ ក្នុងចំណោមសង្គ្រាមរវាង រដ្ឋ និង រដ្ឋ នៃប្រទេសចិនបុរាណ គឺ មិនបាច់សង្ស័យឡើយ ទាហានណារត់ចោលជួរ ទាហាននោះនឹងត្រូវទទួលទារុណកម្មធ្ងន់ធ្ងរជាងវិន័យកងទ័ពសម័យនេះឆ្ងាយណាស់។

ប្រការទី **41** ៖ (១). វិធានការណ៍ ជារង្វាស់រង្វាល់ ផ្សេងៗគ្នាបានស៊ីគ្នាត្រូវនឹងលក្ខណៈសណ្ឋានដីទីតាំង ទាំង ៩ប្រការខុសៗ គ្នានេះ,

សេចក្ដីអធិប្បាយ៖ ចាងអ៊ី ពោលថា៖ «គេមិនត្រូវប្រកាន់យក ផ្ទត់គំនិតចាស់គម្រឹល ក្នុងការបកស្រាយនូវក្រិត្យក្រម នៃ លក្ខណៈសណ្ឋានដី ជាទីតាំងទាំង៩ ប្រការ ខុសៗ គ្នានេះទេ»។



www.facebook.com/7khmer



Fb page : Entertainment And Knowledge

ប្រការទី 41 ៖ (២). ភាពសមទំនង នៃ គាក់ទិចឈ្លានពាន ឬ គាក់ទិចការពារ និង គោលការណ៍គ្រឹះ នៃ ធម្មជាតិរបស់មនុស្ស គឺ៖ ទាំងអស់នេះហើយ ជាកម្មវត្ថុ ដែលយើងត្រូវយកចិត្តទុកដាក់សិក្សា ឲ្យបានដឹងច្បាស់ជាទីបំផុត។

ប្រការទី 42 ៖ នៅពេល ចូលលុកលុយ ក្នុងប្រទេសសត្រូវ គោលការណ៍ជាទូទៅ គឺ៖ ត្រូវចូលលុកលុយ ឲ្យបានជ្រៅ វានឹងនាំឲ្យ កងទ័ពសាមគ្គីគ្នា យ៉ាងស្អិតរមួត, តែកាលណាចូលលុកលុយ ហើយតែមិនបានចូលជ្រៅ នេះមានន័យថា ជាការដាក់ពង្រាយទៅវិញទេ។

*សេចក្តីអធិប្បាយ៖ សូមប្រៀបធៀប ជាមួយ ប្រការទី ២០ នៃជំពូកដដែលនេះ។*

ប្រការទី 43 ៖ (១). នៅពេល ដែលអ្នកចាកចេញពីប្រទេសរបស់ខ្លួន ហើយដឹកនាំកងទ័ពឆ្លងកាត់ប្រទេសជិតខាង អ្នកនឹងដឹងខ្លួនថា អ្នកស្ថិតនៅលើទឹកដី ដែលសម្រេចជោគវាសនា ស្លាប់ រស់។

*សេចក្តីអធិប្បាយ៖ «ទឹកដីជាទីតាំង» ប្រភេទនេះ ត្រូវបាននិយាយរួចមកហើយនៅក្នុងជំពូកទី៨, ប្រការទី ២*




www.facebook.com/7khmer
Fb page : Entertainment And Knowledge

ក៏ប៉ុន្តែ វាមិនមានលក្ខណៈច្បាស់លាស់ថា វាត្រូវនៅក្នុងចំណោមស្ថានការណ៍ទាំង៩ប្រការ ឬ នៅក្នុងវង្វង់គ្រោះឧបទ្រពចង្រៃទាំង៦ប្រការ ក្នុងជំពូកទី១០។ បើយើងនឹងរកសេចក្តីមកបកស្រាយឲ្យចំវិញនោះ គឺ «ទឹកដីឆ្ងាយដាច់ស្រយាល» ក៏ប៉ុន្តែ យើងអាចប្រើពាក្យនេះបាន បើសិនជា យើងមិនទុកចិត្តអ្នកអត្ថាធិប្បាយទាំងឡាយនោះទេ បានជាពោលដូច្នេះ ដោយសារពាក្យនេះ មិនត្រូវបាន អ្នកអត្ថាធិប្បាយណាម្នាក់យកមកប្រើក្នុងទីនេះផងទេ។

ម៉ីយ៉ាវឆិន ពោលថា៖ «បើទីតាំងប្រយុទ្ធ នៅមិនឆ្ងាយ អាចឲ្យយើងសម្រុកចូលទៅដល់ គេហៅថា ទីតាំងងាយស្រួល ហើយ ទីតាំងដែលនៅមិនជិតល្មម មិនអាចនឹងវិលទៅផ្ទះសម្បែងវិញបានទេនោះ គេហៅថា ទីតាំង ដែលមានលក្ខណៈពង្រាយ ប៉ុន្តែអ្វីដែលជាទីតាំងនៅចន្លោះកណ្តាលទីតាំងទាំងពីរនេះ បើតាមវ៉ាងស៊ី គាត់ហៅថាជា៖ «ទឹកដីដែលត្រូវបានខណ្ឌចែកពាក់កណ្តាលផ្លូវទៅផ្ទះដោយដែនដីនៅចន្លោះ ជាទឹកដី




www.facebook.com/7khmer
Fb page : Entertainment And Knowledge

នៃ រដ្ឋផ្សេងទៀត ដែលយើងត្រូវឆ្លងកាត់ ដើម្បីចូលដល់ទីគោលដៅសង្គ្រាមរបស់យើង។

ដូចនេះ អ្វីដែលសំខាន់សម្រាប់យើងនោះ គឺត្រូវចាត់ការរឿងរ៉ាវរបស់យើង ដែលត្រូវធ្វើនៅទីនោះឲ្យបានលឿនបំផុត»។ គាត់បន្ថែមថា ទីតាំងរបៀបនេះគេតែងតែជួបប្រទះដោយកម្រ ហេតុនេះហើយបានជាវាមិនត្រូវបានដាក់បញ្ចូល យកមកនិយាយ នៅក្នុងទីតាំងទាំង៩ប្រការនោះទេ។

ប្រការទី 43 ៖ (២). នៅពេលណា មានមធ្យោបាយទាក់ទងមកខាងក្រៅបានគ្រប់បែបយ៉ាងទាំង៤ទិស, ទីតាំងបែបនេះគេហៅថា ប្រភេទទីតាំង ដែលមានផ្លូវធំឆ្លងកាត់។

ប្រការទី 44 ៖ នៅពេលណា ដែលអ្នកចូលទៅជ្រៅក្នុងនគរណានីមួយ វាគឺជា ទីតាំងមធ្យ័ត។ នៅពេលណា ដែលអ្នកចូលទៅហើយ មានតែផ្លូវតូចចង្អៀត វាជាទីតាំងដែលពិបាកធ្វើការ។




www.facebook.com/7khmer
Fb page : Entertainment And Knowledge

ប្រការទី **45** ៖ នៅពេលណា ដែលសត្រូវនៅពីខាងក្រោយអ្នក វាមានកិច្ចការពារយ៉ាងមាំទាំ ហើយអ្នកមានតែច្រកផ្លូវតូចចង្អៀតនៅពីមុខ, នេះជាទីតាំងដូចគេក្រសោប។ បើសិនជា គ្មានទីតាំងពឹងពាក់ស្នាក់អាស្រ័យទៀតនោះ វាជា ទីតាំងដែលអស់សង្ឃឹមតែម្តង។

ប្រការទី **46** ៖ (១). ដូចនេះ នៅលើទីតាំង ដែលមានលក្ខណៈពង្រាយ ខ្ញុំប្រាថ្នាសូមឲ្យទាហានរបស់ខ្ញុំមានស្មារតីសាមគ្គីភាព រួមចិត្តគំនិត និង រួបរួមគោលបំណងជាមួយគ្នា។

*សេចក្តីអធិប្បាយ៖ ទូមូលើកឡើងថាចុងក្រោយនេះ ជាសេចក្តីល្អបំផុត ដែលសម្រេចដោយឈរលើជំហរ ការពារខ្លួន ហើយចៀសវាងការវាយប្រយុទ្ធគ្នា (សូមប្រៀបធៀប ជាមួយ សេចក្តីក្នុងជំពូកដដែល ប្រការទី១១)។*

ប្រការទី 46 ៖ (២). នៅលើទីតាំង ដែលងាយស្រួលធ្វើការ ខ្ញុំពេញចិត្តនឹងឃើញថា មានទំនាក់ទំនង យ៉ាងជិតស្និទ្ធ ក្នុងរវាង គ្រប់ផ្នែកទាំងអស់ នៃ ទាហានរបស់ខ្ញុំ។

*សេចក្តីអធិប្បាយ៖ ដូចដែល ទូមូ ពោលថា៖ កម្មវត្ថុ គឺត្រូវការពារទប់ទល់នឹងរឿងរ៉ាវ ដែលអាចនឹងកើតឡើងដោយថាហេតុទាំងពីរពួក គឺ ៖ «(១). ទាហានរបស់អ្នក*




www.facebook.com/7khmer
Fb page : Entertainment And Knowledge

ដែលអាចនឹងវត់ចោលជួរ និង (២). ការវាយប្រហារភ្លាមៗ ដោយទាន់ហាន់ពីពួកសត្រូវ» សូមប្រៀបធៀបជាមួយ ជំពូកទី៧ ប្រការទី១៧។ ម៉ីយ៉ាវឆិន ពោលថា៖ «នៅក្នុងការយាត្រាទ័ព កងទាហានត្រូវតែមានទំនាក់ទំនងស្អិតរមួតរវាងគ្នានឹងគ្នា, នៅក្នុងការតាំងបន្ទាយ កងទាហានត្រូវបន្តទំនាក់ទំនង ឲ្យស្អិតរមួត ពីកំពែងមួយ ទៅ កំពែងមួយទៀត»។

ប្រការទី 47 ៖ នៅលើទីតាំង ដែលងាយកើតវិវាទ ខ្ញុំនឹងចល័តទ័ពក្រោយរបស់ខ្ញុំយ៉ាងលឿនរហ័ស។

សេចក្តីអធិប្បាយ៖ នេះជាការបកស្រាយរបស់ឆាវកុង, ចាងអ៊ី បានទទួលស្គាល់ការបកស្រាយនេះ ដោយបានពោលថា៖ «យើងត្រូវតែ បញ្ជូនទ័ពក្រោយ របស់យើងឲ្យទៅខាងមុខយ៉ាងលឿនរហ័ស ដើម្បីឲ្យ ទាំងក្បាលទាំងកន្ទុយ នៃ កងទ័ពយើង (ឬ ទាំងទ័ពមុខ និង ទាំងទ័ពក្រោយ) បានចូលដល់គោលដៅ»។ ស្ថានការណ៍បែបនេះ កងទាហាន មិនត្រូវនៅអែអង់ត្រង់ផ្នែកខាងក្រោយឡើយ។





www.facebook.com/7khmer
Fb page : Entertainment And Knowledge

ម៉ីយ៉ាវឆិន បានឲ្យនូវសេចក្តីពន្យល់ ដ៏គួរឲ្យចាប់ចិត្តស្រដៀងគ្នានេះដែរថា៖ «សន្មតថា សត្រូវមិនទាន់បានចូលដល់ទីតាំងដែលវាចង់បាននោះទេ ហើយយើងនៅពីក្រោយពួកវា យើងគួរតែ សម្រុកទៅមុខដោយល្បឿនលឿន យ៉ាងអស់ពីសមត្ថភាព ដើម្បីទៅវាយដណ្តើមយកទីតាំងនោះ មុនពួកវា»។ តែផ្ទុយទៅវិញ ឆិនហាវបានសន្មតជាមុនថា សត្រូវបានពេលសម្រាប់រកទីតាំងរបស់វាជាមុនរួចទៅហើយ ដូចបាននិយាយក្នុង ជំពូកទី៦ ប្រការទី១ តាមដែល ស៊ុនវូបានហាមប្រាមយើង មិនឲ្យរហ័ន មកចូលច្បាំងទាំងខ្សោះអស់កម្លាំងនោះទេ។ គំនិតផ្ទាល់ខ្លួនរបស់គាត់អំពីស្ថានភាពទីតាំង បានសំដែងមក មិនសូវច្បាស់ដោយអន្លើ ជាសេចក្តីថា៖ «បើសិន មានទីតាំង ដែលមានអំណោយផលនៅពីមុខអ្នក ចូរបំបែកទាហានមួយកងឲ្យទៅដណ្តើមយកទីតាំងនោះចុះ ពេលហ្នឹង បើសិនជាសត្រូវសម្អាងលើចំនួនទាហានរបស់វា ប្រជែងចូលមកវាយដណ្តើមនឹងយើងដែរនោះ អ្នកត្រូវនាំទ័ពធំសម្រេចបណ្តោយ ខ្លួនយ៉ាងរហ័សទៅនៅពីក្រោយពួកវាហើយ



www.facebook.com/7khmer
Fb page : Entertainment And Knowledge

ចូរសង្ឃឹមថាបានឈ្នះចុះ»។ គាត់បន្ថែមថា វាដូចគ្នាទៅនឹងការណ៍ដែល ចាវស៊ី ដឹកនាំទ័ព ទៅប្រហារទាហាននគរឈីន យ៉ាងដូច្នោះដែរ។

ប្រការទី **48** ៖ នៅលើទីតាំងដែលបើកចំហ ខ្ញុំនឹងយកភ្នែកចាំឃ្លាំមើលជាប់ជានិច្ច។ នៅលើទីតាំង ដែលមានផ្លូវធំបំបែក ខ្ញុំនឹងរួមដៃជាមួយសម្ព័ន្ធមិត្តរបស់ខ្ញុំ។

ប្រការទី **49** ៖ (១). នៅលើទីតាំងមធ្យ័ត ខ្ញុំនឹងព្យាយាម ធ្វើឲ្យប្រាកដថា មានខ្សែបណ្តាញផ្គត់ផ្គង់ភស្តុភា ចូលមកដល់ឲ្យបានគ្រប់គ្រាន់។

សេចក្តីអធិប្បាយ៖ អ្នកធ្វើអត្ថាធិប្បាយ បានប្រកាន់យកចំណុចនេះ ដោយនិយាយសំដៅដល់ ចំណីសត្វ និង ការឆក់ប្លន់ បើមិនដូច្នេះទេ គេអាចកាត់យល់ថា អាចនឹងមានរឿងដូចនេះ គឺ មានការឆក់ប្លន់កើតឡើងចំពោះគមនាគមន៍ដឹកជញ្ជូនជំនួយ ពី ប្រទេសកំណើតមកសមរភូមិមុខ។




www.facebook.com/7khmer
Fb page : Entertainment And Knowledge

ប្រការទី 49 ៖ (២). នៅលើទីតាំងដែលលំបាកធ្វើការ ខ្ញុំត្រូវជម្រុញកងទាហានធ្វើដំណើរ ឲ្យបានលឿនទៅមុខ តាមបណ្ដោយផ្លូវ។

ប្រការទី 50 ៖ (១). នៅលើទីតាំង ដែលមានក្ខណៈ ដូចគេខ្ទប់ ខ្ញុំនឹងបិតផ្លូវដកថយទាំងអស់។

សេចក្ដីអធិប្បាយ៖ ម៉េងស៊ី ពោលថា៖ «ដើម្បីធ្វើឲ្យសត្រូវឃើញថា ហាក់ដូចជា ខ្ញុំចង់ការពារទីតាំងនេះទុកខ្លាំងណាស់តែចំណែកឯបំណងពិតរបស់ខ្ញុំវិញនោះគឺ ត្រូវការស្ទុះវាយសម្រុកចេញជាបន្ទាន់ តាមជួរទ័ពរបស់សត្រូវ»។ ម៉ីយ៉ាវឆិន ពោលថា៖ «ដើម្បីធ្វើឲ្យទាហានរបស់ខ្ញុំ បើកការប្រយុទ្ធ ដោយមិនសង្ឃឹមថានឹងរស់ ដូចជា តំណក់ឈាមចុងក្រោយអញ្ចឹង»។ ចំណែក វ៉ាងស៊ី ពោលថា៖ «ក្រែងលោ ទាហានរបស់ខ្ញុំលួចរត់ ដោយសារសភាពភ័យខ្លាច»។

ទូមូ ចង្អុលចង្អាញថា ចំណុចនេះ មានសេចក្ដីខ្វាស់គ្នាជាមួយនឹងជំពូកទី៧ ប្រការទី៣៦ ដែលមានការនិយាយដល់រឿងដែលថាសត្រូវត្រូវបានឡោមព័ទ្ធ។





www.facebook.com/7khmer
Fb page : Entertainment And Knowledge

កាលពីឆ្នាំ៥៣២ នៃ គ.ស ការហ៊ាន់ ដែលក្រោយមកបានក្លាយជាអធិរាជ និង ត្រូវបានគេតែងតាំងជាសន្តិសិនវូ, កាលនោះ គាត់ត្រូវបានឡោមព័ទ្ធដោយទាហានដ៏ច្រើនសន្ធឹករបស់ អ៊ីឈូឆាវ និង បក្សពួក។ បើប្រៀបធៀបទៅឃើញថា ទាហានរបស់គាត់ (ការហ៊ាន់) មានតិចតួចណាស់ មានតែទាហានសេះចំនួន ២,០០០នាក់ និង ទាហានថ្មើរជើង មិនដល់ ចំនួន៣០,០០០នាក់ ផង។ ខ្សែប្រយុទ្ធទាំងសងខាងខុសគ្នាដូចមេឃ និង ដី ដោយសារគម្លាតឆ្ងាយពីគ្នា ដ៏ច្បាស់ក្រឡែត យ៉ាងច្រើនចំណុច។ ក៏ប៉ុន្តែ ការហ៊ាន់ ជាជំនួសឲ្យការព្យាយាមរត់យករួចខ្លួន ទៅជា ការប្តូរស្មៀត បិតអស់ច្រកចេញទាំងឡាយដោយខ្លួនឯង ដោយចេញហ្វូងសត្វគោ និង ហ្វូងសត្វលា ឲ្យទៅពាំងផ្លូវទាំងអស់នោះ ហើយចងពួកវាភ្ជាប់គ្នាទាំងអស់។ ភ្លាមនោះ នាយទាហាន និង ពលទាហាន របស់គាត់ឃើញថា ចប់អស់ផ្លូវហើយ គឺគ្មានអ្វីក្រៅពីការតស៊ូ ឬក៏ រង់ចាំទទួលសេចក្តីស្លាប់, ពេលនោះ ស្មារតីរបស់ពួកគេ ក៏កម្រើកឆាបឆួលឡើងយ៉ាងមហាស្ចារ្យ ហើយពួកគេ ក៏បើកការវាយសម្រុក





www.facebook.com/7khmer
Fb page : Entertainment And Knowledge

បែបលែងសង្ឃឹមថារស់ ដោយភាពសាហាវឃោរឃៅទៅលើជួរទាហានសត្រូវឲ្យខ្ចាត់ខ្ចាយ និង វិនាស ក្រោមអំណាច នៃ ការវាយប្រហារ របស់ពួកគេ។

ប្រការទី 50 ៖ (២). នៅលើទីតាំង ដែលអស់សង្ឃឹម ខ្ញុំនឹងប្រកាសប្រាប់ពលទាហានទាំងឡាយរបស់ខ្ញុំ អំពី ភាពអស់សង្ឃឹម ក្នុងការថែរក្សាជីវិតរបស់ពួកគេ។

សេចក្តីអធិប្បាយ៖ ទូមូពោលថា៖ «ចូរដុតបង្ខិចសំពាយ និង របស់ណាមិនចាំបាច់ក្នុងគ្រាអាសន្ន, ចូរបោះបង់ឃ្លាំង និង របស់បម្រុងទុកទាំងឡាយ, ចូរលុបអណ្តូងទឹក, ចូរបំផ្លាញចោលនូវចង្ក្រានបាយ, ចូរធ្វើឲ្យទាហានឃើញថា គ្មានអ្វីទាំងអស់សម្រាប់ ជាគ្រឿងប្រដាប់សម្រាប់ការរស់នៅតទៅទៀតទេហើយត្រូវចូលប្រយុទ្ធរហូតទាល់តែស្លាប់ខ្លួន»។ ម៉ីយ៉ាវឆិន ពោលថា៖ ខណៈនេះ ភ័ព្វសំណាង នៃ «ភាពគង់វង្សរបស់ជីវិត» គឺត្រូវបោះបង់ចោល នូវ សេចក្តីសង្ឃឹមថា នឹងបានរស់នៅតទៅទៀត»។ សេចក្តីនេះ វាបានសរុបនូវអ្វីដែលត្រូវនិយាយ អំពី «លក្ខណៈទីតាំង» និង «លក្ខណៈបម្រែបម្រួល» នៃ ទីតាំងទាំងនេះអស់ហើយ។




www.facebook.com/7khmer
Fb page : Entertainment And Knowledge

បើយើងពិនិត្យមើលឡើងវិញ នូវ សេចក្ដីដូច ដែលបាននិយាយមក អំពី ចំណុចដ៏សំខាន់នេះ យើងក៏នឹងមិនធ្លាក់ខ្លួនទៅទទួលរងការវាយប្រហារ ដោយសារតែ ការនិយមតាមបែបសម័យថ្មី ដែលបានឆ្លងមកពីមួយជំនាន់ ទៅមួយជំនាន់ និង គ្មានរបៀបដូចដែលគេកំពុងប្រព្រឹត្តិជាទម្លាប់ តៗ គ្នាមកនេះទេ។ ស៊ុនអ៊ូ បានចាប់ផ្ដើមពន្យល់យ៉ាងរួសរាន់ ក្នុងជំពូកទី៨ ប្រការទី២ ដើម្បីរៀបរាប់ទាំងអស់ ម្ដងមួយៗ អំពី «បម្រែបម្រួល ឬ ភាពទីទៃពីគ្នា» (នៃស្ថានការណ៍) មុននឹងឈានចូលដល់ «ទីតាំងសណ្ឋានដី» ក៏ប៉ុន្តែគាត់បាននិយាយដល់ត្រឹមតែ ៥ប្រការប៉ុណ្ណោះ, ក្នុងនោះមានប្រការទី ៧, ៥, ៨ និង ៩ ដែលត្រូវបានរៀបរាប់ជាបន្តបន្ទាប់រួចមកហើយ ក្នុងជំពូកទី៩ និង ជំពូកទី១០ ដោយបាននិយាយចូល ទាំងលក្ខណៈសណ្ឋានដី ៦ប្រការថ្មីទៀត រួមទាំងគម្រោងការ ៦ប្រការ ដើម្បីឲ្យត្រូវគ្នា។ គ្មានប្រការណាមួយ ក្នុងចំណោមប្រការទាំងអស់នេះ ត្រូវបានគេលើក មកនិយាយចំម្ដងទៀតទេ សូម្បីតែ ប្រការទី១ ក៏ពិបាកនឹងញែកបំបែកពីប្រការទី៤ ដែល

និយាយអំពីលក្ខណៈទីតាំងសណ្ឋានដី ក្នុងជំពូកបន្ទាប់តទៅនេះដែរ។ ទីបំផុតនៅក្នុងជំពូកទី១១ យើងចូលដល់លក្ខណៈទីតាំង ទាំង៩ប្រការ យ៉ាងវិសេសវិសាលដែលអមដោយបទពិពណ៌នា អំពី បម្រែបម្រួលដោយផ្ទាល់។ ការណ៍នេះ បាននាំយើងឲ្យយល់ដល់ប្រការទី១៤ ផងដែរ។ នៅក្នុងប្រការទី៤៣ ដល់ ប្រការទី៤៥ មានការឲ្យនិយមន័យ ថ្មីៗ សម្រាប់ ប្រការទី៥, ៦, ២, ៨ និងទី៩ (ដែលផ្តល់ជូនតាមលំដាប់លំដោយ) ក៏ដូចជាលក្ខណៈទីតាំងទី១០ ដែលត្រូវបានកត់ត្រាក្នុងជំពូកទី៨ និង ជាចុងក្រោយ គឺ បម្រែបម្រួលទាំង៩ប្រការ ត្រូវបានរៀបរាប់ ម្តងមួយៗ នៅទីនោះម្តងទៀត តាំងពីដើមដល់ចប់ ដោយលើកលែងតែ ប្រការទី៥, ៦ និង ទី៧ ដែលមានលក្ខណៈប្លែកពីគេបន្តិចតាំងពីដំបូងមក។

វាក៏ជាការណ៍ ដែលមិនអាចទៅរួចទេ ក្នុងការពន្យល់ហេតុផល អំពី លក្ខណៈសម្គាល់ក្នុងចំណុចនេះ នៅលើអត្ថបទរបស់ ស៊ុនអ៊ូ, រឿងពិតដែលមានមកនេះអាចត្រូវបាននាំមកនិយាយយ៉ាងច្បាស់ជ្រងោថា៖ (១). ជំពូកទី៨ ដែលតាមចំណងជើង វាគួរតែនិយាយ អំពី





www.facebook.com/7khmer
Fb page : Entertainment And Knowledge

បម្រែបម្រួលទាំង៩ប្រការ តែយើងឃើញថា មានការនិយាយរៀបរាប់តែចំនួន៥ប្រការប៉ុណ្ណោះ។ (២). វាជាជំពូកខ្លីខុសពីគេ។ (៣). ជំពូកទី១១ មានចំណងជើងថាទីតាំងសណ្ឋានដីទាំង៩ប្រការ។ ប្រការទាំងនេះ ត្រូវបាននិយាយរៀបរាប់ ច្រើនជាងពីរដង ដែលទន្ទឹមគ្នានេះមានការរៀបរាប់ចំនួនពីរបែប អំពី បម្រែបម្រួលនេះ។ (៤). ប្រវែងជំពូកមិនសមាមាត្រគ្នា គឺ មានប្រវែង វែងជាងពីរដង នៃ ជំពូកដទៃទៀត លើកលែងតែជំពូកទី៩មួយចេញប៉ុណ្ណោះ។

ខ្ញុំ ក៏មិនស្នើសុំ ឲ្យមានបទពិចារណាណាមួយ ដោយសារតែការពិតទាំងនេះទេ ជាបន្តពីការបូកសរុបជាទូទៅនេះ យើងអាចនិយាយថា កិច្ចការរបស់ ស៊ុនអ៊ូនេះ មិនអាចបានមកដល់ដៃរបស់យើងក្នុងទម្រង់ដែលសៀវភៅនេះ បានចេញពីដៃរបស់គាត់ពិតផ្ទាល់នោះទេ ដោយសារជំពូកទី៨មានការខ្វះចន្លោះ និង ហាក់ដូចជា ដាក់ការបរិយាយខុសកន្លែង ចំណែកជំពូកទី១១ ហាក់ដូចជា មានការនិយាយ អំពី រឿងរ៉ាវ ដែលអាច





www.facebook.com/7khmer
Fb page : Entertainment And Knowledge

ត្រូវបានគេបន្ថែមវានាពេលក្រោយមកទៀត ឬ វាត្រូវបានគេដកទៅដាក់នៅកន្លែងផ្សេងទៅវិញ។

ប្រការទី 51 ៖ គឺការតាំងទ័ព ឲ្យឈរជើង នៅលើទីតាំងណានីមួយ នេះហើយ ដែលត្រូវប្រកាន់យកការតស៊ូទប់ទល់ដោយរឹងប៉ឹង ត្រូវវាយប្រយុទ្ធយ៉ាងខ្លាំងក្លាពេលណាដែលគេមិនអាចនឹងរំដោះខ្លួនបានហើយត្រូវធ្វើតាមបញ្ញាយ៉ាងមធ្យ័តនៅពេលដែលគេធ្លាក់ខ្លួនចូលទៅក្នុងគ្រោះភ័យអាសន្ន។

*សេចក្ដីអធិប្បាយ៖ ចាងអ៊ី និយាយសំដៅដល់ការដឹកនាំទ័ពរបស់ ប៉ានចាវ ដែលមានអ្នកស៊ូប្ដូជីវិតដើរតាមគាត់ កាលពីឆ្នាំ៧៣ នៃ គ.ស។ បើតាមសៀវភៅហូវហាន់ស៊ុ បានចារទុកថា ដំណើររឿងនេះ បានកើតឡើងដូចតទៅ៖ «នៅពេលដែល ប៉ានចាវ លើកកងទ័ពទៅដល់ដែនដីសានសាន ស្ដេចគ័ង ដែលជាអធិរាជ នៃអាណាចក្រនេះ បានទទួលស្វាគមន៍គាត់ជាលើកដំបូងក្នុងទឹកដីរបស់ព្រះអង្គ ដោយសុភាពរាបសារ និង ការគោរព ប៉ុន្តែក្រោយមកមិនយូរប៉ុន្មាន អាកប្បកិរិយារបស់ព្រះអង្គ ក៏ប្រែរទៅជាវិបល្លាស ភ្លាមៗ តែម្ដង*




www.facebook.com/7khmer
Fb page : Entertainment And Knowledge

ហើយ ព្រះអង្គក៏ក្លាយទៅជាសោះអង្គើយ និង ខ្ជីខ្ជារ។ ឃើញដូច្នេះ ប៉ានចាវ ក៏និយាយនឹងនាយទាហានរបស់គាត់ថា៖ អស់លោកទាំងអស់គ្នា បានកត់សម្គាល់ខ្លះដែរឬទេថា ចេតនាគួរសមរបស់ស្តេចគាំង បានរលាយបាត់រូបរាងអស់ទៅហើយនោះ? ការណ៍នេះ ជាសញ្ញាបង្ហាញឲ្យឃើញថា ដោយសារតែមានបេសកជន ជាទូត ដែលបានមកពីដែនដីសង្គមមនុស្សយង់ឃ្នង ភាគខាងជើងនោះឯងហេតុដូច្នេះហើយបានជាយើងឃើញថា ស្តេចគាំងនៅវិលវល់ក្នុងដំណើររារែកចិត្ត។ មានគេប្រាប់យើងថា មនុស្សដែលមានសតិបញ្ញាពិតប្រាកដអាចសង្កេតដឹងបាននូវបញ្ហាទាំងឡាយ មុនពេលដែលវាឈានចូលមកដល់ តើមានអ្វីជាងហ្នឹងទៀតនោះ? តើមានសញ្ញាអ្វីខ្លះទៀត ដែលពួកគេបានលេចចេញមកឲ្យយើងឃើញនោះ? ពេលនោះ គាត់បានហៅអ្នកបម្រើម្នាក់ មកជម្រឹតសួរថា៖ តើបេសកជនទាំងនោះ ដែលទើបនឹងមកពីដែនដី ស៊ុងនុ ពីរ បីថ្ងៃមុន គេស្នាក់នៅឯណា? អ្នកបម្រើនោះ ស្រឡាំងកាំងភ័យផងភ្ញាក់ផ្អើលផង ហើយឆ្លោយមាត់ប្រាប់ការពិត។




www.facebook.com/7khmer
Fb page : Entertainment And Knowledge

ប៉ានចាវ បានយកអ្នកបម្រើនោះ ទៅទុកមួយកន្លែង យ៉ាងប្រយ័ត្នប្រយែង ក្រែងវារត់រួច ហើយក៏កោះហៅប្រជុំនាយទាហានរបស់គាត់ទាំង៦៦នាក់ ហើយក៏ចាប់ផ្ដើមសេពសុរាជាមួយគ្នា។ នៅពេល ដែលសុរាជ្រាបចូលដល់ក្នុងខួរក្បាលពួកគេបានបន្តិចហើយ ប៉ានចាវព្យាយាមផ្ញើសតិអារម្មណ៍ពួកគេជាបន្ត ដោយនិយាយទៅកាន់ពួកគេថា៖ អស់លោកទាំងឡាយ, ឥឡូវនេះយើងបានឈានជើង ចូលមកដល់ទឹកដីដាច់ស្រយាលឆ្ងាយផុតពីស្រុកទេសយើងហើយ យើងគួរតែ ស្រវាស្រទេញ ដើម្បីសម្រេចកិច្ចការដុំកំភួន និង ជាកិត្តិយសសម្រាប់ជាប្រយោជន៍ ឲ្យប្រទេសជាតិយើង ផងចុះ។ ពេលនេះមានរឿងកើតឡើងដោយហេតុថាបេសកជនជារាជទូតមកពីដែនដី ស៊ុងនុ បានមកដល់រាជាណាចក្រនេះ កាលពីរយៈកាលពីរ បីថ្ងៃមុននេះដែរហើយលទ្ធផល គឺថា សេចក្ដីគោរពកោតក្រែង ដែលគេធ្លាប់មានចំពោះយើង ដោយសារ ឫទ្ធានុភាពរបស់ផងយើងនោះ បានរលាយបាត់អស់ទៅហើយ។ តើយើងគួរទុកឲ្យ បេសកជនដែនដី ស៊ុងនុ នេះ កេងយក





www.facebook.com/7khmer
Fb page : Entertainment And Knowledge

ចំណេញផលប្រយោជន៍ស្តេចគង់ ពីលើក្បាល របស់យើងឬ? ម្យ៉ាងទៀត ឆ្អឹងរបស់យើង ក៏នឹងក្លាយទៅជាចំណីសត្វចចកនៅលើ វាលខ្សាច់រហោស្ថាននេះ មិនខានទេ។ តើយើងត្រូវធ្វើអ្វីទៀត? ពួកនាយទាហានទាំងនោះ ក៏ឆ្លើយព្រមគ្នាថា: ចូរយើងក្រោកឈរ តាំងជំហរឡើង ដើម្បីពុះពារជំនះគ្រោះកាចចង្រៃ ដែលបៀតបៀនជីវិតរបស់យើង, យើងសុខចិត្តធ្វើ អ្វីៗទាំងអស់ តាមលោកមេទ័ព ទោះរស់ក្តី ទោះស្លាប់ខ្លួនក្តី! (សម្រាប់សេចក្តី ដែលមាន ត នៃរឿងនេះ នឹងមាននៅក្នុងសេចក្តីអធិប្បាយនាជំពូកទី១២ ប្រការទី១ ខាងមុខនេះទៀត)។

ប្រការទី **52** ៖ យើងមិនអាចនឹងចងសម្ព័ន្ធមិត្ត ជាមួយស្តេចនគរជិតខាងបានទេ លុះណាតែ យើងបានយល់ដឹង អំពីចេតនារបស់គេជាមុនសិន។ យើង ក៏មិនអាចនឹងដឹកនាំយាត្រាទ័ព នៅលើស្រុកទេសណា ដែលយើងមិនស្គាល់នោះដែរ លុះត្រាតែយើងដឹង អំពី ព្រៃភ្នំ, អន្លង់, ជ្រោះ, វាលភក់ និង វាលល្បប់។ យើងត្រូវចេះប្រើប្រាស់ការមានប្រៀបខាងធម្មជាតិ តាមរយៈ ការប្រើមគ្គុទ្ទេសក៍ក្នុងតំបន់នោះផងដែរ។




www.facebook.com/7khmer
Fb page : Entertainment And Knowledge

សេចក្ដីអធិប្បាយ៖ ប្រយោគទាំង៣នេះ ត្រូវបានគេលើកមកសរសេរឡើងវិញពីជំពូកទី៧ ប្រការទី១២ ដល់ប្រការទី១៤ ដើម្បីសង្កត់ធ្ងន់នូវសេចក្ដី សំខាន់ៗ ក្នុងជំពូកនេះ អ្នកអត្ថាធិប្បាយហាក់ដូចជាបានគិតដូច្នេះ។ ខ្ញុំពេញចិត្តនឹងយកប្រយោគទាំងនេះមកកែខៃច្នៃតម្រូវ ដើម្បីសម្អាងដល់សំណេរពាក្យពេចន៍ខាងមុខនេះ។

ចំពោះមគ្គុទ្ទេសក៏ក្នុងតំបន់ ស៊ុនអ៊ូ អាចនឹងបន្ថែមសេចក្ដីថា តែងតែមានការផ្សងគ្រោះថ្នាក់ជានិច្ចក្នុងការណ៍ដែលចូលទៅដោយខុសទិសតំបន់ ក៏ដូចជាអំពើក្បត់វៀចវេររបស់ពួកមគ្គុទ្ទេសក៏ ឬ មកពីការយល់ខុសផងដែរ។ ក្នុងកំណត់ត្រាលីវី (ជំពូកទី២២ ប្រការទី១៣) មានសេចក្ដីថា៖ មានគេប្រាប់យើងថា ហានីបាល់ បានបញ្ជាឲ្យបុរសម្នាក់នាំគាត់ចូលទៅក្នុងតំបន់កាស៊ីនំ ដែលមានច្រកផ្លូវសំខាន់ត្រូវទៅដណ្ដើមយក ក៏ប៉ុន្តែ សំនៀងសម្ដីនិយាយ ជាភាសាកាថាចរបស់គាត់មិនសូវច្បាស់ ដោយវាមិនត្រូវនឹងសំនៀងឈ្មោះជាភាសាឡាតាំង នាំឲ្យអ្នកនាំផ្លូវនោះយល់ខុសថា កាស៊ីលីនំ ជាជំនួសឲ្យ កាស៊ីនំ ទៅវិញ ហើយក៏





www.facebook.com/7khmer
Fb page : Entertainment And Knowledge

ត្រឡប់ជា ចាកចេញពីផ្លូវដែលត្រូវ នាំឲ្យគាត់ដឹកនាំទាហានតាមទិសដៅខុសនោះ លុះត្រាតែទៅដិតដល់ទើបដឹងថា វាខុសទេ!

ប្រការទី 53 ៖ ត្រូវកុំធ្វើដឹង កុំធ្វើឮ អំពី នរណាម្នាក់ ដែលត្រូវដូចតាមគោលការណ៍ទាំង ៤ ឬ ៥ ប្រការជាបន្តទៅនេះ ដោយនរជននោះ មិនសមនឹងធ្វើជាអធិរាជសង្គ្រាមទេ។

ប្រការទី 54 ៖ នៅពេល ដែលអធិរាជសង្គ្រាម ចូលវាយប្រហារ រដ្ឋដ៏ខ្លាំងក្លា រឹងមាំណាមួយ ភាពជាមេទ័ពរបស់គាត់បង្ហាញចេញមកដោយ ឯងៗ ក្នុងការទប់ស្កាត់សត្រូវ កុំឲ្យប្រមូលកម្លាំង ជាកងទាហានបាន។ គាត់វាយសន្ធាប់លើសត្រូវរបស់គាត់ ហើយចំណែកឯ សម្ព័ន្ធមិត្តរបស់សត្រូវក៏ត្រូវបានបន្ទុចចង្អាក់ មិនឲ្យទៅចូលរួបរួមជាមួយនឹងសត្រូវនោះទេ។

សេចក្តីអធិប្បាយ៖ ម៉ីតាវធិន (ម៉ីយ៉ាវធិន?) ខិតខំបកស្រាយ សេចក្តីភ្ជាប់ទៅនឹងហេតុផលដែលថា មានផលប៉ះពាល់ ជាប់ទាក់ទងជាបន្តគ្នា ក្នុងភាសាចិនថា៖ «នៅក្នុងការវាយប្រហាររដ្ឋដ៏ខ្លាំងក្លាមួយ បើសិនជាអ្នកអាច




www.facebook.com/7khmer
Fb page : Entertainment And Knowledge

បំបែកកម្លាំងទ័ពនគរនោះបាន អ្នកនឹងមានឧត្តមភាពខាងកម្លាំងកងទ័ពជាងនគរនោះ, បើអ្នកមានឧត្តមភាពខាងកម្លាំងកងទ័ពជាងសត្រូវហើយ អ្នកអាចនឹងវាយសន្ធាប់លើសត្រូវបាន, បើអ្នកវាយសន្ធាប់លើសត្រូវបាន ប្រទេសជារដ្ឋជិតខាងនោះ គង់តែនឹងបាក់បបខ្លបខ្លាច, បើសិនជា ប្រទេសជិតខាងទាំងនោះបាក់បបខ្លបខ្លាចហើយ រដ្ឋដែលមានសម្ព័ន្ធភាពជាមួយខាងបច្ចាមិត្រ ក៏ត្រូវទុចរអាក់មិនចូលរួមដៃធ្វើសង្គ្រាមជាមួយនឹងបច្ចាមិត្រនោះឡើយ»។

សេចក្ដីជាបន្តទៅនេះ ផ្ដល់នូវអត្ថន័យច្បាស់ជាងមុនថា៖ «បើសិនជា នគរដែលរឹងមាំណាមួយបានចុះចាញ់យើងហើយ (គឺ មុនដែលនគរនេះ មានពេលដើម្បីនឹងកោះប្រជុំសម្ព័ន្ធមិត្តរបស់ខ្លួនបាន) នោះ រដ្ឋដែលទន់ខ្សោយជាង ក៏នឹងលែងហ៊ានអើពើ ជាមួយ រដ្ឋដែលរឹងមាំនោះដែរ ហើយក៏ទប់ខ្លួនមិនបញ្ជូនទ័ព ឲ្យទៅជួយទេ»។



www.facebook.com/7khmer
Fb page : Entertainment And Knowledge

តែចំណែក ឆិនហាវ និង ចាងអ៊ី បានបកស្រាយប្រយោគនេះ តាមវិធីផ្សេងទៅវិញ។ អ្នកទីមួយគឺ ឆិនហាវ ពោលថា៖ «អ្នកដែលមានអំណាចនោះអាចថាជា ស្តេចក៏ថាបាន បើសិនជា ទ្រង់វាយប្រហារទៅលើប្រទេស ធំៗ នោះ ព្រះអង្គមិនអាចនឹងប្រមូលទាហានបានគ្រប់ល្មមនោះទេ គឺទ្រង់ត្រូវតែពឹងពាក់លើជំនួយពីខាងក្រៅ ត្រឹមកម្រិតណាមួយ បើទ្រង់ឈប់លែងពឹងពាក់គេវិញ ដោយទុកព្រះទ័យតែលើព្រះតម្រិះរបស់ព្រះអង្គ រំពឹងតែកម្លាំងទ័ពរបស់ទ្រង់នោះ ហើយព្យាយាមដោយ ងាយៗ ទៅគម្រាមកំហែងសត្រូវព្រះអង្គនឹងត្រូវបរាជ័យ»។ ចំណែកអ្នកទីពីរ គឺ ចាងអ៊ីបង្ហាញសេចក្តីយល់ឃើញ របស់គាត់ ថា៖ «បើយើងប្រមាថ ដោយសេចក្តីឆ្វេស ហើយទៅវាយប្រហារប្រទេស ធំៗ នោះ ប្រជានុរាស្ត្ររបស់យើងនឹងអាក់អន់ស្រពន់ចិត្តហើយអល់ឯក។ វាអាចមានរឿងកើតឡើងដូចជា (អាចរាប់ជាករណីមួយបាន) ឆាកសង្គ្រាមដែលត្រូវសម្តែងឡើងដោយកងទាហាន ដែលទាហានទាំងនោះ បែរជាតក់ស្លុត ដោយសារចំនួនទាហានខាងខ្លួន





www.facebook.com/7khmer
Fb page : Entertainment And Knowledge

មានតែពាក់កណ្ដាលបើប្រៀបធៀបនឹងទ័ពសត្រូវនោះ នាយទាហានផ្សេងទៀតនឹងភ័យខ្លាចហើយបដិសេធន៍មិនចូលរួមក្នុងចម្បាំងនោះទេ»។

ប្រការទី **55** ៖ (១). ដូចនេះ គាត់មិនត្រូវពុះពារចងខ្លួនគាត់ជាមួយសម្ព័ន្ធមិត្តទាំងអស់ និង រដ្ឋ ផ្សេងៗ នោះទេ ហើយគាត់ក៏មិនត្រូវផ្គត់ផ្គង់កម្លាំងឲ្យទៅជួយរដ្ឋទាំងអស់នោះដែរ។ គាត់ត្រូវបន្ត ធ្វើគម្រោងការសម្ងាត់របស់ខ្លួនគាត់ តទៅទៀត គាត់ត្រូវរក្សាគូបដិបក្ខរបស់គាត់ ឲ្យស្ថិតនៅ បន្តនឹកស្ញើចចំពោះគាត់ជានិច្ចតទៅ។

សេចក្ដីអធិប្បាយ៖ លីឈាន់ ពោលថា លំហូរនៃគំនិតគឺវាលេចចេញមកយ៉ាងនេះ ចូរការពារទប់ទល់នឹងការប្រមូលផ្ដុំទ័ពរបស់សត្រូវ «គាត់អាចនឹងកែខៃលៃលកដើម្បីច្រានចោលសម្ព័ន្ធភាពដែលចាក់ស្រេះ ហើយធ្វើតាមគម្រោងការសម្ងាត់របស់គាត់ឲ្យបាន កិត្យានុភាពរបស់គាត់ ក៏នឹងហុចលទ្ធភាពឲ្យគាត់អាចដោះស្រាយរឿងរបៀបនេះ តាមចំណងមិត្តភាព ខាងក្រៅសម្ព័ន្ធមិត្តបាន»។


www.facebook.com/7khmer
Fb page : Entertainment And Knowledge

- ប្រការទី 55 ៖ (២). បើធ្វើដូចនេះបាន គាត់អាចនឹងក្តាប់ក្តោបទីក្រុងរបស់ពួកគេ ថែមទាំង កាច់បំបាក់អាណាចក្ររបស់ពួកគេបានទៀតផង។

សេចក្តីអធិប្បាយ៖ កថាខ័ណ្ឌនេះ ទោះបីជាត្រូវបានសរសេរជាច្រើនឆ្នាំតាំងពីមុនពេលដែលនគរឈិនបានទទួលរងការគម្រាមកំហែងក៏ដោយ ក៏សេចក្តីបូកសរុបខាងលើនេះមិនជាអាក្រក់ប៉ុន្មានទេ ដែលវានិយាយអំពីគោលនយោបាយដឹកនាំ ដោយសេនាបតី ដ៏ល្បីល្បាញដល់ទៅចំនួន៦តំណ តាមលំដាប់លំដោយ ដែលត្រូវបានត្រួសត្រាយមាគ៌ា ដ៏ជោគជ័យចុងក្រោយបំផុតក្រោមអំណាចស្តេចស៊ីនហ័ងទី។ ចាងអ៊ី បានសរសេរបន្តពីកំណត់ត្រាកន្លងមករបស់គាត់ថា៖ ស៊ុនអ៊ូ កំពុងតែផ្តន្ទាទោសឥរិយាបថស្មូនគួ ឈាមត្រជាក់ និង ការបំបែកបំបាក់គ្នាយ៉ាងក្រអឺតក្រទមនេះហើយ។

ប្រការទី 56 ៖ (១). ចូរផ្តល់បំណាច់រង្វាន់ដោយមិនចាំបាច់គិតដល់គោលវិន័យ ណាៗ ឡើយ,




www.facebook.com/7khmer
Fb page : Entertainment And Knowledge

សេចក្តីអធិប្បាយ៖ ស្មាដៃ វូអ៊ូ (ក្នុងជំពូកទី៣) បាន ពោលទុក (ចំពោះពលទាហាន) ដោយមានអត្ថន័យ ស្រាលជាងនេះបន្តិចថា៖ «ចូរសម្រុកចូលទៅមុខ អ្នក នឹងក្លាយជាអ្នកមានដោយសារបំណាច់រង្វាន់ តែបើ ដកថយ អ្នកនឹងត្រូវទទួលទណ្ឌកម្មយ៉ាងធ្ងន់ធ្ងរ ជាទី បំផុត»។

ប្រការទី 56 ៖ (២). ចូរដាក់ចេញនូវបទបញ្ជាទាំងឡាយ,

សេចក្តីអធិប្បាយ៖ បើតាមន័យរបស់ពាក្យគឺ៖ «ចូរដាក់ ទាហានឲ្យនៅយាមប្រចាំការ» ឬ «ដាក់ទាហានឲ្យនៅ យាម»។

ប្រការទី 56 ៖ (៣). ដោយគ្មានចាំបាច់ខ្វល់ខ្វាយដល់ការ រៀបចំពីដំបូងអ្វីឡើយ,

សេចក្តីអធិប្បាយ៖ វ៉ាងស៊ី ពោលថា៖ «ដើម្បីទប់ស្កាត់ កុំឲ្យមានអំពើក្បត់កើតឡើងបាន»។ ឆាវកុង បានដក ស្រង់សេចក្តី ពី ស៊ូម៉ាហ្វា មកពន្យល់អត្ថន័យជាទូទៅ យ៉ាងច្បាស់ថា៖ «ចូរឲ្យឱវាទទាហាន តែអំពី របៀបរំពៃ ប្រម៉ាញ់សត្រូវបានហើយ ចូរផ្តល់បំណាច់រង្វាន់ នៅ




www.facebook.com/7khmer
Fb page : Entertainment And Knowledge

ពេលណា ដែលអ្នកឃើញថា ពួកគេបម្រើការ ត្រូវចំគោលបំណង បានយ៉ាងល្អគួរឲ្យសរសើរ»។ ឆាវកុងបកស្រាយបន្តថា៖ «ឱវាទការងារជាចុងក្រោយ ដែលត្រូវផ្ដល់ឲ្យទៅទាហានរបស់អ្នក គឺ មិនគួរឲ្យ ដដែលៗដូចគ្នានឹងភារកិច្ច ដែលបានដាក់រួចហើយនោះទេ»។

ចាងអ៊ី បាននិយាយសម្រួលឲ្យស្រួលយល់ថា៖ «ការរៀបចំចាត់ចែងរបស់អ្នក មិនគួរឲ្យលេចឮជាមុននោះទេ» ហើយ ចាលីន ក៏ពោលដែរថា៖ «សូមកុំឲ្យនៅងាប់ក្រឡាផ្កាប់មុខតែនឹងគោលការណ៍ច្បាប់ និង ក្នុងរបៀបរបប នោះៗ ប៉ុណ្ណោះ»។ ការណ៍ដែលបណ្ដោយឲ្យគម្រោងការបែកការណ៍លេចឮជាមុន វាមិនត្រឹមតែមានគ្រោះថ្នាក់ប៉ុណ្ណោះទេក៏ប៉ុន្ដែក្នុងសង្គ្រាមជារឿយៗ វាតែងតែចាប់បង្ខំតាមកិច្ចការចាំបាច់ ឲ្យចេះបត់បែនប្រែប្រួលផែនការទាំងនោះ នៅនាទីចុងក្រោយជានិច្ច។

ប្រការទី 56 ៖ (៩). បើធ្វើដូចខាងលើបាន អ្នកអាចនឹងក្ដាប់ក្ដោបឃោធាទាំងមូលបានតាមដែលអ្នកត្រូវធ្វើ ប្រៀបបាននឹងការគ្រប់គ្រងមនុស្សតែម្នាក់ដូច្នោះដែរ។



www.facebook.com/7khmer
Fb page : Entertainment And Knowledge

សេចក្តីអធិប្បាយ៖ សូមប្រៀបធៀបធៀប ជាមួយនឹង ប្រការទី៣៤ (ជំពូកដំដែល)។

ប្រការទី 57 ៖ (១). ចូរប្រឈមមុខ ជាមួយ ទាហានរបស់អ្នក តែជាមួយនឹងអំពើដែលអ្នកធ្វើបានហើយ ដោយមិនត្រូវអនុញ្ញាតិឲ្យពួកគេដឹងអំពីគម្រោងការដែលអ្នកគិតនោះទេ។

សេចក្តីអធិប្បាយ៖ តាមន័យរបស់ពាក្យ មានន័យថា «ចូរកុំប្រាប់ពួកគេ ជាពាក្យសម្តី» ចូរកុំប្រាប់ហេតុផល ចំពោះបទបញ្ជាទាំងឡាយ។ លោកម្ចាស់ ម៉ាន់ហ្វៀល មានពេលម្តងនោះ បានប្រាប់នាយទាហាននៅក្រោមឱវាទគាត់ថា «ចូរកុំប្រាប់ហេតុផល» ចំពោះការសម្រេចចិត្ត របស់គាត់ ហើយពាក្យទំនឹមទំនាមនេះ ក៏អាចអនុវត្តបានសម្រាប់មេទ័ព ល្អជាងចៅក្រមទៀតផង។

ប្រការទី 57 ៖ (២). ពេលណា ដែលមើលទៅ ឃើញថាអនាគតស្រស់ត្រកាលហើយ ចូរនាំមកបង្ហាញ ឲ្យពលទាហានយើងបានដឹងផង ក៏ប៉ុន្តែ ត្រូវប្រាប់ពួកគេជាបន្ថែមថា មិនទាន់ដឹងថាយ៉ាងណានោះទេ ព្រោះស្ថានការណ៍ពិតវានៅងងិតនៅឡើយ។





www.facebook.com/7khmer
Fb page : Entertainment And Knowledge

ប្រការទី 58 ៖ បើដាក់ទាហានរបស់អ្នក នៅចំណុច គ្រោះថ្នាក់ ស្លាប់ រស់, កងទ័ព ក៏នឹងនៅរស់, បើនឹងបញ្ជូនពួកគេចូលដល់ទីលំបាក ប្រកបដោយភាពអស់សង្ឃឹម កងទ័ព ក៏នឹងបញ្ចប់ការងារ វិលវិញដោយរួចផុតភ័យ។

សេចក្តីអធិប្បាយ៖ ពាក្យពេចន៍ របស់ ស៊ុនអ៊ូ ទាំងនេះ ត្រូវបាន ហាន់ស៊ីន ដកស្រង់យកទៅពន្យល់ អំពីគាត់ទិច ដែលគាត់ប្រើប្រាស់ក្នុងចម្បាំងមួយ នៅក្នុងចំណោមចម្បាំងទាំងឡាយ ដ៏ស្រស់ឆើត របស់គាត់ ដោយមាននិយាយ នៅទំព័រទី ២៨ (ក្នុងតម្រាដើម)។ ដំណើររឿងគឺមានដូច្នេះថា៖ កាលពីឆ្នាំ២០៤ មុន គ.ស គាត់ត្រូវបានស្តេចហាន់បញ្ជូន ឲ្យទៅធ្វើសង្គ្រាមតទល់នឹងទាហាននគរចាវ ហើយក៏ស្រាប់តែទុចដំណើរនៅចម្ងាយ១០ម៉ាយ ពីមាត់ច្រក ជីងស៊ីង ដែលទីនោះ មានពួកសត្រូវប្រមូលផ្តុំទាហានយ៉ាងពេញទី ជាកងទ័ព។ នៅទីតាំងនោះ នាពេលរាត្រី គាត់ក៏បំបែកទាហានបានមួយកង មានគ្នាចំនួន២,០០០នាក់ ជាកងទ័ពសេះលឿនរហ័ស ពលទាហានសេះជម្រើសគ្រប់គ្នានោះ បានតាក់តែងកាយ ដោយកាន់ទង់ពណ៌លឿង គ្រប់ៗ



www.facebook.com/7khmer



Fb page : Entertainment And Knowledge

គ្នា។ ពួកគេទទួលបញ្ជា ឲ្យទៅតាមច្រកភ្នំចង្អៀត ហើយនៅឃ្លាំមើលសភាពការណ៍សត្រូវយ៉ាងសម្ងាត់» ហានស៊ិន ប្រាប់ពួកគេថា៖ «ពេលណាទាហាននគរចាវ ឃើញខ្ញុំនាំទ័ពភៀសខ្លួនរត់ទៅ ពួកវាក៏នឹងលះបង់បន្ទាយវាចោល ហើយដេញតាមខ្ញុំ។ បើអស់លោកឃើញដូចនេះហើយ ត្រូវប្រញាប់ស្ទុះចូលទៅជាបន្ទាន់ចូលទៅក្នុងបន្ទាយពួកវា រើរុះទង់កងទ័ពនគរចាវចេញ ហើយត្រូវដាក់តាំងទង់កងទ័ពហាន់ពណ៌ក្រហម របស់យើងជាជំនួសវិញ»។ ហើយគាត់ក៏ងាកទៅនិយាយនឹងនាយទាហានរបស់គាត់ដទៃទៀតថា៖ «បច្ចាមិត្ររបស់យើង បានកាន់កាប់ទីតាំងដ៏ប្រសើរនេះ ហើយពួកវាហាក់ដូចជា មិនចង់ចេញមកប្រយុទ្ធជាមួយយើងសោះតាមមើល លុះត្រាតែពួកវាឃើញទង់ និង ឮសម្លេងស្គរពីអគ្គមេបញ្ជាការរបស់វាហើយ ខ្ញុំត្រូវធ្វើពុតជាខ្លាចពួកវា ហើយដកទ័ពថយក្រោយរត់តាមច្រកភ្នំ»។ តាមគម្រោងការដែលគាត់បាននិយាយ ជាដំបូង គាត់ចាត់បញ្ជូនទាហានមួយកង មានគ្នា១០,០០០នាក់ ហើយបញ្ជា ឲ្យពួកគេប្រុងប្រៀប ជាខ្សែត្រៀមវាយប្រយុទ្ធ



www.facebook.com/7khmer

Fb page : Entertainment And Knowledge

ដោយបែរខ្នងទៅរកទន្លេទី។ ពេលឃើញកងទ័ពរបស់ហាន់ស៊ីន រៀបក្បួនយ៉ាងនេះ កងទ័ពនគរចាវ ក៏ផ្ទុះសំណើចយ៉ាងខ្លាំង។ វេលានោះ ជាពេលថ្ងៃនៅឡើយហើយ ហាន់ស៊ីន នៅប្រើទង់ទ័ពហ្លួងផង ក៏រៀបជាព្យូហ៍ទ័ព យាត្រាចេញពីច្រកនោះ អមដោយសម្លេងស្គរដែលភ្លាមនោះពួកសត្រូវក៏ឆ្លៀតមកញុះញង់បបួលច្បាំងទៀត។ បន្ទាប់មក ការប្រយុទ្ធដ៏សាហាវ ក៏ចាប់ផ្ដើមឡើង អស់មួយរយៈ ទាល់តែក្បួនខ្សែទ័ព របស់ហាន់ស៊ីន និង នាយទាហានរបស់គាត់ ចាងនី បោះបង់ចោលស្គរ និង បដា នៅលើសមរភូមិ ហើយរត់ភៀសខ្លួនទៅមាត់ទន្លេ ដែលការប្រយុទ្ធដ៏សាហាវ ក៏បានកើតមានម្ដងទៀត។ សត្រូវក៏ដេញតាមមកយ៉ាងប្រកិតហើយរើសដណ្ដើមយកជ័យភ័ណ្ឌ, ឃើញដូចនេះ ពួក

* ទាហានហាន់ស៊ីនក៏បោះលំពែងចោល ស្រាតសម្លៀកបំពាក់ចោលទៀត ប៉ុន្តែទាហានដែលបានបង្កប់ទុក នាមាត់ទន្លេ និង ទាហាន ហាន់ស៊ីន បានចូលចាប់ដៃគ្នាហើយវាយបកមកវិញយ៉ាងកោលាហល។ ពេលនោះក៏ដល់វេន ដែលទាហានសេះជម្រើសទាំង ២,០០០ នាក់



www.facebook.com/7khmer



Fb page : Entertainment And Knowledge

ត្រូវបើកឆាកប្រយុទ្ធម្តងហើយ។ នៅពេល ដែលពួកគេ ឃើញទាហាននគរចាវដេញតាម ហាន់ស៊ីន ដោយមានប្រៀបចេញទៅនោះ ពួកគេ ក៏បំផាយសេះ យ៉ាងលឿន ចូលដល់ក្រោយកំពែងដែលពួកសត្រូវទុកចោល ហើយចូលទៅហែកទង់សត្រូវចោលអស់ រួចដាក់តាំងទង់កងទ័ពហាន់របស់ខ្លួនជាជំនួសវិញ។ នៅពេលដែលទាហាននគរចាវ វិលមកពីដេញតាមប្រយុទ្ធវិញ ក៏ក្រលេកមើលមកពីចម្ងាយឃើញទង់ពណ៌ក្រហមរបស់ទ័ពហាន់ ក៏ភ័យតក់ស្លុតជាខ្លាំង។ ពេលនោះ ទ័ពនគរចាវ ក៏ជឿក្នុងចិត្តថា ទាហានហាន់បានចូលទៅពេញក្នុងបន្ទាយនោះ ហើយ បង្ក្រាបស្តេចពួកគេទៀតផង មើលទៅ, ពួកគេ ក៏បែកបាក់ខ្ចាត់ខ្ចាយអារាត់អារាយអស់ទៅ រាល់សេចក្តីខិតខំប្រឹងប្រែងរបស់មេទ័ពពួកគេក៏ទៅជាស្លន់ស្លោឥតប្រយោជន៍។ ពេលនោះ ទាហានហាន់ ក៏វាយខ្ទប់ទាំងសងខាង មកលើពួកកងទ័ពនគរចាវ ហើយវាយផ្តាច់សឹក សម្លាប់ បានទាហាននគរចាវមួយចំនួនធំ ព្រមទាំង ចាប់បានឈ្លើយសឹកជាច្រើននាក់ទៀត ដែលក្នុងនោះក៏មានស្តេចយ៉ា របស់នគរចាវ




www.facebook.com/7khmer
Fb page : Entertainment And Knowledge

ផងដែរ។ បន្ទាប់ពីវាយប្រយុទ្ធគ្នារួចមក មាននាយទាហានរបស់ហាន់ស៊ិន ក៏បានចូលមករកគាត់ ហើយនិយាយថា៖ «នៅក្នុងជំនាញធ្វើសង្គ្រាម បានបង្រៀនយើង ឲ្យទៅនៅទីណាដែលមានភ្នំ ឬក៏ ទីទួលខ្ពស់ នៅពីខាងក្រោយឈាងខាងស្ដាំ ហើយឲ្យមានទន្លេ ឬក៏វាលភក់នៅខាងមុខឈាងខាងឆ្វេង។ (សេចក្ដីនេះលេចចេញមកឲ្យឃើញថា វាលាយឡំ ជាមួយនឹងមេរៀនរបស់ ស៊ុនអ៊ូ និង តៃកុង ដែលបានសរសេររៀបរាប់មកហើយក្នុងសេចក្ដីអធិប្បាយ ជំពូកទី៩ (ប្រការទី៩) ចំណែកលោកមេទ័ព បែរជា ធ្វើផ្ទុយពីជំនាញនេះទៅវិញ ដោយបានបញ្ជាឲ្យពួកយើងខ្ញុំទៅរៀបចំត្រៀមទ័ពដោយមានទន្លេ នៅចំពីក្រោយទៅវិញ។ នៅក្រោមអំណាចលក្ខ័ណ្ឌទាំងនេះ តើលោកមេទ័ព គ្រប់គ្រងចាត់ចែងរបៀបណា បានជា អាចឈ្នះសង្គ្រាមបានដូច្នេះ?» លោកមេទ័ព ក៏ឆ្លើយតបវិញថា៖ «អស់លោកទាំងអស់គ្នា! ខ្ញុំខ្លាចតែ អស់លោកបានសិក្សាតម្រាពិជ័យសង្គ្រាមហើយ តែមិនបាន យកចិត្តទុកដាក់ឲ្យដល់កម្រិតទេ។ តើតម្រាមានបានសរសេរទេថា៖ បើ




www.facebook.com/7khmer
Fb page : Entertainment And Knowledge

នឹងបញ្ជូនពួកទាហាន របស់អ្នក ចូលដល់ទីលំបាក ប្រកបដោយភាពអស់សង្ឃឹម កងទ័ព ក៏នឹងបញ្ចប់ការងារដោយរួចផុតភ័យ, បើដាក់ទាហានរបស់អ្នក នៅចំណុចគ្រោះថ្នាក់ ស្លាប់ រស់ កងទ័ពក៏នឹងនៅរស់» នោះ? បើសិនជាខ្ញុំបានប្រកាន់យកទិសដៅតាមដំណើរធម្មតា នោះក៏មុខជា មិនអាចបានជួយស្មារតីដល់អ្នកទាំងអស់គ្នាបាននោះទេ។ អ្វីដែលបាន និយាយក្នុងក្បួនទាហានបុរាណនោះគឺថា៖ ចូរឆាបឆក់ក្នុងទីផ្សារហើយកេណ្ឌយកទាហានទៅច្បាំង។ (ឃ្លាឃ្លោងនេះ មិនមាននៅក្នុងអត្ថបទរបស់ ស៊ុនអ៊ូ ទេ) លោកមេទ័ពបន្តថា បើសិនជា ខ្ញុំមិនបានដាក់ទាហាននៅលើទីតាំង ដែលពួកគេត្រូវប្រយុទ្ធយកជីវិតរស់ទេ,បើសិនជាខ្ញុំបណ្តោយតាមតែអំពើចិត្តពលទាហាន ម្នាក់ៗ ក៏នឹងទៅជាប្រសេចប្រសាចតាមយថាផល ហើយយើងក៏មិនអាចនឹងចាត់ការយ៉ាងណា ជាមួយសត្រូវបានដែរ»។ ពួកនាយទាហានទាំងនោះ ក៏បានទទួលយកហេតុផលទាំងអស់នេះ ហើយក៏និយាយថា៖ «ទាំងនេះ គឺជាតាក់ទិច ដែលមានកម្រិតខ្ពស់ជាងសមត្ថភាព របស់ពួក





www.facebook.com/7khmer
Fb page : Entertainment And Knowledge

យើងខ្ញុំទៅទៀត» (សូមមើលសៀវភៅ ឈានហានស៊ុ ជំពូកទី៣៤ លើទំព័រទី៤ ដល់ទី៥)។

ប្រការទី **59** ៖ សម្រាប់អ្វី ដែលជាសភាពជាក់ស្តែងនោះ គឺ ពេលណាកងទ័ពណានីមួយ បានធ្លាក់ចូលទៅក្នុងផ្លូវគ្រោះថ្នាក់ហើយក៏ដោយ ក៏អាចនឹងវាយរំដោះខ្លួន ដើម្បីដណ្តើមយកជ័យ មកវិញបានដែរ។

សេចក្តីអធិប្បាយ៖ គ្រោះថ្នាក់ មានកម្លាំងគាំទ្រ ជួយជម្រុញលទ្ធផល។

ប្រការទី **60** ៖ ជោគជ័យនៅក្នុងសឹកសង្គ្រាម គឺ ដណ្តើមយកបាន ដោយសារ ការសម្របខ្លួនរបស់យើង ឲ្យចូលចុះជាមួយ គោលបំណងរបស់សត្រូវ។

សេចក្តីអធិប្បាយ៖ ឆាវកុង ពោលថា៖ «ចូរក្លែងធ្វើជាឆោតល្ងង់» ដោយបង្ហាញឲ្យសត្រូវឃើញ តាមអាការៈខាងក្រៅ ដូចជា ទន់ជ្រាយ ខ្លបខ្លាច និង ធ្លាក់ចូលក្នុងសេចក្តីប៉ងប្រាថ្នារបស់សត្រូវ។ កំណត់ត្រារបស់ ចាងអ៊ីមានន័យរាងច្បាស់ជាងនេះបន្តិចថា៖ «កាលបើ សត្រូវ




www.facebook.com/7khmer
Fb page : Entertainment And Knowledge

បង្ហាញនូវជំនឿចិត្ត នឹងសម្រុកចូលមកហើយ ចូរបញ្ឆោតពួកវាបន្ថែម ឲ្យចូលមកកាន់តែកៀកទៀតចុះ, តែបើវាស្រេីបចិត្ត ចង់ដកថយទៅវិញ ចូរពន្យាបង្អិតគោលបំណងយើង ឲ្យនៅត្រឹមតែថា សត្រូវអាចនឹងអនុវត្តចេតនារបស់វា ដោយខ្លួនវាទៅបានហើយ»។ កម្មវត្ថុ គឺ នៅត្រង់ថា ត្រូវធ្វើឲ្យសត្រូវធ្វេសប្រហែស ហើយប្រមាថមុនពេលដែលយើងបើកការវាយប្រហារទៅលើពួកវា។ *✓

ប្រការទី **61** ៖ (១). ដោយយើងនៅមានចិត្តមានៈ នៅតស៊ូនៅឃ្លាំមើលសត្រូវពីចំហៀងខ្លួនរបស់វា,

សេចក្តីអធិប្បាយ៖ ខ្ញុំយល់ថា បើមានពាក្យពីខាងដើមដែលមានសេចក្តីថា៖ «ចូរអមដំណើររបស់សត្រូវ តាមទិសដៅតែមួយ» ពិតជាល្អជាង។ ឆាវកុងក៏បានពោលដែរថា៖ «ចូររួបរួមកងទ័ព ហើយ សម្របខ្លួនទៅតាមទិសដៅរបស់សត្រូវ»។ ក៏ប៉ុន្តែចរិតលក្ខណៈ ដែលចេះតែផ្លាស់ប្តូរទីតាំងបែបនេះ គឺ មិនអាចការពារខ្លួនយើងបានទេ។





www.facebook.com/7khmer
Fb page : Entertainment And Knowledge

ប្រការទី 61 ៖ (២). យើងនឹងអាចយកជ័យជំនះបាន នៅក្នុងពេលអនាគតដ៏ឆ្ងាយ,

សេចក្តីអធិប្បាយ៖ បើប្រៀបធៀបតាមន័យរបស់ពាក្យ គឺដូចជា នៅចម្ងាយ ១,០០០លី អញ្ចឹងដែរ។

ប្រការទី 61 ៖ (៣). ដោយការចូលទៅប្រហារអគ្គមេបញ្ជាការ កងទ័ពរបស់វា។

សេចក្តីអធិប្បាយ៖ បើតាមទស្សនៈជនជាតិចិន សេចក្តីនេះ គឺ ជានិច្ចកាលនៅតែជាចំណុចអស្ចារ្យដដែល។

ប្រការទី 62 ៖ ចំណុចនេះហើយដែលគេហៅថា សមត្ថភាពសម្រេចកិច្ចការ ដោយប៉ិនប្រសប់ ត្រង់ទៅ ត្រង់មក។

ប្រការទី 63 ៖ (១). នៅថ្ងៃ ដែលអ្នកដាក់ចេញ នូវបទបញ្ជា ចូរបិតច្រកព្រំដែន ហើយ ចូរបំផ្លាញនូវបញ្ជីស្នាមផ្លូវការទាំងឡាយចោល,

សេចក្តីអធិប្បាយ៖ បញ្ជីស្នាមទាំងនេះ មានដូចជា៖ បន្ទះឬស្សីឬបន្ទះឈើ ដែលចំនួនពាក់កណ្តាលត្រូវបាន





www.facebook.com/7khmer
Fb page : Entertainment And Knowledge

ចេញឲ្យជាលិខិតអនុញ្ញាតិ ឬ លិខិតឆ្លងដែន ដោយអ្នកទទួលខុសត្រូវ គ្រប់គ្រងច្រកទ្វារ, សូមប្រៀបធៀបជាមួយស្នាដៃ «មន្ត្រីគ្រប់គ្រងច្រកទ្វារ» នៃ អក្សរសិល្ប៍លុនអ៊ី ដែលមានភារកិច្ចស្រដៀងគ្នានេះដែរ។ នៅពេលដែលមានចំនួនពាក់កណ្ដាល នៃ លិខិតបែបបទរបៀបនេះ ចូលមកដល់គាត់ តាមថ្ងៃ ខែ កំណត់ហើយគាត់ត្រូវមានសិទ្ធិអំណាចបើកច្រកទ្វារហើយអនុញ្ញាតិឲ្យអ្នកធ្វើដំណើរបានឆ្លងដែនចេញចូលទៅមក។

ប្រការទី **63** ៖ (២). ហើយ ក៏ត្រូវបិតបញ្ឈប់ រាល់ដំណើរចេញចូល របស់បេសកជនទូតដែរ។

សេចក្ដីអធិប្បាយ៖ រួមទាំង អ្នកដំណើរចេញ ទាំងអ្នកដំណើរចូលក្នុងប្រទេសរបស់សត្រូវផងដែរ។

ប្រការទី **64** ៖ (១). ចូរដាក់កំហិត ប្រិតប្រៀងក្នុងចំណោមគណៈប្រឹក្សារដ្ឋ (គណៈរដ្ឋមន្ត្រី)។



www.facebook.com/7khmer
Fb page : Entertainment  And Knowledge

សេចក្តីអធិប្បាយ៖ ចូរកុំបង្ហាញ នូវ ចំណុចខ្សោយ ឲ្យសោះ ហើយស្នើសុំ ដើម្បីឲ្យស្តេចអធិរាជចេញបញ្ជា អនុវត្តផែនការរបស់អ្នកតែម្តងចុះ។

ប្រការទី 64 ៖ (២). ការធ្វើដូចនេះ គឺ ដើម្បីឲ្យខ្លួនអ្នកអាច គ្រប់គ្រងស្ថានការណ៍ទាំងអស់។

សេចក្តីអធិប្បាយ៖ ម៉ីយ៉ាវឆិន យល់ថា ប្រយោគ ទាំងមូលមានន័យថា៖ ចូរប្រុងប្រយ័ត្ន ដោយមធ្យ័ត ដើម្បីធានាថា មានភាពសម្ងាត់ នៅក្នុងកិច្ចជំនុំប្រឹក្សា របស់អ្នក។

✓ ប្រការទី **65** ៖ បើសិនជា សត្រូវរបស់អ្នកទុកច្រកទ្វារ ឲ្យនៅចំហ អ្នកត្រូវតែសម្រុកចូលទៅភ្លាម។

✓ ប្រការទី **66** ៖ (១). ចូរប្រុងប្រៀបទុកជាមុន ឲ្យបានមុន បច្ចាមិត្ររបស់អ្នក តាមរយៈការរឹបអូសយក អ្វីៗ ដែលពួកវា កំពុងតែមាន / កាន់កាប់ ដោយគោរពស្រលាញ់ជាប់ចិត្ត,

សេចក្តីអធិប្បាយ៖ សូមប្រៀបធៀប ជាមួយ ប្រការ ទី១៨ ជំពូកដដែលនេះ។



www.facebook.com/7khmer
Fb page : Entertainment And Knowledge

ប្រការទី 66 ៖ (២). ហើយ ដាក់គម្រោងការ យ៉ាងវាងវៃ ដើម្បីកំណត់ម៉ោងពេល ដែលសត្រូវនឹងមកដល់ទីតាំងជួបប្រយុទ្ធគ្នា។

សេចក្តីអធិប្បាយ៖ ឆិនហាវ បានបរិយាយ ដូចតទៅនេះថា៖ «បើសិនជា ខ្ញុំចាត់ការដណ្តើមយកទីតាំងសមប្រកបហើយ ក៏ប៉ុន្តែសត្រូវបែរជាមិនបានបង្ហាញខ្លួនចេញមកសោះ ការមានរបៀបរបៀបនេះ មិនអាចនឹងយកមកប្រើការបានទេ។ បើនរជនណា ដែលមានចេតនាពីខាងដើមមកថាត្រូវដណ្តើមយកទីតាំងសំខាន់ទល់នឹងសត្រូវ ដូច្នេះគឺ ត្រូវតែចាប់ផ្តើមដោយសិល្បៈនៃ ការណាត់ជួប ដូចជា តាមរយៈការបានជួបចរចាជាមួយគូបដិបក្ខ ហើយល្បួងបញ្ឆោតពួកវាឲ្យចូលទៅក្នុងទីនោះផងដែរ»។ ម៉ីយ៉ាវឆិន ពន្យល់ថា៖ «ការណាត់ជួបប្រកបដោយសិល្បៈ» នេះគឺ ត្រូវធ្វើឡើងតាមរយៈគណៈមជ្ឈឹម នៃ ចារកម្មរបស់សត្រូវនោះឯង ដែលពួកនេះនឹងជ្រើសរើសពាំនាំយកព័ត៌មាន តែល្មមនឹងចិត្តរបស់គេ ដែលវិលទៅវិញតែប៉ុណ្ណោះ។ ខណៈនោះដោយបានបើកបង្ហាញចេតនា របស់យើង «យើងត្រូវ




www.facebook.com/7khmer
Fb page : Entertainment And Knowledge

តែចាត់ការ ដោយចាប់ផ្ដើមក្រោយសត្រូវ តែត្រូវទៅឲ្យបានដល់មុនសត្រូវ (មានសរសេរហើយ នៅក្នុងជំពូកទី៧ ប្រការ ទី២)។

យើងត្រូវតែចាប់ផ្ដើមក្រោយសត្រូវ ដើម្បីមើលឲ្យដឹងប្រាកដ អំពី ទិសដៅ ដំណើររបស់វា យើងត្រូវតែទៅឲ្យដល់ចំណុចទីតាំងមុនវា ដើម្បីនឹងកាន់កាប់ទីតាំងដោយគ្មានការរំខាន។ ដូច្នេះ សេចក្ដីត្រង់ចំណុចនេះបានជួយបង្គ្រប់ន័យឲ្យការបកស្រាយ របស់ ម៉ីយ៉ាវឆិន ដូចដែលមានចែងក្នុងប្រការទី២៧ (ជំពូកដដែលនេះ)។

ប្រការទី **67** ៖ (១). ចូរចាត់ចែងដំណើរកងទ័ព តាមមាគ៌ាដែលបានចែងក្នុងគោលច្បាប់,

សេចក្ដីអធិប្បាយ៖ ចាលីន ពោលថា៖ «ជ័យជំនះគឺជារឿង ដែលបានមកដោយសារ ការណ៍ដែលធ្វើកិច្ចការទាំងឡាយ ឲ្យមានឥទ្ធិពលលើអ្វីដែលកើតឡើងហើយ វាមិនអាចសម្រេចបាន ដោយសារការប្រកាន់ខ្ជាប់ខ្ជួនផ្ដាប់មុខតែទៅនឹងក្បួនច្បាប់ ណាៗ នោះទេ»។ វាជាអកុសលណាស់ ដែលថា ភាពស្រដៀងគ្នានេះ





www.facebook.com/7khmer
Fb page : Entertainment And Knowledge

អាស្រ័យនៅលើអំណាចមួយចំណែកដែរ។ សម្រាប់សេចក្ដី ដែលបានបរិយាយរួចមកហើយនេះ គឺ ពិតជាគួរឲ្យពេញចិត្តណាស់។ ដូចដែលយើងបានដឹងហើយអំពី ណាប៉ូឡេអុង ជាមួយនឹងទាហានជើងចាស់ នៃសាលាយោធាដ៏ ចំណាស់ៗ ដែលគាត់បានវាយប្រហារឲ្យបរាជ័យ គឺ គាត់បានឈ្នះសង្គ្រាមដោយសារតែគាត់វាយកម្ទេច រាល់ការណ៍ដែលសត្រូវរបស់គាត់ផ្កាប់មុខអនុវត្តតាមតែក្បួនសឹកសង្គ្រាមសុទ្ធសាធនោះឯង។

ប្រការទី 67 ៖ (២). ហើយ ត្រូវចេះបត់បែន និង ចេះកែខៃសម្របខ្លួនអ្នកទៅនឹងសត្រូវ រហូតទាល់តែដល់ពេល ដែលអ្នកត្រូវបើកការវាយប្រហារយ៉ាងមុះមុតបំផុតបាន។

សេចក្ដីអធិប្បាយ៖ ទូមូ ពោលថា៖ «ចូរអនុលោមតាមតាក់ទិចរបស់សត្រូវ រហូតទាល់តែ ឱកាសល្អហុចឲ្យដល់ពេលនោះ សឹមអ្នកបង្ហាញខ្លួនឲ្យប្រាកដ ហើយចាប់ផ្ដើមការវាយប្រហារ ដែលជាតឹកតាង នៃ សេចក្ដីអង់អាចមុះមុត»។



www.facebook.com/7khmer
Fb page : Entertainment And Knowledge

ប្រការទី 68 ៖ ជាដំបូងត្រូវបង្កើតនិងបង្ហាញសេចក្តីអាម៉ាស់កំសាកញីចេញមកសិន រង់ចាំរហូតដល់ពេលសត្រូវបើកដៃឲ្យយើង ជាបន្ទាប់មក ស្ទឹមដេញជើងប្រដែងយ៉ាងរហ័សដូចសត្វទន្សាយហើយពេលនោះវានឹងពិតជាយឺតពេកហើយដើម្បីឲ្យសត្រូវដេញតាមប្រដែងនឹងយើងវិញនោះ។

*សេចក្តីអធិប្បាយ៖ ពាក្យ «សត្វទន្សាយ» នៅទីនេះគឺជាពាក្យ ដើម្បីសម្គាល់ភាពអេៀនខ្មាសកំសាកជាទីបំផុត ពាក្យប្រៀបធៀបនេះ វាងពិបាកយល់បន្តិចដោយសារទន្សាយជាសត្វតិរច្ឆាន ក៏ប៉ុន្តែតាមពិត ស៊ុនអ៊ូ គាត់និយាយសំដៅដល់ត្រឹមតែល្បឿនរបស់វា ប៉ុណ្ណោះទេ។ ពាក្យនេះត្រូវបាន ស៊ុនអ៊ូ ប្រើប្រាស់ដើម្បីបញ្ជាក់ន័យថា៖ អ្នកត្រូវភៀសខ្លួនចេញពីសត្រូវឲ្យបានយ៉ាងរហ័សដូចជាសត្វទន្សាយអញ្ចឹង តែន័យនេះ ត្រូវបាន ទូម្ចូច្រានចេញ។ សូមអាន* (១).Gils' Biographical Dictionary, no. 333, (២). *វិទ្យាសាស្ត្រសង្គ្រាម* (Science of War) *ទំព័រទី៣៣៣*, (៣). Stonewall Jackson, vol. I, p. 421។





www.facebook.com/7khmer
Fb page : Entertainment And Knowledge

## ជំពូកទី 12.

## ការវាយប្រហារដោយភ្លើង/ការវាយប្រហារដូចភ្លើង

សេចក្ដីផ្ដើម៖ ខាងពាក់កណ្ដាល នៃ ជំពូកនេះ (ចាប់ពីប្រការទី១ ដល់ (ប្រការទី១៣) គឺមានបរិយាយ អំពី ភ្លើង ហើយប្រការជាបន្តបន្ទាប់ទៅទៀត អ្នកនិពន្ធបរិយាយ អំពី ប្រធានបទផ្សេងទៅវិញ។

ប្រការទី 1 ៖ (១). ស៊ុនអ៊ូ ពោលថា៖ មានវិធី ៥ប្រការ ក្នុងការវាយប្រហារដោយភ្លើង។ ទី១៖ ដុតទាហាន នៅក្នុងជំរុំរបស់ពួកគេតែម្ដង,

សេចក្ដីអធិប្បាយ៖ ហេតុនេះហើយ បានជា ទូមូ និង លីឈាន់ ពោលថា៖ «ចូរបង្កាត់ភ្លើងដុតបន្ទាយ ហើយដេញតាមប្រហារសត្រូវ» (នៅពេល ពួកវាព្យាយាមរត់គេចខ្លួន)។

តួយ៉ាងជាបន្ត អំពី ដំណើររឿង ប៉ានចាវ ត្រូវបានគេចារឹកទុកថា៖ ប៉ានចាវ ត្រូវបានអធិរាជ របស់



www.facebook.com/7khmer



Fb page : Entertainment And Knowledge

គាត់ ចាត់បញ្ជូនជាបេសកជនទូត ឲ្យទៅគាល់ស្ដេចសានសាន (មានបរិយាយផងដែរក្នុងជំពូកទី១១ ប្រការទី៥១ ត្រង់សេចក្ដីអធិប្បាយ) គាត់ដឹងខ្លួនថា បានស្ថិតនៅក្នុងស្ថានភាពគ្រោះថ្នាក់ដល់ទីបំផុត ដោយសារតែពួកទូតពីនគរ ស៊ុងនុ ក៏បានមកដល់ស្ដេចសានសាននេះផងដែរ វាជារឿងមួយ ដែលស្មានមិនដល់ទាល់តែសោះ (នគរនេះ ជាស្រុកស្ដាប់រស់របស់នគរចិន)។ នៅក្នុងអង្គជំនុំ ជាមួយ នាយទាហាន របស់គាត់ ប៉ានចាវបានឧទ្ទានឡើងថា៖ «បើមិនប្រថុយទេ ក៏គ្មានជ័យជំនះដែរ! (លុះត្រាតែអ្នកចូលក្នុងរូងខ្លា ទើបអ្នកអាចចាប់កូនខ្លាបាន)» មានផ្លូវតែមួយគត់ ដែលបានបើកទុកឲ្យយើង គឺ ការវាយប្រហារដោយប្រើភ្លើង ទៅលើពួកមនុស្សព្រៃទាំងនោះ នៅក្នុងវេលារាត្រី បើធ្វើយ៉ាងនេះបាន ពួកវាមិនអាចនឹងដឹង អំពី ចំនួនកម្លាំងរបស់យើងឡើយ, ដោយបានចំណេញ ពីភាពភ័យស្លន់ស្លោរបស់ពួកវា យើងនឹងកម្ទេចពួកវា ឲ្យសោះសូន្យតែម្ដង បើយើងធ្វើយ៉ាងនេះបាន គឺនាំឲ្យសេចក្ដីអង់អាចរបស់ស្ដេចនគរនេះត្រូវស្រុតចុះ ហើយ ទន្ទឹមនឹងការណ៍





www.facebook.com/7khmer
Fb page : Entertainment And Knowledge

ដែលយើងសម្រេចជ័យជំនះ នៅក្នុង បេសកកម្មទូត របស់យើងនេះហើយយើងក៏នឹងបានលើកកិត្យានុភាព របស់យើងមកវិញផងដែរ។ នាយទាហានទាំងនោះ ក៏ឆ្លើយតបមក ប៉ានចាវ វិញថា៖ រឿងនេះ គឺ ចាំបាច់ ត្រូវពិភាក្សា ជាមួយ លោកប្រមុខក្រុមទូត របស់យើង ជាមុនសិន។ ខណៈនោះ ប៉ានចាវ ដែលបានធ្លាក់ចូល ក្នុងបំណាងប្រាថ្នាដ៏ជ្រាលជ្រៅរួចទៅ ហើយក៏ស្រែក ឡើងថា៖ «ជោគវាសនារបស់យើង គឺត្រូវតែសម្រេច ឲ្យ បាននៅថ្ងៃនេះតែម្តង! លោកនាយ ប្រមុខក្រុមទូត របស់យើង គ្រាន់តែជា ជនស៊ីវិលធម្មតាម្នាក់ប៉ុណ្ណោះ បើគាត់បានដឹង អំពី គម្រោងការរបស់យើងនេះ ក៏នឹង ភ័យខ្លាចរួចជាស្រេចទៅហើយ ម្យ៉ាងទៀត រាល់ អ្វីៗ ទាំងអស់ក៏នឹងត្រូវនិយាយចេញមកបើកកកាយឲ្យ គេ ដឹងៗ។ ការធ្វើយ៉ាងនេះ មរណភាពឥតន័យ ឥតកេរ្តិ៍ ឈ្មោះ គឺជា វាសនាដែលគ្មានតម្លៃសម្រាប់អ្នកចម្បាំង ដ៏ក្លាហានដូចជាយើងនេះហើយ។ ពេលនោះ អង្គជំនុំ ទាំងមូល ក៏ទទួលឯកភាពគ្នា ធ្វើតាមអ្វី ដែលលោក មេទ័ពបានប្រាថ្នាមក។ ស្របគ្នានោះដែរ លុះពេលរាត្រី




www.facebook.com/7khmer
Fb page : Entertainment And Knowledge

មកដល់កាលណា គាត់នាំកងទាហានតូច របស់គាត់ចូលទៅដល់ជំរុំពួកមនុស្សព្រៃយ៉ាងរហ័ស។ ពេលនោះជួនជា មានខ្យល់ព្យុះយ៉ាងខ្លាំង បោកបក់ចុះមក។ ប៉ានចាវ បានឲ្យទាហាន១០នាក់កាន់ស្គរ ទៅលាក់ខ្លួននៅពីក្រោយជំរុំតង់ តូចៗ របស់ពួកសត្រូវ ចាំឃ្លាំមើលបើឃើញភ្លើងឆាបឆេះឡើងហើយ ពួកគេត្រូវចាប់ផ្ដើមទូងស្គរ ហើយ ស្រែកហ៊ោរសន្ធាប់ឲ្យពេញទំហឹង។ ពលទាហានដែលក្រៅពីនេះ ត្រូវកាន់ធ្នូ និង ស្នាគ្រប់ដៃត្រូវទៅបង្កប់ខ្លួន នៅតាមច្រកចូលទៅក្នុងបន្ទាយរបស់សត្រូវ។ ពេលនោះ គាត់ក៏ចាប់ផ្ដើមអុជដុតបន្ទាយសត្រូវពីទីដែលនៅលើខ្យល់ ខណៈនោះ សម្លេងស្គរ និងសម្រែកហ៊ោរកញ្ជ្រៀវក៏ចាប់ផ្ដើមឮយ៉ាងកងរំពងឡើងចេញមកពីខាងមុខ និង ខាងក្រោយបន្ទាយទាហានស៊ុងនុ ដែលកំពុងតែច្រូលច្របល់ ខ្វក់ខ្វល់ ប្រជែងគ្នារត់ចេញយ៉ាងពពាក់ពពូន។ ប៉ានចាវ បានសម្លាប់ពួកសត្រូវដោយផ្ទាល់ដៃ ស្លាប់ចំនួនបីនាក់ ចំណែកគូកនរបស់គាត់វិញ បានកាត់ក្បាលបេសកជនទូត និងបរិវារចំនួន៣០នាក់ផ្សេងទៀត។ ទាហានសត្រូវ ដែលនៅ




www.facebook.com/7khmer
Fb page : Entertainment And Knowledge

ដែលយើងសម្រេចជ័យជំនះ នៅក្នុង បេសកកម្មទូត របស់យើងនេះហើយយើងក៏នឹងបានលើកកិត្យានុភាព របស់យើងមកវិញផងដែរ។ នាយទាហានទាំងនោះ ក៏ឆ្លើយតបមក ប៉ានចាវ វិញថា៖ រឿងនេះ គឺ ចាំបាច់ ត្រូវពិភាក្សា ជាមួយ លោកប្រមុខក្រុមទូត របស់យើង ជាមុនសិន។ ខណៈនោះ ប៉ានចាវ ដែលបានធ្លាក់ចូល ក្នុងបំណាងប្រាថ្នាដ៏ជ្រាលជ្រៅរួចទៅ ហើយក៏ស្រែក ឡើងថា៖ «ជោគវាសនារបស់យើង គឺត្រូវតែសម្រេច ឲ្យ បាននៅថ្ងៃនេះតែម្តង! លោកនាយ ប្រមុខក្រុមទូត របស់យើង គ្រាន់តែជា ជនស៊ីវិលធម្មតាម្នាក់ប៉ុណ្ណោះ បើគាត់បានដឹង អំពី គម្រោងការរបស់យើងនេះ ក៏នឹង ភ័យខ្លាចរួចជាស្រេចទៅហើយ ម្យ៉ាងទៀត រាល់ អ្វីៗ ទាំងអស់ក៏នឹងត្រូវនិយាយចេញមកបើកកកាយឲ្យ គេ ដឹងៗ។ ការធ្វើយ៉ាងនេះ មរណភាពឥតន័យ ឥតកេរ្តិ៍ ឈ្មោះ គឺជា វាសនាដែលគ្មានតម្លៃសម្រាប់អ្នកចម្បាំង ដ៏ក្លាហានដូចជាយើងនេះហើយ។ ពេលនោះ អង្គជំនុំ ទាំងមូល ក៏ទទួលឯកភាពគ្នា ធ្វើតាមអ្វី ដែលលោក មេទ័ពបានប្រាថ្នាមក។ ស្របគ្នានោះដែរ លុះពេលរាត្រី




www.facebook.com/7khmer
Fb page : Entertainment And Knowledge

មកដល់កាលណា គាត់នាំកងទាហានតូច របស់គាត់ ចូលទៅដល់ជំរុំពួកមនុស្សព្រៃយ៉ាងរហ័ស។ ពេលនោះ ជួនជា មានខ្យល់ព្យុះយ៉ាងខ្លាំង បោកបក់ចុះមក។ ប៉ានចាវ បានឲ្យទាហាន១០នាក់កាន់ស្គរ ទៅលាក់ខ្លួន នៅពីក្រោយជំរុំតង់ តូចៗ របស់ពួកសត្រូវ ចាំឃ្លាំមើល បើឃើញភ្លើងឆាបឆេះឡើងហើយ ពួកគេត្រូវចាប់ផ្ដើម ទូងស្គរ ហើយ ស្រែកហ៊ោរសន្ធាប់ឲ្យពេញទំហឹង។ ពលទាហានដែលក្រៅពីនេះ ត្រូវកាន់ធ្នូ និង ស្នាគ្រប់ដៃ ត្រូវទៅបង្កប់ខ្លួន នៅតាមច្រកចូលទៅក្នុងបន្ទាយរបស់ សត្រូវ។ ពេលនោះ គាត់ក៏ចាប់ផ្ដើមរុជដុតបន្ទាយ សត្រូវពីទីដែលនៅលើខ្យល់ ខណៈនោះ សម្លេងស្គរ និង សម្រែកហ៊ោរកញ្ច្រៀវក៏ចាប់ផ្ដើមឮយ៉ាងកងរំពងឡើង ចេញមកពីខាងមុខ និង ខាងក្រោយបន្ទាយទាហាន ស៊ុងនុ ដែលកំពុងតែច្រួលច្របល់ ខ្វក់ខ្វល់ ប្រជែងគ្នា រត់ចេញយ៉ាងពពាក់ពពូន។ ប៉ានចាវ បានសម្លាប់ពួក សត្រូវដោយផ្ទាល់ដៃ ស្លាប់ចំនួនបីនាក់ ចំណែកគូកន របស់គាត់វិញ បានកាត់ក្បាលបេសកជនទូត និងបរិវារ ចំនួន៣០នាក់ផ្សេងទៀត។ ទាហានសត្រូវ ដែលនៅ




www.facebook.com/7khmer
Fb page : Entertainment And Knowledge

សល់ពីនេះ ទាំងអស់ជាងមួយរយនាក់ បានត្រូវស្លាប់ក្នុងភ្លើងទាំងអស់។ មួយថ្ងៃបន្ទាប់ពីនោះមក ប៉ានចាវបានប៉ាន់ប្រមាណគំនិតខ្លួនគាត់ ហើយគាត់លើកដៃឡើង គំនាប់ និង និយាយទៅកាន់ប្រមុខក្រុមទូតរបស់គាត់ថា៖ «ថ្វីបើលោកម្ចាស់មិនបានទៅជាមួយនឹងពួកយើងខ្ញុំ កាលពីយប់មិញក៏ដោយ ខ្ញុំក៏មិនបានគិតទេថានឹងយកមុខយកមាត់អ្វី តែម្នាក់ឯងនោះដែរ។ ការណ៍នេះ បានធ្វើឲ្យ កួស៊ុន (ប្រមុខក្រុមទូត?) ពេញចិត្តយ៉ាងខ្លាំង ហើយចំណែក ប៉ានចាវ ក៏បានបញ្ជូនក្បាលនៃប្រមុខការទូត របស់ដែនដីមនុស្សព្រៃ ទៅបង្ហាញស្តេចគ័ង ដែលជាអធិរាជនគរសានសាន។ ព្រឹត្តិការណ៍នេះ បានធ្វើឲ្យនគរសានសានទាំងមូល ធ្លាក់ក្នុងសភាពភ័យខ្លាច និង ញ័ររញ្ជួយ ដែលក្រោយមក ប៉ានចាវបានដើរមួយជំហានទៀត ដើម្បីធ្វើឲ្យអាណាចក្រនេះបានស្រាកស្រាន្តឡើងវិញ គឺ គាត់បានចេញសេចក្តីប្រកាសព័ត៌មានជាសាធារណៈ។ ខណៈនោះ គាត់បានចាប់រាជបុត្រារបស់នគរសានសាន ជាផ្ទួរ ហើយគាត់ក៏វិលទៅស្រុកវិញ និង ធ្វើរបាយការណ៍ ថ្វាយស្តេច





www.facebook.com/7khmer
Fb page : Entertainment  And Knowledge

ទូត»/(សៀវភៅហូវហានស៊ី ជំពូកទី៤៧ ទំព័របន្តបន្ទាប់ទី១ ដល់ ទី២)។

ប្រការទី 1 ៖ (២). ទី២៖ ការដុតឃ្លាំង,

សេចក្តីអធិប្បាយ៖ ទូមូ ពោលថា៖ «មានដូចជា គ្រឿងសម្ភារៈ ឧបភោគ បរិភោគ គ្រឿងបង្ការទុក ឥន្ធនៈ និង ចំណីសត្វ»។ ការកេង បានផ្តល់យោបល់ថ្វាយស្តេច វិនទី នៃរាជវង្សសួយ ឲ្យចូលវាយឆ្មក់តាមដំណាក់កាល និង ចូលដុតឃ្លាំងធញ្ញជាតិរបស់ពួកគាងណានបះបោរ ដើម្បីនឹងបង្ក្រាបពួកនេះ ដែលគោលនយោបាយបែបនេះ ក្នុងស្ថានការណ៍វែងឆ្ងាយ បានបង្ហាញថា ទទួលជ័យជំនះទាំងស្រុង។

ប្រការទី 1 ៖ (៣). ទី៣៖ ការដុតក្បួនរទេះដឹកជញ្ជូនស្បៀង,

សេចក្តីអធិប្បាយ៖ មានឧទាហរណ៍ជាច្រើន ដែលត្រូវបាន គេលើកយកមកបង្ហាញ ឲ្យឃើញតាមរយៈ ការបំផ្លាញរទេះដឹកស្បៀង និង អាវុធយុទ្ធភ័ណ្ឌ របស់ យួនសាវ (វីរៈជនក្នុងរឿងសាមកុក អ្នកខ្លះ គេហៅ





www.facebook.com/7khmer
Fb page : Entertainment And Knowledge

ឈ្មោះគាត់ថា អ្នួនសៀវ) កាលពី ឆ្នាំ២០០ នៃ គ.ស ជាដើម។

ប្រការទី 1 ៖ (៤). ទី៤៖ ការដុតឃ្លាំងអាវុធ និង រោងចក្រផលិតអាវុធទាំងឡាយ,

សេចក្តីអធិប្បាយ៖ ទូមូ ពោលថា វត្ថុដែលមាននៅក្នុងឃ្លាំងអាវុធ និង ក្នុងរោងចក្រផលិតអាវុធ គឺវាដូចតែគ្នាទេ។ គាត់បានកំណត់ប្រភេទអាវុធ និង ឧបករណ៍ ប្រើប្រាស់ ដទៃទៀត មានដូចជា៖ មាសប្រាក់ និង ក្រណាត់ (សូមប្រៀបធៀប ជាមួយ ជំពូកទី៧ ប្រការទី ១១។

ប្រការទី 1 ៖ (៥). ទី៥៖ ការបាញ់ ឬ ការគប់ដុំភ្លើងចូលក្នុងចំណោមពួកសត្រូវ។

សេចក្តីអធិប្បាយ៖ ទូមូ បរិយាយនៅក្នុងស្នាដៃទុងធានថា៖ «ចូរគប់ដុំភ្លើងចូលក្នុងបន្ទាយសត្រូវ។ វិធីធ្វើការនេះ គឺត្រូវដុតចុងព្រួញឲ្យឆេះ ដោយជ្រមុជអុជវាទៅក្នុងជើងក្រាន រួចហើយបាញ់វាចេញទៅ ដោយប្រើស្នាដែលមានកម្លាំងខ្លាំងបញ្ចូលទៅក្នុងជួរទាហានសត្រូវ»។





www.facebook.com/7khmer
Fb page : Entertainment And Knowledge

ប្រការទី 2 ៖ (១). ដើម្បីធ្វើការវាយប្រយុទ្ធបាន យើងត្រូវតែមានមធ្យោបាយត្រៀមបម្រុងទុកជាមុន ឲ្យបានគ្រប់គ្រាន់សិន។

សេចក្ដីអធិប្បាយ៖ ឆាវកុង គិតថា ប្រយោគខាងលើ គឺចង់និយាយសំដៅដល់ «ជនក្បត់ទាំងឡាយ ដែលមាននៅក្នុងបន្ទាយសត្រូវ»។ ក៏ប៉ុន្តែ ឆិនហាវ បានពោលដោយទំនងជាត្រូវជាង តាមសេចក្ដីថា៖ «ជាទូទៅ យើងត្រូវតែរង់ចាំឱកាសល្អ ជនក្បត់ ក៏មិនមែនចេះតែសំបូរទេ ហើយពួកគេក៏មិនចាំតែជួយយើងនោះដែរ»។ ចំណែក ចាលីនពោលថា៖ យើងត្រូវចេះឆ្លៀតឱកាសប្រើប្រាស់កម្លាំងខ្យល់បក់ និង រដូវរាំងស្ងួត»។

ប្រការទី 2 ៖ (២). វត្ថុធាតុសម្រាប់ការដុតភ្លើង យើងគួរតែត្រៀមរៀបចំទុកប្រើប្រាស់ឲ្យបានរួចរាល់ជាស្រេច។

សេចក្ដីអធិប្បាយ៖ ទូមូ ផ្ដល់ជាគំនិតថា៖ សម្ភារៈប្រដាប់ប្រដារ ដើម្បីដុតភ្លើង មាន៖ «ស្មៅក្រៀម, ត្រែង, បបុស, ឈើ, ចំបើង, ខ្លាញ់ និង ប្រេង .ល.»។ យើងត្រូវមានប្រដាប់ប្រដារប្រើប្រាស់ទាំងនេះ នៅនឹង




www.facebook.com/7khmer
Fb page : Entertainment And Knowledge

ដៃយើងជាស្រេច។ ចាងអុីពោលថាជា៖ «ធ្នូនសម្រាប់បង្កាត់ចម្លងភ្លើង និង ប្រដាប់ប្រដាបង្កាត់ភ្លើង»។

ប្រការទី 3 ៖ មានរដូវកាល អំណោយផល ក្នុងការវាយប្រហារដោយភ្លើង និង ថ្ងៃពិសេស ដើម្បីចាប់ផ្ដើមបង្កឲ្យមានអគ្គីភ័យកើតឡើង។

ប្រការទី 4 ៖ (១). រដូវកាលអំណោយផល គឺ នៅពេលណាដែលមានអាកាសធាតុក្ដៅហួតហែង, ថ្ងៃពិសេស គឺ ថ្ងៃណា (តាមពិតគឺរាត្រី) ដែលព្រះច័ន្ទស្ថិតនៅក្នុងចំណោម នៃ ហ្វូងតារា តាមទម្រង់រូបរាងដូចជាកន្ត្រង, ជញ្ជាំង / កំផែង, ស្លាប ឬ ជាគំនូសកាត់ទទឹង,

សេចក្ដីអធិប្បាយ៖ ថ្ងៃទាំងនោះ គឺមានតាមលំដាប់លំដោយដូចតទៅនេះ ថ្ងៃទី៧ ទី១៤ ទី២៧ និង ទី២៨ គិតតាមយាមក្រឡា ដំណើរដួងតារា ទាំង២៨ ដែលស្របគ្នា ដោយអន្លើទៅនឹង ហ្វូងផ្កាយសាហ្គិតារុស (បញ្ជីវិចិត្ររូប ខាងចុងសៀវភៅ, ទំព័រទី២៤០, រូបទី១ (ក) និង ទំព័រទី២៤១, រូបទី១ (ខ) ៖ ផ្កាយប៉ាន់តែ ដែលមានតារាគោចរ កំឡុងពីថ្ងៃទី២២ ខែវិច្ឆិកា ដល់ថ្ងៃ





www.facebook.com/7khmer
Fb page : Entertainment And Knowledge

ទី២២ ខែផ្ទុ តារាវិទូខ្លះថា វាមានរាង ដូចជា ព្រួញ, តំណាងសភាវភ្លើង មានរូបសម្គាល់ពាក់កណ្ដាលខ្លួនជាមនុស្ស និង ពាក់កណ្ដាលខ្លួនទៀត ជាសត្វសេះ), ពីកាស៊ុស (បញ្ជីវិចិត្ររូបខាងចុងសៀវភៅទំព័រទី២៤២ រូបទី២៖ ផ្កាយសេះ មានស្លាបហោះ នៃ ក្រុមផ្កាយភាគខាងជើង) ក្រេទ័រ (បញ្ជីវិចិត្ររូប ខាងចុង សៀវភៅ, ទំព័រទី២៤៣ រូបទី៣៖ ផ្កាយពែងតែ ក្រុមផ្កាយនៅអឌ្ឍគោលខាងត្បូង) និង គ័រវុស (បញ្ជីវិចិត្ររូប ខាងចុង សៀវភៅ, ទំព័រទី២៤៤ រូបទី៤៖ ផ្កាយខ្លែង ក្រុមផ្កាយនៅអឌ្ឍគោលខាងត្បូង)។

ប្រការទី 4 ៖ (២). ថ្ងៃទាំង៤នេះ ជាថ្ងៃមានខ្យល់បក់បោក។

ប្រការទី 5 ៖ នៅក្នុងការវាយប្រហារដោយភ្លើង យើងត្រូវត្រៀមខ្លួន ដើម្បីជួបប្រទះ និង ធ្វើរឿង ឲ្យប្រព្រឹត្តិទៅ ចំនួន ៥ប្រការ។

ប្រការទី 6 ៖ ទី១៖ ពេលណាភ្លើងឆាបឆេះក្នុងបន្ទាយសត្រូវហើយ ត្រូវឆ្លើយតបបន្ថែមពីលើ ដោយការវាយប្រហារពីខាងក្រៅចូលទៅសង្គ្រប់បន្ថែមទៀត។




www.facebook.com/7khmer
Fb page : Entertainment And Knowledge

ប្រការទី 7 ៖ ទី២៖ បើបានដុតភ្លើងឆេះឡើងហើយ ក៏ប៉ុន្តែ ទាហានខាងសត្រូវ នៅតែរក្សាភាពស្ងប់ស្ងាត់ដដែល ចូរសម្ងំរង់ចាំមើលពួកវា ហើយ កុំអាលទាន់វាយប្រហារឲ្យសោះ។

សេចក្តីអធិប្បាយ៖ កម្មវត្ថុ ដែលសំខាន់ជាងគេ នៃការវាយប្រហារដោយភ្លើង គឺការធ្វើឲ្យពួកសត្រូវ ធ្លាក់ទៅក្នុងសភាពវឹកវរប្រទ្បឹបល់។ បើសិនជា ផលបែបនេះ វាមិនហុចឲ្យយើងទេ គឺមានន័យថា ពួកសត្រូវ វាបានត្រៀមខ្លួនរួចរាល់រង់ចាំទទួលយើងហើយ។ ដូចនេះ ចូរដាស់តឿនគ្នាយើង ឲ្យប្រុងប្រយ័ត្ន ឲ្យមែនទែន។

ប្រការទី 8 ៖ ទី៣៖ នៅពេល ដែលភ្លើងឆាបឆេះពេញបន្ទុក ហើយ ចូរចូលទៅចោមវាយពួកសត្រូវបន្ថែមទៀត បើអាចចូលទៅបាន, តែបើចូលទៅមិនរួចទេ ចូររក្សាទីត្រង់ចំណុចណា ដែលអ្នកកំពុងតែស្ថិតនៅនោះបានហើយ។

សេចក្តីអធិប្បាយ៖ ឆាវកុង ពោលថា៖ «បើសិនជាអ្នកឃើញផ្លូវណា ដែលអាចទៅរួច ចូរអ្នកសម្រុកចូលទៅមុខទៀត តែបើអ្នកឃើញថា ការលំបាកវាធំធេង




www.facebook.com/7khmer
Fb page : Entertainment And Knowledge

ពេក មិនអាចជំនះរុលទៅមុខបានទេ ចូរអ្នកដកថយមកវិញ»។

ប្រការទី 9 ៖ ទី៩៖ បើសិនជា អ្នកអាចធ្វើការវាយប្រហារដោយភ្លើងចូលទៅពីខាងក្រៅបាន ចូរកុំចាំទាល់តែភ្លើងឆាបឆេះចេញពីខាងក្នុងបន្ទាយ (សត្រូវ) ចេញមកសិននោះ គឺអ្នកត្រូវវាយប្រហារឲ្យទាន់ឱកាសល្អ។

សេចក្ដីអធិប្បាយ៖ ទូមូ ពោលថា កថាខ័ណ្ឌខាងដើមមានសេចក្ដីអះអាងចំពោះការដុតភ្លើងឲ្យឆាបឆេះឡើងក្នុងបន្ទាយសត្រូវ (ទោះដោយចៃដន្យក៏ដោយ គឺ យើងនៅតែមានចេតនាចង់ដុតដដែលទេ ទោះជាដុតដោយពួកអ្នកនាំបះបោរក៏ដោយ)។ គាត់បន្តទៅទៀតថា៖ «ក៏ប៉ុន្តែ បើសិនជាសត្រូវនៅចំទី ដែលមានសម្រាមកម្ទេចកម្ទី មានស្មៅស៊ុបទ្រុព ឬក៏ សត្រូវបានបោះជំរុំនៅលើទីតាំង ដែលអាចឲ្យយើងដុតបាន យើងក៏ត្រូវយកភ្លើងតាមខ្លួន ដើម្បីទុកតទល់ ជាមួយពួកវា ក្នុងរដូវកាលអំណោយផលដែរ កុំរំពឹងចាំ ទាល់តែមានភ្លើងឆេះ ពីខាងក្នុងបន្ទាយមកវិញ តែផ្ទុយទៅវិញ ដោយសារ



www.facebook.com/7khmer



Fb page : Entertainment And Knowledge

សេចក្ដីខ្លាចរអែង ពួកបច្ចាមិត្រអាចនឹងដុតស្មៅបន្លែដែលនៅជុំវិញនោះ ដោយខ្លួនឯងក៏ថាបាន បើដូច្នេះមែន វានាំឲ្យការខិតខំប្រឹងប្រែង របស់យើង ទៅជាឥតបានផលអ្វីទៅវិញ»។

ជាតួយ៉ាង មេទ័ព លីលីង ឪល្បីល្បាញ មានម្ដងនោះ គាត់ច្បាំងជាមួយមេទ័ព ស៊ុងនុ តាមវិធីដូចគ្នានេះដែរ។ ជាបន្ទាប់មក មេទ័ពស៊ុងនុ ក៏គិតយកប្រៀបដោយប្រើ កម្លាំងខ្យល់បក់ព្យាយាមបាញ់ភ្លើងចូលក្នុងបន្ទាយមេទ័ពចិន (លីលីង) ក៏ប៉ុន្តែ មានតែកម្ទេចកម្ទីងាយឆេះបន្តិចបន្តួចប៉ុណ្ណោះ ដែលនៅជិតបន្ទាយកងទ័ពចិន ព្រោះវត្ថុធាតុដែលងាយឆេះទាំងឡាយ ត្រូវបានមេទ័ពចិនបញ្ជា ឲ្យពលទាហានរបស់គាត់ដុតចោលជាមុន រួចទៅហើយ។

តួយ៉ាងមួយទៀត ប៉ោថៃ មេចលនាបះបោរពួកចោរកន្សែងលឿង បានបរាជ័យយ៉ាងដំណំកាលពីឆ្នាំ១៨៤ នៃ គ.ស ដោយសារតែសេចក្ដីធ្វេស មិនបានប្រយ័ត្នប្រយែងយ៉ាងធម្មតាបែបនេះឯង។ ក្បាលទ័ពធំ




www.facebook.com/7khmer
Fb page : Entertainment And Knowledge

របស់គាត់ (ប៉ោថៃ ចោរកន្សែងលឿង) កំពុងតែឡោមព័ទ្ធក្រុងចាងស៊ី ដែលគ្រប់គ្រងដោយ ហ័ងហ៊្វូស៊ុង។ មានតែទាហានរក្សាក្រុងតិចតួចប៉ុណ្ណោះនាយទាហានរក្សាក្រុងមានអារម្មណ៍ភ័យញ័រ រហូតដល់ជួរទាហានទៀត ឃើញដូចនេះ ហ័ងហ៊្វូស៊ុង ក៏ហៅនាយទាហានរបស់គាត់ ឲ្យមកជួបជុំ ហើយក៏និយាយថា៖ «នៅក្នុងសឹកសង្គ្រាម មានវិធីវាយប្រហារមិនផ្ទាល់ ច្រើនបែបណាស់ ចំនួនកម្លាំងទ័ព វាមិនមែនជា អ្វីៗ ទាំងអស់នោះទេ (អ្នកអត្ថាធិប្បាយត្រង់ចំណុចនេះ បានដកស្រង់សម្ដី របស់ ស៊ុនអ៊្វូ នៅ ជំពូកទី៥ ប្រការទី៥, ទី៦ និង ទី១០) ឥឡូវនេះ ពួកទាហានឧទ្ទាម វាទៅតាំងបន្ទាយនៅកណ្ដាលស្មៅក្រាស់ហើយ ពេលណាមានខ្យល់បក់មក វាជាទីងាយដុតឲ្យឆេះណាស់។ បើយើងបាញ់គ្រាប់ភ្លើងចូលបន្ទាយវានាពេលយប់ ពួកសត្រូវនឹងភ័យស្លន់ស្លោ ពេលនោះហើយ ដែលយើងអាចវាយឆ្មក់ ហើយ ក៏សង្គ្រប់លើពួកវាពីគ្រប់ទិសតែម្ដង (ការណ៍នេះ វាប្រណាំងប្រជែងជាមួយជ័យជំនះ របស់ឆានតាន់, បានបរិយាយលើទំព័រទី៩០ នៅ តម្រាដើម)។




www.facebook.com/7khmer
Fb page : Entertainment And Knowledge

នាល្ងាចដដែលនោះ ខ្យល់ជំនោរ បានបក់បោកមក មានឱកាសដូចនេះហើយ ហាំងហ្វីស៊ុង ក៏ផ្ដល់ឱវាទ ចំពោះពលទាហាន របស់គាត់ ឲ្យចងបបុសជាបាច់ បង្កើតជាដុំចន្លុះឡើង ហើយ ឡើងទៅយាមពីលើ កំពែងក្រុង បន្ទាប់មក គាត់ក៏បញ្ជូនទាហានក្លាហាន ជាងគេ មួយកង ឲ្យលបចូល ទៅក្នុងបន្ទាយសត្រូវ ដុតភ្លើង ស្រែកហោរកញ្ជ្រៀវ ឲ្យកងរំពងឡើង។ ក្នុងពេលដំណាលគ្នានោះដែរ កងទាហាន ដែលនៅ យាមលើកំពែងក្រុង ក៏បាញ់គ្រប់ភ្លើងយ៉ាងច្រើនសន្ធឹក សន្ធាប់ ចម្រុះចូលទៅក្នុងបន្ទាយពួកចោរកន្សែងលឿង ហើយ ហាំងហ្វីស៊ុង ក៏ឲ្យទាហានទូងស្គរឡើង ហើយ ដឹកនាំទាហានវាយសម្រុក ចូលទៅក្នុងបន្ទាយចោរ យ៉ាងតក់ក្រហល់ ធ្វើឲ្យ ពួកទាហានចោរកន្សែងលឿង ភ័យរីករវរចលាចល និង ធ្វើឲ្យពួកវារត់ដាំក្បាលពពាក់ ពពូន»។ (សៀវភៅ ហូវហានស៊ុ ជំពូកទី៧១។)

ប្រការទី 10 ៖ ទី៥៖ នៅពេល ដែលអ្នកចាប់ផ្ដើម ដុតភ្លើង ចូរដុតពីខាងលើខ្យល់។ មិនត្រូវចូលទៅវាយប្រយុទ្ធពីក្រោម ខ្យល់ឡើយ។




www.facebook.com/7khmer
Fb page : Entertainment  And Knowledge

សេចក្តីអធិប្បាយ៖ ចាងអ៊ី និង ទូអ៊ី ពោលថា «នៅពេលដែលអ្នកដុតភ្លើង សត្រូវនឹងថយរត់ចេញពីភ្លើងនោះ បើសិនជា អ្នកទៅតទល់ប្រឆាំងនឹងដំណើរដកថយរបស់វា ហើយវាយប្រហារវានោះ វានឹងវាយតបវិញ ទាល់តែដល់ទីបំផុត ព្រោះពួកវាអស់ក្តីសង្ឃឹមដែលការណ៍នេះ វាមិនធ្វើឲ្យអ្នកទទួលជោគជ័យទេ»។ ទូមូ បានផ្តល់ឧទាហរណ៍វាងច្បាស់ជាងនេះបន្តិច មានសេចក្តីថា៖ «បើសិនជា ខ្យល់បក់មកពីទិសខាងកើត ចូរដុតភ្លើងពីទិសខាងកើត នៃ បន្ទាយសត្រូវ តែបើអ្នកចូលទៅវាយប្រហារសត្រូវពីទិសខាងលិចវិញ អ្នកនឹងទទួលការឈឺចាប់ ដូចដែលសត្រូវ វារងការឈឺចាប់ដូច្នោះដែរ»។

ប្រការទី 11 ៖ ខ្យល់បក់មកក្នុងពេលថ្ងៃ មានរយៈពេលយូរ ក៏ប៉ុន្តែជំនោរពេលរាត្រីធ្លាក់មកក្នុងរយៈពេលខ្លី។

សេចក្តីអធិប្បាយ៖ បើប្រៀបធៀបជាមួយភាសិតរបស់ឡៅសឺ ដែលមានសេចក្តីថា៖ «ព្យុះកំណាចមិនអាចនៅបោកបក់បោកពេញមួយព្រឹកទេ» (តាវតេជីង ជំពូក




www.facebook.com/7khmer
Fb page : Entertainment And Knowledge

ទី២៣)។ ម៉ីយ៉ាវឆិន និង វ៉ាងស៊ី ពោលថា៖ «វាយោ ពេលថ្ងៃស្ងប់ស្ងាត់នាពេលយប់មកដល់ ហើយ ជំនោរ ពេលរាត្រីមានរហូតដល់ពេលថ្ងៃ។ នេះជា អ្វីៗ ដែល កើតឡើងជាច្បាប់ទូទៅ»។ ប្រហែលជា វាត្រូវល្មមសម រម្យហើយ ទៅនឹងបាតុភូត ដែលគេតែងតែសង្កេត ឃើញ ក៏ប៉ុន្តែវិធីទទួលបានដូចមានក្នុងន័យសេចក្តីនេះ វាមិនសូវជាក់ស្តែងប៉ុន្មានទេ។

ប្រការទី 12 ៖ ក្នុងរាល់ដំណើរទាំងអស់ របស់កងទ័ព រឿង ដែលត្រូវកើតឡើង ដោយទាក់ទងនឹងភ្លើង គឺត្រូវតែយល់ដឹង អំពី ចលនាតារាគោចរណ៍ ហើយក៏ត្រូវចេះគណនា ត្រូវចេះ សង្កេតរកមើលថ្ងៃ ដែលមាននក្ខត្តឫក្សល្អផងដែរ។

សេចក្តីអធិប្បាយ៖ ទូមូ ពោលថា៖ «យើងត្រូវចេះ គណនាតាមដំណើរតារាគោចរ ហើយរើសរកមើលថ្ងៃ ណា ដែលមានខ្យល់បក់ខ្លាំង មុននឹងយើងវាយប្រហារ ដោយភ្លើង»។ ឯចំណែក ចាងអ៊ី វិញ ហាក់ដូចជា បកស្រាយសេចក្តីតាមន័យផ្សេងទៅវិញថា៖ «យើងមិន ត្រូវដឹងត្រឹមតែ អំពី របៀបវាយប្រយុទ្ធទៅលើបច្ចាមិត្រ




www.facebook.com/7khmer
Fb page : Entertainment And Knowledge

របស់យើងប៉ុណ្ណោះទេ ក៏ប៉ុន្តែ យើងក៏ត្រូវតែការពារខ្លួនយើង តទល់នឹងការវាយប្រហារ តាមរបៀបនេះមកលើយើងផងដែរ»។

ប្រការទី 13 ៖ ដូចនេះ នរជនណា ដែលចេះប្រើភ្លើង ជាជំនួយក្នុងការវាយប្រយុទ្ធ គឺបានបង្ហាញឲ្យឃើញនូវ សតិបញ្ញា ហើយនរជនណា ដែលចេះប្រើទឹកជាជំនួយក្នុងការវាយប្រហារ គឺ បានចំណេញខាងកម្លាំង។

ប្រការទី 14 ៖ តាមធ្យោបាយ ដោយការប្រើទឹក ជាជំនួយកងទាហានអាចនឹងត្រូវបានគេស្ទាក់ផ្លូវ ក៏ប៉ុន្តែ ការណ៍នេះមិនបានធ្វើឲ្យ ពួកគេបាត់បង់នូវរបស់របរទាំងអស់ ដែលពួកគេត្រូវការប្រើប្រាស់ ជាចាំបាច់នោះទេ។

សេចក្ដីអធិប្បាយ៖ កំណត់ត្រារបស់ ឆាវកុង មានជាសេចក្ដីថា៖ «យើងមិនមែនធ្វើ ត្រឹមតែឲ្យរាំងស្ទះផ្លូវរបស់សត្រូវ ឬក៏ បំបែកទាហានពួកវាប៉ុណ្ណោះទេ តែយើងថែមទាំងកម្ទេចចោល នូវ ឃ្លាំងប្រមូលផ្ដុំរបស់ពួកវាទៀតផង»។ ទឹកអាចជួយយើងបានច្រើន ប៉ុន្តែវាខ្វះនូវថាមពលរំលាយវិសម្បើម មិនដូចជាភ្លើងទេ។



www.facebook.com/7khmer
Fb page : Entertainment And Knowledge

នេះហើយ ជាហេតុផល ដែល ចាងអ៊ី បានរាប់បញ្ចូល ថា ហេតុអ្វីបានជាប្រយោគ មុនៗ ត្រូវបានគេបំភ្លេចដល់ទៅចំនួន២ប្រយោគ តែចំណែកឯការវាយប្រហារដោយភ្លើងត្រូវបានគេពិភាក្សាយ៉ាងពិស្តារតែមួយរឿងយ៉ាងនេះទៅវិញ?

ចំណែក ក្នុងស្នាដៃ របស់ វូអ៊ូ (ជំពូកទី៤) បាននិយាយថា ហេតុនេះហើយ វាមានតម្រុយពីរយ៉ាង ជាសេចក្ដីថា៖ «បើសិនជា កងទ័ពតាំងបន្ទាយនៅលើទីវាលទំនាបសើម ដែលទឹកមិនអាចនឹងហូរចេញបានលុះដល់ពេលមានភ្លៀងធ្លាក់មកខ្លាំង ពួកគេអាចនឹងលិចលង់ក្នុងទឹកជំនន់ តែបើកងទ័ពទៅតាំងបន្ទាយនៅព្រៃរហោស្ថានមានស្មៅស៊ុបទ្រុព និង រុក្ខជាតិមានបន្លាព្រមទាំងមានខ្យល់បក់កាត់ផងនោះ ករណីយ៉ាងនេះ ពួកគេអាចនឹងត្រូវបានកម្ទេចដោយភ្លើងហើយ»។

ប្រការទី 15 ៖ សេចក្ដីមិនសប្បាយចិត្ត គឺជា ផលកម្ម របស់នរជនណា ដែលព្យាយាមយកឈ្នះសឹកសង្គ្រាម ហើយបានទទួលជ័យជំនះ ដោយមិនចាំបាច់ប្រើប្រាស់អស់នូវថាមពល




www.facebook.com/7khmer
Fb page : Entertainment And Knowledge

របស់ខ្លួន ព្រោះថា នរជននោះទទួលបានតែលទ្ធផល ជាការខ្ជះខ្ជាយពេលវេលា ដោយមិនបានរៀនអ្វីថែមទៀតឡើយ។

សេចក្ដីអធិប្បាយ៖ នេះជាគំនិតមួយ ក្នុងចំណោមគំនិតវិលវល់បំផុត ដែលមាននៅក្នុងខ្លួន ស៊ុនអ៊្វ។ ឆាវកុង ពោលថា៖ «បំណាច់រង្វាន់ចំពោះការបំពេញការងារល្អ មិនត្រូវឲ្យយឺតទេ ទោះបីជាក្នុងរយៈកាលតែមួយថ្ងៃក៏ដោយ»។ ទូមូ ពោលថា៖ «បើសិនជា អ្នកមិនយកឱកាស ដើម្បីសម្រេច និង ផ្ដល់រង្វាន់សរសើរទេមនុស្សនៅក្រោមឱវាទ របស់អ្នក ក៏នឹងមិនស្ដាប់បញ្ជារបស់អ្នកដែរហើយពេលនោះអ្នកក៏នឹងជួបគ្រោះមហន្តរាយហើយ»។ ទោះជាយ៉ាងណាក៏ដោយ តាមហេតុផលជាច្រើន បានស្ដែងឡើងយ៉ាងនេះ បើទោះបីជា នរជនណាមានបណ្ដាស័ក្តិ ជំនាញការសង្គ្រាមសម្បើមយ៉ាងណាក៏ដោយចុះ ខ្ញុំនៅតែពេញចិត្តនឹងការបកស្រាយ តាមដែល ម៉ីយ៉ាវឆិន បានផ្ដល់ជាយោបល់មក ហើយខ្ញុំសូមដកស្រង់ ជាសេចក្ដីថា៖ «នរជនណា ដែលប្រាថ្នានឹងយក ជ័យជំនះក្នុងសឹកសង្គ្រាម ឲ្យទាល់តែបាននោះ គឺ ក្នុងការវាយប្រហារ





www.facebook.com/7khmer
Fb page : Entertainment And Knowledge

ត្រូវចេះដណ្ដើមយកឱកាសល្អ ដែលវាមកដល់ ហើយចូរកុំរួញរា ត្រូវគន់គូរវាស់វែង ដោយភាពក្លាហាន នោះគឺចង់និយាយថា: គេត្រូវបង្ខំចិត្តចាប់យកវិធីនានា ដូចជា វាយប្រហារដោយភ្លើង ដោយទឹក និង តាមវិធីផ្សេងទៀត ដែលស្រដៀងគ្នានេះដែរ។ អ្វីដែលគេមិនខិតខំធ្វើ និង អ្វីដែលជាតឹកតាងបង្ហាញចេញមកជាគ្រោះចង្រៃនោះ គឺ ការដែលអង្គុយនៅស្ងៀម និងរមិលចំពោះការមានប្រៀប ដែលមានក្នុងដៃរួចហើយនេះឯង»។

ប្រការទី **16** ៖ ដូចនេះភាសិតដែលថា៖ «អ្នកគ្រប់គ្រង ដែលត្រចង់អង់អាច គេដាក់ផែនការរបស់គេ ឲ្យឆ្ពោះទៅមុខបានយ៉ាងប្រសើរ, មេទ័ពដ៏ល្អ គឺចេះប្រើប្រាស់ធនធានរបស់ខ្លួន។

សេចក្ដីអធិប្បាយ៖ ទូមូ បានដកស្រង់សេចក្ដី ពី ស្នាដៃសានល្វេ ជំពូកទី២ ជាបន្តថា៖ «ស្ដេចចម្បាំងគ្រប់គ្រងកងទ័ព ដោយអំណាចរបស់ទ្រង់, ចិញ្ចឹមថែរក្សាពួកគេដោយសុចរិត ដោយសារចំណាច់រង្វាន់ហ្នឹងហើយទើបញុាំងពួកគេឲ្យខិតខំបំពេញការងារ។ បើសិនជា សេចក្ដី




www.facebook.com/7khmer
Fb page : Entertainment And Knowledge

សុចរិតស្អុយរលួយហើយ ក៏នឹងនាំឲ្យមានភាពរាំងស្ទះចំពោះការរីកចម្រើន ហើយបើបំណាច់រង្វាន់មិនមានគ្រាប់គ្រាន់ទេ បញ្ហារបស់ទ្រង់ ក៏គ្មាននរណាគេគោរពដែរ»។

ប្រការទី **17៖** ចូរកុំអាលធ្វើចលនា បើទោះជា អ្នកឃើញថាមានឱកាសល្អហើយក៏ដោយ, ចូរកុំអាលប្រើកម្លាំងទ័ព បើទោះជា អ្នកឃើញថា នឹងបានចំណេញ អ្វីៗ ទាំងឡាយទាំងពួងក៏ដោយ, ចូរកុំអាលវាយប្រហារ បើទោះជាអ្នកឈរជើងលើទីតាំងជ័យភូមិក៏ដោយ។

សេចក្ដីអធិប្បាយ៖ ពេលនេះ ស៊ុនអ៊ូ ហាក់ដូចជា ស្ដែងចេញមកក្នុងសភាពប្រយ័ត្នប្រយែង ហួសហេតុពេកក៏ប៉ុន្តែ គាត់មិនដែលចាកចេញទៅឆ្ងាយ ពីប្រធានបទដូចដែលបានចារជាសេចក្ដីគួរឲ្យកត់សម្គាល់ ក្នុងគម្ពីរតាវតេជីង ជំពូកទី៦៩ឡើយ ដែលចំណុចនោះ មានសេចក្ដីថា៖ «ខ្ញុំមិនហ៊ានផ្ដើមគំនិតធ្វើអ្វីថ្មីទេ ប៉ុន្តែខ្ញុំពេញចិត្តនឹងចាត់ការនូវកិច្ចការពារខ្លួន, ហើយខ្ញុំមិន




www.facebook.com/7khmer
Fb page : Entertainment And Knowledge

ហ៊ានសម្រុកចូលទៅមុខសូម្បីតែមួយអ៊ីញ ប៉ុន្តែខ្ញុំពេញចិត្តនឹងដកថយមួយជំហានវិញ»។

ប្រការទី 18 ៖ គ្មានមេដឹកនាំណា ដែលដាក់ទាហាន ចូលក្នុងសមរភូមិ ដោយឲ្យពួកគេ ត្រឹមតែបំពេញបំណង ចងអាឃាត គំនុំផ្ទាល់ខ្លួនរបស់គាត់នោះទេ, ហើយក៏គ្មានមេទ័ពរូបណាដែលចូលទៅច្បាំងតាមធម្មតាដោយគ្មានកំហឹងដែរ។

ប្រការទី 19 ៖ បើជូនជា ឱកាលល្អ របស់អ្នក មកដល់ហើយ ចូរចល័តទ័ពទៅខាងមុខ, តែបើឱកាសល្អមិនទាន់មកដល់ទេ ចូរនៅត្រឹមទីណា ដែលអ្នកកំពុងតែនៅនេះសិនចុះ។

សេចក្តីអធិប្បាយ៖ ចំណុចនេះ និយាយម្តងទៀតផ្ទួនលើ ជំពូកទី៩ ប្រការទី១៧។ ត្រង់ចំណុចនេះ ខ្ញុំមានអារម្មណ៍ជឿទុកចិត្តបានថា វាជា ចំណុចថែមថយព្រោះមានភស្តុតាងបញ្ជាក់ថា ប្រការទី២០ ខាងក្រោមនេះ នឹងនិយាយបន្តពីប្រការទី១៨ (ក្នុងជំពូកដដែល)។

ប្រការទី 20 ៖ កំហឹង អាចនឹងមានពេលផ្លាស់ប្តូរ ទៅជាការត្រេកត្រអាល, ចំណែក អារម្មណ៍រំខានឆាឆៅ អាចនឹងយកឈ្នះបាន ដោយការថ្នាក់ថ្នមយកចិត្តយកថ្លើម។




www.facebook.com/7khmer
Fb page : Entertainment And Knowledge

ប្រការទី 21 ៖ (១). ក៏ប៉ុន្តែ អាណាចក្រមួយ ដែលត្រូវបានគេញាំញី បំផ្លិចបំផ្លាញ ឲ្យខ្ទេចខ្ទី ទៅហើយនោះ វាមិនអាចនឹងងាកមករកសភាពដើមវិញបានទេ។

*សេចក្ដីអធិប្បាយ៖ គឺនគរអ៊ូ នេះឯង ដែលត្រូវបានវាសនាចារមកថា ជាឧទាហរណ៍ ដ៏ស្រងេះស្រងោច នៃភាសិតនេះ។*

ប្រការទី 21 (២). ហើយក៏ដូចជា អ្នកស្លាប់ ដែលមិនអាចនឹងប្រស់ជីវិត ឲ្យរស់វិញបានដែរ។

ប្រការទី 22 ៖ ដូចនេះ មេដឹកនាំដ៏ឆ្នើម គឺគាត់យកចិត្តទុកដាក់ណាស់ (ក្នុងកិច្ចការរបស់គាត់) ហើយមេទ័ពដែលល្អ គឺ ពោរពេញទៅដោយ ការប្រុងប្រយ័ត្ន។ ទាំងនេះ ជាវិធីដើម្បីរក្សាប្រទេសជាតិ ឲ្យនៅតែមានសន្តិភាព និង គ្រងរក្សាពលទាហានមិនឲ្យខ្ចាត់ព្រាត់។

*សេចក្ដីអធិប្បាយ៖ លុះត្រាតែអ្នកចូលក្នុងរូងខ្លា ទើបអ្នកអាចចាប់កូនខ្លាបាន។*





www.facebook.com/7khmer
Fb page : Entertainment And Knowledge

## ជំពូកទី 13. **ការប្រើចារកម្ម / ការប្រើសតបញ្ញា**

ប្រការទី **1** ៖ (១). ស៊ុនអ៊ូ ពោលថា៖ បើគេណ្ណកងទ័ព ដែលមានពលទាហានត្រឹមតែ ចំនួន១០០,០០០នាក់ ហើយចល័តពួកគេទៅ**កាន់**ទីឆ្ងាយ គឺបានធ្វើឲ្យ ប្រជាជនខាតបង់យ៉ាងច្រើន ហើយក៏ជា ការចាក់បង្ហូរធនធានរបស់រដ្ឋចេញទៅផងដែរ។ ចំណាយប្រចាំថ្ងៃ ក្នុងមួយថ្ងៃ នឹងឡើងដល់ចំនួន ១,០០០ អោន នៃ ប្រាក់សុទ្ធងណោះ។

*សេចក្ដីអធិប្បាយ៖ សូមប្រៀបធៀប ជាមួយនឹងជំពូកទី២ ប្រការទី១៣ និង ប្រការ ទី១៤។*

ប្រការទី 1 ៖ (២). នឹងមានភាពរំជើបរំជួលកើតឡើង នៅឯស្រុកកំណើត និង នៅឯបរទេស ហើយពលទាហាន ក៏នឹងល្អិតល្ហៃអស់កម្លាំងនៅតាមដងផ្លូវ។

*សេចក្ដីអធិប្បាយ៖ បើប្រៀបធៀប ជាមួយនឹង គម្ពីរតាវតេជីង ជំពូកទី៣០ ដែលមានសេចក្ដីថា៖ «គឺនៅទីណា ដែលទាហានបានបោះទីតាំងមានរុក្ខជាតិបន្លា និង ម្ហូលរលាស់»។ ចាងអុី មានសេចក្ដីកត់ត្រាថា៖ «យើងនឹកដល់ភាសិតថា: នៅទីដ៏មធ្យត៍ មួយអន្លើ ចូរ*



www.facebook.com/7khmer
Fb page : Entertainment And Knowledge

ប្រមូលគ្នាចូលប្លន់។ ហេតុអ្វីបានជា ពេលដឹកជញ្ជូន និង នាំស្បៀង ត្រូវហត់នឿយតាមផ្លូវ? ចម្លើយគឺថា: ព្រោះការដឹកជញ្ជូននោះ មិនមែនមានតែស្បៀង ម្ហូបអាហារតែមួយមុខប៉ុណ្ណោះទេ ក៏ប៉ុន្តែមានទាំង គ្រឿងឧបភោគ បរិភោគ គ្រាប់រំសេវគ្រប់ប្រភេទ សម្រាប់រស់ និង ធ្វើសង្គ្រាម គឺ ត្រូវការដឹកជញ្ជូនឲ្យបានដល់ដៃទាហាននៅសមរភូមិមុខឯណោះ។ ទន្ទឹមគ្នានេះដែរ បទបញ្ជាឲ្យ «តាមប្រមាញ់បច្ចាមិត្រ» គ្រាន់តែមានន័យថា នៅពេលទាហានចូលជ្រៅទៅក្នុងទឹកដីសត្រូវហើយ សេចក្ដីខ្វះខាតចំណីអាហារ ក៏ត្រូវតែកើតមានចំពោះយើងជាមិនខាន។ ដូច្នេះហើយ ដោយមិនចាំបាច់ពឹងផ្អែកលើពោតរបស់សត្រូវតែមួយមុខ យើងត្រូវចេញប្រមាញ់ទៀត ដើម្បីនឹងរកឲ្យឃើញទីណា ដែលអាចនឹងមានលំហូរស្បៀង មិនចេះរីងស្ងួត។ ជាថ្មីម្ដងទៀត ការចេញប្លន់សំខាន់ណាស់ បើខណៈនោះ ជួនជាចូលទៅដល់ទីវាល ស្រែអំបិល ជាទីដែលមិនអាចទទួលជំនួយស្បៀង ដោយសារស្បៀងជំនួយពីស្រុកកំណើតមិនអាចចូលចែកដល់ដៃទាហានបាន»។





www.facebook.com/7khmer
Fb page : Entertainment And Knowledge

ប្រការទី 1 ៖ (៣). មានចំនួនគ្រួសារជាច្រើនអាចរហូតដល់ចំនួន ៧០០,០០០គ្រួសារ ដែលនឹងត្រូវខាតបង់កម្លាំងពលកម្ម។

សេចក្តីអធិប្បាយ៖ ម៉ីយ៉ាវឆិន ពោលថា៖ «នឹងខ្វះបុរសកាន់យាមនង្គ័លហើយ»។ ការសរសេរជៀមដាមនេះ គឺសំដៅដល់ប្រព័ន្ធបែងចែកដីជា ៩ចំណែក, ដែលក្នុងមួយចំណែក មានទំហំប្រហែលជាង៦០អា នៅមួយចំណែកកណ្តាល ជាប្លង់ដីដែលត្រូវដាំដុះចំណែករបស់រដ្ឋ ដែលការដាំដុះនេះ ត្រូវធ្វើដោយអ្នកជួលយកដី ៨ចំណែកនោះឯង។ មានការពន្យល់នៅទីនេះ ទៀតដែរ ដែល ទូមូ ប្រាប់យើងថា ខ្ទមក៏ត្រូវបានគេសង់ឡើង ហើយជីកអណ្តូង ដើម្បីប្រើជាសាធារណៈ។ (សូមមើលជំពូកទី២ ប្រការទី១២ ក្នុងសេចក្តីអធិប្បាយ) ក្នុងពេលស្រុកកើតសង្គ្រាមមនុស្សម្នាក់ក្នុងមួយគ្រួសារត្រូវចេញទៅបម្រើក្នុងជួរកងទ័ព ហើយមនុស្សពានាក់ផ្សេងទៀតត្រូវជួយផ្តល់ជំនួយចំពោះទាហានម្នាក់នេះ។ ហេតុនេះហើយ បានជារដ្ឋត្រូវដកហូតពន្ធសម្រាប់ជួយផ្គត់ផ្គង់ពលទាហាន ១០០,០០០នាក់ (ដោយគិតយកទាហាន



www.facebook.com/7khmer
Fb page : Entertainment And Knowledge

មួយនាក់ ដើងជា ស្មារឹងក្នុងមួយគ្រួសារ) គឺមានកសិករ ចំនួន ៧០០,០០០នាក់ ត្រូវទទួលរងផលប៉ះពាល់នេះ។

ប្រការទី 2 ៖ (១). ទាហាន អាចនឹងប្រឈមមុខជាមួយគ្នា ជាច្រើនឆ្នាំ ឯចំណែកការពុះពារ ដណ្ដើមយកជ័យជំនះ អាចនឹងត្រូវបានគេសម្រេចធ្វើ ក្នុងរយៈពេលតែមួយថ្ងៃគត់។ ការណ៍នេះ គឺ ពិតជាដូច្នេះហើយ គឺ ត្រូវរក្សាការណ៍សម្ងាត់ ក្នុងលក្ខណ្ឌយ៉ាងសាមញ្ញ ដែលមិនឲ្យសត្រូវដឹង ព្រោះថា មានគេប៉ុនប៉ង ដើម្បីនឹងចំណាយ ១០០អោន នៃ ប្រាក់សុទ្ធ ជាកិត្តយស និង ជាកម្រៃទិញទឹកចិត្តមនុស្ស។

សេចក្ដីអធិប្បាយ៖ «ចារកម្ម» គឺមាន ប្រយោជន៍សំខាន់ណាស់ វាអាចនឹងជះឥទ្ធិពលដល់កិច្ចការយោធា យ៉ាងចម្លែកហួសការស្មានដល់ ដោយវាបរិយាយយ៉ាងល្អិតល្អន់ អំពី រង្វាន់ខាន់ខៅ ក្នុងរឿងចារកម្ម ដូចដែលបានចារទុកក្នុងចំណុចខាងលើនេះ។

ប្រការទី 2 (២). វាជាចំណុចកំពូលនៃភាពអមនុស្សធម៌។

សេចក្ដីអធិប្បាយ៖ សេចក្ដីចុះសម្រុងរបស់ស៊ុនអ៊ូ គឺពិតជាប៉ិនប្រសប់មែន។ គាត់ចាប់ផ្ដើម ដោយការបូរបាច់អំពី ទុរគតភាព និង ចំណាយធំ នៃ សាច់សាលោហិត





www.facebook.com/7khmer
Fb page : Entertainment And Knowledge

ព្រមទាំងទ្រព្យសម្បត្តិដែលចម្បាំងតែងតែលេបត្របាក់យក។ ឥឡូវនេះ ចូលមកដល់ចំណុច ដែលអ្នកត្រូវទទួលព័ត៌មាននានា អំពី លក្ខណៈរបស់សត្រូវជាប់ជាប្រចាំហើយ ដើម្បីបានត្រៀម បម្រុងខ្លួនឲ្យរួចជាស្រេច ដើម្បីវាយចូលប្រហារ នៅពេលណាដែល ឱកាសត្រឹមត្រូវមកដល់, សឹកសង្គ្រាម អាចនឹងអូសបន្លាយអស់កាលរាប់ឆ្នាំឯណោះ។ វិធីតែមួយគត់ ដែលអាចនឹងទទួលបានព័ត៌មានសង្គ្រាមនេះ គឺ ត្រូវប្រើចារកម្ម, វាជារឿងមិនអាចនឹងធ្វើទៅកើតទេ ក្នុងការទទួលបាន នូវពួកចារកម្ម ដែលយើងអាចទុកចិត្តបាននោះ លើកលែងតែយើងជួលដោយប្រិតប្រៀងឲ្យមនុស្សមកបម្រើការងារនេះ។ ក៏ប៉ុន្តែជាការពិតណាស់ថា វាជាសេដ្ឋកិច្ចបន្តំ ដើម្បីប៉ុនប៉ងបង្កើតចំណាយ តាមចំនួនរាយរងម្តងបន្តិចៗ ដោយមានការផ្គូផ្គង ប្រៀបធៀបជាមួយគោលបំណង តែនៅពេលដែលពីមួយថ្ងៃ ទៅមួយថ្ងៃចេះតែកន្លងផុតទៅ ចំនួនចំណាយសរុប វាក៏ចេះតែកើនឡើងយ៉ាងច្រើនសន្ធឹកដែរ។ បន្ទុកដ៏ធ្ងន់ធ្ងរនេះ វាធ្លាក់ទៅលើស្មារបស់អ្នកក្រុងដែល ដូចនេះហើយ បាន




www.facebook.com/7khmer
Fb page : Entertainment  And Knowledge

ជា ស៊ុនអ៊ូ គាត់សំយោគថា ការដែលប្រើប្រាស់ចារកម្ម មិនបានដិតដល់គឺជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។

ប្រការទី 3៖ នរជនណា ដែលធ្វើដូចនេះ គឺ មិនមែនជា មេដឹកនាំមនុស្សជាតិទេ, មិនបានជួយចម្រុងចម្រើនអ្វីដល់ ព្រះមហាក្សត្រទេ ហើយក៏មិនមែនជាប្រធាន នៃ ជ័យជំនះដែរ។

សេចក្តីអធិប្បាយ៖ គោលគំនិតនេះ ចង់និយាយថា កម្មវត្ថុពិតប្រាកដនៃសង្គ្រាមគឺ សន្តិភាព (មាននិយាយក្នុងកំណាត់ត្រា របស់ អ្នកស្រាវជ្រាវ ប្រែសម្រួល និងរៀបរៀង) វាគឺជាឫសគល់ក្នុងចរិតលក្ខណៈជាតិនិយមនៃជនជាតិចិន។ គួយ៉ាង បើយើងក្រលេកមើលបកទៅអតីតកាលវិញ កាលពី ឆ្នាំ៥៩៧ មុន គ.ស ពាក្យអនុស្សាវរីយ៍ទាំងនេះ ត្រូវបានបន្លឺចេញមក ដោយស្តេចឈ៉ង នៃនគរឈូ ជាសេចក្តីថា៖ «បើតាមអត្តចរិត (នៃជនជាតិចិន), គឺ៖ វីរកម្ម ត្រូវបានសាងបណ្តុះឡើង (សម្រាប់អត្តចរិត) ដោយផ្តេកផ្តិតជាប់នឹងលំពែង (ជាការកម្ចាត់ចោលបញ្ចប់អរិភាព)។ ចរិតទាហាន ស្តែងចេញឲ្យឃើញ នៅក្នុងការបង្ក្រាប តាមរយៈ អំពើ




www.facebook.com/7khmer
Fb page : Entertainment And Knowledge

*ឃោរឃៅ, ការប្រមូលអាវុធចូលឃ្លាំងវិញ, ការគ្រងរក្សាបាននូវអាណាប្រជានុរាស្ត្រ, ការចងស្ពានមេត្រីភាព រវាងអធិរាជ និង អធិរាជ ព្រមទាំង ដំណើរចម្រើនរីករាយ ដែលបានពីទ្រព្យសម្បត្តិត្រកុំត្រកាលរុងរឿង»។*

ប្រការទី **4** ៖ ដូចនេះ អ្វីដែលញ៉ាំងឲ្យ ស្ដេចអធិរាជ ប្រកបដោយសតិបញ្ញា និង មេទ័ពដ៏ល្អដើម្បីវាយប្រយុទ្ធ ដណ្ដើមយកជ័យជំនះ ព្រមទាំង សម្រេចកិច្ចការសព្វសារពើបានលឿនជាងការមកដល់ នៃ ពលទាហាននោះ គឺ៖ ការគិតដឹងជាមុន។

*សេចក្ដីអធិប្បាយ៖ នេះជាការដឹងបានថា សត្រូវនៅទីណាខ្លះ ហើយវាចង់ធ្វើអ្វី ជាបន្តទៅទៀត។*

ប្រការទី **5** ៖ (១). ឥឡូវនេះការគិតដឹងជាមុននេះឯង យើងមិនអាចបានវាមក ដោយសារការចម្រាញ់បំបែកវា ចេញពីស្មារតី (សតិ) បានទេ, វាក៏មិនអាចនឹងទទួលបានជាផលមកពី បទពិសោធន៍នោះដែរ។

*សេចក្ដីអធិប្បាយ៖ កំណាត់ត្រារបស់ទូមូ មានជាសេចក្ដីថា៖ «(ការយល់ដឹងបាន អំពី សត្រូវ) មិនអាចនឹងទទួល*



www.facebook.com/7khmer
Fb page : Entertainment And Knowledge

បាន ដោយសារការមានហេតុផល មកពី ករណីស្រដៀងគ្នានោះបានទេ»។

ប្រការទី 5 ៖(២). ហើយក៏មិនមែនបានមក ដោយការគិតតាមអនុមាណនោះទេ។

សេចក្ដីអធិប្បាយ៖ លីឈាន់ ពោលថា៖ «បរិមាណ ដូចជា៖ ចម្ងាយ, ព្រំដែន និង ទំហំដែលវាងាយឲ្យយើងសម្រេចចិត្តបាន តាមបែបគណិតវិទ្យា តែទង្វើរបស់មនុស្ស មិនមែនងាយឲ្យយើងគិតដល់នោះទេ។

ប្រការទី 6 ៖ ការយល់ដឹងបាន អំពី ទីតាំងរបស់ខ្មាំងសត្រូវ យើងអាចដឹងបានតាមរយៈមនុស្សដទៃទៀតតែប៉ុណ្ណោះ។

សេចក្ដីអធិប្បាយ៖ ម៉ីយ៉ាវឆិន មានកំណត់ត្រាដ៏គួរឲ្យចាប់អារម្មណ៍មួយទៀត មានសេចក្ដីថា៖ «ការយល់ដឹង អំពី ស្មារតីទូលំទូលាយគឺទទួលបានពីការសន្និដ្ឋាន, ឯចំណែកព័ត៌មាន ក្នុងវិទ្យាសាស្ត្រធម្មជាតិ គេអាចទទួលបានតាមរយៈ ការស្រាវជ្រាវរក ដោយហេតុផលអនុមាណ, ហើយច្បាប់សាកល គេអាចនឹងបកស្រាយ




www.facebook.com/7khmer
Fb page : Entertainment And Knowledge

បាន តាមការគណនាបែបគណិតវិទ្យា: ប៉ុន្តែ ទីតាំងរបស់សត្រូវ គឺអាចនឹងស្វែងរកឃើញតាមរយៈ ចារកម្ម និង ពួកចារកម្មតែម្យ៉ាងប៉ុណ្ណោះ»។

ប្រការទី 7 ៖ ដូចនេះ ចារកម្ម គឺមានចំណាត់ថ្នាក់ ៥ប្រភេទ ដូចតទៅ៖ (១). ចារកម្មក្នុងស្រុក (២). ចារកម្មផ្ទៃក្នុង (៣). ចារកម្មប្រែរូប (៤). ចារកម្មស្លាប់រស់ និង (៥). ចារកម្មរស់។

ប្រការទី 8 ៖ នៅពេលណា ដែលចារកម្មទាំង៥ប្រភេទនេះ ចេញទៅធ្វើការទាំងអស់គ្នាហើយ គ្មាននរណាអាចរកឃើញ ប្រព័ន្ធសម្ងាត់បានទេ។ នេះគេហៅថាជា «ឧបាយដ៏អស្ចារ្យ នៃ បណ្ដាញសម្ងាត់»។ ភាគច្រើន គឺជា ឧត្តមក្រុមប្រឹក្សា នៃ ព្រះមហាក្សត្រតែប៉ុណ្ណោះ។

សេចក្ដីអធិប្បាយ៖ ក្រុមវៃល គឺជា មេទ័ពម្នាក់ក្នុងចំណោមកំពូលមេទ័ពសេះដ៏ប៉ិនប្រសប់ បានក្លាយជាកំពូលទាហានគំរូ ដែលការងាររបស់គាត់ គឺ ការប្រមូលព័ត៌មានណានីមួយ ដែលទាក់ទងទៅនឹងសត្រូវ អាចយកប្រើការបាន តាមរយៈឈ្លបយកការណ៍ និង ចារកម្ម .ល. ហើយជោគជ័យរបស់គាត់ក្នុងសង្គ្រាម គឺ




www.facebook.com/7khmer
Fb page : Entertainment And Knowledge

ត្រូវបានគេរកឃើញថា គាត់ទទួលបាន នូវ ជោគជ័យទាំងនោះ តាមរយៈ ការដឹងជាមុន អំពី ចលនា របស់សត្រូវ ដូចនេះហើយទើបគាត់ឈ្នះ (សៀវភៅជំនួយស្មារតីឈ្លបយកការណ៍)។

ប្រការទី 9៖ ការមានចារកម្មក្នុងស្រុក មានន័យថា ការប្រើសេវាកម្មមនុស្ស ដែលរស់នៅក្នុងភូមិស្រុកនោះឯង។

សេចក្តីអធិប្បាយ៖ ទូមូ ពោលថា៖ «នៅក្នុងប្រទេសរបស់បច្ចាមិត្រ យើងត្រូវយកឈ្នះចិត្តមនុស្សដោយចិត្តធម៌សប្បុរស ហើយប្រើពួកគេ ឲ្យធ្វើចារកម្មឲ្យយើង»។

ប្រការទី 10៖ ការមានចារកម្មផ្ទៃក្នុង គឺជា ការប្រើមន្ត្រីរបស់សត្រូវ។

សេចក្តីអធិប្បាយ៖ ទូមូ រៀបរាប់តាមលំដាប់ថ្នាក់ ដូចមានតទៅនេះអំពីជនទាំងនោះ ដែលហាក់ដូចជា បម្រើការងារល្អ ក្នុងកិត្តិយស មានជាសេចក្តីថា៖ «មនុស្សធ្វើចារកម្មផ្ទៃក្នុង ដែលគួរឲ្យទុកចិត្តបាន គឺជា នរជនណា


www.facebook.com/7khmer
Fb page : Entertainment And Knowledge

ដែលត្រូវបានគេដកចេញពីមុខតំណែង, ជាឧក្រិដ្ឋជនដែលទទួលរងទណ្ឌកម្ម, ហើយក៏រាប់បញ្ចូលផងដែរ នូវជំពូកស្ត្រីទទួលរងការមាក់ងាយ ហើយ ដែលមានចិត្តកម្រើកលោភលន់ ចង់មាន ចង់បានមាសប្រាក់, ជំពូកបុរស ដែលចងកំហឹងនឹងភាពអយុត្តិធម៌ ក្នុងមុខតំណែងនៅក្រោមបង្គាប់របស់នរណាម្នាក់ ឬ ជនណាដែលត្រូវបានគេមើលរំលងមិនបានប្រគល់មុខតំណែងឲ្យ, ប្រភេទពួកជន ដែលរសើបរសល់ប្រាថ្នាចង់ឲ្យក្រុមខាងគេបរាជ័យទៅចុះ ដើម្បីពួកគេអាចនឹងមានឱកាសបានបង្ហាញសមត្ថភាពនិងទេពកោសល្យម្តង, ជំពូកជនក្រឡិចក្រឡុច ពុតត្បុតច្រើន ដែលចង់ជិះទូកពីរ។ គាត់បន្តថា៖ «គួរតែចូលទៅនិយាយនឹងពួកមនុស្សទាំងប៉ុន្មានជំពូក ដែលបានរៀបរាប់មកនេះ ជាសម្ងាត់ ហើយកំណត់ជា ខ សន្យាផ្តល់ផលប្រយោជន៍ តាមមធ្យោបាយផ្តល់រង្វាន់ខាន់ខៅ ឲ្យក្លាយខ្លួនជាអ្នកមាន។ តាមវិធីនេះ អ្នកនឹងមានលទ្ធភាពរកឃើញកិច្ចការរដ្ឋសំខាន់ៗ ក្នុងប្រទេសសត្រូវ ចូរកំណត់រកឲ្យឃើញជាប្រាកដ នូវ ផែនការ ដែលសត្រូវកំពុងកសាង ក្នុងបែប




www.facebook.com/7khmer
Fb page : Entertainment And Knowledge

ផែនទម្រង់ប្រឆាំងនឹងអ្នក ហើយជាងនេះទៅទៀត ចូររកក្បួនរំខានឆាឆៅភាពសុខុដុមរម្យនា និង បង្កើតភាពប្រេះឆា រវាង អធិរាជ និង មន្ត្រីទាំងឡាយរបស់វា»។

ទោះជាយ៉ាងណាក៏ដោយ ជាចាំបាច់ យើងត្រូវតែប្រុងប្រយ័ត្ន ឲ្យបានល្អិតល្អន់បំផុត ក្នុងការចូលទៅនិយាយជាមួយ «ពួកចារកម្មផ្ទៃក្នុង» ព្រោះវាបានលេចចេញពីឧបទ្ទវហេតុក្នុងប្រវត្តិសាស្ត្រ ដោយកើតឡើងជារឿងរ៉ាវ ហើយត្រូវបានលើកយកមក និយាយភ្ជាប់អត្ថន័យក្នុងទីនេះ ដោយ ហាស៊ី មានជាសេចក្តីថា៖ «ឡាសាង គឺជា ចៅហ្វាយស្រុកអ៊ីចុវ បានចាត់បញ្ជូនមេទ័ពរបស់គាត់ឈ្មោះ វ៉ីប៉ូ ឲ្យទៅវាយប្រយុទ្ធតទល់នឹងពួកបះបោរ លីស៊ុង របស់នគរស៊ូ នាតំបន់ពិ។ បន្ទាប់ពីកងទ័ពទាំងសងខាង ទទួលបទពិសោធន៍ឈ្នះចាញ់ទាំងសងខាងទៅវិញទៅមកមួយរយៈរួចហើយ លីស៊ុង បានទៅពឹងពាក់ ប៉ោថៃ ឲ្យមកជួយ ដែល ប៉ោថៃជាជនជាតិអ៊ូទូ។ លីស៊ុង ពេលបាន ប៉ោថៃ មកជួយហើយ ក៏ចាប់ផ្តើមវាយប្រយុទ្ធទៀតលុះត្រាទាល់តែ ប៉ោថៃហូរឈាម ហើយក៏បញ្ជូន ប៉ោថៃ ទៅឲ្យ ឡាសាង ក្នុងគោល





www.facebook.com/7khmer
Fb page : Entertainment And Knowledge

បំណងបោកបញ្ឆោតឲ្យ ឡេាសាង យល់ខុស ដោយឲ្យ ប៉ោថៃ ធ្វើជាមកចុះចូលជាមួយនឹង ឡេាសាង និង ដើម្បីដុតភ្លើង ជាសញ្ញានៅពេលណាឱកាសល្អមកដល់ ដើម្បីឲ្យ លីស៊ុង វាយប្រហារជាទ្រង់ទ្រាយធំ។ ចំណែក ឡេាសាង ទុកចិត្តស្លូងក៏ប្រាប់កិច្ចការសម្ងាត់ទាំងប៉ុន្មាន ដល់ ប៉ោថៃ ហើយក៏ដកទាហានឆ្មើមចេញអស់ ហើយ ដាក់ វ៉ីប៉ូ និង ទាហានដទៃទៀត ជាទ័ពមុខឲ្យចាំទទួល បញ្ជាវាយប្រហារតាមការបញ្ជារបស់ប៉ោថៃទាំងស្រុង។ ខណៈនោះ មេទ័ពរបស់ លីស៊ុង គឺ លីសុាំង បានរៀបចំ បង្កប់ចាំស្ទាក់ជួរក្បួនទ័ពរបស់ឡេាសាងហើយចំណែក ប៉ោថៃ ដោយបានលើកជណ្ដើរវែង ទល់នឹងកំផែង ជញ្ជាំងក្រុងដល់ពេលនេះហើយក៏ដុតភ្លើងសញ្ញាឡើង។ ទាហានរបស់វ៉ីប៉ូ ក៏ប្រជែងឡើងទៅខាងលើតាមជណ្ដើរ ឃើញភ្លើងសញ្ញា ក៏ចាប់ផ្ដើមឡើងតាមជណ្ដើរ ទាំង នោះ យ៉ាងលឿន តាមដែលគេអាចធ្វើបាន ចំណែក ទាហានខ្លះទៀត ត្រូវបានគេទាញទម្លាក់ដោយខ្សែពួរ ធ្លាក់ចុះពីលើមកវិញ។ មានទាហាន ជាង១០០នាក់ របស់ ឡេាសាង បានចូលទៅក្នុងក្រុងតាមវិធីនេះ ដែល




www.facebook.com/7khmer
Fb page : Entertainment And Knowledge

ពួកគេទាំងអស់ត្រូវបានកាត់ក្បាល ភ្លាមៗ។ ខណៈនោះ លីស៊ុង បានសម្រុកចូលទៅខាងមុខ ជាមួយទាហាន ទាំងអស់របស់គាត់ទាំងក្នុងក្រុងនិងទាំងក្រៅក្រុងហើយ កម្ទេចទ័ព ឡៅសាង និង វ៉ីប៉ូ ឲ្យវិនាសទាំងស្រុងតែម្តង» (រឿងនេះ បានកើតឡើងកាលពី ឆ្នាំ៣០៣ នៃ គ.ស) ខ្ញុំមិនដឹងថា ហស៊ី គាត់បានរឿងនេះ មកពីណាទេ។ រឿងនេះ មិនមានចារនៅក្នុងប្រវត្តិរបស់លីស៊ុង ឬឪពុក របស់គាត់ លីតេ នោះឡើយ តែមានក្នុងស្នាដៃឆិនស៊ុ ជំពូកទី១២០ និង ទី១២១ ។)

ប្រការទី 11 ៖ ការដែលមានចារកម្មប្រែរូបគឺនាំឲ្យយើងអាច ស្វែងយល់បាន នូវ ពួកចារកម្មរបស់សត្រូវ និង ប្រើប្រាស់ ពួកគេ ឲ្យបម្រើគោលបំណងរបស់យើងវិញ (កំណត់ត្រា អ្នក ប្រែសម្រួល៖ ប្រហាក់ប្រហែលនឹង ចារកម្មឡង ក្នុងសៀវភៅ ល្បិចទល់មេឃ ដែរ)។

សេចក្តីអធិប្បាយ៖ តាមមធ្យោបាយ ផ្តល់នូវសំណូក ធំដុំ និង ការសន្យាដ៏ល្អស្មោះសចិត្តទូលាយ អាចធ្វើឲ្យ ពួកគេដាច់ចិត្តពីការបម្រើឲ្យខាងក្រុមខ្លួន ហើយញ៉ាំង




www.facebook.com/7khmer
Fb page : Entertainment And Knowledge

ឲ្យពួកគេបញ្ជូនតែព័ត៌មានមិនពិត ទៅឲ្យ ក្រុមខ្លួនឯង ហើយយកការណ៍ពីប្រទេសខ្លួនឯង មករាយការណ៍ ឲ្យយើងវិញទៀតផង។ ម្យ៉ាងវិញទៀត ស៊ៀវស៊ីស៊ៀន ពោលថា យើងត្រូវធ្វើពើដូចជា មិនបានដឹងអ្វីទាំងអស់ អំពី មនុស្សទាំងនោះ ក៏ប៉ុន្តែ ត្រូវរៀបចំផែនការឲ្យមនុស្សទាំងនោះ យកតែព័ត៌មានមិនពិតទៅវិញ ជាការបញ្ជូនដំណឹង អំពី អ្វីៗ ដែលកំពុងតែកើតឡើងនៅខាងយើងឯណោះ។ មានអ្នកអត្ថាធិប្បាយ ជាច្រើនបានទទួលស្គាល់ថា សេចក្ដីនេះ ជាអត្ថន័យជម្រើសមួយ តែវាមិនមែនជាអ្វី ដែលស៊ុនវ៊ូចង់និយាយទេ វាបង្ហាញចេញជាតឹកតាងយ៉ាងជាក់ស្ដែងតាមរយៈ កំណត់ត្រារបស់គាត់ ជាបន្តបន្ទាប់ទៅខាងក្រោយទៀត អំពី វិធីប្រព្រឹត្តិចំពោះពួកចារកម្មប្រែរូប ប្រកបដោយអត្ថន័យទូលំទូលាយ។

ហស៊ី កត់ត្រាទុកនូវព្រឹត្តិការណ៍ ចំនួនពាលើក ដែលចារកម្មប្រែរូបត្រូវបានគេប្រើប្រាស់ ហើយទទួលបានជ័យជំនះ ជ្រងោៗ គឺ៖ (១). ដោយ ឆានតាន ក្នុងការដែលគាត់ការពារទល់នឹង ជីម៉ូ (តម្រាដើមទំព័រទី៩០),





www.facebook.com/7khmer
Fb page : Entertainment And Knowledge

(២). ដោយ ឆាវស៊ី ក្នុងក្បួនទ័ពរបស់គាត់ឆ្ពោះទៅ អ៊ូយ៉ូ (ក្នុងតម្រាដើម ទំព័រទី៥៧) (៣). ដោយបុគ្គលដ៏ឆ្លាតវៃ ហ្វានជូ (នគរឈិន) កាលពីឆ្នាំ២៦០មុនគ.ស នៅពេលដែល លានប៉ូ កំពុង តែដឹកនាំយុទ្ធនាការសឹកការពារទល់នឹងនគរឈិន។ ស្តេចនគរឆាវ បានទម្លាស់ យ៉ាងខ្លាំង ចំពោះការប្រយ័ត្នប្រយែងល្អិតល្អន់ និង វិធីអូសបន្លាយពេលយូរ របស់ លានប៉ូ ដែលព្រះអង្គយល់ថាការណ៍នេះ មិនអាចនឹងទប់ស្កាត់ស៊េរី នៃ គ្រោះភ័យទាំងឡាយបានឡើយ ដូចនេះហើយព្រះអង្គបានស្រាលព្រះកាណ៌ ជឿលើសេចក្តីរាយការណ៍ ពី ពួកចារកម្មរបស់ទ្រង់ ដែលបានចូលដៃជាមួយសត្រូវរួចទៅហើយថែមទាំងបានទទួលលាភសក្ការៈពី ហ្វានជូ រួចជាស្រេចនោះ។ មានគេនិយាយចចាមអារ៉ាមថា៖ «រឿងតែមួយគត់ ដែលបណ្តាលឲ្យអ្នកនគរឈិន ថប់អារម្មណ៍នោះគឺក្រែងតែ ឆាវគ័រ ធ្វើជាមេទ័ពនគរឆាវទេ។ ចំណែកលានប៉ូ ត្រូវបានគេចាត់ទុកថា ជាសត្រូវងាយផ្តួលរំលំណាស់ ដែលគេយល់យ៉ាងច្បាស់ថា មុខតែនឹងត្រូវបានគេកម្ចាត់ចោល ក្នុងពេលណាមួយ នាថ្ងៃខាងមុខ




www.facebook.com/7khmer
Fb page : Entertainment And Knowledge

មិនខាន»។ ឥឡូវនេះ ឆាវគ័រ គឺជាកូនប្រុសរបស់ ឆាវស៊ី ដ៏ល្បីល្បាញ នៃ នគរឆាវទៅហើយ។ កាលពីវ័យកុមារ ឆាវគ័រ បានស្លុងចិត្តតែនឹងការសិក្សា អំពី សង្គ្រាម និង កិច្ចការកងទ័ពរហូតមក ទាល់តែដល់ ដំណាក់កាល ចុងក្រោយ ឆាវគ័របានជឿថានៅទូទាំងអាណាចក្រឆាវ នេះ គ្មានមេបញ្ជាការកងទ័ពណា អាចស៊ូនឹងគាត់បាន ទេ។ ឪពុករបស់គាត់ខ្វល់ចិត្តណាស់ ដោយសារតែ សភាពក្អេងក្អាងហួសហេតុ និង ការលេងសើចរបស់ កូននេះ ជាមួយនឹងអ្វីដែលគាត់យល់ថា ជារឿងមធ្យត់ ក្នុងសឹកសង្គ្រាមពេក ព្រមទាំងសេចក្ដីប្រកាស ដ៏គួរឲ្យ អស់សំណើចថា បើសិនជាគាត់ (ឆាវគ័រ) ត្រូវបានគេ តែងតាំងឲ្យធ្វើជាមេទ័ព គាត់នឹងកម្ទេចកងទ័ព ខ្មាំងនៃ នគរឆាវ ឲ្យវិនាសសាបសូន្យតែម្ដង។ នេះគឺជាបុរស ដែលហ៊ានទាមទារដោយ មានភាពមានៈកាត់ទៅម្ដាយ របស់គាត់និងរដ្ឋបុរសជើងចាស់ លីនសាំងជូ, គ្រាឥឡូវ នេះ គាត់ (ឆាវគ័រ) ត្រូវបានគេបញ្ជូនឲ្យទៅធ្វើសឹក ជំនួស លានប៉ូ ហើយ។ មិនចាំបាច់និយាយអ្វីឡើយ គាត់បានបង្ហាញឲ្យឃើញដោយអំនួតថា ប្រហែល ប៉ូជី




www.facebook.com/7khmer
Fb page : Entertainment And Knowledge

ដែលគួរឲ្យព្រឺខ្លាច និង មានកម្លាំងទាហាន ដ៏មហិមា នៃនគរឈីនក៏នៅខ្សោយជាងគាត់ផង។ តែចុងក្រោយ ឆាវគ័រ បែរជាធ្លាក់ខ្លួនជាប់អន្ទាក់ ដោយសារកងទ័ព របស់គាត់ ត្រូវបានកាត់បំបែកជាពីរភាគ ហើយខ្សែ បណ្តាញទំនាក់ទំនងនាំសារព័ត៌មាន របស់គាត់ ក៏ត្រូវ បានកាត់ផ្តាច់ ហើយបន្ទាប់ពីការតស៊ូ ដោយអស់ សង្ឃឹម រយៈពេល៤៦ថ្ងៃ កន្លងហួសទៅ ដែលទាហាន របស់គាត់អត់អាហារស្លាប់ ជាបន្តបន្ទាប់ គាត់ក៏ សម្លាប់ខ្លួនដោយផ្លែព្រួញ ចំណែកឯកងទ័ពទាំងមូល របស់គាត់សរុបទាំងអស់ដល់ទៅ ចំនួន៤០០,០០០នាក់ ក៏ទម្លាក់អាវុធចុះចាញ់ ដោយគ្មានស្តាយស្រណោះអ្វី សោះឡើយ។

ប្រការទី 12 ៖ ការមានពួកចារកម្មស្លាប់រស់ គឺ ដើម្បីធ្វើ កិច្ចការជាក់លាក់ណាមួយ ដោយចំហ ដើម្បីបំពេញរាល់ គោលបំណងបំភាន់ចិត្ត និង បើកដៃអនុញ្ញាតិឲ្យពួកចារកម្ម របស់យើងបានដឹង អំពី គោលបំណងទាំងនោះ ហើយ រាយការណ៍ទៅឲ្យសត្រូវ។




www.facebook.com/7khmer
Fb page : Entertainment And Knowledge

សេចក្តីអធិប្បាយ៖ ទូអ៊ី ផ្តល់បទបង្ហាញ ដ៏ល្អបំផុត ចំពោះន័យនេះ ជាសេចក្តីថា៖ «យើងធ្វើ អ្វីៗ ដោយ សម្ងៃង ដោយបង្អួត ដើម្បីបោកពញ្ញោតពួកចារកម្ម របស់យើង ឲ្យពួកគេស្លូងចិត្តជឿថា ពួកគេបានដឹង រឿងរ៉ាវរាក់ជ្រៅទាំងអស់ដោយពួកគេមិនមានផែនការ ចង់ដឹងទុកជាមុនសោះឡើយ។ ខណៈនោះហើយ ពេល ណា ដែលពួកចារកម្មទាំងនោះ ត្រូវបានសត្រូវចាប់ខ្លួន ពួកគេនឹងរាយការណ៍ រឿងមិនពិតទាំងស្រុង ហើយ សត្រូវនឹងចាប់ផ្តើមធ្វើការប៉ាន់ស្មាន តាមរយៈព័ត៌មាន ទាំងនោះ។ សេចក្តីនេះគឺ ចង់បញ្ជាក់ថា យើងត្រូវធ្វើអ្វី ដែលផ្សេងទៅវិញទេ។ នៅពេលនោះ ពួកចារកម្មនឹង ត្រូវបានគេសម្លាប់»។ ដើម្បីជាឧទាហរណ៍ នៃ ចារកម្ម ស្លាប់រស់ ហាស៊ី និយាយសំដៅដល់អ្នកទោស ដែលត្រូវ បានដោះលែងដោយ ប៉ានចាវ នៅក្នុងប្រតិបត្តិការ ឃោធារបស់គាត់តទល់នឹងពួក យ៉ាខាន់ (ទំព័រទី១៣២ នៅក្នុងតម្រាដើម) គាត់ក៏បាននិយាយដល់ តាងឈាន ផងដែរ ដែលកាលពីឆ្នាំ៦៣០ នៃ គ.ស គាត់ត្រូវបាន តៃស៊ុង បញ្ជូនឲ្យទៅបង្ក្រាប កាញ់ឈាលី នៅដែនដី




www.facebook.com/7khmer
Fb page : Entertainment And Knowledge

ទូត៍ ឲ្យបានស្ងប់សុខតាមចិត្តប្រាថ្នា តែផ្ទុយទៅវិញ លីជីង បានឡើងដៃវាយបង្ក្រាបគាត់ (តាងឈាន) វិញយ៉ាងចាស់ដៃ។ ចាងអ៊ី ពោលថា ពួកទូត៍ បានសងសឹកបកទៅលើខ្លួនឯង ដោយសម្លាប់ តាងឈាន ប៉ុន្តែនេះជាកំហុសមួយរួចទៅហើយ តាមដែលយើងបានអានប្រវត្តិរបស់ តាងឈាន (ជំពូកទី៥ ទី៨ និង ទី៨៩) ដែលបានចារឹកទុកថា គាត់បានរត់ភៀសខ្លួន រួចជីវិតទៅរស់នៅ រហូតដល់ឆ្នាំ៦៥៦នៃគ.ស។ ចំណែក លីអាយជី បានសម្តែងឆាកល្ខោន តាមរូបភាព ជាអ៊ីម្យ៉ាង ដែលស្រដៀងគ្នាទៅនឹងភាគមួយចំណិត នៃ ប្រវត្តិសាស្ត្រ ដែលបានកើត ឡើងកាលពីឆ្នាំ២០៣មុនគ.ស ដែលកាលនោះ គាត់ត្រូវបានចាត់បញ្ជូនដោយស្តេចហាន់ឲ្យទៅបើកការចរចាដោយសន្តិភាពជាមួយនគរឈី។

គាត់បានប្រកាន់ខ្លួនដោយដាក់ស្តែងតាមអ៊ីម្យ៉ាង ដែលគេបានពិពណ៌នាថាជា «ចារកម្មស្លាប់រស់» តែសម្រាប់ស្តេចឈី ដែលធ្លាប់តែទទួលរងការវាយប្រហារជាបន្តបន្ទាប់មក ដោយគ្មានទាំងការប្រកាសសង្គ្រាមជាមុនពីហានស៊ីន ហើយនិង ត្រូវបានដុតកំហឹងតាមរយៈអ៊ី




www.facebook.com/7khmer
Fb page : Entertainment And Knowledge

ម្យ៉ាង ដែលគាត់ត្រិះរិះថាជា ឧបាយកលក្បត់ របស់លីវអាយជី ជាអកុសលភ្លាមនោះ បេសកជនទូតកំសត់ក៏ត្រូវបានគេបញ្ជា ឲ្យយកទៅសម្លាប់ ដោយស្រុះទាំងរស់តែម្តង។

ប្រការទី 13 ៖ ចុងក្រោយនេះ ជាចារកម្មរស់ គឺជា ពួកជនទាំងនោះ ដែលពួកគេនាំយកព័ត៌មានពីជំរុំសត្រូវមកវិញ។

សេចក្តីអធិប្បាយ៖ បើនិយាយឲ្យកាន់តែសមទៅទៀត នេះជាលំដាប់ធម្មតានៃចារកម្ម ជាការកសាងភាគផែនទម្រង់ប្រក្រតី នៃ កងទ័ព។ ទូមូ ពោលថា៖ «ចារកម្មរស់របស់អ្នក ត្រូវតែជាមនុស្ស ដែលមានសតិបញ្ញាស្រួចស្រាវ ចំណាប់ចំណាន ទោះជាយ៉ាងនេះហើយក្តី គាត់ត្រូវមានសភាពសម្តែងចេញមកខាងក្រៅ ធ្វើជាមនុស្សដែលឡប់សតិ, ជាមនុស្សរយីករយាកផ្នែកសម្បកក្រៅ ប៉ុន្តែគេជាមនុស្សមានឆន្ទៈរឹងមាំ មុះមុត។ គាត់ត្រូវតែជាមនុស្សសកម្ម រឹងប៉ឹង មានអំណោយផលខាងកម្លាំងកាយសម្បទា និង សេចក្តីក្លាហាន ហ្មត់ចត់ ស៊ាំនឹងការងារស្មោកគ្រោក តោកយ៉ាកគ្រប់បែបយ៉ាង អាច


www.facebook.com/7khmer
Fb page : Entertainment And Knowledge

អត់ធ្មត់ ស៊ូទ្រាំបាននឹងសេចក្ដីស្រេកឃ្លាន សភាពក្ដៅ រងារ និង អាចស៊ូទ្រាំនឹងសេចក្ដីអាម៉ាស និង អប្បយស ជាសាធារណៈបានទៀតផង»។

ហាស៊ី ដំណាលរឿង តាស៊ីវ្ង នៃ រាជវង្សសួយ ជាសេចក្ដីថា៖ «កាលដែលគាត់ នៅជា ចៅហ្វាយស្រុក ឈីនភាគខាងកើតនោះ សិនវូមកពីនគរឈីបានបង្កើត ចលនាបះបោរ នៅលើតំបន់សាយាន់។ អធិរាជតែស៊ុ បានបញ្ជូន តាស៊ីវ្ង ឲ្យទៅស៊ើបយកការការណ៍ពីខាង សត្រូវ។ មានមនុស្សពីរនាក់ទៀត បានអមដំណើរទៅ ជាមួយគាត់ (តាស៊ីវ្ង) ផង។ មនុស្សទាំង៣នាក់នេះ បានជិះលើខ្នងសេះ ហើយ តាក់តែងកាយដោយប្រើ ឯកសណ្ឋានសត្រូវ។ លុះពេលព្រលប់មកដល់ ពួកគេក៏ បានចុះពីលើខ្នងសេះ នៅចម្ងាយ ពីរ បី រយហ្វីតពីជំរុំ សត្រូវ ហើយលបលូនចូលទៅស្ដាប់យកការណ៍លុះត្រា តែពួកគេ (តាស៊ីវ្ង) សម្រេចបាន ក្នុងការចាប់យកបាន នូវពាក្យសម្ងាត់ដែលប្រើប្រាស់ក្នុងកងទ័ពរបស់សត្រូវ។ ខណៈនោះ ពួកគេក៏ឡើងជិះសេះបន្តទៅទៀត ហើយ បន្តឆ្លងកាត់បន្ទាយសត្រូវនោះ យ៉ាងក្រអឺត ក្រោម





www.facebook.com/7khmer
Fb page : Entertainment And Knowledge

ក្រសែភ្នែកអ្នកយាមពេលយប់ ហើយ មិនមែនតែមួយដងទេ គឺមានច្រើនលើក ដែលពួកគេបានជួបប្រទះនឹងពួកទាហានសត្រូវ ដែលមានសេចក្តីធ្វេស មិនធ្វើតាមគោលវិន័យ ពួកគេបានឈប់ ដោយដាក់ស្នែង ហើយផ្តល់ឲ្យពួកកំហូចទាំងនោះបានស្គាល់នូវមេរៀនព្រនង់ ដ៏ត្រឹមត្រូវជាការប្រៀនប្រដៅ ថែមទៀតផង! ដូចនេះ ពួកគេក៏ចាត់ការវិលមកបន្ទាយវិញ ដោយនាំមកនូវព័ត៌មាន ដ៏មានប្រសិទ្ធិភាពពេញលេញ អំពី ការតាំងទ័ពរបស់សត្រូវ ហើយពួកគេទទួលបាននូវសេចក្តីកោតសរសើរយ៉ាងកក់ក្តៅពីព្រះចៅអធិរាជក្នុងការណ៍ដែលពួកគេបាននាំយកមកនូវ ប្រយោជន៍ដ៏ប្រសើរនៃសេចក្តីរាយការណ៍ អាចធ្វើឲ្យទ្រង់ បើកការវាយលុកផ្តួលរំលំយកឈ្នះលើសត្រូវរបស់ព្រះអង្គបាន។

ប្រការទី 14 ៖ (១). ការណ៍នេះ ស្តែងឲ្យឃើញថា ក្នុងកងទ័ពទាំងមូល គ្មានកិច្ចការរាក់ជ្រៅឯណា ដែលអាចនឹងកប់បាត់ស្ងាត់កំបាំង និង លាក់ឲ្យជិតពីទំនាក់ទំនងដ៏ស្និទ្ធស្នាលជាមួយពួកចារកម្មបានទេ។





www.facebook.com/7khmer
Fb page : Entertainment And Knowledge

សេចក្តីអធិប្បាយ៖ ទូមូ និង ម៉ីយ៉ាវឆិន បង្ហាញថា ពួកចារកម្មមានអភ័យឯកសិទ្ធិ ដើម្បីចូលទៅរហូតដល់ទីគ្រែដេកជាឯកជនក្នុងជំរុំរបស់មេទ័ពទៀតផង។

ប្រការទី 14 ៖ (២). គ្មាននរជនណា ដែលសមនឹងទទួលបំណាច់រង្វាន់តាមសទ្ធានោះឡើយ បើសិនជា ក្នុងកិច្ចការរបស់ពួកគេ មិនអាចរក្សាការណ៍សម្ងាត់បានល្អទេនោះ។

សេចក្តីអធិប្បាយ៖ ទូមូ ផ្តល់នូវគំនិត ដ៏ច្បាស់លាស់ជាសេចក្តីថា៖ រាល់ទំនាក់ទំនងជាមួយពួកចារកម្ម ត្រូវធ្វើឡើង តាមរយៈ «មាត់ទល់នឹងត្រចៀក»។ សេចក្តីកត់ត្រាជាបន្តបន្ទាប់ទៅនេះ គឺស្តីអំពី ក្បួនចារកម្ម ដែលដកស្រង់ពីស្នាដៃធូរ៉ែន ដែលប្រហែលជា គាត់បានប្រើប្រាស់វា ច្រើនជាង មេបញ្ជាការយោធា មុនៗ ដែលជារៀមច្បងគាត់ទៀតផង ដែលសេចក្តីនេះ មានដូចតទៅ៖ ពួកចារកម្ម គឺ សំដៅដល់នរជនណា ដែលធ្វើចារកិច្ចបានច្រើនជាងគេ នរជនណា ដែលធ្វើការនេះ មិនបានល្អ គេមិនហៅថា ជាពួកចារកម្មទេ។ ពួកគេមិនត្រូវឲ្យអ្នកដទៃស្គាល់ថា ខ្លួនគេ ជានរណានោះទេ ហើយ ពួកគេក៏មិនស្គាល់គ្នាដែរ។ ពេលខ្លះ





www.facebook.com/7khmer
Fb page : Entertainment And Knowledge

ពួកគេអាចនឹងស្នើសុំអ្វីណានីមួយ ដូចជា សម្ភារៈ ចំណែកសុវត្ថិភាពបុគ្គលខ្លួនគេ ឬ ប្រពន្ធកូនគេ គឺបាន ស្ថិតក្នុងកណ្ដាប់ដៃរបស់អ្នក ក្នុងរូបភាពជា ចំណាប់ ខ្មាំង ជាថ្នូរនឹងភាពស្មោះត្រង់របស់ពួកគេ។ អ្នកមិនត្រូវ ទាក់ទងពួកគេ ដោយសារតែរឿងទាំងឡាយគ្រប់យ៉ាង នោះទេ លើកលែងតែរឿងចាំបាច់បំផុត ដែលពួកគេ ត្រូវដឹងប៉ុណ្ណោះ (ម៉ាហ្សេល ធ្យូរីន ទំព័រទី៣១១)។

ប្រការទី 15 ៖ ចារកម្មមិនអាចនឹងត្រូវបានប្រើប្រាស់ឲ្យកើត ជាប្រយោជន៍បានឡើយ បើយើងគ្មានបញ្ញាញាណល្អិតល្អ សុខុម ប្រាកដប្រជាទេនោះ។

សេចក្ដីអធិប្បាយ៖ ម៉ីយ៉ាវឆិន ពោលថា៖ «ដើម្បីប្រើ ប្រាស់ពួកចារកម្មបាន នរជនត្រូវដឹងសេចក្ដីជាការពិត ដែលលេចចេញ មកពី ចរិតភូតកុហក ហើយមាន សមត្ថភាព ដើម្បីនឹងវែកញែកឲ្យដាច់ រវាង គុណភាព នៃ សេចក្ដីទុកចិត្ត ជាភាពទៀងត្រង់ និង អាកប្បកិរិយា ទុច្ចរិតប្រុងក្បត់របស់ពួកគេផងដែរ»។ ចំណែក វ៉ាងស៊ី បានផ្ដល់ នូវ យោបល់បកស្រាយផ្សេងទៅវិញ មាន




www.facebook.com/7khmer
Fb page : Entertainment And Knowledge

សេចក្ដីថា៖ «ត្រូវមានការយល់ដឹងបាន ដោយអព្ភន្តរញ្ញាណ» និង «សតិបញ្ញាប្រសប់វាងវៃ»។ ចំណែក ទូមូនិយាយសំដៅដល់ ចរិតលក្ខណៈទាំងនេះ យ៉ាងចម្លែកចំពោះពួកចារកម្មថា៖ «មុននឹងប្រើពួកចារកម្ម យើងត្រូវធានាអះអាង ចំពោះ ខ្លួនយើង អំពី ភាពសុចរិត និង វិសាលភាព នៃ ជំនាញ ព្រមទាំង បទពិសោធន៍របស់ពួកគេ»។ គាត់បន្តថា៖ «ក៏ប៉ុន្តែ ទឹកមុខ ដែលមានកិរិយា ដូចឥតលាក់លាម និង ភាពមានល្បិចកលពុតត្បុតធ្វើពើ គឺ មានគ្រោះថ្នាក់ជាងភ្នំ និង ស្ទឹងទន្លេទាំងឡាយទៅទៀត វាអាចធ្វើឲ្យ មនុស្សដែលមានជំនាញ ធ្វើរឿងទាំងអម្បាលមាណនេះ ឲ្យកើតឡើងបាន»។ ដូចនេះ យើងក៏នៅតែមានមន្ទិលសង្ស័យដដែល បើសិនមតិរបស់គាត់ខាងលើទាំងនេះ ជាការពិតមែន។

ប្រការទី **16** ៖ ពួកគេ មិនអាចត្រូវបានគ្រប់គ្រង ឲ្យជិតដល់ ដោយគ្មានសប្បុរសធម៌ និង សភាពសាមញ្ញ ងាយយល់បានឡើយ។



www.facebook.com/7khmer



Fb page : Entertainment And Knowledge

សេចក្តីអធិប្បាយ៖ ចាងអ៊ី ពោលថា៖ «នៅពេលដែលអ្នកទាក់ទាញពួកគេបានមកតាមរយៈការផ្តល់នូវរង្វាន់ខាន់ខៅជាដុំកំភួនហើយ អ្នកត្រូវតែ មើលថែពួកគេប្រកបដោយភាពស្មោះត្រង់ឥតងាករេ ពេលនោះ ពួកគេ ក៏នឹងធ្វើការបម្រើអ្នកវិញ យ៉ាងអស់ពីអានុភាពរបស់ពួកគេដែរ។

ប្រការទី 17 ៖ បើគ្មានគំនិត ជាឧបាយ ប៉ិនប្រសប់កែខៃទេ នរជនមិនអាចនឹងវែកញែក ឲ្យបានច្បាស់លាស់ រកការពិតចេញពីសេចក្តីរាយការណ៍របស់ពួកគេបានឡើយ។

សេចក្តីអធិប្បាយ៖ ម៉ីយ៉ាវឆិន ពោលថា៖ «ចូរការពារខ្លួនអ្នក តទល់នឹងការណ៍ ដែលអាចមាន ពួកចារកម្មវាលួចក្បត់រំលងទៅបម្រើចលនាឲ្យសត្រូវផងដែរ»។

ប្រការទី 18 ៖ ចូរឈ្លាសវៃឡើង! ចូរឈ្លាសវៃឡើង! ហើយចូរប្រើប្រាស់ ពួកចារកម្មរបស់អ្នក ឲ្យបានជា ប្រយោជន៍សម្រាប់រាល់កិច្ចការទាំងពួង។




www.facebook.com/7khmer
Fb page : Entertainment And Knowledge

សេចក្ដីអធិប្បាយ៖ សូមប្រៀបធៀបជាមួយសេចក្ដីក្នុងជំពូកទី៦ ប្រការទី៩។

ប្រការទី **19** ៖ បើសិនជា ចំណែកណាមួយ នៃ ព័ត៌មាន វាស្ថិតនៅក្នុងសភាពលេចធ្លាយ ឲ្យដឹងឮ ដោយអាថ៌កំបាំង ដោយសារពួកចារកម្មណាមួយមុនពេលវេលាដែលត្រូវឲ្យគេដឹង គឺ ត្រូវតែសម្លាប់ពួកចារកម្មទាំងនោះទាំងអស់គ្នាតែម្ដង ដោយរួមទាំង មនុស្សណា ដែលបានដឹងរឿងសម្ងាត់នោះផងដែរ។

សេចក្ដីអធិប្បាយ៖ បើបកស្រាយ ពាក្យ តាម ពាក្យ, ចំណុចនេះមានសេចក្ដីថា៖ «បើសិនជា កិច្ចការចារកម្ម ត្រូវបានគេដឹងឮមុនពេលផែនការរបស់យើងត្រូវបានអនុវត្ត ...ល...» ។ ចំណុចសំខាន់នៅក្នុងសេចក្ដី របស់ ស៊ុនអ៊ូ នៅទីនេះ គឺថា៖ បើទោះជា អ្នកទៅសម្លាប់ពួកចារកម្មទាំងនោះ «ទុកជាទណ្ឌកម្ម ដែលពួកគេបានធ្វើឲ្យបែកធ្លាយរឿងសម្ងាត់ទាំងនោះ» ហើយក៏ដោយ ក៏កម្មវត្ថុ នៃ ការសម្លាប់មនុស្សដទៃទៀត គឺ ដូចដែលឆិនហាវ បានពោលថា គឺ ដើម្បីតែ «បញ្ឈប់មាត់ ដែលនិយាយរឿងបែកការណ៍នេះប៉ុណ្ណោះ» និង ការពារ





www.facebook.com/7khmer
Fb page : Entertainment And Knowledge

ព័ត៌មានទុក មិនឲ្យលេចព្រាតទៅទៀតតែប៉ុណ្ណឹង។ បើសិនជារឿងនេះ ត្រូវបានជនដទៃនិយាយរ ដដែលៗនោះ កិច្ចការសង្គ្រាម នឹងមិនអាចសម្រេចជោគជ័យបានឡើយ។ មានវិធីផ្សេងមួយទៀត ដែល ស៊ុនអ៊ូ បានដាក់ខ្លួនជាចំហ ទទួលការរិះគន់ នូវ ភាពអមនុស្សធម៌ ហើយ ទូមូ ខិតខំព្យាយាមជួយការពារគាត់ ដោយនិយាយថា៖ ចារជន ដែលគួរតែនឹងទទួលទោសប្រហារជីវិត គឺ ពួកចារកម្មទាំងឡាយណា ដែលពិតជាមិនបានប្រាប់ឲ្យបែកការណ៍សម្ងាត់ លើកលែងតែចារជននោះបានទទួលការឈឺចាប់ ដោយសារការបង្ខំ ឈ្លេចឈ្លីជម្រិតយកព័ត៌មានទាំងឡាយពីគាត់»។

ប្រការទី 20 ៖ (១). ទោះបីជាមានកម្មវត្ថុថា ត្រូវវាយកម្ទេចកងទ័ពណានីមួយ, ធ្វើព្យុះភ្លៀងដាក់ក្រុងណាមួយ ឬក៏ ចូលទៅធ្វើឃាតបុគ្គលណាម្នាក់ក៏ដោយ វាជា ការណ៍ចាំបាច់ដែលត្រូវចាប់ផ្ដើម ដោយការស្វែងរកឲ្យឃើញនូវឈ្មោះ នៃពួកបរិវារទាំងឡាយ និង ឧបត្ថម្ភក៍ជន របស់គេផងដែរ,




www.facebook.com/7khmer
Fb page : Entertainment And Knowledge

សេចក្ដីអធិប្បាយ៖ បើតាមសេចក្ដីរបស់ពាក្យ «ភ្ញៀវ» គឺមានន័យអាចសមមូលបាន ដូចដែល ទូអ៊ី ពោលថា៖ «គឺជនទាំងឡាយណាដែលមានភារកិច្ចប្រមូលព័ត៌មានមកជូនលោកមេទ័ព» ដែលធម្មជាតិតម្រូវ ឲ្យគាត់ចេះសាកសួរខ្លួនឯងជាញឹកញយ និងជា រឿយៗ នូវសំណួររបៀបនេះ។

ប្រការទី 20 ៖ (២). និង អ្នកយាមទ្វារដ៏ល្អ ព្រមទាំងអ្នកឃ្លាំរក្សាច្រកចូល របស់លោកមេទ័ព ដ៏រម្យទមនោះ ផងដែរ។ ចារកម្មរបស់យើង ត្រូវតែមានបេសកកម្មរកឲ្យឃើញប្រាកដនូវ ពពួកមនុស្សទាំងអស់នេះ។

សេចក្ដីអធិប្បាយ៖ នៅជំហានទីមួយ គ្មានមន្ទិលសង្ស័យអ្វីឡើយ ក្នុងការរកឲ្យឃើញមនុស្ស ដែលបម្រើការ តាមតួនាទី សំខាន់ៗ ទាំងនេះណាខ្លះ ដែលអាចត្រូវយើងយកឈ្នះដោយឥទ្ធិពលសំណូកសូកប៉ាន់។

ប្រការទី 21 ៖ ពួកចារកម្ម របស់សត្រូវ ដែលបានចូលមកស៊ើបយកការណ៍ពីខាងយើង ត្រូវតែបាន ជីករកឲ្យឃើញ ហើយល្បួងទិញទឹកចិត្ត ដោយសំណូក ឬ បញ្ជូន ឬ នាំចេញ





www.facebook.com/7khmer
Fb page : Entertainment And Knowledge

ឲ្យឆ្ងាយ និង ឲ្យផ្ទុះសម្លេង ដែលមានជាសុភភាពទៅពួកគេទៀតផង។ ធ្វើដូចនេះ ពួកគេអាចនឹងក្លាយមកជា ចារកម្មប្រែរូប និង អាចជួយបម្រើការឲ្យយើងបានវិញទៀតផង។

ប្រការទី 22 ៖ គឺ តាមរយៈព័ត៌មាន ដែលត្រូវបាននាំយកមកដោយចារកម្មប្រែរូបនេះហើយដែលយើងអាចនឹងទទួលបាន និង ប្រើប្រាស់ចារកម្មក្នុងស្រុក ព្រមទាំងចារកម្មផ្ទៃក្នុងជាបន្តទៅទៀត។

*សេចក្តីអធិប្បាយ៖ ទូអ៊ុ ពោលថា៖ «គឺតាមរយៈ ការប្រែរូប នៃ ចារកម្មរបស់សត្រូវនេះហើយ ដែលយើងអាចរៀនសូត្របាននូវលក្ខណ្ឌនានារបស់សត្រូវបាន»។ ចំណែក ចាងអ៊ី ពោលថា៖ «យើងត្រូវតែ ល្បងប្រើប្រាស់ពួកចារកម្មប្រែរូប ឲ្យមកបម្រើយើង ពីព្រោះមានតែពួកគេនេះហើយ ដែលដឹងថា អ្នកស្រុកម្នាក់ណា ដែលស្រេកឃ្លាន លោភលន់ ចង់មាន ចង់បាន ហើយមានមន្ត្រីណាខ្លះ ដែលទទួលសំណូកពុករលួយ។*

ប្រការទី 23 ៖ ជាការបញ្ជាក់ម្តងទៀត គឺរឿងរ៉ាវ ដែលមាននៅក្នុងព័ត៌មានរបស់ពួកគេ (ពួកចារកម្មប្រែរូប) នេះហើយ


www.facebook.com/7khmer
Fb page : Entertainment And Knowledge

ដែលយើងអាចនឹងញ៉ាំង ឲ្យចារកម្មស្លាប់រស់នាំយកព័ត៌មាន មិនពិត ទៅឲ្យសត្រូវបាន។

សេចក្តីអធិប្បាយ៖ ចាងអ៊ី បានពោលថា៖ «ដោយសារ តែចារកម្មប្រែរូបដឹងពីវិធីណា ដែលល្អបំផុត ក្នុងការ បញ្ឆោតសត្រូវ» នោះឯង។

ប្រការទី **24** ៖ ចុងក្រោយនេះ គឺ ចង់បញ្ជាក់ថា ដោយសារ តែព័ត៌មានរបស់ពួកគេ (ពួកចារកម្មប្រែរូប) នេះហើយ ដែល យើងអាចប្រើចារកម្មរស់ ឲ្យធ្វើកិច្ចការ តាមតម្រូវការចាំបាច់ បានសម្រេច មួយគ្រាៗ។

ប្រការទី **25** ៖ (១). លទ្ធផល និង គោលបំណង នៃការធ្វើ ចារកម្មនៅក្នុងនានាភាពទាំង៥ប្រការរបស់វាគឺជាចំណេះដឹង ស្តីអំពី សត្រូវ ហើយចំណេះដឹងទាំងនេះ អាចទាញចេញមក បាន តាមរយៈ ការដណ្តើមយកឱកាស ធ្វើឲ្យបានមុនគេ ពីចារកម្មប្រែរូបនេះហើយ។

សេចក្តីអធិប្បាយ៖ ដូចដែលមានសេចក្តីពន្យល់ នៅ ក្នុងប្រការទី២២ ដល់ ប្រការទី២៤។ ពួកចារកម្មប្រែរូប មិនត្រឹមតែនាំយកមកនូវព័ត៌មានរបស់ខ្លួន មកឲ្យយើង





www.facebook.com/7khmer
Fb page : Entertainment And Knowledge

តែប៉ុណ្ណោះទេ ប៉ុន្តែពួកគេធ្វើឲ្យយើងអាចប្រើប្រាស់ចារកម្មប្រភេទដទៃទៀត តាមដែលយើងមានប្រៀប។

ប្រការទី 25 ៖ (២). ដូចនេះ វាជារឿងចាំបាច់ណាស់ ដែលថា ពួកចារកម្មប្រែរូប ត្រូវតែបានមើលថែ ដោយចិត្តធម៌សប្បុរសជាទីបំផុត។

ប្រការទី 26 ៖ (១). យូរយារណាស់មកហើយ ភាពរុងរឿងនៃរាជវង្សយិន,

សេចក្តីអធិប្បាយ៖ ស៊ុនអ៊ូ ចង់និយាយសំដៅដល់រាជវង្សសាង ដែលត្រូវបាន កសាងឡើង កាលពីឆ្នាំ ១៧៦៦ មុន គ.ស។ ព្រះនាមរបស់រាជវង្សនេះ ត្រូវបានផ្លាស់ប្រែទៅជា រាជវង្សយិន ដោយសារ ប៉ានកេង កាលពីឆ្នាំ១៤០១ (មុនគ.ស?)។

ប្រការទី 26 ៖ (២). គឺ ដោយសារតែ អាជី,

សេចក្តីអធិប្បាយ៖ បើហៅថា អាយយិន មានគេស្គាល់ច្រើនជាង គាត់ជាមេទ័ព និង ជារដ្ឋបុរស




www.facebook.com/7khmer
Fb page : Entertainment And Knowledge

S.R, ២២ / ០៧ / ២៥៥៧ / ២០១៣

ង៍ល្បីល្បាញ ដែលបានចូលរួម នៅក្នុង បេសកកម្ម ចេងតាង តតាំងទល់នឹងពួក ចេក្ងួយ។

ប្រការទី 26 ៖ (៣). ដែលបានបម្រើការ នៅក្រោមអំណាច ស្ដេចសៀ។ ដូចគ្នាដែរ ភាពរុងរឿង នៃ រាជវង្សចូវ គឺបាន ដោយសារ លូយ៉ា,

សេចក្ដីអធិប្បាយ៖ លូសាង បានឈានឡើងឋាន: នៅ ក្រោមអំណាចនៃជនផ្ដាច់ការ ចូស៊ិន ដែលក្រោយមក គាត់បានកម្ចាត់ជនផ្ដាច់ការនោះចោលទៀត។ បើហៅ ថា ថៃកុង នឹងមានគេស្គាល់ច្រើនជាង, ស្ដេចវិនវ៉ាង បានផ្ដល់បំណាច់រង្វាន់ និង លើកកិត្តិយសគាត់ថា គាត់ បាននិពន្ធតម្រាពិជ័យសង្គ្រាម ហើយ មានការយល់ ច្រឡំ អំពី សៀវភៅនេះ ជាមួយនឹង លាវតាវ។ (កំណត់ ត្រាអ្នកប្រែសម្រួល៖ ជាភាគបន្ត ក្នុងស៊េរីសៀវភៅនេះ ខ្ញុំនឹងរៀបរៀងស្នាដៃ របស់គាត់ ដើម្បីកំដរអារម្មណ៍ មិត្តអ្នកអានជាបន្តទៅទៀត។)

ប្រការទី 26 ៖ (៤). ដូចគ្នានឹង អ្នកដែលបានបម្រើ ក្រោម អំណាចរាជវង្សយិន។


www.facebook.com/7khmer
Fb page : Entertainment And Knowledge

សេចក្តីអធិប្បាយ៖ មានសភាពស្រពេចស្រពិលនៅក្នុងភាសាចិន ជាងការណ៍ ដែលខ្ញុំបានគិត ដោយច្បាស់លាស់ទៅទៀត ដើម្បីនឹងនាំមកបង្ហាញ ក្នុងការបកប្រែរបស់ខ្ញុំ ហើយគ្មានសេចក្តីអធិប្បាយ ឲ្យបានច្បាស់ជាងនេះទៀតទេ ប៉ុន្តែ ដោយមានការគិតដល់បរិបថ យើងអាចមានមន្ទិលសង្ស័យថា ប្រហែលជា ស៊ុនវូនិយាយចង្អុលដាក់ អាយជី និង លូយ៉ា ដែលមានកិត្តិនាមល្បីល្បាញជាឧទាហរណ៍ នៃចារកម្មប្រែរូប ឬមានអ្វីមួយជាសទិសភាពយ៉ាងស្រដៀងគ្នានេះដែរ។ សេចក្តីណែនាំរបស់គាត់ គឺថា ស្តេចស្យៀ និង រាជវង្សយិនមានភាពរកាំរកូស តាមការយល់ដឹងបានដ៏ជ្រាលជ្រៅអំពី ភាពខ្សោយរបស់រាជវង្សនេះ ព្រមទាំង សេចក្តីខ្វះចន្លោះ ដែលមន្ត្រីទាំងនេះ មិនអាចនឹងទាក់ទងចូលដល់ភាគីម្ខាងទៀតបាន (ដែលជាសត្រូវ?)។ ការស្តែងចេញរបស់ មុីយ៉ាវឆិន បានបង្ហាញនូវភាពតូចចិត្ត ហើយដកជំនឿចិត្តចេញពីប្រវត្តិសាស្ត្រនេះ ហើយ រអ៊ូរទាំថា៖ «អាយយិន និង លូយ៉ា មិនមែនជាជនបះបោរប្រឆាំងរដ្ឋាភិបាលនោះទេ។ ស្តេចស្យៀ មិនអាចប្រើប្រាស់ពួក


www.facebook.com/7khmer
Fb page : Entertainment  And Knowledge

មន្ត្រី ចាស់ៗ ដូចនេះហើយ បានជា អោយយិន បានប្រើប្រាស់គាត់។ អោយយិន មិនអាចប្រើអ្នកទីពីរនោះទៀតជាបន្ទាប់មក ទើបស្តេចហូវប្រើគាត់។ ការសម្រេចលទ្ធផលដុំកំភួន គឺ អ្វីៗ គ្រប់យ៉ាង សម្រាប់សេចក្តីប្រសើររុងរឿងរបស់ប្រជានុរាស្ត្រតែប៉ុណ្ណោះ»។ ហាស៊ីក៏ឈឺចិត្តដែរហើយបានពោលថា៖ «តើមនុស្សដែលគួរជាទីរព្ញកទាំងពីរនាក់នេះ ធ្វើការងារបែបជាពួកចារកម្មបែបនេះយ៉ាងម៉េចកើតទៅ»? សេចក្តីអះអាង របស់ស៊ុនអ៊ូ ស្តីពី មនុស្សទាំងនោះ មានន័យយ៉ាងសាមញ្ញថា ការប្រើប្រាស់ឲ្យជិតដល់ នូវ ចារកម្មទាំង៥ប្រភេទ គឺជារឿងទាមទារ ឲ្យមានមនុស្ស ដែលមានសមត្ថភាពជាវង្វាស់វង្វាល់ យ៉ាងប្រសើរបំផុត ដូចជា អោយ និង លូដែលគាត់មានសតិបញ្ញា និង សមត្ថភាព ត្រូវនឹងភារកិច្ចរបៀបនេះ។ ពាក្យខាងលើ គឺ គ្រាន់តែចង់បញ្ជាក់ន័យក្នុងចំណុចនេះតែប៉ុណ្ណោះ»។ ហាស៊ី ជឿជាក់ថា៖ វីរជនទាំងពីរនាក់ ដែលត្រូវបានគេនិយាយចំណោះនេះ ក៏ព្រោះតែ គាត់មានជំនាញដែលគេត្រូវការ





www.facebook.com/7khmer
Fb page : Entertainment And Knowledge

គឺ ការប្រើចារកម្ម។ តែការនិយាយរបៀបនេះ គឺ ធ្វើឲ្យអ្នកដែលនិយាយខ្មាសទៅវិញទេ។

ប្រការទី **27** ៖ (១). ដូចនេះ គឺមានតែមេដឹកនាំ ដែលមានសតិបញ្ញាភ្លឺស្វាង និង មេទ័ពដ៏ល្អទេ ដែលអាចប្រើប្រាស់សតិបញ្ញាខ្ពង់ខ្ពស់បំផុតខាងយោធា សម្រាប់ គោលបំណងចារកម្ម និង តាមរយៈនេះ គាត់ក៏នឹងទទួលបាន នូវ ផលប្រយោជន៍ ដ៏អស្ចារ្យមកវិញផងដែរ។

សេចក្តីអធិប្បាយ៖ ទូមូ បានបិតបញ្ចប់សៀវភៅនេះ ដោយកំណត់ត្រារបស់គាត់ ជាសេចក្តីថា៖ «គឺប្រៀបបានដូចទឹក ដែលអាចនឹងនាំយកទូកពីត្រើយម្ខាង ទៅដល់ត្រើយម្ខាងទៀតបាន ហើយក៏អាចនឹងពន្លិចវាបានទៀត, ដូចនេះ ការពឹងអាស្រ័យទៅលើចារកម្ម ដែលនាំឲ្យយើងធ្វើការសម្រេចផលធំដុំបានដែរ, ជា រឿយៗ វាក៏អាចបណ្តាលឲ្យមានសភាពហិនហោច ជាទីបំផុតដល់យើងវិញផងដែរ»។





www.facebook.com/7khmer
Fb page : Entertainment And Knowledge

✓ប្រការទី 27 ៖ (២). ចារកម្ម គឺជា ធាតុផ្សំ ដ៏សំខាន់បំផុត ប្រៀបបាននឹងទឹកយ៉ាងដូច្នោះដែរ ពីព្រោះ ត្រូវពឹងផ្អែកលើពួកចារកម្មនេះហើយ ដែលជាកម្លាំងចល័តយាត្រាទ័ពបាន។

សេចក្ដីអធិប្បាយ៖ «ចាលីន ពោលថា កងទ័ពណា ដែលគ្មានចារកម្ម គឺ ប្រៀបបាននឹងមនុស្សគ្មានភ្នែក គ្មានត្រចៀកអញ្ចឹងដែរ»។ មានបរិយាយផងដែរ នៅក្នុងសៀវភៅ ជំនួយស្មារតីឈ្លបយកការណ៍ ទំព័រទី២ និង សៀវភៅ ម៉ាហ្សល ធ្យូរិន ទំព័រទី៣១១។




www.facebook.com/7khmer
Fb page : Entertainment And Knowledge

# បញ្ជីខចិត្ររូប

*រូបភាព អំពី ដំណើរផ្កាយ*

*ពន្យល់ ចំពោះ សេចក្តីអធិប្បាយ ទំព័រទី ១៨៥ - ១៨៦*



www.facebook.com/7khmer
Fb page : Entertainment And Knowledge

## រូបទី១ (ក)៖ ផ្កាយប៉ាន់តែ (Sagittarius)






www.facebook.com/7khmer
Fb page : Entertainment And Knowledge

រូបទី១ (ខ)៖ ផ្កាយប៉ាន់តែ (Sagittarius)




ទំព័រទី 241 នៃ 245


www.facebook.com/7khmer
Fb page : Entertainment And Knowledge

រូបទី២ ៖ ផ្កាយសេះ មានស្លាបហោះ (Pegasus)




| Bayer designation | Name | Origin | Meaning |
|---|---|---|---|
| α | Markab | Arabic | the saddle of the horse |
| β | Scheat | Arabic | the leg |
| γ | Algenib | Arabic | the flank |
| ε | Enif | Arabic | nose |
| ζ | Homam | Arabic | man of high spirit |
| η | Matar | Arabic | lucky star of rain |
| θ | Baham | Arabic | the livestocks |
| μ | Sadalbari | Arabic | luck star of the splendid one |




www.facebook.com/7khmer
Fb page : Entertainment And Knowledge

## រូបទី៣ ៖ ផ្កាយពែងតែ (Crater)




| Bayer | Name | Origin | Meaning |
|---|---|---|---|
| α | Alkes | Arabic | name of constellation |
| β | Al Sharas | Arabic | The rib |



www.facebook.com/7khmer
Fb page : Entertainment And Knowledge

## រូបទី៤ ៖ ផ្កាយខ្វែង (Corvus)







www.facebook.com/7khmer
Fb page : Entertainment And Knowledge

សូមរង់ចាំអាន សៀវភៅ

ស្ដីអំពី

ស៊ុនអ៊ូ និង គម្រាពិជ័យសង្គ្រាម

ទំព័រទី 245 នៃ 245

www.facebook.com/7khmer

Fb page : Entertainment And Knowledge

## ជំនួយស្មារតី ដើម្បីចូលសមរភូមិជីវិត

គេហទំព័រ ប៉ាកកាឯក : *www.paka.co*

ប៉ាកកាឯក : *www.facebook.com/kingofpen*

តម្រាពិជ័យសង្គ្រាម : *www.facebook.com/PicheySangkream*

---

តម្រាពិជ័យសង្គ្រាម ជាសៀវភៅទស្សនវិជ្ជា ខាងការប្រើមនុស្សដើម្បីប្រកួតប្រជែងយកឈ្នះនៅលើសមរភូមិជីវិត សម្រាប់មនុស្សគ្រប់ស្រទាប់ ។ តម្រានេះ ជាបទនិពន្ធដើមរបស់កំពូលមេទ័ពចិនបុរាណ ឈ្មោះ **ស៊ុន ឆ្វឺ** ដែលមានអាយុកាល ២៥០៨ ឆ្នាំ មកហើយ មកទល់នឹងឆ្នាំ ២០១២ នៃ គ.ស នេះ ដោយមានអាយុកាល មុនព្រឹត្តិការណ៍សាមកុក រយៈពេល ៦៦៥ ឆ្នាំ ។ តម្រានេះ ផ្តល់ទាំង "**ចំណេះដឹង**" ទាំង "**ប្រាជ្ញា**" ជូននរជនណាដែលបានអាន ដើម្បីទុកជាគ្រឿងប្រដាប់សម្រាប់ជីវិត គឺ "**ចំណេះជាអាហារ ប្រាជ្ញាជាអាវុធ**"។

---

**បើសិនជីវិតជាការប្រកួតប្រជែងពិតមែន សៀវភៅនេះ**
**ជាជំនួយស្មារតី ដើម្បីចូលសមរភូមិជីវិត**



**តម្លៃ ៖ ១១,០០០ រៀល**

www.facebook.com/7khmer
Fb page : Entertainment And Knowledge